ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្ដីណែនាំប្រតិបត្តិ

# ស្ដីពី

# សំណុំសកម្មភាពអប្បបរមា

រៀបចំដោយ

**អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល**

**នាយកដ្ឋានមន្ទីរពេទ្យ**

**ឧសភា ឆ្នាំ២០១៨**

# អារម្ភកថា

ឯកសារ "សេចក្តីណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមា" សម្រាប់អភិវឌ្ឍន៍មណ្ឌលសុខភាព នេះគឺជាលទ្ធផលនៃការប្រឹងប្រែងរបស់ក្រុមការងារពិនិត្យ និងកែសម្រួលសៀវភៅសំណុំសកម្មភាពអប្បបរមា សម្រាប់អភិវឌ្ឍន៍មណ្ឌលសុខភាព និងសេចក្តីណែនាំស្តីពីមគ្គុទេសក៍ព្យាបាលថ្នាក់មណ្ឌលសុខភាព របស់ក្រសួងសុខាភិបាល។ ភាគីដៃគូអភិវឌ្ឍន៍ និងដៃគូប្រតិបត្តិសំខាន់ៗក្នុងវិស័យសុខាភិបាល ក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍឯកសារដ៏មានសារៈសំខាន់នេះផងដែរ។

សេចក្តីណែនាំនេះ គឺជាឯកសារដែលបានធ្វើការកែលម្អ ដោយផ្អែកលើសេចក្តីណែនាំ ស្តីពីសំណុំសកម្មភាពអប្បបរមា សម្រាប់អភិវឌ្ឍន៍មណ្ឌលសុខភាព ដែលបានចេញផ្សាយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ និងឯកសារពាក់ព័ន្ធសំខាន់ៗមួយចំនួនទៀត ព្រមទាំងស្របតាមការវិវត្តជឿនលឿននៃវិស័យសុខាភិបាល។ ឯកសារលើកនេះ គឺជាឯកសារដៃគូគ្នាជាមួយគ្នានឹង "សេចក្តីណែនាំគ្លីនិក ស្តីពីសំណុំសកម្មភាពអប្បបរមាសម្រាប់មណ្ឌលសុខភាព" និងត្រូវបំពេញបង្គ្រប់គ្នាទៅវិញទៅមក។

គោលបំណងសំខាន់នៃ សេចក្តីណែនាំនេះ គឺផ្តល់ការណែនាំជាគោលការណ៍ដ៏ទូលំទូលាយ ស្តីពីកញ្ចប់សេវាផ្សេងៗក្នុង "សំណុំសកម្មភាពអប្បបរមា" ព្រមទាំងសកម្មភាពសំខាន់ពាក់ព័ន្ធមួយចំនួន ដែលត្រូវផ្តល់ដោយមណ្ឌលសុខភាព ហើយដែលត្រូវមានទំនាក់ទំនង និងភាពស៊ីគ្នាព្រមទាំងបំពេញគ្នាទៅវិញទៅមក ជាពិសេសជាមួយនឹងឯកសារដៃគូគ្នា គឺសេចក្តីណែនាំគ្លីនិក ស្តីពីសំណុំសកម្មភាពអប្បបរមាសម្រាប់មណ្ឌលសុខភាព ក៏ដូចជា សេចក្តីណែនាំស្តីពីសេវាចុះមូលដ្ឋាន ព្រមទាំងសេចក្តីណែនាំស្តីពី សំណុំសកម្មភាពបង្គ្រប់សម្រាប់អភិវឌ្ឍន៍មន្ទីរពេទ្យបង្អែក។

សេចក្តីណែនាំនេះ រៀបចំឡើងសម្រាប់អ្នកបម្រើការងារសុខាភិបាល នៅថ្នាក់មណ្ឌលសុខភាព និងសហគមន៍ ដើម្បីយកជាគោលការណ៍សម្រាប់ការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពខ្ពស់ សមធម៌ និងគុណភាព។ លើសនេះថែមទៀត សេចក្តីណែនាំនេះ ក៏ប្រើសម្រាប់ថ្នាក់ជាតិ ខេត្ត និងស្រុកប្រតិបត្តិ ដើម្បីយកជាទិសដៅក្នុងការរៀបចំផែនការ ការបណ្តុះបណ្តាល ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងក្នុងការ ផ្តល់ធនធាន សំដៅលើកកម្ពស់ទាំងបរិមាណ និងគុណភាពនៃការផ្តល់សេវាសុខាភិបាល នៅ ថ្នាក់មណ្ឌលសុខភាព រាប់បញ្ចូលទាំងថ្នាក់សហគមន៍ផងដែរ។

សេចក្តីណែនាំនេះ ក៏មានសារៈប្រយោជន៍ផងដែរ ដល់ភាគីពាក់ព័ន្ធផ្សេងទៀត ដោយរួមបញ្ចូលទាំងអាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងភ្នាក់ងារផ្តល់ជំនួយនានា ដើម្បីស្វែងយល់ ចូលរួម និងគាំទ្រសកម្មភាពរបស់មណ្ឌលសុខភាពនៅទូទាំងប្រទេស ក្នុងគោលបំណងសម្រេចឲ្យបាននូវគោលដៅនៃផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ២០១៦-២០២០ និងបណ្តាឆ្នាំបន្ត ៕

ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

សាស្ត្រាចារ្យ អេង ហួត

# សេចក្តីថ្លែងអំណរគុណ

ក្រសួងសុខាភិបាល មានមោទនភាពដែលបានសម្រេចបាននូវ សេចក្តីណែនាំប្រតិបត្តិ និង សេចក្តីណែនាំគ្លីនិក ស្តីពីសំណុំសកម្មភាពអប្បបរមាសម្រាប់មណ្ឌលសុខភាពជាលើកទីបី នេះ ។ យើងជឿជាក់ថា ជាមួយនឹងសេចក្តីណែនាំទាំងពីរនេះ នឹងជួយដល់មន្ត្រីដែលកំពុងធ្វើការងារគ្រប់គ្រង ប្រតិបត្តិនិងផ្តល់សេវាសុខភាព សំណុំសកម្មភាពអប្បបរមានៅតាមមូលដ្ឋានសុខាភិបាល ក្នុងការបង្កើន ប្រសិទ្ធភាព និង គុណភាពសេវារបស់ខ្លួន ។ យើងមានសេចក្តីសោមនស្សជាពន់ពេក និង សូមថ្លែង អំណរគុណចំពោះសមាជិកក្រុមការងារទាំងអស់ ដូចមានរាយនាមខាងក្រោម ដែលបានចូលរួម យ៉ាងសកម្មក្នុងការបង្កើតបាននូវសមិទ្ធិផលដ៏មានប្រយោជន៍នេះនិងសូមថ្លែងអំណរគុណចំពោះដៃគូ អភិវឌ្ឍន៍សុខាភិបាលទាំងអស់ ដែលបានជួយជ្រោមជ្រែងយ៉ាងពេញទំហឹង ហើយមិនត្រឹមតែបាន ជួយគាំទ្រផ្នែកបច្ចេកទេសប៉ុណ្ណោះទេ ថែមទាំងជួយផ្តល់ ថវិកាចាំបាច់ក្នុងការរៀបរៀង និងចងក្រង សេចក្តីណែនាំទាំងពីរនេះឡើងផងដែរ ។

## ក្រុមការងារពិនិត្យ និងកែសម្រួលសៀវភៅសេចក្តីណែនាំប្រតិបត្តិនិងគ្លីនិក ស្តីពីសំណុំសកម្មភាពអប្បបរមា សម្រាប់មណ្ឌលសុខភាព

| ល.រ | នាម និង គោត្តនាម | អង្គភាពខេត្តនិងក្រុង | តួនាទី | មុខងារ |
|---|---|---|---|---|
| ១ | ឯ.ឧ សាស្ត្រ. **យឹត ស៊ុនណារ៉ា** | ក្រសួងសុខាភិបាល | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២ | ឯ.ឧ វេជ្ជ. **ម៉ៅ តាន់អ៊ាង** | ម.ជ.កំ.ជ.របេង. ហង់សិន | នាយកមជ្ឈមណ្ឌលជាតិ | អនុប្រធាន |
| ៣ | លោកទន្ត. **អឿន ម្ញ៉ារត្នន៍** | អគ្គនាយកដ្ឋានបច្ចេកទេស | អគ្គនាយករង | អនុប្រធាន |
| ៤ | លោកវេជ្ជ. សុខ ស្រ៊ុន | នាយកដ្ឋានមន្ទីរពេទ្យ | ប្រធាននាយកដ្ឋាន | សមាជិកអចិន្ត្រៃយ៍ |
| ៥ | លោកវេជ្ជ. ម៉ី សំបូរ | នាយកដ្ឋានគ្រប់គ្រងបុគ្គលិក | ប្រធាននាយកដ្ឋាន | សមាជិក |
| ៦ | លោក ហុក ខៀវ | នាយកដ្ឋាននិតិកម្ម | ប្រធាននាយកដ្ឋាន | សមាជិក |
| ៧ | លោកវេជ្ជ. ឈិត សុផល | នា.ស.ផ.ច និង ប.ព.គ.ញ | ប្រធាននាយកដ្ឋាន | សមាជិក |
| ៨ | លោកស្រីសាស្ត្រ. អ៊ីវ ម៉ាឡៃន | មន្ទីរពេទ្យគន្ធបុប្ផា II | នាយកមន្ទីរពេទ្យជាតិ | សមាជិក |
| ៩ | លោកវេជ្ជ. សុខ ប៉ូ | នាយកដ្ឋានមន្ទីរពេទ្យ | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១០ | លោកវេជ្ជ. លី វិជ្ជារ៉ាវុធ | នា.ផែនការ និង ព័ត៌មានសុខា. | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១១ | លោកវេជ្ជ. ប៊ុន ស្រេង | នា.ប្រយុទ្ធនឹងជំងឺឆ្លង | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១២ | លោកវេជ្ជ. ភុំ សំសុង | នា.អភិវឌ្ឍធនធានមនុស្ស | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៣ | លោកឱ.បណ្ឌិត យ៉ង់ ដារ៉ាវុធ | នា.ឱសថ និង ចំណីអាហារ | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៤ | លោកវេជ្ជ. សៅ សុគន្ធណា | នាយកដ្ឋានមន្ទីរពេទ្យ | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៥ | លោកស្រីវេជ្ជ. សុខ កញ្ញា | នា.ផែនការ និង ព័ត៌មានសុខា. | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៦ | លោកវេជ្ជ.យូ អ៊ាងអ៊ូ | នា.ផែនការ និង ព័ត៌មានសុខា. | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៧ | លោកវេជ្ជ. ង៉ែត សុវណ្ណ | នាយកដ្ឋានការពារសុខភាព | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៨ | លោកស្រីវេជ្ជ. យុត ថាវរី | នា.ថវិកា និង ហិរញ្ញវត្ថុ | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៩ | លោកសាស្ត្រា. គឹម សាវួន | នាយកដ្ឋានមន្ទីរពេទ្យ | អនុប្រធាននាយកដ្ឋាន | សមាជិក |

| | | | | |
|---|---|---|---|---|
| ២០ | លោកទន្ត. ហាក់ ស៊ីថន | នាយកដ្ឋានការពារសុខភាព | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២១ | លោកសាស្ត្រ. ម៉ម វិទ្យារិទ្ធ | មន្ទីរពេទ្យកុមារជាតិ | នាយករងមន្ទីរពេទ្យជាតិ | សមាជិក |
| ២២ | លោកវេជ្ជ. ចុង ម៉េងឡុង | មន្ទីរពេទ្យជាតិព្រះអង្គឌួង | នាយករងមន្ទីរពេទ្យជាតិ | សមាជិក |
| ២៣ | លោកសាស្ត្រា. ចុង សុខហ៊ាន | មន្ទីរពេទ្យព្រះកុសមៈ | នាយករងមន្ទីរពេទ្យជាតិ | សមាជិក |
| ២៤ | លោកសាស្ត្រ. ហេង សុទ្ធី | មន្ទីរពេទ្យគន្ធបុប្ផា IV | នាយករងមន្ទីរពេទ្យជាតិ | សមាជិក |
| ២៥ | លោកសាស្ត្រ. អ៊ា ប៉ | វិទ្យាស្ថានសុខភាពសាធារណៈ | ប្រធានការិ.បច្ចេកទេស | សមាជិក |
| ២៦ | លោកស្រីវេជ្ជ. ឈុន លន់ | នាយកដ្ឋានការពារសុខភាព | ប្រធានការិ.ប្រ.ជ.មិនឆ្លង | សមាជិក |
| ២៧ | លោកវេជ្ជ. ជី ស៊ីវុទ្ធី | នាយកដ្ឋានមន្ទីរពេទ្យ | ប្រធានការិ.សេវាមន្ទីរពេទ្យ | លេខាអចិន្ត្រៃយ៍ |
| ២៨ | លោកស្រីឱសថ សំ សុភាព | នាយកដ្ឋានមន្ទីរពេទ្យ | ប្រធានការិ.សេវាមន្ទីរពិសោធន៍ | សមាជិក |
| ២៩ | លោកស្រីវេជ្ជ. លុន មណ្ឌល | នា.ផែនការ និង ព័ត៌មានសុខា. | ប្រធានការិ.គ/នបាយនិងកទស | សមាជិក |
| ៣០ | លោកវេជ្ជ. ថៃ សាវុធ | នា.ប្រយុទ្ធនឹងជំងឺឆ្លង | ប្រធានការិ.បង្ការត្រួតពិ .ជ ឆ | សមាជិក |
| ៣១ | លោកវេជ្ជ. រស់ ឈុនអៀង | នា.ផែនការ និង ព័ត៌មានសុខា | ប្រធានការិ.ស.ក.និងហ.ទ.ស | សមាជិក |
| ៣២ | លោកគ្រូពេទ្យ អៀន សុខគី | នាយកដ្ឋានការពារសុខភាព | ប្រធានការិ.គ្រ.គ្រ.មនិងស.ប | សមាជិក |
| ៣៣ | លោកសាស្ត្រា. កុយ វ៉ាន់នី | អគ្គនា.ដ្ឋានមន្ទីរពេទ្យកាល់ម៉ែត | ប្រធានការិយាល័យបច្ចេកទេស | សមាជិក |
| ៣៤ | លោកស្រីវេជ្ជ. ឡាក់ មួយស៊ាង | នាយកដ្ឋានការពារសុខភាព | អនុប្រ.ការិ.គ្រ.គ្រ.មនិងស.ប | សមាជិក |
| ៣៥ | លោកវេជ្ជ. សុខ គង់ | នាយកដ្ឋានការពារសុខភាព | អនុប្រ.ការិ. ប្រយុទ្ធ ជ.ម.ឆ. | សមាជិក |
| ៣៦ | លោក ប៊ុត សាបេន | នា.ផែនការ និង ព័ត៌មានសុខា | អនុប្រ.ការិ. ព័ត៌មានសុខា. | សមាជិក |
| ៣៧ | លោកស្រី ហែម ណាវី | នាយកដ្ឋានមន្ទីរពេទ្យ | អនុប្រ.ការិ.គិលា. និង ឆ្មប | សមាជិក |
| ៣៨ | លោកសាស្ត្រ. ដួង ប៊ុណ្ណ | មន្ទីរពេទ្យព្រះកុសមៈ | ប្រធានផ្នែកជំងឺវះកាត់ | សមាជិក |
| ៣៩ | លោកវេជ្ជ.ឯកទេស លី ជាតិតា | មន្ទីរពេទ្យមិត្តភាព ខ្មែរ សូវៀត | ប្រធានផ្នែកជំងឺទូទៅ | សមាជិក |
| ៤០ | លោកវេជ្ជ. កាអឿន ចិត្រា | ម.ជ.ប្រ.ជ.អេដស៍ កាមរោគ | ប្រធានផ្នែកថែទាំជំងឺអេដស៍ | សមាជិក |
| ៤១ | លោកសាស្ត្រ. សាំង សាលី | ម.ជ.កំ.ជ.របេង. ហង់សិន | ប្រធានផ្នែកស្រាវជ្រាវ/បង្ការ | សមាជិក |
| ៤២ | លោកវេជ្ជ. ស៊ុំ សត្ថា | អគ្គនា.ដ្ឋានមន្ទីរពេទ្យកាល់ម៉ែត | ព្យាបាលផ្នែកជំងឺទឹកនោមផ្អែម | សមាជិក |
| ៤៣ | លោកសាស្ត្រ. អ៊ុង ចក្រាវុធ | អគ្គនា.ដ្ឋានមន្ទីរពេទ្យកាល់ម៉ែត | ប្រធានផ្នែកក្រពះ ពោះវៀន | សមាជិក |
| ៤៤ | លោកសាស្ត្រ. ឈរ ណារ៉េត | អគ្គនា.ដ្ឋានមន្ទីរពេទ្យកាល់ម៉ែត | ប្រធានផ្នែកសង្គ្រោះបន្ទាន់ | សមាជិក |
| ៤៥ | លោកវេជ្ជ. ចេង យូដាលីន | អគ្គនា.ដ្ឋានមន្ទីរពេទ្យកាល់ម៉ែត | ព្យាបាលផ្នែកជំងឺបេះដូង | សមាជិក |
| ៤៦ | លោកសាស្ត្រ. វ៉ាន់ ម៉ិច | មន្ទីរពេទ្យមិត្តភាព ខ្មែរ សូវៀត | ប្រធានផ្នែកជំងឺផ្លូវដង្ហើម | សមាជិក |
| ៤៧ | លោកវេជ្ជ. លន់ សាយហេង | ម.ជ.ប្រ.ជ.អេ. សើ.កាមរោគ | ផ្នែកថែទាំជំងឺអេដស៍ | សមាជិក |
| ៤៨ | លោកសាស្ត្រ. គឹម អាង | មន្ទីរពេទ្យកុមារជាតិ | ប្រធានផ្នែកជំងឺផ្លូវដង្ហើម | សមាជិក |
| ៤៩ | លោកវេជ្ជឯកទេស ទូច យុន | មន្ទីរពេទ្យជាតិព្រះកុសមៈ | ប្រធានផ្នែកជំងឺទឹកនោមផ្អែម | សមាជិក |
| ៥០ | លោកសាស្ត្រ. អ៊ុង សុផល | មន្ទីរពេទ្យកុមារជាតិ | ប្រធានផ្នែកជំងឺឆ្លង | សមាជិក |
| ៥១ | លោកវេជ្ជ. ប៉ុក សារឿន | ម.ជ.ប្រ.ជ.អេ.សើ. កាមរោគ | ប្រធានផ្នែកជំងឺសើស្បែក | សមាជិក |
| ៥២ | លោកសាស្ត្រ. ឈឿន វុឌ្ឍី | មន្ទីរពេទ្យកុមារជាតិ | ប្រធានផ្នែកវះកាត់ជំងឺកុមារ | សមាជិក |
| ៥៣ | លោកវេជ្ជ. អ៊ិច យុយ | មន្ទីរពេទ្យព្រះកុសមៈ | ប្រធានផ្នែកសល្យ. វះកាត់ឆ្អឹង | សមាជិក |
| ៥៤ | លោកសាស្ត្រ. ឡឹក ឱសូឡី | ម.ជ.ប្រ.ជ.គ.ច. | នាយករងមជ្ឈមណ្ឌលជាតិ | សមាជិក |
| ៥៥ | លោកវេជ្ជ. ស៊ិន សុវណ្ណ | ម.ជ.លើកកម្ពស់សុខភាព | នាយករងមជ្ឈមណ្ឌលជាតិ | សមាជិក |

| | | | | |
|---|---|---|---|---|
| ៥៦ | លោកស្រីវេជ្ជ. ប្រាក់ សោភ័ណ្ឌនារី | ម.ជ.គាំពារមាតានិងទារក | នាយករងមជ្ឈមណ្ឌលជាតិ | សមាជិក |
| ៥៧ | លោកសាស្ត្រា. ជំនួយ វ៉ា សុខគា | ឃ្លាំងឱសថកណ្តាល | អនុប្រធាន | សមាជិក |
| ៥៨ | លោកស្រីវេជ្ជ. ឡាំ ភីរុណ | ម.ជ.គាំពារមាតានិងទារក | ប្រធានកម្មវិធីសុខភាពបន្តពូជ | សមាជិក |
| ៥៩ | លោកវេជ្ជ. សាំង សូណា | ម.ជ.គាំពារមាតានិងទារក | អនុប្រធានផ្នែកបណ្តុះបណ្តាល | សមាជិក |
| ៦០ | លោកស្រីវេជ្ជ. ព្រុំ ឆោមសាយឿន | ម.ជ.កំ.ជ.របេង. ហង់សិន | នាយករងមជ្ឈមណ្ឌល | សមាជិក |
| ៦១ | លោកស្រីវេជ្ជ. ជន ស៊ីនួន | នាយកដ្ឋានមន្ទីរពេទ្យ | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦២ | លោកវេជ្ជ. ដោ សីហា | មន្ទីរពេទ្យមិត្តភាព ខ្មែរ សូវៀត | អនុប្រ.កម្មវិធីជាតិសុខភាពភ្នែក | សមាជិក |
| ៦៣ | លោកវេជ្ជ. ស៊ិន ទូច | នាយកដ្ឋានមន្ទីរពេទ្យ | មន្ត្រីផ្នែកការប្រើឱសថសមស្រប | សមាជិក |
| ៦៤ | លោកស្រីវេជ្ជ អ៊ូច សិរី | នាយកដ្ឋានមន្ទីរពេទ្យ | មន្ត្រីផ្នែកការប្រើឱសថសមស្រប | សមាជិក |
| ៦៥ | លោកស្រីឱសថ អ៊ុក រមនា | នាយកដ្ឋានមន្ទីរពេទ្យ | មន្ត្រីផ្នែកការគ្រប់គ្រងសំណល់ | សមាជិក |
| ៦៦ | លោកស្រីវេជ្ជ ស៊ឹម សន្សំ | នាយកដ្ឋានមន្ទីរពេទ្យ | មន្ត្រីផ្នែកបង្ការការចម្លងរោគ | សមាជិក |
| ៦៧ | លោកស្រីវេជ្ជ សូ ណាគ្រី | នាយកដ្ឋានមន្ទីរពេទ្យ | មន្ត្រីផ្នែកបង្ការការចម្លងរោគ | សមាជិក |
| ៦៨ | លោកស្រីវេជ្ជ ឆាយ លក្ខិណា | នាយកដ្ឋានមន្ទីរពេទ្យ | មន្ត្រីផ្នែកគ្រប់គ្រងឧបករណ៍ពេទ្យ | សមាជិក |
| ៦៩ | លោកស្រីវេជ្ជ. សៅ ចំរើន | នា.ស.ផ.ច និង ប.ព.គ.ញ | មន្ត្រីផ្នែកសុខភាពផ្លូវចិត្ត... | សមាជិក |
| ៧០ | លោកអនុបណ្ឌិត កែវ សុមុនី | នា.ស.ផ.ច និង ប.ព.គ.ញ | មន្ត្រីផ្នែកសុខភាពផ្លូវចិត្ត... | សមាជិក |
| ៧១ | វេជ្ជ. ទូច សុខនាង | នាយក.អភិវឌ្ឍធនធានមនុស្ស | ប្រធាននាយកដ្ឋាន | សមាជិក |
| ៧២ | លោកស្រី អាន ធាវី | នា.ស.ផ.ច និង ប.ព.គ.ញ | មន្ត្រីផ្នែកសុខភាពផ្លូវចិត្ត... | សមាជិក |
| ៧៣ | លោកស្រីទន្តបណ្ឌិត ឆៃ ទេព្វិរូ | នាយកដ្ឋានការពារសុខភាព | ប្រធានការិយាល័យ | សមាជិក |
| ៧៤ | លោកស្រីទន្តបណ្ឌិត ហ៊ូ សុគន្ធារី | នាយកដ្ឋានការពារសុខភាព | អនុប្រធានការិយាល័យ | សមាជិក |

**លោក លោកស្រី ដែលបានចូលរួមយ៉ាងសកម្មផងដែរក្នុងដំណើរការកែសម្រួលសេចក្តីណែនាំ**

| | | | | |
|---|---|---|---|---|
| ៧៥ | Katherin KRASOVEC | URC/QHS | Senior advisor | សមាជិក |
| ៧៦ | លោកវេជ្ជ. សោម ហ៊ុន | URC/QHS | ប្រធានគម្រោង | សមាជិក |
| ៧៧ | លោកស្រីវេជ្ជ. ឈឿ សុជាតិ | URC/QHS | អនុប្រធានគម្រោង | សមាជិក |
| ៧៨ | លោក កុយ សុមន្ថា | URC/QHS | HCQI TL | សមាជិក |
| ៧៩ | លោកស្រី ស៊ុន ណាវ៉ា | URC/QHS | Comp3 Team Leader | សមាជិក |
| ៨០ | លោកវេជ្ជ. ដេង សិរងា | WHO | NPO | សមាជិក |
| ៨១ | លោកវេជ្ជ. ឃឹម សំអាត | WHO | NCD | សមាជិក |
| ៨២ | លោក ផល សាណូ | WHO | NPO | សមាជិក |
| ៨៣ | Dr. Indrajit Hazarikai | WHO | Consultant | សមាជិក |
| ៨៤ | Mo Mai | WHO | Consultant | សមាជិក |
| ៨៥ | Dr. Cheang Kannika | WHO | NPO | សមាជិក |
| ៨៦ | Dr. Taketo Tanaka | WHO/HSD | Intern | សមាជិក |
| ៨៧ | Dr. Chou VIVATH | WHO | Officer | សមាជិក |
| ៨៨ | Mr. PETER MILLER | WHO/HSE | H.Resources for Health | សមាជិក |

| | | | | |
|---|---|---|---|---|
| ៨៩ | Dr.Chham Samnang | WHO | Technical officer | សមាជិក |
| ៩០ | លោកវេជ្ជ. អ៊ឹង ព្រហស្បតិ៍ | GIZ HSPP | HSD TL | សមាជិក |
| ៩១ | លោកវេជ្ជ. យ៉ាត យ៉ាធី | GIZ.SHP | QA Advisor | សមាជិក |
| ៩២ | វេជ្ជ ជា ម៉េងទៀង | GIZ/Muskoka | MCH Advisory | សមាជិក |
| ៩៣ | លោក សៅ ឈន | GIZ | Local Consultant | សមាជិក |
| ៩៤ | Mrs. LUCY Freundel | GIZ | Development Advisor | សមាជិក |
| ៩៥ | Dr.Huong Vuthy | GIZ | QI Advisor | សមាជិក |
| ៩៦ | លោកស្រី ធូ កញ្ញាប៊ែល | UNFPA | NPO-MH | សមាជិក |
| ៩៧ | លោក ងួន ប្រុស | UNFPA | PA | សមាជិក |
| ៩៨ | Moung Sopha | UNFPA | PA-Emonc | សមាជិក |
| ៩៩ | Chaing Chanthea | UNICEF | WASH Officer | សមាជិក |
| ១០០ | Dr. Hong Rathmony | UNICEF | | សមាជិក |
| ១០១ | លោក ខាន់ សុខន | FHI 360 | Senior Technical Officer | សមាជិក |
| ១០២ | លោកស្រី សំអុល ច័ន្ទណា | WaterAid | Health Program Manager | សមាជិក |
| ១០៣ | Dr. Lim Khankryka | Wateraid | Training Coordinator | សមាជិក |
| ១០៤ | Dr. Azusa IWAMOTO | JICA | Senior advisor | សមាជិក |
| ១០៥ | Yoko MASAK | JICA | Community NB Health | សមាជិក |
| ១០៦ | Bun Kimchheng | JICA | Technical Assistant | សមាជិក |
| ១០៧ | លោកវេជ្ជ. បូរី សុច្ចរិទ្ធ | អគ្គនា.ដ្ឋានមន្ត្រីពេទ្យកាល់ម៉េត | ប្រធានផ្នែកជំងឺទូទៅ "ក" | សមាជិក |
| ១០៨ | លោកសាស្ត្រ. សុខ ជួរ | អគ្គនា.ដ្ឋានមន្ត្រីពេទ្យកាល់ម៉េត | Head Cardiology | សមាជិក |
| ១០៩ | លោកវេជ្ជ. លឹម ឧស្សាហ៍ | អគ្គនា.ដ្ឋានមន្ត្រីពេទ្យកាល់ម៉េត | ព្យាបាលផ្នែក Oncology | សមាជិក |
| ១១០ | លោកវេជ្ជ. សុខ សុធា | អគ្គនា.ដ្ឋានមន្ទីរពេទ្យកាល់ម៉េត | គ្រូពេទ្យព្យាបាល | សមាជិក |
| ១១១ | វេជ្ជ. ក្លាន់ យុវឌ្ឍនា | មន្ទីរពេទ្យកុមារជាតិ | គ្រូពេទ្យព្យាបាល | សមាជិក |
| ១១២ | វេជ្ជ. សោម លក្ខ័ណ្ឌ | មន្ទីរពេទ្យកុមារជាតិ | ប្រធានផ្នែក | សមាជិក |
| ១១៣ | វេជ្ជ. អ៊ុំង នរិទ្ធ | មន្ទីរពេទ្យជាតិព្រះអង្គឌួង | ព្យាបាលផ្នែក ENT | សមាជិក |
| ១១៤ | សាស្ត្រាចារ្យ ជុំ ណារុធ | មន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត | ប្រធានផ្នែក NEURO | សមាជិក |
| ១១៥ | វេជ្ជ. ទេស សុវណ្ណារ៉ា | មន្ទីរពេទ្យមិត្តភាព ខ្មែរ សូវៀត | គ្រូពេទ្យព្យាបាល | សមាជិក |
| ១១៦ | លោកវេជ្ជ. ជា អ៊ុង | មន្ទីរពេទ្យមិត្តភាព ខ្មែរ សូវៀត | ផ្នែក Gastro Enterology | សមាជិក |
| ១១៧ | លោកវេជ្ជ. ជួរ ម៉េង | ម.ជ.ស្រាវជ្រាវវេជ្ជសាស្ត្រ | Deputy NCTM | សមាជិក |
| ១១៨ | លោកសាស្ត្រ. តឹក លីវណ្ណារ៉ា | មន្ទីរពេទ្យគន្ធបុប្ផា IV | គ្រូពេទ្យព្យាបាល | សមាជិក |
| ១១៩ | លោកសាស្ត្រ. នី ចន្ទី | មន្ទីរពេទ្យព្រះកុសុមៈ | ប្រធានផ្នែកជំងឺសួត | សមាជិក |
| ១២០ | វេជ្ជ. ហុក ស៊ីវ៉ានី | នាយកដ្ឋានការពារសុខភាព | | សមាជិក |
| ១២១ | លោក លុន ថានវុធ | ម.ជ.លើកកម្ពស់សុខភាព | បុគ្គលិក | សមាជិក |

| | | | | |
|---|---|---|---|---|
| ១២២ | ឱសថ. សៀ ថុល | នាយកដ្ឋានឱសថ ចំណីអាហារ | ប្រ.ការិ.ឱសថសារវន្ត | សមាជិក |
| ១២៣ | វេជ្ជ. ក្រង ស៊ីដន | នាយក.ប្រយុទ្ធជំងឺឆ្លង | អនុប្រធាន | សមាជិក |
| ១២៤ | វេជ្ជ. ឱក វិជិត | កម្មវិធីជាតិផ្តល់ថ្នាំបង្ការ | ប្រធាន | សមាជិក |
| ១២៥ | វេជ្ជ. ឡាក់ ឡេង | ម.ជ លើកកម្ពស់សុខភាព | អនុប្រធាន | សមាជិក |
| ១២៦ | វេជ្ជ.នេត្រ នី | នា.សហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន | សមាជិក |
| ១២៧ | WILLE VANDE PUT | Health Net TPO | Director | សមាជិក |
| ១២៨ | វេជ្ជ. ចេងលី ប៊ុនទី | ICRC | SMFO | សមាជិក |
| ១២៩ | លោក យុន បញ្ញាវ័ន្ត | ICRC | MFO | សមាជិក |
| ១៣០ | លោក សុខ សែនអាល័យ | FHR | PC | សមាជិក |
| ១៣១ | Ouk Somuny | Eye Care Foundation | | សមាជិក |
| ១៣២ | លោកស្រី ឡាយ ច័ន្ទនាង | CARE | Senior Clinical SRMH | សមាជិក |

# មាតិកា


អារម្ភកថា....................................................................... Error! Bookmark not defined.

សេចក្តីថ្លែងអំណរគុណ ........................................................................ iii

មាតិកា ........................................................................ viii

១-សេចក្តីផ្តើម និងគោលបំណង........................................................................១

១.១-សារតៈ ........................................................................១

១.២-គោលបំណងនៃសេចក្តីណែនាំ........................................................................២

២-ការថែទាំសុខភាពបឋមជាគោលដៅរបស់មណ្ឌលសុខភាព ........................................................................ ៣

២.១. និយមន័យនៃការថែទាំសុខភាពបឋម ........................................................................ ៣

២.២. គោលការណ៍និងលក្ខណៈរបស់ការថែទាំសុខភាពបឋម ........................................................................៤

២.៣. យុទ្ធសាស្ត្ររបស់សេវាសុខភាពបឋម........................................................................៥

២.៤. សមាសធាតុរបស់ការថែទាំសុខភាពបឋម ........................................................................៥

៣-តួនាទី និងការទទួលខុសត្រូវ ........................................................................ ៧

៣.១. តួនាទី និងការទទួលខុសត្រូវរួមរបស់មណ្ឌលសុខភាព........................................................................ ៧

៣.២. រចនាសម្ព័ន្ធចាត់តាំង និងស្តង់ដារបុគ្គលិក........................................................................៩

៣.៣. កញ្ចប់សេវាសំខាន់ៗ សម្រាប់មណ្ឌលសុខភាព ........................................................................ ១១

៣.៤ កញ្ចប់សេវានៅប៉ុស្តិ៍សុខភាព ........................................................................២៤

៣.៥ ការងារអប់រំសុខភាព និងលើកកម្ពស់សុខភាព........................................................................២៥

៣.៦ ការផ្តល់សេវាចុះតាមមូលដ្ឋាន........................................................................២៦

៣.៧. សេវាសង្គ្រោះបន្ទាន់........................................................................៣០

៤- ចរាចរ ការបែងចែក និងបញ្ជូនអ្នកជំងឺ ........................................................................៣១

៤.១ ចរាចរអ្នកជំងឺ........................................................................៣១

៤.២ ការតាមដាន និង បញ្ជូនជំងឺ ........................................................................ ៣២

៥- ការចូលរួមរបស់សហគមន៍........................................................................ ៣៣

៥.១ សារៈសំខាន់នៃការចូលរួមរបស់សហគមន៍........................................................................ ៣៣

៥.២ គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព........................................................................៣៤

៥.៣ ភារកិច្ចរបស់ក្រុមទ្រទ្រង់សុខភាពភូមិ ........................................................................៣៨

៥.៤ ភារកិច្ចរបស់អ្នកស្ម័គ្រចិត្តសុខភាពភូមិ ........................................................................៣៩

៥.៥ ភារកិច្ចរបស់មណ្ឌលសុខភាព........................................................................ ៤០

៦-ហេដ្ឋារចនាសម្ព័ន្ធអគារ ........ ៤១

៧-សេវាត្រួតពិនិត្យអ្នកជំងឺ និងកម្មវិធី ........ ៤៣
៧.១ ការកត់ត្រាព័ត៌មាននិងតាមដានការផ្តល់សេវា: ........ ៤៣
៧.២-ការអនុវត្តន៍សមាហរណកម្ម សម្រាប់ការតាមដានអ្នកជំងឺ ........ ៤៦
៧.៣- ការអភិបាលគាំទ្រ: ........ ៤៦
៧.៤- ការប្រជុំបុគ្គលិកជាទៀងទាត់ ........ ៤៨
៧.៥- របាយការណ៍ជូនទៅស្រុកប្រតិបត្តិ ........ ៤៨
៧-៦ ស្ថិតិ និងស្ថានភាពប្រជាជន ក្នុងតំបន់ទទួលខុសត្រូវ ........ ៤៩

៨-ធនធានមនុស្សសុខាភិបាល ........ ៥០
៨.១. ការអភិវឌ្ឍន៍ធនធានមនុស្ស ........ ៥០
៨.២. ការគ្រប់គ្រងធនធនមនុស្ស ........ ៥២
៨.៣. ការធានាការផ្តល់សេវា ២៤ម៉ោង ........ ៥៣
៨.៤ ការប្រជុំការងារបុគ្គលិកជាទៀងទាត់ ........ ៥៣
៨.៥. ការចូលរួមការប្រជុំនៅថ្នាក់ស្រុកប្រតិបត្តិ ........ ៥៤

៩- ការគ្រប់គ្រងថវិកានៅមណ្ឌលសុខភាព ........ ៥៥
៩-១ ហិរញ្ញប្បទានសុខាភិបាល និងការគ្រប់គ្រងថវិកានៅមណ្ឌលសុខភាព ........ ៥៥
៩.២ ភារកិច្ចសំខាន់ៗក្នុងការគ្រប់គ្រងថវិកាមណ្ឌលសុខភាព ........ ៥៨

១០. ការបង្ការការចម្លងរោគ អនាម័យ និងទឹកស្អាត ........ ៥៩
១០.១ ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ ........ ៥៩
១០.២ គោលការណ៍គ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាព ........ ៦៥
១០.៣ ទឹកស្អាត និងអនាម័យ ........ ៦៩

១១-ការគ្រប់គ្រង ការផ្គត់ផ្គង់ឱសថ បរិក្ខារពេទ្យ ........ ៧១
១១.១ ការចែកចាយឱសថនៅផ្នែកឱសថស្ថាន ........ ៧១
១១.២ ការគ្រប់គ្រងឯកសារ និងបញ្ជីសារពើភណ្ឌ ........ ៧១
១១.៣ ឱសថសារវន្ត និងការផ្គត់ផ្គង់ ........ ៧២

១២-សេវាមន្ទីរពិសោធន៍ ........ ៧៤
១២.១ កញ្ចប់សេវាមន្ទីរពិសោធន៍ នៅមណ្ឌលសុខភាព ........ ៧៤
១២.២ សុវត្ថិភាពមន្ទីរពិសោធន៍ ........ ៧៥
១២.៣ ការរក្សានិរន្តភាពឧបករណ៍បរិក្ខារពេទ្យ ........ ៧៧

១៣-ធានាគុណភាព ........ ៧៧

១៤-ឧបសម្ព័ន្ធ ........................................................................................................................... ៧៩
១៤.១ បញ្ជីឈ្មោះមូលដ្ឋានសុខាភិបាលសាធារណៈ ឆ្នាំ២០១៨ ........................................... ៨០
១៤.២ បញ្ជីកត់ត្រាផ្នែកពិគ្រោះជំងឺក្រៅសម្រាប់មណ្ឌលសុខភាព ....................................... ១១៧
១៤.៣ បញ្ជីកត់ត្រាផ្នែកពិនិត្យផ្ទៃពោះ ............................................................................ ១២០
១៤.៤ បញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព ............................................. ១២៣
១៤.៥ បញ្ជីកត់ត្រាការថែទាំក្រោយសម្រាល ....................................................................... ១២៦
១៤.៦ បញ្ជីសម្រង់អតិថិជនពន្យារកំណើត ........................................................................ ១២៩
១៤.៧ ទម្រង់ពិគ្រោះនិងព្យាបាលជំងឺ (សេវាគាំពារមាតានិងទារក) ...................................... ១៣១
១៤.៨ ទម្រង់ពិគ្រោះនិងព្យាបាលជំងឺ (ជំងឺទូទៅនិងកុមារ) .................................................. ១៣២
១៤.៩ លិខិតបញ្ជូនអ្នកជំងឺ .............................................................................................. ១៣៣
១៤.១០ លិខិតបញ្ជូនទារក ................................................................................................ ១៣៧
១៤.១១ លិខិតបញ្ជូនអ្នកជំងឺរបេង ..................................................................................... ១៣៩
១៤.១២ របាយការណ៍ថែទាំអ្នកជំងឺ(លើរថយន្តគិលានសង្គ្រោះ) ......................................... ១៤០
១៤.១៣ តួនាទី ការទទួលខុសត្រូវរួម និងកញ្ចប់សេវារបស់ប៉ុស្តិ៍សុខភាពពន្ធនាគារ ............... ១៤១

# ១-សេចក្តីផ្តើម និងគោលបំណង

## ១.១-សាវតា

នៅឆ្នាំ១៩៩៥ ក្រសួងសុខាភិបាល បានរៀបចំកំណែទម្រង់ប្រព័ន្ធសុខាភិបាល ស្របតាមកំណែទម្រង់រដ្ឋបាល សាធារណៈ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃកំណែទម្រង់នេះគឺ ដើម្បីលើកកម្ពស់ និងពង្រីកការផ្តល់សេវាសុខាភិបាល ប្រកបដោយគុណភាព ពិសេសការថែទាំសុខភាពបឋមជូនប្រជាពលរដ្ឋទាំងអស់ ផ្តោតសំខាន់នៅតំបន់ជនបទដាច់ស្រយាល តាមរយៈការអនុវត្តន៍ប្រព័ន្ធសុខាភិបាលស្រុកថ្មី។

ផែនការគ្របដណ្តប់សុខាភិបាល ដែលជាផ្នែកមួយនៃកំណែទម្រង់សុខាភិបាល បញ្ជាក់យ៉ាងច្បាស់អំពីទីតាំង និងចំនួនមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ព្រមទាំងកំណត់តំបន់ទទួលខុសត្រូវរបស់មូលដ្ឋានសុខាភិបាលនីមួយៗ ក្នុងការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ។

ផែនការគ្របដណ្តប់សុខាភិបាល ត្រូវបានរៀបចំដោយផ្អែកលើលក្ខណៈវិនិច្ឆ័យពីរសំខាន់គឺៈ ចំនួនប្រជាជនដែលត្រូវបម្រើដោយមូលដ្ឋានសុខាភិបាលនិមួយៗ និងលទ្ធភាពនៃការចូលមកទទួល យកសេវាផ្អែកភូមិសាស្រ្ត។ ផែនការនេះផ្អែកលើមូលដ្ឋាន ស្រុកប្រតិបត្តិជាថ្នាក់ប្រតិបត្តិ ដែលក្នុងនោះ មណ្ឌលសុខភាពមានតួនាទីផ្តល់សេវាសុខាភិបាលជាមូលដ្ឋាន និងចាំបាច់មានឈ្មោះថា "សំណុំសកម្មភាពអប្បបរមា" (ស.អ) រីឯមន្ទីរពេទ្យបង្អែក ជាអ្នកផ្តល់សេវានៅថ្នាក់បន្ទាប់មានឈ្មោះថា "សំណុំសកម្មភាពបង្គ្រប់" (ស.ប)។ ប្រព័ន្ធសុខាភិបាលថ្មីនេះ បានចាប់ផ្តើមអនុវត្តចាប់តាំងពីឆ្នាំ ១៩៩៦ រហូតមកដល់សព្វថ្ងៃនេះ។ ដំបូងឡើយ តាមគម្រោងក្នុងផែនការគ្របដណ្តប់សុខាភិបាល ត្រូវមានស្រុកប្រតិបត្តិចំនួន ៧១ និងមណ្ឌលសុខភាពចំនួន ៩៤២ ។ មកដល់ដំណាច់ឆ្នាំ២០១៧ ស្រុកប្រតិបត្តិកើនឡើងរហូតដល់ចំនួន ១០០ និងមណ្ឌលសុខភាពចំនួន ១ ១៩០ ព្រមទាំងប៉ុស្តិ៍សុខភាពចំនួន ១១៩ ។

ការផ្តល់សេវា " សំណុំសកម្មភាពអប្បបរមា " បានត្រូវអនុវត្តអស់រយៈពេលជាង ២០ឆ្នាំមកហើយ។ សេចក្តីណែនាំស្តីពី សំណុំសកម្មភាពអប្បបរមា ដែលបានចេញផ្សាយចុងក្រោយគឺនៅឆ្នាំ២០០៧ និងសម្រាប់អនុវត្តពីឆ្នាំ ២០០៨ ដល់ ២០១៥។ យោងទៅតាមការរីកចម្រើន នៃប្រព័ន្ធសុខាភិបាល ក៏ដូចជាតម្រូវការផ្នែកសុខភាពរបស់ប្រជាពលរដ្ឋ ជាពិសេសយោងទៅតាមតម្រូវការចាំបាច់ ដើម្បីដោះស្រាយបញ្ហាសុខភាពជាអាទិភាពថ្មីៗ គឺតម្រូវឲ្យមានការពិនិត្យមើលឡើងវិញ នូវកញ្ចប់សកម្មភាព និងសេវាទាំងឡាយដែលត្រូវផ្តល់ ដោយមណ្ឌលសុខភាព ដែលក្នុងនោះរាប់បញ្ចូលទាំងសេវាដែលត្រូវផ្តល់នៅប៉ុស្តិ៍សុខភាពផង។

## ១.២-គោលបំណងនៃសេចក្តីណែនាំ

សេចក្តីណែនាំនេះ គឺជាឯកសារដែលបានធ្វើការកែលម្អ ដោយផ្អែកលើសេចក្តីណែនាំ ស្តីពីសំណុំសកម្មភាពអប្បបរមា ដែលបានចេញផ្សាយនៅថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០០៧។ ឯកសារនេះ គឺជាឯកសារដៃគូជាមួយគ្នានឹង "សេចក្តីណែនាំគ្លីនិក ស្តីពីសំណុំសកម្មភាពអប្បបរមាសម្រាប់មណ្ឌលសុខភាព"។

គោលបំណងសំខាន់នៃ "សេចក្តីណែនាំប្រតិបត្តិ សម្រាប់សំណុំសកម្មភាពអប្បបរមា" នេះគឺផ្តល់ការណែនាំជាគោលការណ៍ដ៏ទូលំទូលាយ ស្តីពីសេវាផ្សេងៗក្នុង "សំណុំសកម្មភាពអប្បបរមា" ព្រមទាំងសកម្មភាពសំខាន់ៗមួយចំនួន ដែលត្រូវផ្តល់ដោយមណ្ឌលសុខភាព ។ សេចក្តីណែនាំនេះ ត្រូវមានទំនាក់ទំនងនិងភាពស៊ីគ្នា ព្រមទាំងបំពេញគ្នាទៅវិញទៅមកជាមួយនឹងសេចក្តីណែនាំស្តីពី សំណុំសកម្មភាពបង្គ្រប់សម្រាប់អភិវឌ្ឍន៍មន្ទីរពេទ្យបង្អែក។ ចំពោះវិធីសាស្ត្រ ឬយុទ្ធសាស្ត្រ ឬគោលការណ៍បច្ចេកទេសជាលម្អិត ដែលពាក់ព័ន្ធនឹងការងារ សំខាន់ៗ សេចក្តីណែនាំ នឹងណែនាំទៅរកឯកសារយោង នៃអង្គភាពឬកម្មវិធីជាតិពាក់ព័ន្ធ ។

សេវាទាំងឡាយខាងលើនេះ រាប់បញ្ចូលទាំងសេវាសំខាន់ៗ ដែលត្រូវផ្តល់ឲ្យនៅនឹងកន្លែងនៃមណ្ឌលសុខភាព ( រួមទាំងការថែទាំបឋម ) ព្រមទាំងសេវាចម្បងៗ ដែលត្រូវផ្តល់ទៅថ្នាក់សហគមន៍ផងដែរ ពិសេសគឺសេវាចុះមូលដ្ឋាន និងការចូលរួមរបស់សហគមន៍ ក្នុងការថែទាំសុខភាព។

លើសពីនេះទៀតគោលការណ៍ពាក់ព័ន្ធ នឹងសកម្មភាពមួយចំនួន ដើម្បីទ្រទ្រង់និងគាំទ្រដល់ការផ្តល់សេវាមានជាអាទិ៍ ការងារបណ្តុះបណ្តាល និងគ្រប់គ្រងបុគ្គលិកសុខាភិបាល ការងារថវិកា ការងារគ្រប់គ្រងឱសថ និងសម្ភារបរិក្ខារផ្សេងៗ ការងារពាក់ព័ន្ធនឹងសហគមន៍ ព្រមទាំងការគ្រប់គ្រងប្រព័ន្ធព័ត៌មាន ការគ្រប់គ្រងសំណល់ថែទាំ និងអនាម័យជាដើមក៏មានចែងនៅក្នុងសេចក្តីណែនាំនេះផងដែរ។

សេចក្តីណែនាំនេះ រៀបចំឡើងសម្រាប់អ្នកបម្រើការងារសុខាភិបាល នៅថ្នាក់មណ្ឌលសុខភាព និងសហគមន៍ដើម្បីយកជាគោលការណ៍សម្រាប់ការផ្តល់សេវា ប្រកបដោយប្រសិទ្ធភាពខ្ពស់ សមធម៌ និងគុណភាព។ លើសនេះថែមទៀត សេចក្តីណែនាំនេះក៏ប្រើសម្រាប់ថ្នាក់ជាតិ ខេត្ត និងស្រុកប្រតិបត្តិ ដើម្បីយកជាទិសដៅ ក្នុងការរៀបចំផែនការ ការបណ្តុះបណ្តាល ការតាមដាន ត្រួតពិនិត្យ និងវាយតំលៃ ព្រមទាំងក្នុងការផ្តល់ធនធាន សំដៅលើកកម្ពស់ទាំងបរិមាណ និងគុណភាពនៃការផ្តល់សេវាសុខាភិបាលនៅថ្នាក់មណ្ឌលសុខភាព រាប់បញ្ចូលទាំងថ្នាក់សហគមន៍ផងដែរ។

នាយកដ្ឋានផែនការ និងប្រព័ន្ធព័ត៌មានសុខាភិបាល ជាមួយនាយកដ្ឋាននិងផ្នែកពាក់ព័ន្ធ នៃក្រសួងសុខាភិបាល មានភារកិច្ចអនុវត្តផែនការគ្របដណ្តប់សុខាភិបាល ក្នុងនោះមានការពិនិត្យ លក្ខណៈវិនិច្ឆ័យក្នុងការដាក់ឲ្យដំណើរការមណ្ឌលសុខភាពឬប៉ុស្តិ៍សុខភាព ពិនិត្យលើសំណើសាងសង់មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព ព្រមទាំងការអនុញ្ញាតិផ្តល់សម្ភារបរិក្ខារពេទ្យ ឱសថ ការសាងសង់ បុគ្គលិក និងការបណ្តុះបណ្តាលស្របតាមសេចក្តីណែនាំ ស្តីពីសំណុំសកម្មភាពអប្បបរមា ព្រមទាំងដោយមានការទទួលស្គាល់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំណែកឯនាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល ជាមួយនាយកដ្ឋាន និងផ្នែកពាក់ព័ន្ធ មានភារកិច្ចត្រួតពិនិត្យ តាមដាន វាយតម្លៃ សកម្មភាពផ្តល់សេវា របស់មណ្ឌលសុខភាព ទាំងក្នុងមណ្ឌលសុខភាព និងសេវាចុះមូលដ្ឋាន។

ការវាយតម្លៃសកម្មភាពការងាររួម របស់មណ្ឌលសុខភាព នឹងប្រព្រឹត្តទៅ ១ឆ្នាំម្តង ក្នុងត្រីមាសទី៤ នៃឆ្នាំ ដែលធ្វើឡើងដោយក្រុមការងារចំរុះ រួមបញ្ចូលទាំងមន្ត្រីនាយកដ្ឋានផែនការ និងប្រព័ន្ធព័ត៌មានសុខាភិបាល នាយកដ្ឋានមន្ទីរពេទ្យ និងនាយកដ្ឋាន និងភាគីពាក់ព័ន្ធដទៃទៀត។

# ២-ការថែទាំសុខភាពបឋមជាគោលដៅរបស់មណ្ឌលសុខភាព

## ២.១. និយមន័យនៃការថែទាំសុខភាពបឋម

ការថែទាំសុខភាពបឋម (PHC) ជាការថែទាំសុខភាពសារវន្ត ផ្អែកទៅលើវិធីសាស្ត្រមានលក្ខណៈវិទ្យាសាស្ត្រ និងវិធីសាស្ត្រដែលសង្គមអាចទទួលយកបាន និងអាចចូលយកសេវាបានជាសកលសម្រាប់គ្រប់បុគ្គល គ្រួសារ និងដោយមានការចូលរួមពេញលេញដោយតម្លៃមួយ ដែលសហគមន៍ និងប្រទេសជាតិអាចមានលទ្ធភាពចំណាយ ក្នុងស្មារតីម្ចាស់ការខ្លួនឯង និងកំណត់ខ្លួនឯងបាន។ ការថែទាំសុខភាពបឋមជាវិធីសាស្ត្រ ផ្អែកលើប្រព័ន្ធសុខាភិបាលមួយ ដែលឈរលើគុណតម្លៃនៃការថែទាំសុខភាពបឋម ដូចដែលមានចែងក្នុងនិយមន័យខាងលើ ។ ប្រព័ន្ធដែលផ្អែកលើការថែទាំសុខភាពបឋមផ្សាភ្ជាប់សេវាសុខភាពនៅកម្រិតបឋមទៅនឹងកម្រិតទី២និងទី៣ ហើយដែលបំពេញបាននូវគុណតម្លៃទាំងឡាយ នៃការថែទាំសុខភាពបឋម។ សេវាសុខភាពកម្រិតទី២ និងទី៣ មានទំនាក់ទំនងជាមួយកម្រិតបឋម តាមរយៈការបញ្ជូនទៅវិញទៅមក ប្រកបដោយប្រសិទ្ធិភាព ។ ការថែទាំសុខភាពបឋម កសាងដោយផ្អែកលើប្រព័ន្ធការថែទាំបឋម (Primary care: PC) ដ៏រឹងមាំ។

ការថែទាំបឋម(PC) ជាកន្លែងជួបពិគ្រោះដំបូង របស់បុគ្គលគ្រួសារ និងសហគមន៍ជាមួយប្រព័ន្ធសុខភាពសាធារណៈ ហើយនាំមកនូវការថែទាំសុខភាព នៅជិតបំផុតតាមដែលអាចធ្វើបានទៅដល់កន្លែងប្រជាជនរស់នៅនិងប្រកបការងារ។ ការថែទាំបឋម(PC)ត្រូវបានរៀបចំឡើង នៅមណ្ឌលសុខភាព ដើម្បីផ្តល់សេវាសុខភាព ដែល(១)ផ្តោតលើប្រជាជនសម្រាប់ប្រជាជន សហគមន៍ឬចំនួនភូមិដែលបានកំណត់ជាក់លាក់(២) ផ្តល់ដល់បុគ្គលឬអ្នកជំងឺនូវសេវាសុខភាពដែលមានគុណភាព និងប្រកបដោយសុវត្ថិភាព ដែលជាតម្រូវការដំបូង ហើយនឹងត្រូវបានរៀបចំតាមបែបសមាហរណកម្ម ហើយចំពោះកម្ពុជា ហៅថា "សំណុំសកម្មភាពអប្បរមា" ដែលមានចែងក្នុងសេចក្តីណែនាំនេះ(៣)អាចបញ្ជូនទៅសេវាសុខាភិបាលកម្រិតខ្ពស់ជាង នៅពេលអ្នកជំងឺមានសភាពសាំញ៉ាំមិនធម្មតា ឬមានរោគសញ្ញាកម្រនៃបញ្ហាសុខភាព។ ប្រព័ន្ធសុខាភិបាលដែលរឹងមាំត្រូវការគុណតម្លៃ នៃការថែទាំសុខភាពបឋមច្បាស់លាស់ និងការថែទាំបឋមរឹងមាំ។ ភ័ស្តុតាងបានបង្ហាញថាការថែទាំបឋមដែលរឹងមាំ នឹងចូលរួមចំណែកក្នុងការបំពេញភារកិច្ចរបស់ប្រព័ន្ធសុខាភិបាលជារួម និងជួយធ្វើឲ្យប្រសើរឡើងនូវគុណភាព ប្រសិទ្ធផល សមធម៌ និងលទ្ធផល។

## ២.២. គោលការណ៍និងលក្ខណៈរបស់ការថែទាំសុខភាពបឋម

### ២.២.១ គោលការណ៍របស់ការថែទាំសុខភាពបឋម

ការថែទាំសុខភាពបឋម នឹងលើកកម្ពស់សិទ្ធរបស់ប្រជាពលរដ្ឋទាំងអស់ ឲ្យសម្រេចបាននូវសុខភាពកម្រិតខ្ពស់បំផុតពេញមួយជីវិត ដែលគាំទ្រដោយសេវាសុខភាព និងដែលរៀបចំប្រកបដោយសាមគ្គីភាព និងសមធម៌ជាអតិបរមា ដោយអនុវត្តវិធីសាស្ត្រនៃការថែទាំសុខភាពផ្តោតលើប្រជាជន ។

**ការថែទាំសុខភាពដែលផ្តោតលើប្រជាជន** (People-centred care): មានន័យថា

ជាការផ្តោតការយកចិត្តទុកដាក់ លើតម្រូវការផ្នែកសុខភាព និងការរំពឹងទុករបស់ប្រជាជននិងសហគមន៍ពេញមួយជីវិត។

មិនផ្តោតលើរោគឬជំងឺទេ។

ពង្រីកបញ្ញតិនៃការថែទាំបឋម(PC) ទៅដល់គ្រួសារ សហគមន៍ហើយនិងសុខភាពប្រជាជននៅសហគមន៍។

លើកកម្ពស់តួនាទីសហគមន៍ ដើម្បីជួយធ្វើឲ្យប្រសើរឡើង នូវសេវាសុខាភិបាល និងជួយធ្វើឲ្យប្រសើរឡើងនូវគោលនយោបាយសុខាភិបាល។

រួមបញ្ចូលនូវការថែទាំគ្លីនិក ផ្អែកលើបុគ្គលឬអ្នកជំងឺ ដែលមានចែងក្នុងសំណុំសកម្មភាពអប្បបរមា។

ការថែទាំផ្តោតលើបុគ្គលឬអ្នកជំងឺ ជាទូទៅសំដៅលើការស្វែងរកសេវាសុខភាពរបស់បុគ្គលឬអ្នកជំងឺ។

### ២.២.២ លក្ខណៈសំខាន់ៗនៃប្រព័ន្ធសុខាភិបាល ផ្អែកលើការថែទាំបឋម មានដូចខាងក្រោមៈ

ផ្តោតលើប្រជាជនឬអ្នកជំងឺនៅពេញមួយជីវិត ជាជាងផ្អែកតាមរោគ ឬជំងឺ។

សេវាទាំងឡាយ (ស.អ) ត្រូវរាប់បញ្ចូលផងដែរ នូវសេវាអប់រំ និងការពារសុខភាព។

សេវាអាចចូលយកបាន ដោយមិនចាំបាច់មានការចំណាយប្រាក់ពីហោប៉ៅ ចំពោះអ្នកក្រីក្រឬជនងាយរងគ្រោះ។

ប្រភពធនធានទាំងអស់ ត្រូវបែងចែកដោយផ្អែកតាមតម្រូវការរបស់ប្រជាជន (មិនមែនផ្អែកតាមតែការកំណត់កញ្ចប់បែងចែកថវិកាឲ្យនោះទេ )។

ការប្រាស្រ័យទាក់ទងនិងការសម្របសម្រួល ប្រកបដោយប្រសិទ្ធភាព រវាងសេវាកម្រិតខុសៗគ្នានៅក្នុងប្រព័ន្ធសេវាសុខាភិបាល ។

ព្រមទាំង ការប្រើប្រាស់វិធីសាស្ត្រផ្សេងៗ សម្រាប់ពិភាក្សាគោលនយោបាយ និងបង្កើនការចូលរួមពីអតិថិជន។

## ២.៣. យុទ្ធសាស្ត្ររបស់សេវាសុខភាពបឋម Primary Health Care Strategy

គោលដៅរបស់ការថែទាំសុខភាពបឋម គឺធ្វើឲ្យសុខភាពប្រសើរឡើង សម្រាប់ជនគ្រប់រូប។ អង្គការសុខភាពពិភពលោក បានកំណត់សមាសធាតុជាយុទ្ធសាស្ត្រចំនួន៥ ដើម្បីសម្រេចបាននូវគោលដៅរបស់ការថែទាំសុខភាពបឋមៈ

ការគ្របដណ្តប់ជាសកល ដើម្បីកាត់បន្ថយ "ការមិនរួមបញ្ចូល" និង "ភាពមិនដូចគ្នាក្នុងសង្គម" ពាក់ព័ន្ធនឹងសុខភាព។

ការផ្តល់សេវាត្រូវរៀបចំឡើងនៅជុំវិញ ឬជិតប្រជាជនដែលត្រូវការនិងរំពឹងទុក។

គោលនយោបាយសាធារណៈ ដែលធ្វើសមាហរណកម្មសុខភាពទៅក្នុងគ្រប់វិស័យ។

ភាពជាអ្នកដឹកនាំដើម្បីពង្រឹងគម្រូកិច្ចសហការនៃការពិភាក្សាពីគោលនយោបាយ និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការថែទាំសុខភាពរបស់ខ្លួន។

## ២.៤. សមាសធាតុរបស់ការថែទាំសុខភាពបឋម Elements of Primary Health Care

ប្រព័ន្ធសុខាភិបាល ដែលផ្អែកលើការថែទាំសុខភាពបឋម មានសមាសធាតុរចនាសម្ព័ន្ធនិងសមាសធាតុមុខងារ ដូចខាងក្រោមៈ

### ១. សមាសធាតុរចនាសម្ព័ន្ធ

ការថែទាំសុខភាពបឋមត្រូវបានរៀបចំឡើងដើម្បី(១)ធានាបានការគ្របដណ្តប់សេវាសុខាភិបាលជាសកល (២) ធ្វើឲ្យប្រសើរឡើងនូវការចូលយកសេវា ដែលប្រជាជនអាចទទួលយកបាន(៣) ផ្តោតទៅលើបញ្ហាសុខភាព និងអន្តរាគមន៍ជាអាទិភាពនៅនឹងកន្លែង (ដើម្បីជំរុញភាពសមធម៌) (៤)ដោះស្រាយកត្តាកំណត់សុខភាពដទៃទៀត និងសមធម៌ដែលមាន ដូចជាធនធានមនុស្សសមស្រប និងមានជំនាញគ្រប់គ្រាន់ ក៏ដូចជាមធ្យោបាយធ្វើរោគវិនិច្ឆ័យ ព្រមទាំងការព្យាបាល និង(៥)ការផ្តល់ការថែទាំបឋមបែបសមាហរណកម្ម និងសមស្រប។

### ២. សមាសធាតុ មុខងារ

ការថែទាំបឋម បែបសមាហរណកម្មគឺប្រជាជនទទួលបាននូវ ការថែទាំជាបន្តពេញមួយជីវិត និងដែលមានការពាក់ព័ន្ធនឹងការគ្រប់គ្រង និងការផ្តល់សេវាសុខភាព ប្រកបដោយគុណភាព និងសុវត្ថិភាពតាមរយៈកម្រិតនិងទីតាំងផ្សេងៗ ការថែទាំសុខភាពបឋម ដែលរួមមានការលើកកម្ពស់សុខភាព ការការពារជំងឺ ការធ្វើរោគវិនិច្ឆ័យ ការព្យាបាល ការគ្រប់គ្រងជំងឺ ការស្តារលទ្ធភាពពលកម្ម និងសេវាព្យាបាលសម្រន់។

✳ **លក្ខណៈវិនិច្ឆ័យគុណភាព** ក្នុងការវាស់វែងការអនុវត្តន៍ ការថែទាំសុខភាពបឋម រួមមានៈ

- ប្រសិទ្ធភាព
- សុវត្ថិភាព

- ផ្តោតលើប្រជាជន
- លក្ខណៈគ្រប់ជ្រុងជ្រោយ
- លក្ខណៈបន្ត (ជាប់គ្នា)

✳ មុខងារសេវាសុខភាពជាសារវន្ត ចំពោះការថែទាំសុខភាពបឋម ដូចដែលបានប្រកាសតាំងពីមហាសន្និបាតនៅទីក្រុងអាល់ម៉ា អាល់តា(Alma Alta, Kazakhstan,1978) សង្កត់ធ្ងន់លើបណ្តាចំណុចដូចខាងក្រោម៖

- ការអប់រំដើម្បីសុខភាព
- ការប្រយុទ្ធនឹងជំងឺរាតត្បាតជាប្រចាំ ( endemic disease ) នៅនឹងកន្លែង
- កម្មវិធីផ្តល់ថ្នាំបង្ការ ( NIP )
- សុខភាពមាតានិងទារក រាប់បញ្ចូលទាំងការទទួលខុសត្រូវក្នុងភាពជាមាតា បិតា
- ឱសថសារវន្ត
- អាហារូបត្ថម្ភ
- ការព្យាបាលជំងឺឆ្លងនិងជំងឺមិនឆ្លង និង
- អនាម័យនិងទឹកស្អាត។

✳ **ជំងឺមិនឆ្លង**:ការផ្លាស់ប្តូរធម្មជាតិនិងបែបផែន នៃជំងឺ(អេពីដេមីសាស្ត្រ) ត្រូវបានទទួលឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ រួមផ្សំនឹងបែបបទនៃការហូបចំណីអាហារ ហើយដែលទាមទារអោយកម្រិតការថែទាំបឋមត្រូវធ្វើការបង្កើនស្រាវជ្រាវរកបញ្ហាសុខភាព (ឬពិនិត្យសុខភាព) ចំពោះជំងឺមិនឆ្លងរបស់ប្រជាជន ពិសេសប្រជាជន ដែលប្រឈមឬងាយរីវត្តន៍ ឬកើតជំងឺមិនឆ្លង ព្រមទាំង ផ្តល់អន្តរាគមន៍មានប្រសិទ្ធភាពដល់ប្រជាជន ដែលមានជំងឺមិនឆ្លងទាំងនោះ ។

ការដោះស្រាយបន្ទុកជំងឺមិនឆ្លង ទាមទារអោយមានយុទ្ធសាស្ត្រយូរអង្វែង ព្រមទាំងសេវាថែទាំបឋមដែលផ្តល់នូវការថែទាំឲ្យជិតបំផុត នឹងផ្ទះអ្នកជំងឺ ក្នុងនោះមាន៖

- ការផ្តោតលើបុគ្គល
- ផ្អែកលើភ័ស្តុតាង និងមានបច្ចុប្បន្នភាព
- រៀបចំដើម្បីត្រៀមនូវការកើនឡើងនៃ តម្រូវការពាក់ព័ន្ធនឹងជំងឺមិនឆ្លង និងកិច្ចការបច្ចេកទេសចំពោះជំងឺមិនឆ្លង
- មានទំនាក់ទំនងជាមួយសហគមន៍
- មានលក្ខណៈជាបន្តជាប់ជានិច្ច និងមាននិរន្តរភាព។

ដើម្បីសម្រេចបានការគ្របដណ្តប់សេវាសុខភាពជាសកល ត្រូវការភាពផ្តោតលើប្រជាជននិងសេវាថែទាំបឋម បែបសមាហរណកម្មពេញមួយជីវិត។

# ៣-តួនាទី និងការទទួលខុសត្រូវ

## ៣.១. តួនាទី និងការទទួលខុសត្រូវរួមរបស់មណ្ឌលសុខភាព

### ៣.១.១. តួនាទីការទទួលខុសត្រូវនិងគោលការណ៍រួម

មណ្ឌលសុខភាពមានតួនាទី ផ្តល់សេវាសុខាភិបាលជាមូលដ្ឋាន និងចាំបាច់ មានឈ្មោះថា "សំណុំសកម្មភាពអប្បបរមា" (ស.អ) ជូនដល់ប្រជាជន ជាពិសេសជនក្រីក្រ និងជនងាយរងគ្រោះ។ សេវាទាំងនោះរាប់បញ្ចូលទាំង សេវាសុខភាពមាតា-ទារក កុមារ និងសុខភាពបន្តពូជ អាហារូបត្ថម្ភ សេវាប្រយុទ្ធនឹងជំងឺឆ្លង សេវាប្រយុទ្ធនឹងជំងឺមិនឆ្លង សេវាសុខភាពមាត់ ធ្មេញ សុខភាពផ្លូវចិត្តនិងបញ្ហាសុខភាពដទៃទៀតប្រកបដោយគុណភាព។សេវាទាំងឡាយនេះក៏រួមបញ្ចូលផងដែរ ទាំងសេវាបែបព្យាបាល សេវាបង្ការ សេវាលើកកំពស់សុខភាព និងសេវាស្តារលទ្ធភាពពលកម្ម ព្រមទាំងសេវាដែលត្រូវអាចផ្តល់នៅមណ្ឌលសុខភាពនឹងកន្លែង និងនៅសហគមន៍ ពិសេសតាមរយៈសេវាចុះមូលដ្ឋាន។លើសពីនេះ សេវាទាំងនេះត្រូវមានទំនាក់ទំនង និងបំពេញឲ្យគ្នាទៅវិញទៅមក ជាមួយសេវានៃ "សំណុំសកម្មភាពបង្គ្រប់" (ស.ប) នៅថ្នាក់មន្ទីរពេទ្យបង្អែក។

មណ្ឌលសុខភាពត្រូវពង្រឹងការផ្តល់សេវាសុខាភិបាល ផ្តោតទៅលើតម្រូវការរបស់ប្រជាជន និងស្របទៅតាមស្តង់ដារនៃគុណភាព (សូមអានសេចក្តីលម្អិតនៅជំពូកទី១៣)។

ជាទូទៅ បញ្ហាសុខភាពសំខាន់ៗមួយចំនួន អាចត្រូវបានដោះស្រាយនៅថ្នាក់មណ្ឌលសុខភាព ដោយឡែកបញ្ហាសុខភាពមួយចំនួនទៀត មណ្ឌលសុខភាពពុំមានលទ្ធភាពផ្តល់ការធ្វើរោគវិនិច្ឆ័យ និងថែទាំព្យាបាលឡើយ។ ក្នុងករណីនេះ មណ្ឌលសុខភាពត្រូវមានសមត្ថភាព ក្នុងការកំណត់រកបញ្ហាសុខភាព ដែលត្រូវបញ្ជូនទៅថ្នាក់លើ ពិសេសមន្ទីរពេទ្យបង្អែក ឬមន្ទីរពេទ្យជាតិ ឧទាហរណ៍ ជំងឺរបេងកុមារ និងបញ្ហាសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ ឬអាចនិយាយបានម្យ៉ាងទៀតបានថា ចំពោះជំងឺមួយចំនួន តួនាទីមណ្ឌលសុខភាពគឺត្រឹមតែពិនិត្យសុខភាពរកជំងឺឬកំណត់ការសង្ស័យលើបញ្ហាសុខភាព (Screening) តែប៉ុណ្ណោះ ពុំមែនធ្វើរោគវិនិច្ឆ័យ (Diagnosing) និងដាក់អោយព្យាបាលពីដំបូងទីឡើយ។ ប៉ុន្តែ មណ្ឌលសុខភាពអាចទទួលដាក់ព្យាបាល ឬព្យាបាលបន្ត តាមវេជ្ជបញ្ជាពីគ្រូពេទ្យនៅមន្ទីរពេទ្យបង្អែក។

មណ្ឌលសុខភាពត្រូវអភិវឌ្ឍន៍ ចំណេះដឹងធនធានមនុស្សតាមរយៈ ការបណ្តុះបណ្តាល បំពាក់បំប៉នបច្ចេកទេសបន្ថែម និងការលើកទឹកចិត្តជូនបុគ្គលិក។លើសនេះថែមទៀត មណ្ឌលសុខភាពត្រូវគ្រប់គ្រងថវិកាពីគ្រប់ប្រភពអោយបានល្អ និងមានតម្លាភាព និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសមស្រប ព្រមទាំងចូលរួមអនុវត្តកម្មវិធីការគាំពារសង្គម រាប់ទាំងមូលនិធិសមធម៌ និងការធានារ៉ាប់រងសុខភាពផ្សេងៗទៀតផងដែរ។ ព្រមគ្នានេះដែរ មណ្ឌលសុខភាពត្រូវពង្រឹងប្រព័ន្ធព័ត៌មាន និងប្រព័ន្ធបញ្ជូនជំងឺអោយបានល្អ ព្រមទាំងត្រូវមានអភិបាលកិច្ចល្អ សុខដុមណីកម្ម ជាមួយដៃគូអភិវឌ្ឍន៍ និងសហគមន៍ទៀតផង។

ចំពោះមណ្ឌលសុខភាពដែលមានគ្រែ ពិសេសមណ្ឌលសុខភាពដែលជាអតីតមន្ទីរពេទ្យស្រុក ក្រៅពីភារកិច្ចជាអប្បបរមា ដូចមានចែងក្នុងសេចក្តីណែនាំនេះ ការងារបន្ថែមអាស្រ័យលើស្ថានភាពធនធានជាក់ស្តែង នៃមណ្ឌលសុខភាពនីមួយៗ។

## ៣.១.២ ភារកិច្ចបុគ្គលិកទទួលពិគ្រោះជំងឺក្រៅ៖ (គិលានុបដ្ឋាកមធ្យម ឬ គ្រូពេទ្យ)

ផ្តល់សេវាពិគ្រោះព្យាបាល និងថែទាំជំងឺដល់អ្នកជំងឺរាប់បញ្ចូលទាំងកុមារ នៅមណ្ឌលសុខភាព

បង្កើនការយល់ដឹងរបស់អ្នកជំងឺ និងគ្រួសារទាក់នឹងការបង្ការជំងឺឆ្លង ជំងឺមិនឆ្លង និងការលើកកំពស់សុខភាព។

ចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍសេវាសំណុំសកម្មភាពអប្បបរិមារបស់មណ្ឌលសុខភាព

- ចូលរួមក្នុងការផ្តល់សេវាពិនិត្យនិងពិគ្រោះជំងឺក្រៅ និងវះកាត់តូចបន្ទាប់បន្សំដល់ទាំងមនុស្សធំ និងកុមារ ដោយរួមបញ្ចូលទាំងសមារណកម្ម នៃការទទួលបន្ទុកទុកពិនិត្យ និងព្យាបាលជំងឺកុមារដល់អាយុក្រោម៥ឆ្នាំ រួមទាំងការពិនិត្យប័ណ្ណលឿង និងស្ថានភាពស្តីពីការចាក់ថ្នាំបង្ការ។
- ចូលរួមតាមដានសុខភាពកុមារអាយុក្រោម៥ឆ្នាំ និងផ្តល់ការព្យាបាលសមស្រប ឬបញ្ជូន។ ជាមួយគ្នានេះដែរ គឺរួមទាំងការស្រាវជ្រាវរកកម្សោយ ឬពិការភាពពីកំណើតរបស់ទារកនិងកុមារអាយុ ១ខែដល់៥ឆ្នាំ។ ប្រសិនបើកុមារមិនទាន់បានពិនិត្យស្រាវជ្រាវទេនោះគឺបុគ្គលិកត្រូវធ្វើនៅ៖
    - អាយុ៩ទៅ១២ខែ (ពេលផ្តល់ថ្នាំបង្ការ)
    - អាយុ២ទៅ៣ឆ្នាំ (ពេលដែលកុមារមានការរីកលូតលាស់យឺត)
    - អាយុ៥ទៅ៦ឆ្នាំ (ចាប់ផ្តើមចូលរៀនសាលា)។
- ផ្តល់ការអប់រំសុខភាពដល់អ្នកជំងឺ និង គ្រួសារ អំពីបញ្ហាសុខភាពរបស់ពួកគេ។
- ផ្តល់ការព្យាបាលសង្គ្រោះបន្ទាន់សមស្របដល់អ្នកជំងឺធ្ងន់ធ្ងរ មុននឹងបញ្ជូនទៅមន្ទីរពេទ្យ
- ណែនាំអ្នកជំងឺ និងគ្រួសារ អោយមកបន្តព្យាបាលនៅមណ្ឌលសុខភាព ដើម្បីតាមដានការវិវដ្តនៃជំងឺ។
- ធានាថាគ្រប់ការធ្វើរោគវិនិច្ឆ័យ និងព្យាបាល ត្រូវបានកត់ត្រាទុកត្រឹមត្រូវ។
- កត់ត្រា និងរាយការណ៍ត្រឹមត្រូវរាល់សកម្មភាពទាំងអស់។
- ធ្វើការលាងសម្អាតនិងរម្ងាប់មេរោគ នូវរាល់សម្ភារបរិក្ខារពេទ្យ ដែលត្រូវការថែទាំរបួស ឬប្រើប្រាស់ ។

## ៣.២. រចនាសម្ព័ន្ធចាត់តាំង និងស្តង់ដារបុគ្គលិក

### ៣.២.១ រចនាសម្ព័ន្ធចាត់តាំង

មណ្ឌលសុខភាពនីមួយៗ ត្រូវមានរចនាសម្ព័ន្ធចាត់តាំងមួយច្បាស់លាស់ សម្រាប់ដំណើរការការងារគ្រប់គ្រង និងការផ្តល់សេវារបស់ខ្លួន ។ រូបភាពទី១ ខាងក្រោមជាអង្គការលេខ បែបឧទាហរណ៍គម្រូមួយរបស់មណ្ឌលសុខភាព ដែលអាចយកទៅធ្វើបម្រែបម្រួលទៅតាមស្ថានភាពនៃចំនួនបុគ្គលិកក្នុងមណ្ឌលសុខភាព។ ការផ្លាស់ប្តូរទាំងឡាយអាចធ្វើបានបើចាំបាច់។ ឧទាហរណ៍ នៅក្នុងមណ្ឌលសុខភាពខ្លះ មានអ្នកទទួលខុសត្រូវផ្នែកសុខភាពផ្លូវចិត្ត ឬអ្នកទទួលបន្ទុកព្យាបាលធ្មេញជាដើម។ការបែងចែកផ្នែកឬសេវា អាស្រ័យលើចំនួនបុគ្គលិក ដែលក្នុងនោះបុគ្គលិកម្នាក់ អាចទទួលខុសត្រូវលើសពីសេវាឬផ្នែកមួយ ព្រមទាំងអាចបំពេញការងារតាមលក្ខណៈសមាហរណកម្ម។

**រូបភាពទី១: រចនាសម្ព័នចាត់តាំងមណ្ឌលសុខភាព**



## ៣.២.២ ស្តង់ដារបុគ្គលិក

ចំនួន និងប្រភេទ រួមទាំងកម្រិតជំនាញបច្ចេកទេស នៃបុគ្គលិកសុខាភិបាលមានលក្ខណៈសំខាន់បំផុត ដែលតម្រូវអោយមានជាចាំបាច់ នៅតាមមណ្ឌលសុខភាពនានាទូទាំងប្រទេស ដើម្បីផ្តល់សេវាសុខាភិបាល សមស្របទៅតាមសកម្មភាព និង ដំណើរការរបស់មណ្ឌលសុខភាព រួមទាំងការផ្តល់សេវាទាំងឡាយនៅនឹងកន្លែង រាប់ទាំងសេវា ២៤ម៉ោង ព្រមទាំងការធានាផ្តល់នូវសេវាចុះមូលដ្ឋាន ឱ្យបានទៀងទាត់ ដោយផ្អែកលើសេចក្តីណែនាំស្តីពីសេវាចុះមូលដ្ឋាន។

ក្រសួងសុខាភិបាលនឹងជំរុញការពង្រាយបុគ្គលិកក្របខ័ណ្ឌវេជ្ជបណ្ឌិតជាបណ្តើរៗ ឱ្យបានដល់គ្រប់មណ្ឌលសុខភាពទូទាំងប្រទេស ដោយផ្តល់អទិភាពដល់មណ្ឌលសុខភាពប្រភេទ "គ" ជាងមណ្ឌលសុខភាពប្រភេទដទៃ។

ជាទូទៅ ដើម្បីឱ្យមណ្ឌលសុខភាព ធានាបាននូវដំណើរការល្អប្រសើរ យ៉ាងហោចណាស់ទាមទារអោយមានបុគ្គលិកយ៉ាងតិចចំនួន៨រូប។ ដោយឡែកចំពោះស្រុកប្រតិបត្តិដែលមានលទ្ធភាពធនធានមនុស្ស ចំនួនបុគ្គលិកអាចមានច្រើនជាងនេះ រហូតដល់១១រូប ។ សូមបញ្ជាក់ថា ចំនួនបុគ្គលិកខាងលើនេះ មិនរាប់បញ្ចូល ចំនួនបុគ្គលិក ដែលបម្រើការនៅប៉ុស្តិ៍សុខភាព ហើយក៏មិនគ្របដណ្តប់មណ្ឌលសុខភាពដែលជាអតីតមន្ទីរពេទ្យស្រុកឡើយ។ ប៉ុស្តិ៍សុខភាពនីមួយៗ ត្រូវមានបុគ្គលិកយ៉ាងតិច ២នាក់ (គិលានុប្បដ្ឋាក ១នាក់ និងឆ្មប១នាក់)។ មណ្ឌលសុខភាពនិមួយៗត្រូវមានបុគ្គលិកមួយរូប សម្រាប់ការងារអនាម័យទូទៅ។ នៅថ្ងៃអនាគតក្របខ័ណ្ឌបឋមអាចចុះថយ ឬលែងមាន ក្នុងករណីនេះ នឹងត្រូវជំនួសដោយក្របខ័ណ្ឌមធ្យមឬបរិញ្ញាបត្រវិញ។ សូមអានតារាងទី២ ខាងក្រោម។

**តារាងទី២: ចំនួនបុគ្គលិកតាមប្រភេទមណ្ឌលសុខភាព**

| ល.រ | ប្រភេទបុគ្គលិក | ក | ខ | គ |
|---|---|---|---|---|
| ១ | វេជ្ជបណ្ឌិត | 0 | 0 | ១ |
| | គ្រូពេទ្យមធ្យម | | | |
| ២ | ឆ្មបបរិញ្ញាបត្រ | ១ | ២ | ២ |
| | ឆ្មបមធ្យម | | | |
| ៣ | ឆ្មបបឋម* | ១ | ១ | ២ |
| ៤ | គិលានុបដ្ឋាកបរិញ្ញាបត្រ | ២ | ២ | ២ |
| | គិលានុបដ្ឋាកមធ្យម | | | |
| ៥ | គិលានុបដ្ឋាកបឋម* | ២ | ២ | ២ |
| ៦ | បុគ្គលិកដទៃទៀត**(ទន្តគិលានុបដ្ឋាក, អ្នកព្យាបាលដោយចលនា, ចក្ខុគិលានុបដ្ឋាក....) | ២ | ២ | ២ |
| សរុប | | ៨ | ៩ | ១១ |

** នៅពេលអនាគតយូរអង្វែងក្រុមបខ័ណ្ឌបឋម ទាំងនេះនឹងលែងមាន ហើយត្រូវជំនួសដោយក្របខ័ណ្ឌមធ្យម។*

*** ក្រុមបុគ្គលិកប្រភេទនេះរាប់បញ្ចូលទាំង ទន្តគិលានុបដ្ឋាក, អ្នកព្យាបាលដោយចលនា, ចក្ខុគិលានុបដ្ឋាក និងបុគ្គលិកផ្សេងៗទៀតរាប់ទាំងអ្នកមានជំនាញ និងពុំមានជំនាញសុខាភិបាល ។*

**<u>មណ្ឌលសុខភាពប្រភេទ " ក "</u>**

ជាមណ្ឌលសុខភាពសំណុំសកម្មភាពអប្បបរមា ដែលមានបុគ្គលិកតិចជាងគេ (៨នាក់)និងគ្របដណ្តប់ប្រជាជនតិចឬស្មើ ៨០០០នាក់។ បច្ចុប្បន្ននេះ មណ្ឌលសុខភាពមួយចំនួនធំស្ថិតនៅក្នុងប្រភេទ "ក"។

**<u>មណ្ឌលសុខភាពប្រភេទ " ខ "</u>**

បុគ្គលិកមានចំនួនលើសពីប្រភេទ " ក " តែម្នាក់ប៉ុណ្ណោះ គឺជាបុគ្គលិកឆ្មបបរិញ្ញាបត្រឬ ឆ្មបមធ្យម និងគ្រប់ដណ្តប់ប្រជាជនចន្លោះ ៨០០០ ដល់ ១២០០០ នាក់។

**<u>មណ្ឌលសុខភាពប្រភេទ " គ "</u>**

គឺជាប្រភេទមណ្ឌលសុខភាព ដែលមានបុគ្គលិក១១នាក់ ក្នុងនោះមានវេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ១រូប និងឆ្មប ១រូប (បរិញ្ញាបត្រ ឬមធ្យម) លើសពីមណ្ឌលសុខភាពប្រភេទ " ខ "និងគ្រប់ដណ្តប់ប្រជាជនស្មើ ឬលើសពី ១២០០០នាក់ ។

ដោយហេតុថា ក្របខ័ណ្ឌមធ្យមឬបរិញ្ញាបត្រ បីបួនប្រភេទ ខាងលើមានកំរិត ចំណេះដឹងបច្ចេកទេសជាមូលដ្ឋាន ប្រហាក់ប្រហែលគ្នា បុគ្គលិកក្របខ័ណ្ឌមួយអាចបំពេញប្រអប់ ឬកិច្ចការជំនួសក្របខ័ណ្ឌមួយទៀតបាន ឧ.ក្របខ័ណ្ឌទន្តគិលានុបដ្ឋាក ឬព្យាបាលដោយចលនា អាចជំនួសគិលានុបដ្ឋាកបាន។ល។ ក្នុងករណីចាំបាច់ ការវិភាគមុខងារ និងតួនាទីនិងភារកិច្ចពាក់ព័ន្ធនឹងបុគ្គលិកក្របខ័ណ្ឌទាំងនេះ ព្រមទាំងបុគ្គលិកប្រភេទដទៃទៀតនៃមណ្ឌលសុខភាព គប្បីរៀបចំធ្វើ ដើម្បីផ្តល់ការណែនាំបន្ថែមលើកិច្ចការនេះ។

## ៣.៣. កញ្ចប់សេវាសំខាន់ៗ សម្រាប់មណ្ឌលសុខភាព

### ៣.៣.១ សុខភាពបន្តពូជ មាតា ទារក កុមារ អាហារូបត្ថម្ភ និងថ្នាំបង្ការ

**<u>តួនាទីសំខាន់ៗមណ្ឌលសុខភាព</u>**

១. ផ្តល់សេវាពិនិត្យផ្ទៃពោះមុនសម្រាល ក្នុងមណ្ឌលសុខភាព និងតាមសហគមន៍ សមស្របតាមគោលការណ៍ណែនាំរបស់កម្មវិធីជាតិ។

២. ផ្តល់ថ្នាំបង្ការគ្រប់ប្រភេទតាមគោលការណ៍ណែនាំ របស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ។

៣. ផ្តល់សេវាពន្យារកំណើត សុខភាពបន្តពូជ និងយុវវ័យ។
៤. ផ្តល់សេវាសម្រាលកូន ពិនិត្យក្រោយសម្រាល រួមទាំងការថែទាំទារកទើបនឹងកើត រំលូត/រលូត ដោយសុវត្ថិភាព តាមពិធីសារជាតិមាតុភាពគ្មានគ្រោះថ្នាក់។
៥. ផ្តល់សេវាសុខភាពជូនកុមារ តាមយុទ្ធសាស្ត្រសមាហរណកម្មទទួលបន្ទុកពិនិត្យព្យាបាលជំងឺកុមារ (ស.ព.ជ.ក) រាប់បញ្ចូលទាំងការងារអាហារូបត្ថម្ភ។
៦. ផ្តល់ការប្រឹក្សា និងណែនាំ ឬអប់រំសុខភាពអោយបានសមស្រប ដែលទាក់ទងនឹងៈ
   - ការត្រៀមជុំវិញកំណើត សញ្ញាគ្រោះថ្នាក់ពេលមានផ្ទៃពោះ ការថែទាំក្រោយសម្រាល និងស្រាវជ្រាវរកកត្តាប្រឈមមុខ រួមទាំងបញ្ហាពិការភាពផ្សេងៗ និងធ្វើការបញ្ជូនអោយបានសមស្រប។
   - សារៈប្រយោជន៍នៃការចិញ្ចឹមកូនដោយទឹកដោះម្តាយសុទ្ធ និងផលវិបាកនៃការបំបៅកូនដោយម្សៅទឹកដោះគោ។
   - មធ្យោបាយពន្យារកំណើត សុខភាពយុវវ័យ សុខភាពផ្លូវភេទ និងអំពើហិង្សា។ល។
៧. អនុវត្តការបង្ការការចម្លងរោគជាសាកលដូចជាលាងសម្អាតនិងសម្លាប់មេរោគនូវរាល់សម្ភារបរិក្ខារពេទ្យដែលត្រូវការសម្រាប់ការថែទាំមុនសម្រាល។
៨. ចូលរួមសហការសកម្មភាពស្រាវជ្រាវទារកស្លាប់ និងមាតាស្លាប់ ជាមួយបុគ្គលិកថ្នាក់ស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាលខេត្ត ពិសេសការងារអភិបាល។
៩. រួមដំណើរជាមួយអ្នកជំងឺ ក្នុងការបញ្ជូនករណីសម្រាលពិបាកពីសហគមន៍ មកមណ្ឌលសុខភាព និងពីមណ្ឌលសុខភាព នៅមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ ឬមន្ទីរពេទ្យបង្អែក ខេត្ត-រាជធានី។
១០. សហការណ៍ជាមួយ អ្នកស្ម័គ្រចិត្តក្នុងសហគមន៍ និងអង្គការក្រៅរដ្ឋាភិបាល ឆ្មបបុរាណ ដើម្បីអប់រំសុខភាពនិងផ្តល់ការប្រឹក្សាអំពីសុខភាពមាតា ទារក កុមារ និងសុខភាពបន្តពូជ។
១១. ចូលរួមស្រាវជ្រាវរកភាពកម្សោយទារក និងពិការភាពរបស់ទារកក្រោយកើត ដោយពិនិត្យពីក្បាលរហូតដល់ចុងជើង ដើម្បីបញ្ជាក់ពីសុខភាពរបស់ទារក ហើយបើសិនមានសញ្ញាណាមួយមិនប្រក្រតី ដូចជា ឆែបមាត់ ជើងខ្វេ គ្មានរន្ធគូថ ឬបញ្ហាពិការភាពផ្សេងទៀត ត្រូវបញ្ជូនទៅរកមន្ទីរពេទ្យណាដែលអាចជួយព្យាបាល និងផ្តល់សេវាស្តារលទ្ធភាពពលកម្ម ទាន់ពេលវេលាបាន។ បន្ទាប់មកផ្តល់ដំបូន្មានដល់ម្តាយឬក្រុមគ្រួសារពីបញ្ហាទាំងអស់នេះ។
១២. ចូលរួមការប្រជុំថ្នាក់មណ្ឌលសុខភាព ជាមួយក្រុមទ្រទ្រង់សុខភាព និងគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព។
១៣. ចូលរួមសហការ ក្នុងការងារលើកកំពស់គុណភាព នៃផ្តល់សេវាដល់ប្រជាពលរដ្ឋ ដូចជា ការផ្តល់ថ្នាំបង្ការដល់ស្ត្រី ទារក និងកុមារ ជាដើម។
១៤. បំពេញរបាយការណ៍អោយបានត្រឹមត្រូវ តាមទម្រង់ដែលមានស្រាប់របស់មណ្ឌលសុខភាព និងធ្វើរបាយការណ៍ស្តីពីសុខភាពមាតា ទារក កុមារ និងសុខភាពបន្តពូជទៅអោយស្រុកប្រតិបត្តិ ។

លើសនេះថែមទៀត ក្រៅពីការងារខាងលើ ឆ្មប ឬបុគ្គលិកបំរើការងារផ្នែកនេះ ត្រូវមានភារកិច្ចគ្រប់គ្រង និងថែរក្សា សម្ភារបរិក្ខារពេទ្យ ឱសថ តេស្ត( តេស្តទឹកនោមជាដើម ) ព្រមទាំងកត់ត្រាព័ត៌មាន និងរាយការណ៍ពីសកម្មភាពប្រជុំបណ្តុះបណ្តាលផ្សេងៗ ដែលពាក់ព័ន្ធ នឹងសុខភាព មាតា ទារក កុមារ និងសុខភាពបន្តពូជ។

## ៣.៣.២ ជំងឺឆ្លង

### ៣.៣.២.១ ជំងឺរបេង

តួនាទីរួមសំខាន់ៗរបស់មណ្ឌលសុខភាព សម្រាប់ការស្រាវជ្រាវ ព្យាបាល និងបង្ការជំងឺរបេងមានដូចខាងក្រោមៈ

១- ពិនិត្យសុខភាពរកជំងឺរបេងឬកំណត់រកអ្នកសង្ស័យជំងឺរបេង(TB screeing) គ្រប់ប្រភេទ។

២- ធ្វើរោគវិនិច្ឆ័យចំពោះជំងឺរបេងសួតវិជ្ជមានបេកា ដោយការពិនិត្យមីក្រូទស្សន៍ ឬតេស្តជីនអិចស្ពឺត។

៣- ដាក់អ្នកជំងឺឲ្យព្យាបាលពីដំបូងទី និងទទួលការព្យាបាលបន្ត រាប់ទាំងការព្យាបាលបង្ការ។

៤- ផ្តល់សេវាបញ្ជូនដើម្បីធ្វើរោគវិនិច្ឆ័យ និងព្យាបាលនៅថ្នាក់បន្ទាប់ពិសេសមន្ទីរពេទ្យបង្អែករាប់ទាំងអ្នកជំងឺរបេងធ្ងន់ធ្ងរ ករណីសង្ស័យរបេងកុមារ និងរបេងស៊ាំថ្នាំ។

៥- ផ្តល់ការអប់រំសុខភាព ស្តីពីជំងឺរបេងនៅមណ្ឌលសុខភាព រួមទាំងការផ្តល់ដំបូន្មានមុនទទួលការព្យាបាល និងអំឡុងពេលព្យាបាល។

៦- សកម្មភាពចុះមូលដ្ឋាន រាប់បញ្ចូលទាំងការតាមដានអ្នកជំងឺខកខានមកព្យាបាលការស្រាវជ្រាវរកករណីជំងឺរបេង និងការអប់រំសុខភាព។

លើសនេះថែមទៀត ក្រៅពីការងារបច្ចេកទេស ពិសេសការផ្តល់សេវា មណ្ឌលសុខភាព ត្រូវមានភារកិច្ចគ្រប់គ្រង និងថែរក្សា ឱសថ បរិក្ខារ ប្រតិករ របេង ព្រមទាំងការកត់ត្រាព័ត៌មាន និងរាយការណ៍ក៏ដូចជា ការងារប្រជុំផ្សេងៗ ពាក់ព័ន្ធនឹងជំងឺរបេង ផងដែរ។

មណ្ឌលសុខភាពមានតួនាទី ពិនិត្យសុខភាពរកជំងឺរបេងគ្រប់សណ្ឋានទាំងអស់ ។ ចំពោះការធ្វើរោគវិនិច្ឆ័យ មណ្ឌលសុខភាពមានតួនាទី សម្រាប់តែជំងឺរបេងសួតវិជ្ជមានបេកាតែប៉ុណ្ណោះ ពិសេសការយកឬពាសកំហាក(ពីអ្នកសង្ស័យ) និងបញ្ជូនទៅមណ្ឌលមីក្រូទស្សន៍ ឬជីនអ៊ិចស្ពើត។ ចំពោះជំងឺរបេងកុមារ របេងអវិជ្ជមានបេកា និងរបេងក្រៅសួត ក្រោយពីមានការសង្ស័យ មណ្ឌលសុខភាពត្រូវបញ្ជូនករណីសង្ស័យទៅមន្ទីរពេទ្យបង្អែក ដើម្បីធ្វើរោគវិនិច្ឆ័យ។ ដោយឡែកចំពោះជំងឺរបេងស៊ាំថ្នាំ ក្រោយពីសង្ស័យហើយ ត្រូវចាត់ចែងតាមលក្ខណៈពិសេស (សូមអានសេចក្តីលម្អិត នៅក្នុងសេចក្តីណែនាំ និងពិធីសារបច្ចេកទេស នៃកម្មវិធីជាតិកំចាត់រោគរបេង)។

## ៣.៣.២.២ ជំងឺហង់សិន

កំណត់រកអ្នកសង្ស័យ និងធ្វើរោគវិនិច្ឆ័យដាក់អ្នកជំងឺឲ្យព្យាបាល រាប់ទាំងការព្យាបាលបង្ការ ផ្តល់សេវាបញ្ជូន រាប់បញ្ចូលទាំងសម្រាប់សេវាស្តារលទ្ធភាពពលកម្ម ។ ការកត់ត្រានិងរាយការណ៍ រួមទាំងការថែរក្សាឱសថ បរិក្ខារជំងឺហង់សិន។

(សូមអានសេចក្តីលម្អិត នៅក្នុងសេចក្តីណែនាំ និងពិធីសារបច្ចេកទេស នៃកម្មវិធីជាតិកំចាត់ជំងឺហង់សិន)។

## ៣.៣.២.៣ ជំងឺគ្រុនចាញ់

តួនាទីនិងភារកិច្ច មណ្ឌលសុខភាពៈ

១. ផ្តល់ការប្រឹក្សាស្តីពីជំងឺគ្រុនចាញ់ចំពោះអ្នកដែលសង្ស័យមានជំងឺគ្រុនចាញ់។
២. ផ្តល់សេវាធ្វើតេស្តឈាម (តេស្តរហ័ស/មីក្រូទស្សន៍) រកមេរោគគ្រុនចាញ់ ដល់អ្នកដែលសង្ស័យមានជំងឺគ្រុនចាញ់។
៣. ផ្តល់សេវាព្យាបាលជំងឺគ្រុនចាញ់ស្រាល ដល់អ្នកដែលមានជំងឺគ្រុនចាញ់ និងចំពោះអ្នកជំងឺគ្រុនចាញ់ធ្ងន់ ចំពោះមណ្ឌលសុខភាព ដែលមានគ្រែសំរាក។
៤. ផ្តល់សេវាបញ្ជូនអ្នកជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ ទៅមន្ទីរពេទ្យបង្អែក។
៥. ចូលរួមផ្តល់សេវាបែងចែកមុងជ្រលក់ថ្នាំដល់ប្រជាជន ដែលរស់នៅប្រឈមនឹងជំងឺ គ្រុនចាញ់ ។
៦. ធ្វើការប្រជុំជាមួយអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ភូមិ ផ្ទៀងផ្ទាត់ការធ្វើរោគវិនិច្ឆ័យ/ការព្យាបាល ផ្តល់សំភារៈតេស្ត និងថ្នាំគ្រុនចាញ់ និងពិនិត្យរបាយការណ៍ ។
៧. ចូលរួមការប្រជុំជាមួយអ្នកផ្តល់សេវាឯកជនជំងឺគ្រុនចាញ់ ផ្ទៀងផ្ទាត់ការធ្វើរោគវិនិច្ឆ័យ/ការព្យាបាល ផ្តល់សំភារៈតេស្ត និងថ្នាំគ្រុនចាញ់ និង ពិនិត្យរបាយការណ៍ ។
៨. ចូលរួមផ្តល់សេវាអប់រំពីការចម្លងជំងឺគ្រុនចាញ់នៅតាមសហគមន៍ ។
៩. ធ្វើរបាយការណ៍ជំងឺគ្រុនចាញ់របស់មណ្ឌលសុខភាព/អ្នកស្មគ្រ័ចិត្ត/សេវាឯកជន ស្តីពីជំងឺគ្រុនចាញ់បន្ថែមទៅលើរបាយការណ៍ MIS តាមបែបអេឡិចត្រូនិក។
១០. ធ្វើរបាយការណ៍ស្តុក ឱសថ បរិក្ខារជំងឺគ្រុនចាញ់ រួមមាន ថ្នាំ តេស្តរហ័ស មុង កញ្ចក់ឈាម ជាដើម។
១១. ចូលរួមសកម្មភាពដែលទាក់ទងជំងឺគ្រុនចាញ់ផ្សេងទៀត ដូចជាសកម្មភាពឆ្លើយតបបន្ទាន់តាមដានជំងឺគ្រុនចាញ់ និងជំរឿនប្រជាជនចល័តជាដើម ។

(សូមអានសេចក្តីលម្អិត នៅក្នុងសេចក្តីណែនាំ និងពិធីសារបច្ចេកទេស នៃកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់)។

## ៣.៣.២.៤ ជំងឺគ្រុនឈាម

តួនាទីនិងភារកិច្ច មណ្ឌលសុខភាព ចំពោះជំងឺគ្រុនឈាម៖

១. ផ្តល់ការប្រឹក្សាស្តីពីជំងឺគ្រុនឈាម ចំពោះអ្នកដែលសង្ស័យមានជំងឺគ្រុនឈាម។

២. ផ្តល់សេវាធ្វើតេស្ត ប៉ារ៉ាគ្លីនិកដល់អ្នកដែលសង្ស័យ មានជំងឺគ្រុនឈាម ។

៣. ផ្តល់សេវាបញ្ជូនអ្នកជំងឺសង្ស័យគ្រុនឈាម ទៅមន្ទីរពេទ្យបង្អែក។

៤. ចូលរួមផ្សព្វផ្សាយ និងផ្តល់សេវាអប់រំសុខភាព រួមទាំងចលនាសហគមន៍ ចូលរួមស្តីពីវិធានការបង្ការ និងគ្រប់គ្រងជំងឺគ្រុនឈាម ។

៥. ចូលរួមធ្វើការការពារការចម្លងជំងឺគ្រុនឈាម តាមរយៈការដាក់ថ្នាំបាណកឃាដក្នុងពាងទឹក និងលុបបំបាត់វត្ថុដែលអាចដក់ទឹកបាន។

៦. ចូលរួមសកម្មភាពគ្រប់គ្រងជំងឺគ្រុនឈាម រួមទាំងសកម្មភាពពាក់ព័ន្ធផ្សេងទៀត ដូចជាយុទ្ធនាការដាក់ថ្នាំអាបែត បាញ់ថ្នាំ ពិសេសពេលមានការរាតត្បាត ជាដើម ។

(សូមអានសេចក្តីលម្អិត នៅក្នុងសេចក្តីណែនាំ និងពិធីសារបច្ចេកទេស នៃកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម)។

## ៣.៣.២.៥ ជំងឺអេដស៍ និងកាមរោគ

### តួនាទីរបស់មណ្ឌលសុខភាព

១- ស្រាវជ្រាវករណីឆ្លងជំងឺអេដស៍ ដោយផ្តល់ការធ្វើតេស្តជួសចុងម្រាមដៃ តេស្តទី១ (1st Screening test)។

២- បញ្ជូនករណីដែលប្រតិកម្មតេស្តចុងម្រាមដៃ ដែលជាតេស្តទី១ ទៅមន្ទីរពេទ្យ ដែលមានសេវាធ្វើតេស្តឈាមដោយស្មគ្រ័ចិត្ត និងរក្សាការសម្ងាត់ (VCCT) ដើម្បីធ្វើតេស្តបញ្ជាក់ មួយចំនួនទៀត និងធ្វើរោគវិនិច្ឆ័យ ហើយបន្តចុះឈ្មោះនៅសេវាព្យាបាលជំងឺអេដស៍ បើសិនជាវិជ្ជមាន។

៣- ធ្វើការព្យាបាលជំងឺកាមរោគ តាមចង្កោមរោគសញ្ញា។

៤- ផ្តល់ការងារអប់រំសុខភាព ទាំងនៅមណ្ឌលសុខភាព និងសហគមន៍។

លើសពីនេះទៅទៀត ក្រៅពីការងារបច្ចេកទេសខាងលើ មណ្ឌលសុខភាពត្រូវមានភារកិច្ចក្នុងការគ្រប់គ្រង និងថៃរក្សាឱសថ បរិក្ខារ ប្រតិករ ជំងឺអេដស៍ ព្រមទាំងការកត់ត្រាព័ត៌មានរាយការណ៍ ក៏ដូចជាការងារប្រជុំផ្សេងៗពាក់ព័ន្ធនឹងការប្រយុទ្ធនឹងជំងឺអេដស៍ផងដែរ។ (សូមអានសេចក្តីលម្អិត នៅក្នុងសេចក្តីណែនាំ និងពិធីសារបច្ចេកទេស នៃកម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍)។

## ៣.៣.២.៦ ជំងឺឆ្លងដទៃទៀត

ជំរុញការតាមដាន និងការឆ្លើយតបនឹងជំងឺឆ្លង និងជំងឺបង្កឱ្យមានការរាតត្បាតផ្សេងៗ (Outbreak-prone diseases) នៅក្នុងសហគមន៍ រួមមានប្រព័ន្ធតាមដានជំងឺទាន់ហេតុការ (CamEWARN) និងជំងឺកើតឡើងថ្មីជាច្រើនទៀត (Emerging and re-emerging diseases) ស្របទៅតាមគោលនយោបាយ និងមគ្គទេសក៍របស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ក្រសួងសុខាភិបាល ។

១. ប្រមូល វិភាគ បកស្រាយ និងរាយការណ៍ពីជំងឺ និងព្រឹត្តិការសុខភាពសាធារណៈ ឱ្យបានទាន់ពេលវេលា និងប្រកបដោយគុណភាព។

២. សហការណ៍ជាមួយស្រុកប្រតិបត្តិ មន្ទីរសុខាភិបាលខេត្ត និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង នៅក្នុងការអង្កេតស្រាវជ្រាវ និងការឆ្លើយតបនឹងព្រឹត្តិការសុខភាពសាធារណៈ ឱ្យបានទាន់ពេលវេលា។

៣. ស្វែងយល់ជំងឺឆ្លងកើតឡើងថ្មីៗ ផ្តល់ការគ្រប់គ្រងជំងឺ និងការអប់រំសុខភាព ជាពិសេសជំងឺឆ្លងពីសត្វ។

៤. លើកកម្ពស់ការព្យាបាលជំងឺឆ្លង ទៅតាមពិធីសារជាតិ ដើម្បីកាត់បន្ថយនូវភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ជាពិសេសអង់ទីប៊ីយ៉ូទិក។

**ជំងឺដែលអាចការពារបានដោយវ៉ាក់សាំង (Vaccine Preventable Disease ) និងផលរំខានមិនល្អដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ (Adverse Events Following Immunization) ជំងឺពាក់ព័ន្ធនឹងកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ដែលត្រូវតាមដាននិងស្រាវជ្រាវមាន៖** ករណីសង្ស័យជំងឺគ្រុនស្វិតដៃជើង ជំងឺកញ្ជ្រឹល ជំងឺស្អូច ជំងឺខាន់ស្លាក់ ជំងឺក្អកមាន់ ទារកស្លាប់ក្រោម២៨ថ្ងៃ និងជំងឺតេតាណូសទារក។

**តួនាទីរបស់មណ្ឌលសុខភាព**

១. កំណត់អ្នកទទួលខុសត្រូវក្នុងការតាមដានស្រាវជ្រាវជំងឺពាក់ព័ន្ធនឹងកម្មវិធីជាតិផ្តល់ថ្នាំបង្ការនិងហេតុការណ៍មិនល្អដែលកើតមានក្រោយការផ្តល់ថ្នាំបង្ការ។

២. រាយការណ៍ជាបន្ទាន់រាល់ករណីសង្ស័យជំងឺពាក់ព័ន្ធនឹងកម្មវិធីជាតិផ្តល់ថ្នាំបង្ការនិង ហេតុការណ៍មិនល្អដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ (ទាំងករណីស្រាល និង ធ្ងន់ធ្ងរ) ទៅស្រុកប្រតិបត្តិ ឬ មន្ទីរសុខាភិបាលរាជធានី ខេត្ត។

៣. ផ្ញើរបាយការណ៍ប្រចាំខែនៃករណីសង្ស័យជំងឺពាក់ព័ន្ធនឹងកម្មវិធីជាតិផ្តល់ថ្នាំបង្ការនិង ហេតុការណ៍មិនល្អដែលកើតមានក្រោយផ្តល់ថ្នាំបង្ការ (ទាំងករណីស្រាល និងធ្ងន់ធ្ងរ) ទៅស្រុកប្រតិបត្តិអោយបានទៀនទាត់។

៤. ស្រាវជ្រាវសកម្មដើម្បីស្វែងរកជំងឺពាក់ព័ន្ធនឹងកម្មវិធីជាតិផ្តល់ថ្នាំបង្ការ នៅសហគមន៍ក្នុងកំឡុងពេលចុះផ្តល់វ៉ាក់សាំងតាមមូលដ្ឋាន។

៥. ផ្តល់ចំណេះដឹង និង និយមន័យអំពីជំងឺពាក់ព័ន្ធនឹងកម្មវិធីជាតិផ្តល់ថ្នាំបង្ការទៅដល់ក្រុមទ្រទ្រង់សុខភាពភូមិព្រមទាំងអោយពួកគាត់រាយការណ៍ឱ្យបានទៀងទាត់។

៦. បញ្ចូលសកម្មភាពនិងកម្មវិធីតាមដានស្រាវជ្រាវជំងឺពាក់ព័ន្ធកម្មវិធីជាតិផ្តល់ថ្នាំបង្ការទៅក្នុងកម្មវិធីប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន។

៧. សហការណ៍ជាមួយស្រុកប្រតិបត្តិ ឬមន្ទីរសុខាភិបាលខេត្តក្នុងការចុះអង្កេត និងយកវត្ថុវិភាគ។

## ៣.៣.៣ ជំងឺមិនឆ្លង

### ៣.៣.៣.១ ជំងឺលើសសម្ពាធឈាម និងជំងឺទឹកនោមផ្អែម

### ក. ជំងឺលើសសម្ពាធឈាម

តួនាទីនិងភារកិច្ចសំខាន់ៗ របស់មណ្ឌលសុខភាព សម្រាប់ការពិនិត្យសុខភាព ធ្វើរោគវិនិច្ឆ័យ ព្យាបាល បង្ការ អប់រំ និងផ្តល់ការប្រឹក្សា ជំងឺលើសសម្ពាធឈាម ពិសេសលើប្រជាជនដែលមានអាយុចាប់ពី៤០ឆ្នាំឡើង មានដូចខាងក្រោម៖

១. ធ្វើការពិនិត្យដោយវាស់សម្ពាធឈាមនិងពិគ្រោះយោបល់ ។

២. ផ្តល់ការព្យាបាលដល់អ្នកជំងឺលើសសម្ពាធឈាម ដែលពុំមានផលវិបាក។

៣. ផ្តល់ការប្រឹក្សាស្តីអំពីហានិភ័យនៃជំងឺលើសសម្ពាធឈាម អប់រំពីរបបអាហារ ការធ្វើកាយវប្បកម្ម គ្រោះថ្នាក់ នៃការប្រើប្រាស់គ្រឿងស្រវឹង និងការប្រើប្រាស់ថ្នាំជក់។ល។

៤. សម្របសម្រួល ក្នុងការបញ្ជូនអ្នកមានជំងឺលើសសម្ពាធឈាមធ្ងន់ធ្ងរ និងមានផលវិបាកទៅកាន់មន្ទីរពេទ្យបង្អែក។

៥. ផ្តល់ការថែទាំនិងព្យាបាលបន្ត ចំពោះអ្នកជំងឺលើសម្ពាធឈាម ដែលបញ្ជូនមកពីមន្ទីរពេទ្យបង្អែកត្រលប់មកមណ្ឌលសុខភាពវិញ។

៦. រៀបចំសកម្មភាពអប់រំផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹងពីហានិភ័យនៃជំងឺមិនឆ្លង និងជំងឺលើសសម្ពាធឈាម។

៧. រៀបចំបញ្ជីឱសថសារវន្តសម្រាប់ជំងឺលើសសម្ពាធឈាមសម្រាប់ស្នើទៅស្រុកប្រតិបត្តិ

### ខ. ជំងឺទឹកនោមផ្អែម

តួនាទីនិងភារកិច្ចសំខាន់ៗ របស់មណ្ឌលសុខភាព សម្រាប់ការពិនិត្យសុខភាព ធ្វើរោគវិនិច្ឆ័យ ព្យាបាល បង្ការ អប់រំ និងផ្តល់ការប្រឹក្សា ជំងឺទឹកនោមផ្អែម ពិសេសលើប្រជាជនដែលមានអាយុចាប់ពី ៤០ឆ្នាំឡើង មានដូចខាងក្រោម៖

១. ផ្តល់សេវាធ្វើតេស្តរកជាតិស្ករមុនអាហារដល់អតិថិជន។

២. ផ្តល់ការប្រឹក្សាស្តីអំពីហានិភ័យនៃជំងឺទឹកនោមផ្អែម អប់រំពីរបបអាហារ ការធ្វើកាយវប្បកម្ម ការប្រើប្រាស់គ្រឿងស្រវឹង និងការប្រើប្រាស់ថ្នាំជក់។ល។

៣. សម្របសម្រួល ក្នុងការបញ្ជូនអ្នកប្រឈមមុខនឹងជំងឺទឹកនោមផ្អែម នៅមន្ទីរពេទ្យបង្អែកដែលមានគ្លីនិកទឹកនោមផ្អែម ដើម្បីធ្វើការបញ្ជាក់បន្ថែមក្នុងការធ្វើរោគវិនិច្ឆ័យ និងព្យាបាល។
៤. ផ្តល់ការថែទាំនិងព្យាបាលបន្ត ចំពោះអ្នកជំងឺទឹកនោមផ្អែមដែលបញ្ជូនពីមន្ទីរពេទ្យបង្អែកដែលមានគ្លីនិកទឹកនោមផ្អែម ត្រលប់មកមណ្ឌលសុខភាពវិញ។
៥. រៀបចំសកម្មភាពអប់រំផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹងពីហានិភ័យនៃជំងឺមិនឆ្លង និងជំងឺទឹកនោមផ្អែម។
៦. រៀបចំបញ្ជីឱសថសារវ័ន្តសម្រាប់ជំងឺទឹកនោមផ្អែម សម្រាប់ស្នើទៅស្រុកប្រតិបត្តិ។

## ៣.៣.៣.២ ជំងឺមហារីកដោះនិងមហារីកមាត់ស្បូន

## ក. ជំងឺមហារីកដោះ

តួនាទីនិងភារកិច្ចសំខាន់ៗ របស់មណ្ឌលសុខភាព សម្រាប់ការស្រាវជ្រាវ បង្ការ អប់រំ ជាប្រចាំជំងឺមហារីកដោះ សំដៅរកឲ្យឃើញទាន់ពេលវេលា ដើម្បីបង្ការ ព្រមទាំងបញ្ជូនទៅធ្វើ រោគវិនិច្ឆ័យនិងព្យាបាល ចំពោះអ្នកដែលសង្ស័យថាមាន ឬមហារីកដោះ ពិសេសលើស្ត្រីក្នុងវ័យបន្តពូជ។ អ្នកពិគ្រោះជំងឺជាឆ្មបនៅមណ្ឌលសុខភាពដែលបានទទួលការបណ្តុះបណ្តាល មានដូចខាងក្រោម៖

- ពិនិត្យដោះជូនដល់ស្ត្រីដែលបានមកដល់មណ្ឌលសុខភាព ឬ ស្ត្រីដែលមក ពិគ្រោះថាមានដុំដោះ។
- បញ្ជូនទៅរកការធ្វើរោគវិនិច្ឆ័យនិងព្យាបាលប្រសិនជាសង្ស័យថាមានដុំដោះ ឬ សង្ស័យថាមានមហារីកដោះ។
- បង្កើនការយល់ដឹងដល់ស្ត្រី ពិសេសក្នុងវ័យបន្តពូជអំពីជំងឺមហារីកដោះ និងផលលំបាក ដែលបណ្តាលមកពីជំងឺនេះ។
- ផ្តល់ការប្រឹក្សាឲ្យបានត្រឹមត្រូវស្តីអំពី ការពិនិត្យដោះដោយខ្លួនឯង (ផលលំបាក ផលចំណេញផ្នែកសុខភាព កត្តាគ្រោះថ្នាក់និងប្រាប់ពីជម្រើសនៃការស្រាវជ្រាវ)។
- បង្រៀនអំពីការពិនិត្យដោះដោយខ្លួនឯងដល់ស្ត្រី ពិសេសស្ត្រី ដែលស្ថិតនៅក្នុងវ័យបន្តពូជដើម្បីស្រាវជ្រាវឲ្យទាន់ពេលវេលា។

## ខ. ជំងឺមហារីកមាត់ស្បូន

តួនាទីនិងភារកិច្ចសំខាន់ៗ របស់មណ្ឌលសុខភាព សម្រាប់ការស្រាវជ្រាវ បង្ការ អប់រំជាប្រចាំ ជំងឺមហារីកមាត់ស្បូន សំដៅរកឲ្យឃើញទាន់ពេលវេលា ដើម្បីបង្ការ និងបញ្ជូន ទៅធ្វើរោគវិនិច្ឆ័យនិងព្យាបាលចំពោះអ្នកដែលមានតេស្ត VIA វិជ្ជមាន ឬសង្ស័យថាមានជំងឺមហារីកមាត់ស្បូន ពិសេសលើស្ត្រីអាយុពី ៣០ ទៅ ៤៩ឆ្នាំ ។ អ្នកពិគ្រោះជំងឺជាឆ្មបនៅមណ្ឌលសុខ ភាពដែលបានទទួលការបណ្តុះបណ្តាលមានដូចខាងក្រោម៖

- ផ្តល់ការពិនិត្យមាត់ស្បូន ដោយប្រើសូលុយស្យុងអាស៊ីតអាសេទិច៥% ផ្តិតនៅលើមាត់ស្បូន។ បើសូលុយស្យុងនេះបង្ហាញថាមានការប្រែប្រួលខ្លះនៅលើកោសិកាដែលពាសនៅលើមាត់ស្បូន (epithelial cells) ដោយបង្កើតជាប្រតិកម្មបន្ទះពណ៌សក្រាស់ ដែលហៅថា តេស្ត VIA វិជ្ជមាន បានន័យថាស្ត្រី ប្រឈមមុខនឹងកើតជំងឺមហារីកមាត់ស្បូន ។
- បញ្ជូនទៅធ្វើរោគវិនិច្ឆ័យ និងព្យាបាល ចំពោះស្ត្រីដែលមានតេស្ត VIA វិជ្ជមានឬសង្ស័យថាមានជំងឺមហារីកមាត់ស្បូន។
- បង្កើនការយល់ដឹងដល់ស្ត្រីអំពីជំងឺមហារីកមាត់ស្បូន និងផលលំបាកដែល បណ្តាលមកពីជំងឺនេះ។
- ផ្តល់ការប្រឹក្សាឲ្យបានត្រឹមត្រូវស្តីអំពីការពិនិត្យមាត់ស្បូន (ផលលំបាក ផលចំណេញផ្នែកសុខភាព កត្តាគ្រោះថ្នាក់និង ប្រាប់ពីជម្រើសនៃការស្រាវជ្រាវ)។

## ៣.៣.៣.៣ សុខភាពផ្លូវចិត្ត

### ក. តួនាទី នឹងភារកិច្ចរបស់មណ្ឌលសុខភាព

- កំណត់រកបញ្ហាសុខភាពផ្លូវចិត្ត និងភាពញៀននឹងគ្រឿងញៀន។
- បញ្ជូនអ្នកជំងឺផ្លូវចិត្ត និងអ្នកញៀនគ្រឿងញៀន កម្រិតធ្ងន់ធ្ងរទៅមន្ទីរពេទ្យបង្អែក។
- ផ្តល់ការព្យាបាលជាបឋមបញ្ហាសុខភាពផ្លូវចិត្ត និងភាពញៀនគ្រឿងញៀនកម្រិតស្រាល ពិសេសដោយប្រើវិធីសាស្ត្រផ្តោតលើចង្កោមរោគសញ្ញា ដោយប្រើឱសថ ឬការអប់រំផ្លូវចិត្ត និងការផ្តល់ប្រឹក្សា។
- ផ្តល់ការព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀនដែលបញ្ជូនពីមន្ទីរពេទ្យបង្អែកដើម្បីធ្វើការព្យាបាលបន្ត ។
- សហការជាមួយអ្នកស្ម័គ្រចិត្តក្នុងសហគមន៍ អង្គការក្រៅរដ្ឋាភិបាល  និងព្រះសង្ឃ ដើម្បីអប់រំ និងផ្តល់ការប្រឹក្សាអំពីសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀននៅតាមផ្ទះ និងនៅតាមសហគមន៍ដល់អ្នក ជំងឺផ្លូវចិត្ត ព្រមទាំងគ្រួសារ និងធ្វើការបញ្ជូនទៅកាន់មន្ទីរពេទ្យបង្អែកក្នុងករណីចាំបាច់។
- ចូលរួមអន្តរាគមន៍ជាបន្ទាន់ដល់បុគ្គលដែលមានវិបត្តិផ្លូវចិត្ត (Crisis) ឬបុគ្គលព្យាយាមធ្វើអត្តឃាតនៅក្នុងសហគមន៍ និងបញ្ជូនទៅកាន់មន្ទីរពេទ្យបង្អែកក្នុងករណីចាំបាច់។
- ធ្វើរបាយការណ៍ស្តីពីជំងឺផ្លូវចិត្ត និងការបំពានគ្រឿងញៀន ទៅកាន់ការិយាល័យស្រុកប្រតិបត្តិ។

### ខ. ជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀនដែលត្រូវបានអនុញ្ញាតឱ្យព្យាបាលនៅមណ្ឌលសុខភាព

១. ជំងឺថប់បារម្ភ (Anxiety Disorders)

២. ជំងឺធ្លាក់ទឹកចិត្ត (Depressive Disorders)

៣. ជំងឺវិកលចរិក (Psychoses)

៤. បញ្ហាការដេក (Sleep problems)
៥. ភាពការតានតឹងចិត្ត និងការប៉ះទង្គិចផ្លូវចិត្ត ( stress and Trauma Interventions)
៦. ភាពញៀនគ្រឿងញៀនក្នុងកម្រិតស្រាល និងមធ្យម រាប់ទាំងគ្រឿងស្រវឹង និងថ្នាំជក់ (Mild and Moderate Substance Use Disorders including Alcohol and Tobacco)
៧. បញ្ហាវិបត្តិនៃការលូតលាស់ និងអាកប្បកិរិយាលើកុមារ (Child developmental and behavioral disorders)
៨. ការបង្កឱ្យមានគ្រោះថ្នាក់លើខ្លួនឯង ឬការប៉ងធ្វើអត្តឃាត (Self-Harm)
៩. ជំងឺចាស់វង្វេង (Dementia)
១០. ការស្តារលទ្ធភាពពលកម្ម ក្នុងជំងឺផ្លូវចិត្ត

មណ្ឌលសុខភាពនីមួយៗត្រូវមានគ្រូពេទ្យ ឬគិលានុបដ្ឋាក ដែលបានទទួលការបណ្តុះបណ្តាលផ្នែកសុខភាពផ្លូវចិត្ត និងគ្រឿងញៀន។

## ៣.៣.៣.៤ សុខភាពមាត់ធ្មេញ

## ក-តួនាទី និងភារកិច្ចរបស់មណ្ឌលសុខភាព

ភារកិច្ចសំខាន់ៗ រួមមាន៖

១. ពិគ្រោះនិងពិនិត្យសុខភាពមាត់ធ្មេញជូនដល់ប្រជាពលរដ្ឋដែលមានតម្រូវការ ក្នុងវង្វង់សមត្ថភាពរបស់ខ្លួន ដូចជា៖
- បិទប៉ះធ្មេញដោយបច្ចេកទេស ART ។ចំពោះមណ្ឌលសុខភាពណាដែលមានកៅអីធ្មេញដែលអាចធ្វើការរ៉ែខៃធ្មេញបាន (Dental Unit)និងមានឧបករណ៍ ទន្តគិលានុបដ្ឋាក អាច បិទប៉ះធ្មេញជាមួយ Composite ឬ Amalgam។ដកធ្មេញដែលមានបញ្ហាមិនអាចរក្សាទុកបាន
- វះបង្ហូរខ្ទុះ អាប់សែធ្មេញ
- កោសសម្អាតផ្ទាំងកំបោរតាមជើងធ្មេញ (ក ធ្មេញ) (Scaling)
- ជួយសម្រួលការភ្លាត់សន្លាក់ឆ្អឹងថ្គាម (Jaw Dislocation)
- ផ្តល់ការសង្គ្រោះបន្ទាន់បឋម ក្នុងករណីគ្រោះថ្នាក់បាក់ឆ្អឹងថ្គាម ហូរឈាម(មុនពេលចាត់ចែងបញ្ជូនជំងឺទៅមន្ទីរពេទ្យបង្អែក។
- ពិនិត្យរកមើលដំបៅមាត់និងភាពមិនប្រក្រតីក្នុងមាត់ និងចាត់បញ្ជូនជំងឺទៅមន្ទីរពេទ្យបង្អែក។

២. ចាត់បញ្ជូនករណីជំងឺដែលហួសពីវង្វង់សមត្ថភាពរបស់ខ្លួន ទៅមន្ទីរពេទ្យបង្អែក ដែលមានទន្តពេទ្យ ទន្តបណ្ឌិតជំនាញ

៣. ផ្តល់ការអប់រំលើការថែទាំសុខភាពមាត់ធ្មេញបឋម ពិសេសដល់ស្ត្រីមានផ្ទៃពោះនិងស្ត្រីមានកូនតូច ដែលមកទទួលសេវាគាំពារមាតានិងទារកនៅមណ្ឌលសុខភាព និងពេលចុះចាក់វ៉ាក់សាំង ។
៤. ចូលរួមការអប់រំបង្ការនិងលើកកម្ពស់សុខភាពមាត់ធ្មេញ ដល់កុមារតាមសាលារៀន និងតាមសហគមន៍ ។
៥. ចូលរួមការងារផ្តល់សេវាថែទាំបឋមទូទៅ នៅក្នុងសហគមន៍ ឬ មណ្ឌលសុខភាព
៦. អនុវត្តអន្តរាគមន៍ការពារ និងបង្ការរោគពុកធ្មេញសម្រាប់ក្រុមកុមារដូចជា៖ បិទប៉ះចង្អូរធ្មេញថ្គាម (pit and fissure protection-sealants); លាបភ្លុយអរ៉ាយវ៉ានីស; លាបថ្នាំ Silver Diamine Fluoride បញ្ឈប់ការវិវត្តន៍រោគពុកធ្មេញ ។ល។
៧. ផ្តល់សារអប់រំលើការថែទាំសុខភាពមាត់ធ្មេញបឋម ដល់បុគ្គលិកសុខាភិបាលដទៃទៀត ដើម្បីបង្កើនការយល់ដឹងនិងជួយផ្សព្វផ្សាយ ឲ្យបានទូលាយជូនដល់ប្រជាពលរដ្ឋ ក្នុងតំបន់គ្របដណ្តប់ធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋ យល់ដឹងនិងអនុវត្តបាននូវការថែទាំសុខភាពមាត់ធ្មេញ និងប្រើថ្នាំដុសធ្មេញ ដែលមានសារធាតុភ្លុយអរ៉ាយ (Fluoride Toothpaste) បង្ការជំងឺពុកធ្មេញ។
៨. ធ្វើរបាយការណ៍សកម្មភាពនៃសេវាកម្មក្នុងមណ្ឌល តាមរយៈស្រុកប្រតិបត្តិ ជូនដល់ប្រព័ន្ធព័ត៌មានសុខាភិបាល(HIS) ថ្នាក់ជាតិ ។

## ខ. ការថែទាំសុខភាពមាត់ធ្មេញ ដែលអនុញ្ញាតឲ្យអនុវត្តនៅថ្នាក់មណ្ឌលសុខភាព

១. វិធីសាស្ត្រនៃការអប់រំ បង្ការនិងលើកកម្ពស់សុខភាពមាត់ធ្មេញដល់ក្រុមកុមារ និងក្រុមស្ត្រី
២. អនុវត្តអន្តរាគមន៍ការពារនិងបង្ការរោគពុកធ្មេញសម្រាប់ក្រុមកុមារដូចជា៖
   - បិទប៉ះចង្អូរធ្មេញថ្គាម (pit and fissure protection-sealants)
   - លាបភ្លុយអរ៉ាយវ៉ានីស (Fluoride Varnish Application) បង្ការរោគពុកធ្មេញ
   - ប្រើ Silver Diamine Fluoride បញ្ឈប់ការវិវត្តន៍រោគពុកធ្មេញ (Arrest Caries Technique)

៣. ការព្យាបាលមាត់ធ្មេញបន្ទាន់ (Oral Urgent Treatment)
៤. ជំងឺពុកធ្មេញ (Dental Caries)
៥. ជំងឺរលាកអញ្ចាញធ្មេញ (ដំណាក់កាលទី១និងទី២) (Gingivitis)
៦. បញ្ហាដំបៅក្នុងមាត់៖ ការពិនិត្យរកមើលដំបៅនិងភាពមិនប្រក្រតីនៃជាលិកាក្នុងមាត់ (Oral Lesions: Early detection of oral cancer and precancerous lesions)

### ៣.៣.៣.៥. សុខភាពភ្នែក

**ក.តួនាទី និងការទទួលខុសត្រូវរបស់ គិលានុបដ្ឋាក ឬចក្ខុគិលានុបដ្ឋាក នៅមណ្ឌលសុខភាព៖**

ពិនិត្យ ពិគ្រោះ និងធ្វើរោគវិនិច្ឆ័យ ជំងឺភ្នែកដែលជួបប្រទះញឹកញាប់ក្នុងសហគមន៍។

ព្យាបាល ឬ ថែទាំបឋម ជំងឺភ្នែកដែលជួបប្រទះញឹកញាប់ក្នុងសហគមន៍ ។

ផ្តល់ការប្រឹក្សា អប់រំ និងផ្សព្វផ្សាយអំពីការថែទាំសុខភាពភ្នែកដល់សហគមន៍។

កំណត់បញ្ហាជំងឺភ្នែកដែលត្រូវបញ្ជូនព្យាបាលបន្តនៅមន្ទីរពេទ្យបង្អែកស្រុក បង្អែកខេត្ត ឬមន្ទីរពេទ្យថ្នាក់ជាតិ (ត្រូវចេះវាស់គំហើញភ្នែកអ្នកជំងឺដែលមានបញ្ហាសុខភាពភ្នែក)។

ថែរក្សាសម្ភារ និងបរិក្ខារភ្នែក។

កត់ត្រា និងធ្វើរបាយការណ៍អំពីជំងឺភ្នែកទៅការិយាល័យស្រុកប្រតិបត្តិ។

**ខ.ការថែទាំសុខភាពភ្នែក ដែលអនុញ្ញាតិឱ្យអនុវត្ត នៅមណ្ឌលសុខភាព:**

ភ្នែកក្រហមឆ្លង ( Viral/ Bacterial Conjunctivitis )

រលាកគល់រោមត្របកភ្នែក និងពពៃភ្នែក ( Stye/ Chalazion)

**គ.ជំងឺភ្នែកដែលបុគ្គលិកមណ្ឌលសុខភាពអាចធ្វើរោគវិនិច្ឆ័យបាន និងបញ្ជូន**

រលាកភ្នាសស្តើងភ្នែកទារកដែលទើបនឹងកើត (Ophthalmia Neonatorium)

របួសគ្រាប់ភ្នែក (Eye Injury)

របួសភ្នែកដោយសារធាតុគីមី (Chemical Burn)

រលាត់កញ្ចក់ភ្នែកដោយសារការប៉ះទង្គិច (Corneal Abrasion)

ដំបៅកញ្ចក់ភ្នែក (Corneal Ulcer)

ជំងឺទឹកដក់ក្នុងភ្នែកស្រួចស្រាវ (Acute Glaucoma)

ភ្នែកឡើងបាយ ( Cataract)

ភ្នែកកន្ទុយថ្លែន (Pterygium)

ត្រូវមានបិទប័ណ្ណផ្សព្វផ្សាយ និងខិតប័ណ្ណផ្សព្វផ្សាយ អប់រំអំពីជំងឺភ្នែកនៅមណ្ឌលសុខភាព។

### ៣.៣.៣.៦ ការស្តារលទ្ធភាពពលកម្ម

សេវាស្តារលទ្ធភាពពលកម្ម រួមបញ្ចូលទាំងការស្តារលទ្ធភាពពលកម្មតាមបែបវេជ្ជសាស្ត្រ ការស្តារលទ្ធភាពពលកម្មដោយឧបករណ៍ជំនួយ និងការស្តារលទ្ធភាពពលកម្មដោយការព្យាបាលដោយចលនា។ កិច្ចការនៃការស្តារលទ្ធភាពពលកម្មរាប់បញ្ចូលទាំងការកំណត់រកបញ្ហា ការបង្កើតផែនការព្យាបាល

ការផ្តល់បទអន្តរាគមន៍ (ជាមូលដ្ឋាន) និងការរៀបចំផែនការបញ្ជូនចេញពីកន្លែងព្យាបាលទៅសហគមន៍ និងស្ថាប័នពាក់ព័ន្ធ។

**តួនាទីសំខាន់ៗរបស់មណ្ឌលសុខភាពក្នុងការផ្តល់សេវាស្តារលទ្ធភាពពលកម្ម រួមមាន៖**

- កំណត់រកទាន់ពេលវេលា នូវបញ្ហាសុខភាពឬការប៉ះពាល់នានា ពាក់ព័ន្ធនឹងការបង្ការពិការភាព។
- បញ្ជូនអ្នកជំងឺទៅរកសេវាស្តារលទ្ធភាពពលកម្មជាក់លាក់ ដូចជាការស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ ការទទួលបានឧបករណ៍ជំនួយ ការព្យាបាលដោយចលនា និងការព្យាបាលឯកទេសផ្សេងទៀត (ការព្យាបាលដោយការនិយាយ-Speech Therapy និងការព្យាបាលដោយមុខងារប្រចាំថ្ងៃ Occupational Therapy) ដែលមាននៅតាមមន្ទីរពេទ្យបង្អែក មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា មន្ទីរពេទ្យថ្នាក់ជាតិ ឬមន្ទីរពេទ្យឯកទេសនានា។
- ធ្វើការវាយតម្លៃ ផ្តល់សេវាស្តារលទ្ធភាពពលកម្មជាមូលដ្ឋាន និងផ្តល់ការប្រឹក្សាដល់អ្នកជំងឺ និងក្រុមគ្រួសារ ដែលបញ្ជូនពីមន្ទីរពេទ្យ ឬមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មនានា ដើម្បីបង្ការផលវិបាកផ្សេងៗ។ល។
- សហការជាមួយអ្នកស្ម័គ្រចិត្តភូមិ សហគមន៍ អង្គការពាក់ព័ន្ធនឹងជនពិការ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីផ្តល់ការអប់រំ ផ្សព្វផ្សាយពីសេវាស្តារលទ្ធភាពពលកម្ម និងការបង្ការពិការភាព។
- សម្របសម្រួល និងផ្តល់បទអន្តរាគមន៍ផ្សេងៗ ក្នុងការធ្វើសមាហរណកម្មអ្នកជំងឺទៅក្នុងសហគមន៍។

**ជំងឺមួយចំនួនដែលមណ្ឌលសុខភាពអាចផ្តល់ សេវាស្តារលទ្ធភាពពលកម្ម រួមមាន ៖**

- សម្រាប់កុមារ៖ ១.ពិការចលករខួរក្បាល, ២.ជើងខ្វេរ,៣.ករៀច, ៤.ស្ពាយណាលបីហ្វីដា
- សម្រាប់មនុស្សពេញវ័យ៖ ១.ជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាល, ២.ពិការខួរឆ្អឹងខ្នង, ៣. ជំងឺស្ទះផ្លូវដង្ហើមរ៉ាំរ៉ៃ, ៤.ជើងទឹកនោមផ្អែម។

សូមអានសេចក្តីណែនាំគ្លីនិក សម្រាប់ព័ត៌មានលម្អិត។

## ៣.៣.៣.៧ ការប្រើប្រាស់រុក្ខជាតិឱសថ ក្នុងការថែទាំបឋមនៅមណ្ឌលសុខភាព

ក្រសួងសុខាភិបាល គាំទ្រការការប្រើប្រាស់រុក្ខជាតិឱសថ ក្នុងការថែទាំបឋមនៅមណ្ឌលសុខភាព ក៏ដូចជាសហគមន៍។ រុក្ខជាតិឱសថមួយចំនួនអាចប្រើជំនួសឬបំពេញបង្គ្រប់លើឱសថសម័យ។ ដូចនេះ មណ្ឌលសុខភាពមានតួនាទីសំខាន់ៗ ដូចជាផ្សព្វផ្សាយនិង បំផុសឲ្យមានការដាំដុះនិងប្រើប្រាស់រុក្ខជាតិឱសថក្នុងការថែទាំសុខភាពបឋម នៅតាមមណ្ឌលសុខភាព និងសហគមន៍។ សូមអានសេចក្តីលម្អិតឯកសាររៀបចំឡើងដោយមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ។

## ៣.៤ កញ្ចប់សេវានៅប៉ុស្តិ៍សុខភាព

### ៣.៤.១ សេវាសំខាន់ៗ

ជារួមកញ្ចប់សេវាសុខាភិបាលនៅប៉ុស្តិ៍សុខភាព មានប្រហាក់ប្រហែលទៅនឹងសេវារបស់មណ្ឌលសុខភាព លើកលែងតែការសំរាលកូន សេវាចាក់ថ្នាំបង្ការជាប្រចាំ និងតេស្តមន្ទីរពិសោធន៍ ដែលពុំមានឡើយនៅប៉ុស្តិ៍សុខភាព។

សេវាសំខាន់ៗរួមមានៈ

- ការពិនិត្យពិគ្រោះជំងឺជំងឺក្រៅ ( កុមារឬមនុស្សចាស់ )
- ការពិនិត្យផ្ទៃពោះ និងពន្យារកំណើត និង
- សេវាចុះមូលដ្ឋាន។

ដោយឡែកចំពោះប៉ុស្តិ៍សុខភាព នៅក្នុងពន្ធនាគារ ត្រូវមានកញ្ចប់សេវាពិសេស(សូមអានឧបសម្ព័ន្ធ)។

### ៣.៤.២ លក្ខណៈវិនិច្ឆ័យសម្រាប់ប៉ុស្តិ៍សុខភាព

គេអាចបង្កើតប៉ុស្តិ៍សុខភាព ដោយជំនួសការបន្ថែមចំនួនមណ្ឌលសុខភាព ដើម្បីពង្រីកការគ្របដណ្តប់ប្រជាជន ពិសេសចំពោះតំបន់ដាច់ស្រយាល ហើយមានប្រជាជនគ្របដណ្តប់តិច។ ប៉ុស្តិ៍សុខភាពត្រូវស្ថិតនៅកន្លែងឆ្ងាយឬដាច់ស្រយាល ហើយដំណើរការជាសេវាថ្នាក់ក្រោមបង្អស់នៅក្នុងប្រព័ន្ធសុខាភិបាលស្រុក។ ដូច្នេះវាគឺជាចំណុចនៃការជួបគ្នាដំបូងរបស់ប្រជាជនជាមួយនឹងសេវាសុខាភិបាលរដ្ឋ នៅកន្លែងដែលមានដង់ស៊ីតេប្រជាជនទាប។ ប៉ុស្តិ៍សុខភាពពុំមែនជាគិលានដ្ឋានឃុំទេ ប៉ុន្តែជាកន្លែងមួយសម្រាប់ផ្តល់សេវានៅកន្លែងឆ្ងាយឬដាច់ស្រយាលហើយស្ថិតនៅក្រោមមណ្ឌលសុខភាពណាមួយ។ ដូចនេះត្រូវគោរពលក្ខណៈវិនិច្ឆ័យយ៉ាងម៉ឺងម៉ាត់មុនពេលបង្កើតប៉ុស្តិ៍សុខភាព។

**លក្ខណៈវិនិច្ឆ័យសម្រាប់បង្កើតប៉ុស្តិ៍សុខភាព (ខេត្តមានដង់ស៊ីតេប្រជាជនទាប)**

១. **ទីតាំងប៉ុស្តិ៍សុខភាពៈ**
   - លក្ខណៈវិនិច្ឆ័យប្រជាជនៈ ប៉ុស្តិ៍សុខភាពត្រូវស្ថិតនៅក្នុងភូមិ ឃុំនៅឆ្ងាយឬដាច់ស្រយាល ដែលមានប្រជាជនពី ២០០០ទៅ៣០០០នាក់។ក្នុងករណីចំនួនប្រជាជនតិចជាងនេះ ជម្រើសដទៃទៀតគប្បីលើកមកពិចារណា ដូចជាៈបង្កើនសកម្មភាពចុះតាមភូមិ និងការបង្កើតអ្នកស្ម័គ្រចិត្តសុខាភិបាល ជាដើម។
   - លក្ខណៈវិនិច្ឆ័យភូមិសាស្ត្រៈ ចម្ងាយពីភូមិ ឃុំមួយទៅមណ្ឌលសុខភាពដែលជិតបំផុត ១៥គ.ម (ឬ៣ម៉ោងដោយថ្មើរជើង) ហើយមានឧបស័គ្គភូមិសាស្ត្រ(ទន្លេ, ភ្នំ, ឬផ្លូវពិបាក) ។

២. **ការគាំទ្រពីមណ្ឌលសុខភាពៈ** បណ្តាប៉ុស្តិ៍សុខភាព ត្រូវភ្ជាប់ទៅមណ្ឌលសុខភាពមួយដែលធ្វើការអភិបាល និងគ្រប់គ្រងប៉ុស្តិ៍សុខភាពទាំងនោះ។ ឧទាហរណ៍មណ្ឌលសុខភាពមួយដែលគ្រប

ដណ្តាប់ប្រជាជន១០.០០០នាក់ អាចមានប៉ុស្តិ៍សុខភាពមួយក្នុងតំបន់ ទទួលខុសត្រូវរបស់មណ្ឌលសុខភាពនោះហើយ ត្រូវបញ្ចូលធនធានសម្រាប់គាំទ្រប៉ុស្តិ៍សុខភាពផងដែរ។

៣. **បុគ្គលិក:** ប៉ុស្តិ៍សុខភាពនីមួយៗ និងត្រូវដាក់អោយមានបុគ្គលិកយ៉ាងហោចណាស់ គិលានុបដ្ឋាកមធ្យមម្នាក់ និងឆ្មបបឋមម្នាក់ ដោយបង្កើតសមត្ថភាព និងបណ្តុះបណ្តាលបុគ្គលិកមណ្ឌលសុខភាពដែលមានស្រាប់ ។

៤. **សំណុំសកម្មភាពអប្បបរិមា:** ប៉ុស្តិ៍សុខភាពត្រូវផ្តល់នូវសេវាបង្ការ ព្យាបាលជាមូលដ្ឋាន និងអប់រំបង្កើនសុខភាពដូចជា ការថែទាំមុនសម្រាលកូន និង ក្រោយសម្រាល ព្យាបាលជំងឺរាគរូស ផ្លូវដង្ហើមគ្រុនចាញ់គ្រុន ផ្តាសាយបក្សី របេងធម្មតា ឃ្លង់ និងបញ្ជូនករណីស្មុកស្មាញ ។

៥. **ឱសថសារវ័ន្ត:** ប៉ុស្តិ៍សុខភាពត្រូវទទួលកូតាឱសថពីមណ្ឌលសុខភាព យោងតាមកម្រិតសកម្មភាព ដែលបានរាយកាណ៍តាមប្រព័ន្ធព័ត៌មានសុខាភិបាល ។

៦. **ហេដ្ឋារចនាសម្ព័ន្ធ:** ត្រូវមានអគារអោយបានសមស្របទៅតាមប្លង់ស្តង់ដារ របស់ក្រសួងសុខាភិបាល ។ ប្រសិនបើគ្មានអគារទេនោះ ត្រូវកៀងគរធនធាន ដើម្បីសាងសង់អោយសមស្របទៅតាមប្លង់ស្តង់ដារ របស់ក្រសួងសុខាភិបាល។

## ៣.៥ ការខារអប់រំសុខភាព និងលើកកម្ពស់សុខភាព

### ៣.៥.១ និយមន័យ

**ការអបរំសុខភាព/លើកកម្ពស់សុខភាព** គឺជាការផ្សព្វផ្សាយឬផ្តល់ព័ត៌មានទាំងឡាយដែលធ្វើឱ្យបុគ្គល គ្រួសារ ក្រុមមនុស្ស និងសហគមន៍**ផ្លាស់ប្តូរឥរិយាបថ**ពីឥរិយាបថ ដែលមិនអំណោយផលដល់សុខភាពទៅជាឥរិយាបថផ្តល់អត្ថប្រយោជន៍ដល់សុខភាព។

ដើម្បីសម្រេចបានគោលដៅនេះ អ្នកផ្តល់សេវាអបរំសុខភាព/លើកកម្ពស់សុខភាព ត្រូវធ្វើយ៉ាងណាឱ្យបុគ្គល គ្រួសារ ក្រុមមនុស្ស និងសហគមន៍យល់ថាសុខភាពរបស់ពួកគេ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយទម្លាប់រស់នៅ ឬឥរិយាបថរបស់ពួកគាត់ទៅនឹងបរិស្ថាន ដែលគាត់កំពុងរស់នៅ ព្រមទាំងគាំទ្រពួកគាត់ដើម្បីធ្វើការផ្លាស់ប្តូរទៅរកឥរិយាបថ ប្រកបដោយសុខភាព។

### ៣.៥.២ អ្នកអប់រំសុខភាព/លើកកម្ពស់សុខភាព

បុគ្គលិកមណ្ឌលសុខភាព និងក្រុមទ្រទ្រង់សុខភាពភូមិ ជាអ្នកដែលមានតួនាទីសំខាន់ ក្នុងការអប់រំសុខភាព/លើកកម្ពស់សុខភាព នៅក្នុងមណ្ឌលសុខភាព និងសហគមន៍។

បុគ្គលិកមណ្ឌលសុខភាព មានតួនាទីអប់រំសុខភាព/លើកកម្ពស់សុខភាព ទាំងនៅពេលបំពេញភារកិច្ចក្នុងមណ្ឌលសុខភាព ក្នុងពេលចុះផ្តល់សេវាតាមមូលដ្ឋាន និងពេលធ្វើយុទ្ធនាការអប់រំសុខភាពនានានៅតាមសហគមន៍ដោយប្រើប្រាស់ជំនាញប្រាស្រ័យទាក់ទងអន្តរបុគ្គលជាមួយអតិថិជន ព្រមទាំងអនុវត្តឱ្យបានត្រឹមត្រូវនូវ ក្រមសីលធ៌មវិជ្ជាជីវវេជ្ជសាស្ត្រ សិទ្ធិ-កាតព្វកិច្ចរបស់អ្នកផ្តល់សេវា និងសិទ្ធិ

អតិថិជន។ ចំណែកក្រុមទ្រទ្រង់សុខភាពភូមិ មានតួនាទី ផ្តលការអប់រំសុខភាពតាមសហគមន៍ ស្របទៅតាមសេចក្តីណែនាំ ពីក្រសួងសុខាភិបាល និងពីបុគ្គលិកមណ្ឌលសុខភាព។

### ៣.៥.៣ លក្ខណៈសម្បត្តិអ្នកអប់រំសុខភាព/លើកកម្ពស់សុខភាព

ដើម្បីអាចផ្តល់ការអប់រំសុខភាព/លើកកម្ពស់សុខភាពប្រកបដោយប្រសិទ្ធិភាព និងឆ្លើយតបបានត្រឹមត្រូវ ចំពោះបញ្ហាសុខភាពពិតប្រាកដរបស់អតិថិជន អ្នកអប់រំសុខភាព ត្រូវមានចំណេះដឹង ជំនាញអប់រំសុខភាពនិងបទពិសោធន៍ ជាមូលដ្ឋានលើការងារអប់រំសុខភាព/លើកកម្ពស់សុខភាព។ អ្នកអប់រំសុខភាពគប្បីឆ្លងកាត់ការបណ្តុះបណ្តាល អំពីបច្ចេកទេសអប់រំសុខភាព និងជំនាញផ្តល់ប្រឹក្សា ការសម្របសម្រួលជំនាញប្រាស្រ័យទាក់ទងអន្តរបុគ្គលដើម្បីផ្លាស់ប្តូរការប្រព្រឹត្តិ ការប្រើប្រាស់សម្ភារអប់រំសុខភាពជាដើម ។ល។ លើសពីនេះទៀត អ្នកអប់រំសុខភាពគប្បីប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវភាពជាគម្រូនៃឥរិយាបថរស់នៅប្រកបដោយសុខភាព រស់រាយរាក់ទាក់ ស្វាគមន៍ និងគោរព ផ្តល់តម្លៃដល់អតិថិជនរបស់ខ្លួន។

### ៣.៥.៤ ប្រធានបទការអប់រំសុខភាព/លើកកម្ពស់សុខភាព

ប្រធានបទដែលត្រូវធ្វើការអប់រំសុខភាពជាប្រចាំដល់ អតិថិជនក្នុងសហគមន៍មាន ការថែទាំសុខភាពមាតា ទារក និងកុមារ អាហារូបត្ថម្ភ សុខភាពបន្តពូជ ការការពារ និងថែទាំជំងឺឆ្លង ជំងឺមិនឆ្លង (រួមទាំងសុខភាពភ្នែក និងសុខភាពផ្លូវចិត្ត) អនាម័យ ទឹកស្អាត។

ទន្ទឹមនឹងនេះ បុគ្គលិកមណ្ឌលសុខភាពមានតួនាទីសំខាន់ណាស់ដែរ ក្នុងការផ្តល់ការប្រឹក្សាចំពោះអ្នកជំងឺឲ្យលះបង់ទម្លាប់ប្រើប្រាស់ផលិតផលថ្នាំជក់ (អតិថិជន) ការប្រើប្រាស់គ្រឿងស្រវឹង ប្រកបដោយគ្រោះថ្នាក់ជាដើម ព្រមទាំងអប់រំអតិថិជន នឹងសហគមន៍ឲ្យយល់ដឹងពីសិទ្ធ និង កាតព្វកិច្ចអ្នកផ្តល់សេវា និងសិទ្ធិអតិថិជនផងដែរ។

## ៣.៦ ការផ្តល់សេវាចុះតាមមូលដ្ឋាន

### ៣.៦.១ និយមន័យ គោលការណ៍ និងគោលបំណង

ការចុះផ្តល់សេវាសុខភាពដល់មូលដ្ឋាន ជាវិធីសាស្រ្តផ្តល់សេវាដោយបុគ្គលិកមណ្ឌលសុខភាពនៅតាមភូមិ ឬសហគមន៍ដាច់ស្រយ៉ាលដែលប្រជាពលរដ្ឋ ជាពិសេសអ្នកដែលមិនបានទទួលសេវាមានការលំបាកក្នុងការមកទទួលសេវា ហើយការផ្តល់សេវានោះជាការបំពេញបន្ថែម ដល់ការគ្របដណ្តប់ការនៃសេវាសុខភាព ដែលត្រូវបានផ្តល់ជាប្រចាំនៅមណ្ឌលសុខភាព ដើម្បីធ្វើអោយការទទួលបានសេវាសុខភាពដោយប្រជាពលរដ្ឋប្រសើរឡើង ជាពិសេសសេវាថែទាំសុខភាពសារវ័ន្ត និងដើម្បីធានាថាពុំមានផលប៉ះពាល់ ឬរាំងស្ទះដល់ដំណើរការផ្តល់សេវាសុខភាព ជាប្រចាំនៅមណ្ឌលសុខភាពទេ។

ក្រសួងសុខាភិបាល លើកទឹកចិត្តសហគមន៍ ក្នុងការមកប្រើប្រាស់សេវាសុខភាពនៅមូលដ្ឋានពិសេសគឺមណ្ឌលសុខភាព។ ប៉ុន្តែ ដើម្បីឆ្លើយតបទៅនឹងឧបសគ្គ និងការបំពេញចន្លោះមួយចំនួនក្នុងការចូលមកប្រើប្រាស់ ត្រូវមានការបំពេញបន្ថែមដោយសេវាចុះមូលដ្ឋាន។

ការចុះផ្តល់សេវានៅតាមមូលដ្ឋានគឺមានបំណង៖

- ធ្វើអោយការផ្តល់សេវាមានប្រសិទ្ធភាព និងមានអាត្រាគ្របដណ្តប់ខ្ពស់ ដែលនឹងអាចកាត់បន្ថយអត្រាឈឺ និងអត្រាស្លាប់ជាពិសេសរបស់មាតា ទារក និងកុមារ។
- ធ្វើអោយសេវាសុខភាពសុខាភិបាលសារវ័ន្ត និងការអប់រំសុខភាពបានទៅដល់ប្រជាជនភាគច្រើន នៅក្នុងតំបន់គ្របដណ្តប់ ជាពិសេសប្រជាជន ដែលរស់នៅឆ្ងាយពីមណ្ឌលសុខភាព។
- ធ្វើអោយប្រជាជនស្គាល់និងដឹង ពីសកម្មភាពមណ្ឌលសុខភាពច្បាស់ និងជំរុញការប្រើប្រាស់សេវានៅមណ្ឌលសុខភាព និងការបញ្ជូនអ្នកជំងឺអោយទៅពិនិត្យ នៅមណ្ឌលសុខភាពដោយសហគមន៍។
- ពង្រឹងទំនាក់ទំនងរវាងមណ្ឌលសុខភាព និងសហគមន៍ដោយនាំបុគ្គលិកមណ្ឌលសុខភាពអោយទៅដល់សហគមន៍ ដើម្បីយល់ចិត្តគ្នា និងដឹងពីបញ្ហាសុខភាពប្រជាជននៅមូលដ្ឋាន។

**ការអនុវត្តន៍ការចុះផ្តល់សេវានៅតាមមូលដ្ឋានៈ**

ក) សំណុំសេវាជាសារវ័ន្តសម្រាប់ភូមិជិតៈ ភូមិដែលធ្វើដំណើរតិចជាង១ម៉ោង ដោយមធ្យោបាយដែលមានក្នុងភូមិ។

ខ) សំណុំសេវាពង្រីកបន្ថែមសម្រាប់ភូមិដាច់ស្រយាលៈ ភូមិដែលត្រូវធ្វើដំណើររយៈពេលលើសពី ១ ម៉ោង ដោយមធ្យោបាយដែលមានក្នុងភូមិ ។

## ៣.៦.២ សំណុំសេវានៃការចុះផ្តល់សេវានៅមូលដ្ឋាន

### <u>សំណុំសេវាសុខភាពមូលដ្ឋាន</u>

១. ការផ្តល់ថ្នាំបង្ការ ដូចក្នុងគោលនយោបាយ និងគោលការណ៍ណែនាំរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ។

២. ការផ្តល់បន្ថែមជីវជាតិអា សម្រាប់កុមារអាយុ ៦-៥៩ ខែ (ពីរដងក្នុង ១ឆ្នាំ គឺនៅខែឧសភា និងខែវិច្ឆិកា ជាមួយនឹងការផ្តល់ម៉េបង់ដាហ្សុល)។

៣. ការអប់រំសុខភាព និងលើកកម្ពស់សុខភាព។

៤. ការផ្តល់កញ្ចប់អូរ៉ាលីត និងថ្នាំគ្រាប់ជាតិស័ង្កសី សម្រាប់កុមារដែលមានជំងឺរាក។

៥. ការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែក និងអាស៊ីដហ្វូលិកដល់ស្ត្រីមានផ្ទៃពោះ និងការលើកទឹកចិត្តអោយស្ត្រីមានផ្ទៃពោះទៅពិនិត្យផ្ទៃពោះអោយបាន តាំងពីខែដំបូងបន្ទាប់ពីបាត់រដូវភ្លាម និងអោយបានយ៉ាងតិច ៤ដង ព្រមទាំងអោយទៅសម្រាលកូននៅមណ្ឌលសុខភាព និងត្រឡប់មកតាមដាន និងទទួលការថែទាំក្រោយសម្រាល ជាមួយទារកទើបកើតរបស់គាត់អោយបាន ៤ដងក្នុង អំឡុង ៦សប្តាហ៍ក្រោយសម្រាល។

៦. ការផ្តល់បន្ថែមគ្រាប់ ថ្នាំជាតិដែក និងអាស៊ីតហ្វូលីក និងម៉េបង់ដាហ្សុល ដល់ស្ត្រីក្រោយសម្រាលរួច ។

៧. ការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែក និងអាស៊ីតហ្វូលីក ប្រចាំសប្តាហ៍ដល់ស្ត្រីក្នុងវ័យបន្តពូជ នៃគ្រួសារក្រីក្រដែលមានប័ណ្ណសមធម៌ និងជម្រុញការលើកទឹកចិត្តឲ្យស្ត្រីក្នុងវ័យបន្តពូជ ទៅប្រើប្រាស់សេវានៅមណ្ឌលសុខភាព។

៨. ការផ្តល់សេវាពន្យាកំណើតរួមទាំងការផ្តល់ប្រឹក្សាពីវិធីសាស្ត្រពន្យារកំណើតតាមការជ្រើសរើស ការផ្តល់មធ្យោបាយពន្យាកំណើត និងការបញ្ជូនស្ត្រីទៅមូលដ្ឋានសុខាភិបាល ដោយយោងទៅតាមមធ្យោបាយពន្យាកំណើតដែលជ្រើសរើស ឬដែលកំពុងប្រើប្រាស់។

៩. ការផ្តល់ម៉េបង់ដាហ្សុលទៀងទាត់ដល់កុមារអាយុ១២-៥៩ខែ(ពីរដងក្នុង១ឆ្នាំ គឺនៅក្នុងខែឧសភា និងខែវិច្ឆិកាជាមួយនឹងការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា)

១០. ការផ្តល់បន្ថែមនូវកញ្ចប់ម្សៅវីតាមីន (ម្សៅមីក្រូសារជាតិចំរុះ) ដល់កុមារអាយុ ៦-២៣ខែ ឲ្យបានជាប់លាប់(ធ្វើយ៉ាងណាឲ្យបាន១៥ថ្ងៃក្នុងមួយខែរៀងរាល់ខែ) នៅក្នុងតំបន់ដែលមានការអនុវត្តន៍កម្មវិធីនេះ។

១១. ស្វែងរកកុមារដែលមានកង្វះអាហារូបត្ថម្ភស្រួចស្រាល់ធ្ងន់ធ្ងរ ដែលមិនបានទទួលការព្យាបាល និងបញ្ជូនដោយការពិនិត្យ រកហើយដែលអាចឃើញច្បាស់នៅជើងទាំងសងខាង និង ប្រើប្រាស់រង្វាស់ជុំវិញពាក់កណ្តាលដើមដៃ ឬទម្ងន់ធៀប និងកម្ពស់ ចំពោះកុមារអាយុ ៦-៥៩ខែ។ ពិនិត្យរកស្គមស្គាំងឃើញច្បាស់សម្រាប់កុមារអាយុក្រោម ៦ខែ។

១២.តាមដានកុមារមានកង្វះអាហារូបត្ថម្ភស្រួចស្រាល់ធ្ងន់ធ្ងរដែលលះបង់ការព្យាបាល ព្រមទាំងបញ្ជូនករណីដែលរកឃើញទៅមូលដ្ឋានសុខាភិបាល ដើម្បីទទួលការថែទាំព្យាបាលសមស្រប។

១៣.តាមដានអ្នកជំងឺរបេងនិងហង់សិនដែលលះបង់ការព្យាបាល និងបញ្ជូនករណីសង្ស័យទៅមូលដ្ឋានសុខាភិបាល ពិសេសសម្រាប់តំបន់ដែលអនុវត្តកម្មវិធីដូតស៍សហគមន៍។

១៤. ផ្តល់ការប្រឹក្សាអំពីការបំបៅកូន ដោយទឹកដោះម្តាយតែមួយមុខគត់រយៈពេល ៦ខែដំបូង និងការផ្តល់អាហារបន្ថែមដល់កុមារអាយុចាប់ពី ៦ខែឡើង និងការបន្តបំបៅដោះកូនរហូតដល់កុមារអាយុបាន ២ ឆ្នាំ ឬលើស។

១៥.តាមដានស្ថានភាពជំងឺ ឬបញ្ហាសុខភាពដែលកើតថ្មីក្នុងសហគមន៍ (Emerging Infectious Diseases) និងការស្លាប់របស់ទារកមុនអាយុ ២៨ថ្ងៃ មូលហេតុនៃការស្លាប់របស់មាតា ជំងឺដែលមានសក្តានុពលបង្ករជាការរាតត្បាត តាមការណែនាំរបស់កម្មវិធីជាតិ។

## <u>សំណុំសេវាសុខភាពពង្រីកបន្ថែម</u>

បន្ថែមលើកញ្ចប់សំណុំសេវាសុខភាពមូលដ្ឋាន សេវាសុខភាពសារវ័ន្តខាងក្រោមត្រូវបានដាក់បញ្ចូលក្នុងសំណុំសេវាសុខភាពពង្រីកបន្ថែម។

១- **ការពិនិត្យផ្ទៃពោះមុនសម្រាល៖** រួមបញ្ចូលទាំងការពិនិត្យផ្ទៃពោះមុនសម្រាល ការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែក និងអាស៊ីដហ្វូលីក ការផ្តល់មុងបង់ជាហ្សុលដល់គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់ (មិនត្រូវឲ្យមុងបង់ជាហ្សុលដល់ស្ត្រីមានផ្ទៃពោះក្នុងត្រីមាសទី១ទេ) រួមទាំងការផ្តល់ថ្នាំបង្ការជំងឺគេតាណូស និងការពិនិត្យរកសញ្ញាគ្រោះថ្នាក់ក្នុងពេលមានផ្ទៃពោះ ដើម្បីបញ្ជូនស្ត្រីមានផ្ទៃពោះដែលមានសញ្ញាគ្រោះថ្នាក់ ទៅមណ្ឌលសុខភាពឲ្យទាន់ពេលវេលា។

២- **ការថែទាំក្រោយសម្រាល៖** រួមបញ្ចូលទាំងការពិនិត្យថែទាំស្ត្រី ក្រោយសម្រាលនិងទារកទើបកើត ការផ្តល់បន្ថែមគ្រាប់ថ្នាំជាតិដែក/ អាស៊ីដហ្វូលីក មុងបង់ជាហ្សុល ការផ្តល់ថ្នាំបង្ការជំងឺតេតាណូស (បើដល់ពេលត្រូវចាក់) និងការពិនិត្យតាមដានរកសញ្ញាគ្រោះថ្នាក់ផ្សេងៗ។ ត្រូវពន្យល់និងលើកទឹកចិត្តស្ត្រីឲ្យបន្ត ការពិនិត្យតាមដានសុខភាពនៅមណ្ឌលសុខភាព ណែនាំពីការថែរក្សាទារកឲ្យបានកក់ក្តៅដោយទារកដាក់លើទ្រូង អោយស្បែកប៉ះស្បែក និងបំបៅទារកដោយទឹកដោះម្តាយតែមួយមុខគត់ រហូតអាយុបាន ៦ខែ។

៣- **ការពិនិត្យរបាយការណ៍និងការបំពេញបន្ថែមអូរ៉ាលីតនិងថ្នាំគ្រាប់ជាតិស័ង្កសី៖** រួមមានការពិនិត្យផ្ទៀងផ្ទាត់របាយការណ៍នៃក្រុមទ្រទ្រង់សុខភាពភូមិលើការអនុវត្តន៍ព្យាបាលកុមារដែលមានខ្សោះជាតិទឹក និងបំពេញបន្ថែមកញ្ចប់អូរ៉ាលីតនិងថ្នាំគ្រាប់ជាតិស័ង្កសី ដើម្បីធានាថាក្រុមទ្រទ្រង់សុខភាពភូមិមានកញ្ចប់អូរ៉ាលីតនិងថ្នាំគ្រាប់ជាតិស័ង្កសីគ្រប់គ្រាន់សម្រាប់ព្យាបាលកុមារដែលមានខ្សោះជាតិទឹក (សូមអានគោលនយោបាយជាតិស្តីពីការប្រយុទ្ធនិងជំងឺរលាកផ្លូវដង្ហើមស្រួចនិងជំងឺរាក។

៤- **ការធ្វើតេស្តរហ័សនិងព្យាបាលជំងឺគ្រុនចាញ់៖** សកម្មភាពនេះគួរធ្វើតែនៅភូមិដែលស្ថិតក្នុងតំបន់កំពុងមានការឆ្លងដោយសកម្មនៃជំងឺគ្រុនចាញ់ ដោយបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលប៉ុណ្ណោះ។ រោគវិនិច្ឆ័យត្រូវបញ្ជាក់ដោយការធ្វើតេស្តឌីបស្ទីកវិជ្ជមានប៉ុណ្ណោះ ដោយប្រើថ្នាំព្យាបាលគ្រុនចាញ់ ដែលបានវេចខ្ចប់ហើយជាស្រេច (អានពិធីសារពិនិត្យនិងព្យាបាលជំងឺគ្រុនចាញ់ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ)។

៥- តាមដានការលូតលាស់របស់កុមារអាយុក្រោម៥ឆ្នាំ ដោយប្រើទម្ងន់ធៀបនិងអាយុ។

## ៣.៦.៣. សកម្មភាពនៅក្រៅសំណុំសេវាសុខភាពចុះផ្តល់ដល់មូលដ្ឋាន

១- សេវាពិនិត្យព្យាបាលមិនមែនជាសមាសភាគចម្បង នៃសកម្មភាពចុះផ្តល់សេវាសុខភាព ដល់មូលដ្ឋានជាទៀងទាត់ទេ អាស្រ័យដោយផលប៉ះពាល់ផ្នែកសុខភាពសាធារណៈមានកម្រិត និងផលវិបាកក្នុងការផ្គត់ផ្គង់ផ្នែកភស្តុភារ។ អ្នកដែលមានជំងឺគួរត្រូវបានបញ្ជូនឲ្យទៅទទួលការព្យាបាលតាមមូលដ្ឋានសុខាភិបាល ដើម្បីទទួលបានការពិនិត្យព្យាបាលនិងតាមដានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។ តំបន់សម្រាប់ភូមិដែលដាច់ស្រយាល ដែលការទៅទទួលសេវាសុខភាពនៅមូលដ្ឋានសុខាភិបាលមានការលំបាកខ្លាំង និងដែលតម្រូវឲ្យមានការពិចារណា ដល់ការផ្តល់សេវាព្យាបាលតាមរយៈការផ្តល់សេវាដល់មូលដ្ឋាននោះការសម្រេចមួយគួរ ត្រូវបានធ្វើតាមរយៈ

ការពិគ្រោះយោបល់ រវាងគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព ការិយាល័យស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាល។

២- ការចែកមុងជ្រលក់ថ្នាំនិងជ្រលក់ថ្នាំមុងឡើងវិញនៅតំបន់ដែលមានការចម្លងសកម្មនៃជំងឺគ្រុនចាញ់ត្រូវធ្វើម្តងក្នុងមួយឆ្នាំគឺជាសកម្មភាពដែលត្រូវការផ្តត់ផ្តង់ពិសេស និងមិនអាចចាត់ទុកជាផ្នែកដែលត្រូវធ្វើជាប្រចាំរបស់សកម្មភាពចុះផ្តល់សេវាដល់មូលដ្ឋានឡើយ។

៣- សកម្មតាមដាននិងប្រយុទ្ធនឹងជំងឺដោយឡែកដទៃទៀត។

## ៣.៦.៤ ការតាមដានត្រួតពិនិត្យ និងរាយការណ៍ពីការចុះផ្តល់សេវានៅមូលដ្ឋាន

ដើម្បីអោយការងារចុះផ្តល់សេវាតាមភូមិមានប្រសិទ្ធភាព បុគ្គលិកមណ្ឌលសុខភាពត្រូវធ្វើរបាយការណ៍ពីសកម្មភាពដែលបានអនុវត្តន៍ ឱសថដែលបានយកទៅប្រើប្រាស់ និងបំពេញរាល់តារាង ឬបញ្ជីដែលកំណត់អោយដោយកម្មវិធីជាតិ និងបញ្ហាផ្សេងៗ ដែលជួបនៅពេលកំពុងអនុវត្តន៍ការងារ។ ត្រូវបញ្ចូលព័ត៌មានពីសកម្មភាពចុះផ្តល់សេវាកម្ម នៅតាមភូមិក្នុងរបាយការណ៍ ប្រព័ន្ធព័ត៌មានសុខាភិបាល និងរបាយការណ៍សំខាន់ៗ ដទៃទៀត របស់មណ្ឌលសុខភាព។

## ៣.៦.៥ ការចូលរួមរបស់សហគមន៍

ដើម្បីអោយការងារនេះអាចមានដំណើរការល្អ បុគ្គលិកមណ្ឌលសុខភាពត្រូវផ្តល់ដំណឹងពីកម្មវិធីដែលត្រូវចុះដល់មេភូមិក្រុមទ្រទ្រង់សុខភាពភូមិ ឬអ្នកស្មគ្រ័ចិត្តដទៃទៀត ដើម្បីអោយពួកគាត់អាចចាត់ចែងកិច្ចសហការណ៍ជាមួយ។

រាល់បញ្ហាដែលជួបប្រទះ នៅពេលធ្វើសកម្មភាពត្រូវតែបានលើកឡើង នៅពេលប្រជុំគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព។(សូមអានសេចក្តីលម្អិត សេចក្តីណែនាំពីសេវាចុះមូលដ្ឋាន)

## ៣.៧. សេវាសង្គ្រោះបន្ទាន់

សេវាសង្គ្រោះបន្ទាន់ផ្តល់នៅមណ្ឌលសុខភាព មានគោលបំណងជួយទ្រទ្រង់ជីវិតអ្នករងគ្រោះឱ្យមានសភាពនឹងនរមុនពេល និងក្នុងពេលបញ្ជូនអ្នករងគ្រោះ ឬអ្នកជំងឺទៅមន្ទីរពេទ្យបង្អែក។ ប្រជាជនដែលមានជំងឺត្រូវសង្គ្រោះបន្ទាន់ និងអ្នករងគ្រោះថ្នាក់ផ្សេងៗ ដែលត្រូវការជំនួយសង្គ្រោះបន្ទាន់ដែលមកដល់មណ្ឌលសុខភាព ត្រូវតែបានទទួលនូវជំនួយសង្គ្រោះបន្ទាន់ មុននឹងបញ្ជូនទៅមន្ទីរពេទ្យបង្អែក ដើម្បីទទួលយកការសង្គ្រោះបន្ត និងថែទាំការព្យាបាល ។ ដើម្បីឱ្យការផ្តល់សេវាសង្គ្រោះបន្ទាន់មានប្រសិទ្ធភាព បុគ្គលិកមណ្ឌលសុខភាពត្រូវតែទទួលការបណ្តុះបណ្តាល ដើម្បីស្គាល់ឱ្យច្បាស់ ពីសញ្ញាគ្រោះថ្នាក់បន្ទាន់ដែលត្រូវផ្តល់ការសង្គ្រោះ និងចេះធ្វើការចាត់ថ្នាក់កម្រិតធ្ងន់ធ្ងរនៃអ្នករងគ្រោះ វិធីសាស្ត្រជួយអ្នករងគ្រោះ និងរបៀបបញ្ជូនឱ្យស្ទាត់ ។ ជាទូទៅសេវានេះ ត្រូវនៅជាមួយនឹងសេវាពិគ្រោះជំងឺក្រៅ ។

គ្រប់គ្រូពេទ្យឬបុគ្គលិកមណ្ឌលសុខភាពដែលបម្រើការងារនៅមណ្ឌលសុខភាពត្រូវចេះជំនួយសង្គ្រោះបឋម និងការសង្គ្រោះបន្ទាន់មូលដ្ឋាន ដើម្បីធានាការសង្គ្រោះជីវិតបានទាន់ពេល និងធ្វើការបញ្ជូនបានត្រឹមត្រូវ។ការផ្តល់ជំនួយសង្គ្រោះបឋម និង ការសង្គ្រោះបន្ទាន់មូលដ្ឋានសំខាន់ៗរួមមានៈ

- ការសង្គ្រោះការថប់ដង្ហើម
- ការលង់ទឹក
- ការហូរឈាម ដោយរបួស
- ស្កុក
- ការប្រកាច់
- ភាពមិនដឹងខ្លួនដោយឱ្យបុគ្គលិកបណ្ឌលសុខភាព យល់ដឹងពីកម្រិតនៃភាពមិនដឹងខ្លួនរបស់ក្លាស់កូរ
- ការបាក់ឆ្អឹង
- រលាក(ភ្លើង....)
- ការពុល
- ឆ្កែខាំ ឬការខាំដោយសត្វដទៃទៀត (ឆ្មា កណ្តុរ ស្វា.....)
- ពស់ចឹក និង សត្វមានពិសខាំ ។ល។

# ៤- ចរាចរ ការបែងចែក និងបញ្ជូនអ្នកជំងឺ

## ៤.១ ចរាចរអ្នកជំងឺ

ការរៀបចំលំហូរឬចរាចរអ្នកជំងឺ គឺជាការងារយ៉ាងសំខាន់មួយ របស់មណ្ឌលសុខភាព។ ចរាចរនេះត្រូវរៀបចំឡើងអោយបានល្អ ដើម្បីជៀសវាងប្រការ ដែលអ្នកជំងឺមិនដឹងជាទៅទីណា និងការខាតបង់ពេលវេលា។ គ្រប់អតិថិជនដែលមករកសេវានៅមណ្ឌលសុខភាព ត្រូវទទួលនៅ "កន្លែងទទួលជំងឺដំបូង" តែមួយគត់ ដែលជាកន្លែងសម្រាប់បែងចែកលំហូរពួកគាត់ ទៅកាន់សេវា ឬផ្នែកផ្សេងនៃមណ្ឌលសុខភាព។ គ្រប់អតិតិជនទាំងអស់ ពេលមកដល់មណ្ឌលសុខភាព ត្រូវណែនាំអោយទៅកាន់ "កន្លែងទទួលជំងឺដំបូង" ដើម្បីទទួលការចុះឈ្មោះ និងសួរនាំពីអ្នកទទួលនិងបែងចែកជំងឺ។ ក្រោយពីចុះឈ្មោះរួចហើយ "អ្នកទទួលនិងបែងចែកជំងឺ" ត្រូវបង្ហាញនូវលំហូរអ្នកជំងឺថា ត្រូវទៅសេវាណា ដែលពាក់ព័ន្ធនឹងអតិថិជននីមួយៗ។ ផ្នែកឬសេវាទាំងនោះមានជាអាទិ ផ្នែកពិគ្រោះជំងឺទូទៅ (ចាស់និងកុមារ) ផ្នែកពិនិត្យផ្ទៃពោះ ឬចាក់ថ្នាំបង្ការ និងផ្នែកសម្រាលកូន។ល។

**លំហូរអ្នកជំងឺ -- ពេលមកដល់មណ្ឌលសុខភាព**




## ៤.២ ការតាមដាន និង បញ្ជូនជំងឺ

មណ្ឌលសុខភាពទទួលខុសត្រូវ ក្នុងការតាមដានជំងឺផ្សេងៗ ក្នុងតំបន់ដែលគ្របដណ្តប់។

### <u>ការតាមដានជំងឺ ដែលមកពិគ្រោះព្យាបាល និង ករណីសង្ស័យ</u>

អតិថិជនដែលបានមកពិគ្រោះ ពិនិត្យព្យាបាលជំងឺនៅកន្លែងពិគ្រោះជំងឺក្រៅ ជាពិសេសជំងឺ មិនឆ្លង និង ជំងឺរ៉ាំរ៉ៃ ត្រូវតែបានទទួលការពន្យល់ណែនាំ ពីពេលវេលានៃការត្រូវមកតាមដាន ជាទៀងទាត់ ពីបញ្ហាសុខភាពរបស់គាត់ ។ ចំពោះករណីដែលជាករណីសង្ស័យ ត្រូវសាកសួរល្អិតល្អន់ ពីប្រវត្តិជំងឺ និងព្យាបាលពីមុនមក ដើម្បីងាយស្រួលក្នុងការតាមដាន កំណត់រកបញ្ហាសុខភាពឱ្យបានច្បាស់លាស់ ។

### ការតាមដានអ្នកជំងឺដែលបញ្ជូន

នៅពេលដែលអតិថិជនមានបញ្ហាសុខភាព ដែលមានសភាពស្មុគស្មាញ មិនអាចទទួលការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលបាននៅមណ្ឌលសុខភាព ត្រូវបញ្ជូនពួកគាត់ឱ្យទៅមន្ទីរពេទ្យបង្អែកដើម្បីពិនិត្យព្យាបាលបន្ត ឬ ផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់។ ក្នុងករណីនេះ មណ្ឌលសុខភាព ពិសេសបុគ្គលិកដែលទទួលខុសត្រូវផ្នែកពិគ្រោះ ពិនិត្យព្យាបាលជំងឺក្រៅ ត្រូវដឹងឱ្យច្បាស់ពីសេវា ដែលមាននៅមន្ទីរពេទ្យបង្អែក។ នៅពេលដែលបានទទួលព័ត៌មានត្រឡប់ពី មន្ទីរពេទ្យបង្អែកពីអ្នកជំងឺ ដែលបានបញ្ជូនទៅ បុគ្គលិកនៅផ្នែកពិគ្រោះពិនិត្យព្យាបាលជំងឺក្រៅ ត្រូវពន្យល់ទៅអ្នកជំងឺដែលត្រឡប់មកវិញពីបញ្ហាសុខភាពរបស់គាត់ដែលត្រូវទទួលការព្យាបាលបន្តនៅផ្ទះ ឬ នៅមណ្ឌលសុខភាពជាដើម ។

### ការបញ្ជូនជំងឺ

ការបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យបង្អែក ត្រូវមានលិខិតបញ្ជូនជំងឺ សូមអានគម្រូលិខិតបញ្ជូននៅជំពូកឧបសម្ព័ន្ធ ហើយបើសិនជាអមដំណើរអ្នកជំងឺមានសភាពធ្ងន់ធ្ងរ ឬក៏ទើបតែទទួលការសង្គ្រោះបន្ទាន់ហើយត្រូវមានបុគ្គលិកម្នាក់ជូនអ្នកជំងឺនោះ។ ក្នុងករណីដែលអ្នកជំងឺជាអ្នករងគ្រោះដោយសារគ្រោះថ្នាក់ចរាចរត្រូវបញ្ជូនទម្រង់បែបបទគ្រោះថ្នាក់ចរាចរភ្ជាប់ទៅជាមួយលិខិតបញ្ជូន ។

# ៥- ការចូលរួមរបស់សហគមន៍

## ៥.១ សារៈសំខាន់នៃការចូលរួមរបស់សហគមន៍

ការចូលរួមរបស់សហគមន៍អាចផ្តល់វិភាគទានដ៏ធំធេង ក្នុងការបង្កើនការទទួលបាននូវសេវា និងសកម្មភាពអភិវឌ្ឍន៍មណ្ឌលសុខភាព ព្រមទាំងការបង្កើនគុណភាពសេវា ដែលផ្តល់ដោយបុគ្គលិកមណ្ឌលសុខភាព។ ដូចនេះ ការចូលរួមរបស់សហគមន៍ និងការប្រាស្រ័យទាក់ទង ជាមួយតួអង្គទាំងឡាយនៅក្នុងសហគមន៍ វាជាកត្តាមួយដ៏សំខាន់ ដើម្បីបង្កលទ្ធភាពអោយមណ្ឌលសុខភាពដំណើរការបានល្អប្រសើរ។ ហើយតាមរយៈការចូលរួមរបស់សហគមន៍នេះផងដែរ ដែលញ៉ាំងអោយប្រជាពលរដ្ឋយល់ថា មណ្ឌលសុខភាពគឺជាទ្រព្យសម្បត្តិរបស់គាត់ និងជាផ្នែកមួយនៃសហគមន៍គាត់។ លើសពីនេះទៀត ការចូលរួមរបស់សហគមន៍គឺ មានបំណងដើម្បីអោយមានសេវាថែទាំសុខភាពល្អក្នុងតម្លៃសមស្របមួយ ទៅដល់ពលរដ្ឋដែលរស់នៅក្នុងតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាព។ ការចូលរួមពីសំណាក់សហគមន៍ នាំអោយបុគ្គលគ្រប់រូបចេះទទួលខុសត្រូវក្នុងការសម្រេចចិត្តប្តូរអកប្បកិរិយា សម្រាប់ការប្រសើរឡើងខាងសុខភាព និងបង្កើនចំណេះដឹងខាងការថែទាំសុខភាពផ្ទាល់ខ្លួន។ ដូចនេះ មណ្ឌលសុខភាពត្រូវមានទំនាក់ទំនងល្អ ជាមួយសហគមន៍។

ក្រសួងសុខាភិបាល ប្រើគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ និងអ្នកស្ម័គ្រចិត្តសុខភាពភូមិ សម្រាប់ចលនាក្រុមប្រជាជនទាំងឡាយ នៅក្នុងសហគមន៍អោយពាក់ព័ន្ធចូលរួមនៅគ្រប់ដំណាក់កាល នៃសកម្មភាពសុខភាពបឋម និងសម្រាប់ពង្រឹងការផ្សាភ្ជាប់រវាងសហគមន៍ នឹងមណ្ឌល

សុខភាព។ អត្ថប្រយោជន៍ នៃការចូលរួមរបស់ក្រុមទាំងឡាយ នៅក្នុងសហគមន៍ទាំងនោះ គឺប្រជាពលរដ្ឋបានដឹងថា តើមណ្ឌលសុខភាពបានធ្វើអ្វីខ្លះ និងថាតើមានសេវាអ្វីខ្លះដែលមណ្ឌលសុខភាពអាចផ្តល់ជូនពួកគាត់។ ព័ត៌មានពាក់ព័ន្ធផ្សេងៗ ត្រូវបានផ្សព្វផ្សាយពីមណ្ឌលសុខភាពទៅសហគមន៍ និងពីសហគមន៍មកមណ្ឌលសុខភាព តាមរយៈតំណាងរបស់ក្រុមទាំងនោះ។ មណ្ឌលសុខភាពក៏ត្រូវបានផ្តល់ព័ត៌មានផងដែរ អំពីបញ្ហាទាំងឡាយដែលសហគមន៍កំពុងជួបប្រទះ និងអំពីតម្រូវការរបស់សហគមន៍ តាមរយៈដំណើរការនៃទំនាក់ទំនងគ្នានេះ។

ការចូលរួមរបស់សហគមន៍មិនត្រឹមតែជួយផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋប៉ុណ្ណោះទេ តែវាក៏ បង្កើតការប្រាស្រ័យទាក់ទងល្អ  ពិសេសលើលក្ខណៈចំនួនបី  ដែលអាចលើកទឹកចិត្តអោយសហគមន៍ប្រើប្រាស់សេវាដែលមានសម្រាប់ពួកគាត់។ លក្ខណៈទាំងបីនោះគឺ ***ភាពរាក់ទាក់របស់បុគ្គលិក សេវាប្រកបដោយគុណភាពនិងអាចទុកចិត្ត*** និង ***តម្លាភាពនៃតំលៃសេវា***។ ប្រសិនបើពលរដ្ឋដឹងថា មណ្ឌលសុខភាពស្វាគមន៍ពួកគាត់ មានបុគ្គលិករាក់ទាក់ ផ្តល់សេវាល្អក្នុងតម្លៃសមស្រប ហើយ ថែមទាំងដឹងជាមុនថាពួកគាត់ត្រូវបង់ថ្លៃប៉ុន្មាន ឬពុំត្រូវបង់ថ្លៃនោះ(ឧ.សេវារបេង)ពួកគាត់នឹងប្រើប្រាស់សេវារបស់មណ្ឌសុខភាព កាន់តែញឹកញាប់ឡើង។ ការចូលរួមរបស់សហគមន៍  ក៏គាំទ្រផងដែរនូវភាពត្រឹមត្រូវ ឬយុត្តិធម៌ (fairness) នៅក្នុងសង្គម។ តារាងតំលៃសេវាគប្បីកំណត់  ដោយមានការចូលរួមពីសហគមន៍ ដើម្បីធានាថាពួកគាត់មានលទ្ធភាពបង់ថ្លៃសេវា។ ប្រព័ន្ធការពារសង្គមរាប់ទាំងមូលនិធិសមធម៌ និងការលើកលែងបង់ថ្លៃសម្រាប់ពលរដ្ឋក្រីក្រ គប្បីត្រូវបានពន្យល់យ៉ាងច្បាស់ ដល់តំណាងសហគមន៍ផងដែរ។

## ៥.២ គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព

ដើម្បីដំណើរការបានរលូន ការចូលរួមរបស់សហគមន៍ ក្នុងការថែទាំសុខភាពពឹងផ្អែកលើការមានរចនាសម្ព័ន្ធជាក់លាក់ ។ ត្រូវមានទម្រង់ការមួយ និងត្រូវចែកចាយអោយភាគីពាក់ព័ន្ធទាំងអស់ ពិសេសបុគ្គលិកមណ្ឌលសុខភាពនិង តំណាងសហគមន៍ ដែលតម្រង់ទិសពួកគាត់ ក្នុងការធ្វើយ៉ាងណា អោយពួកគាត់ធ្វើការជាមួយគ្នាយ៉ាងប្រសើរបំផុត និងក្លាយជាដៃគូប្រកបដោយគុណតម្លៃ។

បទពិសោធន៍នៃការអនុវត្តន៍ស្តីពី ការចូលរួមរបស់សហគមន៍ នៅក្នុងវិស័យសុខាភិបាលកម្ពុជាបានបង្ហាញអោយឃើញថា សហគ្រប់គ្រង និងការផ្លាស់ប្តូរព័ត៌មានជាទិដ្ឋភាពដ៏សំខាន់ក្នុងការប្រាស្រ័យទាក់ទង រវាងសហគមន៍និងមណ្ឌលសុខភាព។ ទាំងសហគ្រប់គ្រងនិងការផ្លាស់ប្តូរព័ត៌មាន រួមនឹងខ្សែបន្ទាត់រាយការណ៍ផ្លូវការ និងការយល់ដឹងអំពីការផ្តល់សេវា ត្រូវបានចាត់ទុកថាជាគំនិតគន្លឹះ ក្នុងការកំណត់ទំហំការងារ  និងកំណត់រចនាសម្ព័ន្ធសម្រាប់ការចូលរួមរបស់សហគមន៍។ ដូច្នេះ រចនាសម្ព័ន្ធមួយដែលមានការរួមចំណែកពីសហគមន៍ ត្រូវតែបង្កើតឡើង ហើយនឹងឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃកិច្ចការសហគ្រប់គ្រង និងការផ្លាស់ប្តូរព័ត៌មាន។ រចនាសម្ព័ន្ធនេះគួរតែមានការចូលរួមពី"**គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព**" និង"**ក្រុមទ្រទ្រង់សុខភាពភូមិ**"។ ជាគោលការណ៍និងការអនុវត្តន៍ជាក់ស្តែង គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមទ្រទ្រង់សុខភាពភូមិមានតួនាទីបំពេញបង្គ្រប់គ្នាទៅវិញទៅមក។ ក្នុងន័យម៉្យាងទៀត ក្រុមពួកគាត់នីមួយៗគួរតែបំពេញគោលបំណងទាំងឡាយនៃទិដ្ឋភាពសំខាន់ៗ

ដែលទាក់ទងនឹងការចូលរួមរបស់សហគមន៍ ក្នុងកិច្ចដំណើរការរបស់មណ្ឌលសុខភាព។ គួរកត់សម្គាល់ថា មានតំណាងសហគមន៍ជាច្រើន នៅក្នុងរចនាសម្ព័ន្ធទាំងពីរនេះ។




## ៥.២.១ សមាជិករបស់គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព

គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព មានសមាសភាពពីតំណាងបុគ្គលិកមណ្ឌលសុខភាព ពីក្រុមទ្រទ្រង់សុខភាពភូមិ និងពីក្រុមប្រឹក្សាឃុំ ឬសង្កាត់។គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព ត្រូវមានសមាជិកសរុបយ៉ាងតិច៧នាក់ នឹងអាចបញ្ចូលសមាជិកបន្ថែមទៅតាមចំនួនឃុំ ឬសង្កាត់ដែលគ្របដណ្តប់ដោយមណ្ឌលសុខភាព(ឧ.៩នាក់ ១៣ឬ១៥នាក់)។ សមាជិកគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព ត្រូវតែជាចំនួនសេសហើយនិងមានអំណាចគ្រប់គ្រាន់ ដើម្បីធ្វើការសម្រេចចិត្ត។ សមាសភាពនៃគណកម្មការរួមមាន ដូចខាងក្រោមៈ

មណ្ឌលសុខភាពៈ ប្រធានម្នាក់និងឆ្មប២នាក់ ឬប្រធានម្នាក់ អនុប្រធានម្នាក់ និងឆ្មប៣នាក់។ ប្រធានមណ្ឌលសុខភាព ត្រូវតែជាអនុប្រធានអចិន្ត្រៃយ៍របស់គណកម្មការគ្រប់គ្រង មណ្ឌលសុខភាព។

តំណាងក្រុមប្រឹក្សាឃុំ ឬ សង្កាត់ឬ ប្រធានក្រុមប្រឹក្សាឃុំ ឬសង្កាត់១រូប ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់១រូប ដែលទទួលខុសត្រូវផ្នែកសុខភាពតាមឃុំ ឬសង្កាត់។ បើសិនជាមណ្ឌលសុខភាព គ្របដណ្តប់លើសពី១ឃុំ ឬសង្កាត់ ត្រូវមានតំណាងពីឃុំ សង្កាត់នីមួយៗ។ តំណាងមួយរូមនៃក្រុមនេះគឺជាប្រធានគណកម្មការ។

តំណាងក្រុមទ្រទ្រង់សុខភាពភូមិៈបើសិនជាមណ្ឌលសុខភាពគ្របដណ្តប់ឃុំ សង្កាត់តែ១ គួរមានតំណាងស្រី២នាក់ និងប្រុស២នាក់(សរុប៤នាក់)។ក្នុងករណីមណ្ឌលសុខភាពគ្រប

ដណ្តប់លើសពី១ឃុំ សង្កាត់ គួរមានតំណាងស្រី១នាក់ និងប្រុស១នាក់ពីឃុំ សង្កាត់នីមួយៗ (សរុប២នាក់ក្នុង១ឃុំ សង្កាត់)។តំណាងទាំងនោះត្រូវជ្រើសរើសដោយការបោះឆ្នោត។

## ៥.២.២ តួនាទីនិងមុខងាររបស់ គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព

តួនាទីសំខាន់ៗ របស់គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព គឺទទួលខុសត្រូវក្នុងការតំរង់ទិសការគ្រប់គ្រង និងផ្តល់អនុសាសន៍ឲ្យបុគ្គលិកមណ្ឌលសុខភាព ដើម្បីធានាថាសេវាមាននៅមណ្ឌលសុខភាពត្រូវតាមសំណុំសកម្មភាពអប្បរមា របស់ក្រសួងសុខាភិបាល ហើយនិងប្រជាជនក្នុងតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាព មានលទ្ធភាពប្រើសេវាទាំងនោះបាន។

### ៥.២.២.១ ប្រធានគណកម្មការគ្រប់គ្រងមណ្ឌលសុខភាពត្រូវ:

ធ្វើជាអធិបតីនៃការប្រជុំប្រចាំខែ របស់គណកម្មការនិងធ្វើសេចក្តីសម្រេច ផ្អែកលើមតិភាគច្រើនរបស់សមាជិកអង្គប្រជុំ និងត្រូវតាមគោលនយោបាយជាតិ។

ធ្វើការគាំទ្រនិងសម្របសម្រួល ការងារសុខាភិបាលនៅក្នុងតំបន់គ្របដណ្តប់ របស់មណ្ឌលសុខភាព។

ចូលរួមក្នុងការស្វែងរកថវិកាបន្ថែមពីប្រភពផ្សេងៗ ដើម្បីអភិវឌ្ឍន៍សុខភាពសហគមន៍។

ជួយជម្រុញគ្រប់សកម្មភាព របស់ក្រុមទ្រទ្រង់សុខភាពភូមិ ដើម្បីអភិវឌ្ឍន៍សុខភាពសហគមន៍។

### ៥.២.២.២ អនុប្រធានគណកម្មការគ្រប់គ្រងមណ្ឌលសុខភាពត្រូវ:

ធ្វើជាអធិបតីនៃការប្រជុំប្រចាំខែរបស់គណកម្មការ និងធ្វើសេចក្តីសម្រេចផ្អែកលើមតិភាគច្រើនរបស់សមាជិកអង្គប្រជុំ នៅពេលអវត្តមានប្រធានគណកម្មការហើយត្រូវរាយការណ៍ឲ្យប្រធានតាមដំណើររឿងនៃការប្រជុំ។

រៀបចំរាល់ឯកសារដែលទាក់ទង នឹងរបៀបវារៈប្រជុំ អញ្ជើញសមាជិកចូលរួមប្រជុំប្រចាំខែហើយនិងធ្វើកំណត់ហេតុប្រជុំ។

### ៥.២.២.៣ សមាជិកគណកម្មការគ្រប់គ្រងមណ្ឌលសុខភាពត្រូវ:

ចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានឬអនុប្រធាន

សុំដាក់បញ្ចូលប្រធានបទក្នុងរបៀបវារៈប្រជុំ។

ផ្តល់ការរាយការណ៍ និងយោបល់ពិភាក្សា

## ៥.២.៣ ភារកិច្ចរបស់គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព

### ៥.២.៣.១. ចូលរួមក្នុងការសម្រេចលើការងារគ្រប់គ្រង និងការអភិវឌ្ឍន៍សេវាមណ្ឌលសុខភាព ទិដ្ឋភាព ខាងក្រោមៈ

- ចូលរួមធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មណ្ឌលសុខភាព
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តន៍ ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មណ្ឌលសុខភាព (សកម្មភាព និងលទ្ធផល) ។
- ពិភាក្សាលើការរៀបចំអនុវត្តន៍ និងគ្រប់គ្រងហិរញ្ញប្បទាន ដូចជាការបង់ថ្លៃសេវា កំណត់តម្លៃសេវា និងពិនិត្យឡើងវិញក្នុងករណីចាំបាច់ និងការចូលរួមកំណត់អត្តសញ្ញាណអ្នកក្រីក្រ ដើម្បីទទួលការ អនុគ្រោះបង់ថ្លៃសេវា ។
- ស្វែងរកប្រភពធនធាន និងតាមដានការគ្រប់គ្រងថវិកា មណ្ឌលសុខភាព ថវិការដ្ឋ ចំណូលពីការ បង់ថ្លៃសេវា អំណោយសប្បុរសជន អង្គការផ្តល់ជំនួយ។ល។
- តាមដានការថែទាំ ជួសជុលអគារ និងមធ្យោបាយបញ្ជូនអ្នកជំងឺរបស់មណ្ឌលសុខភាពសម្រាប់ បម្រើអោយការផ្តល់សេវានៅមណ្ឌលសុខភាព។
- រៀបចំចាត់ចែងមធ្យោបាយបញ្ជូនអ្នកជំងឺពីភូមិមកមណ្ឌលសុខភាព ឬទៅមន្ទីរពេទ្យបង្អែក។
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃគុណភាព នៃការផ្តល់សេវានៅមណ្ឌលសុខភាព នៅសហគមន៍ ក្រុមទ្រទ្រង់សុខភាពភូមិ និង អ្នកស្ម័គ្រចិត្តផ្សេងៗទៀត

### ៥.២.៣.២. ផ្តល់នូវការផ្សាភ្ជាប់ រវាងមណ្ឌលសុខភាព និងសហគមន៍ សម្របសម្រួលដល់កិច្ច ខិតខំប្រឹងប្រែង អន្តរវិស័យ-ចលនាប្រជាជន និងផ្នែកដទៃទៀត ក្នុងការលើកស្ទួយ ការចូលរួមពីសហគមន៍ជុំវិញបញ្ហាសុខភាព និងបញ្ហាពាក់ព័ន្ធនឹងសុខភាពៈ

ស្វែងរកដំណោះស្រាយសមស្រប លើការផ្តល់សេវារបស់មណ្ឌលសុខភាពឆ្លើយតបទៅនឹងសំណូមពរ និងការត្អូញត្អែរពីសហគមន៍ ដើម្បីការផ្តល់សេវាទាំងនេះ មានប្រសិទ្ធភាពខ្ពស់។

ធានាថាក្រុមទ្រទ្រង់សុខភាពភូមិ និងភ្នាក់ងារសុខភាពស្ម័គ្រចិត្តភូមិបានផ្សព្វផ្សាយព័ត៌មានសុខភាព និងព័ត៌មានថ្មីៗ ពីជំងឺឆ្លងជាអាទិ៍ ជំងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាម និងមិនឆ្លងសំខាន់ៗ។ល។ ដល់សហគមន៍ ពិសេសអំពីការផ្ទុះឡើងនូវជំងឺរាតត្បាតដូចជាជំងឺផ្តាសាយបក្សី អាសន្នរោគ រាករូស។ល។

រក្សាអោយបានជាប់លាប់នូវការផ្លាស់ប្តូរព័ត៌មាន រវាងសហគមន៍ និងមណ្ឌលសុខភាព ដោយផ្តល់ ព័ត៌មានដល់សហគមន៍អំពីសេវា ដែលមាននៅមណ្ឌលសុខភាព និងទទួលមកវិញនូវ ព័ត៌មានស្តីពី បញ្ហាសុខភាព នៅក្នុងសហគមន៍។

ជួយសម្រួលដល់ការរៀបចំ និងកិច្ចដំណើរការប្រជុំរបស់ក្រុមទ្រទ្រង់សុខភាពភូមិ កំណត់ទីកន្លែង ថ្ងៃប្រជុំ និងរបៀបវារៈ នៃការប្រជុំ ។ល។

### ៥.២.៣.៣. លើកស្ទួយការចូលរួមពីសហគមន៍ ក្នុងសកម្មភាពមណ្ឌលសុខភាព ដោយចលនាប្រជាជន និងផ្នែកផ្សេងៗទៀត ក្នុងសហគមន៍ធ្វើសកម្មភាពដើម្បីបុព្វហេតុរួមៈ

ចលនាសហគមន៍អោយចូលរួមសកម្មសុខភាពដូចជាៈ កម្មវិធីផ្តល់ថ្នាំបង្ការ វិធានការបង្ការការរាតត្បាតនៃជំងឺឆ្លង(ដូចជា រាគរូស អាសន្នរោគ គ្រុនឈាម ផ្តាសាយបក្សី) អនាម័យតាមសាលារៀន ភូមិដ្ឋាន ទីផ្សារ ។ល។

ចូលរួមធ្វើយុទ្ធនាការបង្ការជំងឺឆ្លងគ្រប់ប្រភេទ ពិសេសជំងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាម ផ្តាសាយបក្សី និងជំងឺមិនឆ្លងសំខាន់ៗ ។ល។

លើកទឹកចិត្តប្រជាជនក្នុងសហគមន៍ អោយមកប្រើប្រាស់សេវាទាន់ពេលវេលា នៅមណ្ឌលសុខភាពរាល់ពេលមានបញ្ហាសុខភាព។

## ៥.៣ តួនាទីភារកិច្ចរបស់ក្រុមទ្រទ្រង់សុខភាពភូមិ

ក្រុមទ្រទ្រង់សុខភាពភូមិ ផ្តល់ព័ត៌មានពីមណ្ឌលសុខភាពទៅសហគមន៍ និងពី សហគមន៍មកមណ្ឌលសុខភាពវិញ និងជ្រើសរើសតាមរយៈការបោះឆ្នោតដោយសហគមន៍ មានសមាជិក ២នាក់ ស្រី១នាក់ ប្រុស១នាក់ ក្នុងភូមិ។

តំណាងក្រុមទ្រទ្រង់សុខភាពភូមិ ចូលរួមផ្តល់យោបល់ក្នុងការធ្វើផែនការរបស់មណ្ឌលសុខភាព។

គាំទ្របុគ្គលិកមណ្ឌលសុខភាពក្នុងការផ្តល់សេវានៅសហគមន៍ និងបំផុសគំនិតប្រជាជនឲ្យប្រើប្រាស់សេវាមណ្ឌលសុខភាព។

ចូលរួមជួយក្នុងការរៀបចំប្រព័ន្ធបញ្ជូនករណីជំងឺសង្គ្រោះបន្ទាន់ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក។

ចូលរួមផ្សព្វផ្សាយពីការបង្កើតគណកម្មការគ្រប់គ្រងមណ្ឌល និងការជ្រើសរើសគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព។

ក្រុមទ្រទ្រង់សុខភាពភូមិត្រូវផ្តល់ព័ត៌មានពីសុខភាពទៅសហគមន៍ទាន់ពេលវេលា។ក្រុមទ្រទ្រង់សុខភាពភូមិត្រូវផ្តល់ព័ត៌មានពីសុខភាព បញ្ហានៅសហគមន៍សំណូមពរ របាយការណ៍ទៅមណ្ឌលសុខភាព។

សហការណ៍ល្អជាមួយមណ្ឌលសុខភាព ចុះធ្វើការនៅសហគមន៍។

រាយការណ៍ជាបន្ទាន់ពេលមានផ្ទុះជំងឺរាតត្បាត គ្រោះមហន្តរាយ ។ល។

ផ្សព្វផ្សាយសេវានៅមណ្ឌល និងរាយការណ៍ពីចំនួនប្រជាជន ដែលបានចូលរួមស្តាប់ការអប់រំ។

រួមចំណែកក្នុងការបញ្ជូនជំងឺពីសហគមន៍ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ

បំពេញបញ្ជីសម្រង់ប្រជាជនចំណុចតាមភូមិ។

តំណាងក្រុមទ្រទ្រង់សុខភាពភូមិ ចូលរួមប្រជុំទៀងទាត់តាមការអញ្ជើញរបស់ប្រធានគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព។

ផ្តល់របាយការណ៍ព័ត៌មានសុខភាព ដែលកើតឡើងនៅក្នុងសហគមន៍ ទៅគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងផ្សព្វផ្សាយដល់សហគមន៍។

ចូលរួមការប្រជុំគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមទ្រទ្រង់សុខភាពភូមិនៅមណ្ឌលសុខភាព។

## ៥.៤ ភារកិច្ចរបស់អ្នកស្ម័គ្រចិត្តសុខភាពភូមិ

អ្នកស្ម័គ្រចិត្តសុខភាពភូមិគឺជាអ្នកសកម្មនៅក្នុងភូមិរបស់ពួកគាត់ក៏ប៉ុន្តែពួកគាត់មិនមែនជាផ្នែកមួយរបស់ក្រុមទ្រទ្រង់សុខភាពភូមិ ឬជាផ្នែកមួយរបស់គណកម្មការទ្រទ្រង់មណ្ឌលសុខភាពទេ។ អ្នកស្ម័គ្រចិត្តសុខភាពភូមិ រាយការណ៍ទៅមណ្ឌលសុខភាព និងភាគីដៃគូផ្សេងៗហើយនិងសហប្រតិបត្តិការជាមួយក្រុមទ្រទ្រង់សុខភាពភូមិ ដើម្បីលើកកម្ពស់ផ្នែកសុខភាពនិងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពសហគមន៍តាមរយៈសកម្មភាពខាងក្រោមៈ

ភ្នាក់ងារសុខភាពស្ម័គ្រចិត្តភូមិ ជាជនសកម្មក្នុងភូមិ  ដែលមិនមែនជាក្រុមទ្រទ្រង់សុខភាពភូមិ។

សហការជាមួយមណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ និងភាគីដៃគូផ្សេងៗ ដើម្បីជំរុញផ្នែកសុខភាព និងលើកកម្ពស់ស្ថានភាពសុខភាពរបស់សហគមន៍។

ធ្វើការតាមលទ្ធភាព និងពេលវេលារបស់គេ។

ផ្តល់ការអប់រំសុខភាព និងផ្តល់ការប្រឹក្សាជូនអ្នកភូមិ អំពីបញ្ហាសុខភាពដូចជាៈ ការចាក់ថ្នាំបង្ការ ការពន្យារកំណើត និងជំងឺឆ្លងតាមរយៈ

- ចលនាអ្នកភូមិឱ្យប្រើប្រាស់សេវាសុខភាព និងឱ្យចូលរួមក្នុងការងារសុខាភិបាល ដូចជាការផ្តល់ថ្នាំបង្ការ និងការពន្យារកំណើត។
- ចូលរួមក្នុងការតាមដានការលូតលាស់របស់កុមារអាយុក្រោម៥ឆ្នាំ។

ផ្តល់ការសង្គ្រោះបឋមនៅពេលមានគ្រោះមហន្តរាយ ឬក៏ពេលមានជំងឺរាតត្បាតនៅក្នុងភូមិ។

សហការជាមួយសហគមន៍ បុគ្គលិកមណ្ឌលសុខភាព ក្នុងការបញ្ជូនអ្នកជំងឺទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក។

សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា ដែលធ្វើការក្នុងសហគមន៍ និងជាពិសេសជាមួយសាមីស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពអនាម័យក្នុងភូមិ។

សហការជាមួយក្រុមទ្រទ្រង់សុខភាពភូមិ គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព គណកម្មការអភិវឌ្ឍន៍ភូមិ អាជ្ញាធរដែនដី និងអ្នកភូមិក្នុងការរៀបចំផែនការសុខាភិបាល និងផែនការអភិវឌ្ឍន៍ក្នុងភូមិ។

ចូលរួមក្នុងការត្រួតពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពលើកកម្ពស់សុខភាពក្នុងភូមិជាមួយ បុគ្គលិកមណ្ឌលសុខភាព បណ្តាស្ថាប័ន អង្គការនានា និងអាជ្ញាធរដែនដី។

## ៥.៥ ភារកិច្ចរបស់មណ្ឌលសុខភាព

បុគ្គលិកមណ្ឌលសុខភាពគឺជាសមាជិកកំពុងធ្វើការនិងជាតំណាងឲ្យមណ្ឌលសុខភាពដែលរាយការណ៍រហូតដល់ក្រសួងសុខាភិបាល។ភារកិច្ចចំបងរបស់បុគ្គលិកមណ្ឌលសុខភាពគឺការផ្តល់សេវាថែទាំសុខភាពដល់សហគមន៍ ពួកគាត់បម្រើដោយធ្វើសកម្មភាពដូចតទៅៈ

រាយការណ៍យ៉ាងទៀងទាត់ទៅគណកម្មការគ្រប់គ្រងមណ្ឌលសុខភាពពីការគ្រប់គ្រងសកម្មភាពរបស់មណ្ឌលសុខភាព។

ស្នើសុំការគាំទ្រពីស្រុកប្រតិបត្តិចំពោះរាល់បញ្ហាផ្សេងៗ ដែលទាក់ទងនឹងសកម្មភាពនៃការផ្តល់សេវានៅមណ្ឌលសុខភាព។

រៀបចំការប្រជុំពិនិត្យឡើងវិញប្រចាំឆ្នាំ(លទ្ធផល)

ផ្តល់ព័ត៌មានទៅដល់អ្នកពាក់ព័ន្ធតាមរយៈការប្រជុំប្រចាំខែរបស់មណ្ឌលសុខភាពនិងឃុំ សង្កាត់ក្នុងការរៀបចំផែនការខាងមុខ។

ផ្សព្វផ្សាយព័ត៌មានពីការប្រជុំជាបន្តបន្ទាប់ ទៅស្រុកប្រតិបត្តិនិងសហគមន៍មុនមួយសប្តាហ៍(៥ថ្ងៃធ្វើការ)៖ គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ និងក្រុម ប្រឹក្សាឃុំ សង្កាត់នៅស្រុកប្រតិបត្តិ។

រាយការណ៍ពីការប្រជុំគណកម្មការប្រចាំខែពីសកម្មភាព លទ្ធផល ការលំបាក បញ្ហាដែល ជួបប្រទះ ការប្រើប្រាស់សេវាបង់ថ្លៃ ថវិកាពីម្ចាស់ជំនួយ រៀបចំផែនការសកម្មភាពបន្ទាប់ ហើយនិងត្រូវការឲ្យមានការគាំទ្រពីគណកម្មការ។

លើកទឹកចិត្តសមាជិកគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព ឲ្យចូលរួមក្នុងសកម្មភាពរបស់មណ្ឌលសុខភាព។

អភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធគ្រប់ៗគ្នា។

រៀបចំការប្រជុំគណកម្មការគ្រប់គ្រងមណ្ឌលសុខភាពពៈ ទីកន្លែង របៀបវារៈ លិខិតអញ្ជើញឯកសារពាក់ព័ន្ធ(របាយការសកម្មភាពប្រចាំខែ របាយការណ៍ហិរញ្ញវត្ថុហើយនិងព័ត៌មានសុខភាពថ្មីៗ) និងកំណត់ហេតុប្រជុំ។

ជាបន្ថែមទៀតជួយរៀបចំការប្រជុំដូចតទៅៈ

- រៀបចំការប្រជុំក្រុមទ្រទ្រង់សុខភាពភូមិយ៉ាងទៀងទាត់ បន្តពិនិត្យរបាយការណ៍អប់រំសុខភាពនិងទទួលយកសំណើពីសហគមន៍
- រៀបចំការប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្សព្វផ្សាយព័ត៌មានពីការប្រជុំប្រចាំខែរបស់គណកម្មការគ្រប់គ្រងមណ្ឌលសុខភាពនៅស្រុកប្រតិបត្តិ។

បន្តពិនិត្យលើសកម្មភាព លទ្ធផលប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ។

បន្តពិនិត្យលើរបាយការណ៍និងចេញអន្តរាគមន៍ភ្លាមៗនៅពេលមានការផ្ទុះជំងឺឆ្លង គ្រោះមហន្តរាយ។ល។

ពង្រឹងការផ្តល់សេវាប្រកបដោយគុណភាពនៅមណ្ឌលសុខភាពឆ្លើយតបនឹងសេចក្តីត្រូវការរបស់សហគមន៍។

គ្រប់គ្រងប្រាក់ហិរញ្ញប្បទាន និងថវិកាពីប្រភពផ្សេងទៀត ឲ្យមានតម្លាភាពនិងធ្វើរបាយការណ៍ទៅគណកម្មការទ្រទ្រង់មណ្ឌលសុខភាព។

វាយតម្លៃការថែទាំជួសជុលអគារ មធ្យោបាយបញ្ជូនអ្នកជំងឺនិងប្រព័ន្ធទំនាក់ទំនងសម្រាប់ការផ្តល់សេវារបស់មណ្ឌលសុខភាព។

រៀបចំឲ្យមានអនាម័យល្អនៅមណ្ឌលសុខភាព ដើម្បីទាក់ទាញសហគមន៍ឲ្យប្រើប្រាស់សេវាមណ្ឌលសុខភាព។

# ៦-ហេដ្ឋារចនាសម្ព័ន្ធអគារ

ដើម្បីអោយការផ្តល់សេវាសុខាភិបាល មានលក្ខណៈស្របតាមតំរូវការថ្មី មណ្ឌលសុខភាពត្រូវមានហេដ្ឋារចនាសម្ព័នរូបវ័ន្តគ្រប់គ្រាន់ និងស្របតាមលក្ខណៈស្តង់ដារ។ មណ្ឌលសុខភាពត្រូវមានបន្ទប់យ៉ាងតិចចំនួន ៨ ដោយមិនរាប់បញ្ចូលបង្គន់ និងបន្ទប់ទឹកឡើយ។ បន្ទប់ទាំងនោះរួមមានៈ

- បន្ទប់ពិនិត្យពិគ្រោះជំងឺទូទៅ
- បន្ទប់ពិនិត្យផ្ទៃពោះ និងថែទាំមុនសំរាល
- បន្ទប់សំរាលកូន
- បន្ទប់ថែទាំក្រោយសំរាល
- បន្ទប់ចាក់ថ្នាំបង្ការ
- បន្ទប់រុំរបួស វះកាត់តូចតាច និងថែទាំព្យាបាលធ្មេញ
- បន្ទប់ផ្តល់ការប្រឹក្សារួម(សុខភាពផ្លូវចិត្ត, អ្នកផ្ទុកមេរោគអេដស៍....) និង
- បន្ទប់ឱសថស្ថាន។

គ្រប់បន្ទប់ទាំងអស់ ជាពិសេសបន្ទប់សម្រាលកូនរបស់មណ្ឌលសុខភាព គួរតែមានភ្ជាប់ប្រព័ន្ធសៀគ្វី អគ្គិសនីដែលមានលក្ខណៈសមស្រប និងផ្តល់ដោយប្រភពអគ្គិសនីដូចជា បណ្តាញអគ្គិសនីរដ្ឋ ឬឯកជនដែលមានការផ្គត់ផ្គង់ជាប់លាប់ ប្រព័ន្ធប្រើពន្លឺព្រះអាទិត្យ ឬក៏មានម៉ាស៊ីនភ្លើង។ ដោយឡែកចំពោះបន្ទប់យាម បុគ្គលិកអាចប្រើប្រាស់បន្ទប់ណាមួយ ក្នុងចំណោមបន្ទប់៨ខាងលើ ឧ.បន្ទប់ផ្តល់ការប្រឹក្សារួម ឬបន្ទប់ដោយឡែកតាមលទ្ធភាពជាក់ស្តែងរបស់មណ្ឌលសុខភាព។

ដើម្បីជួយសម្រួលដល់ការប្រើប្រាស់/ចេញចូល ជាពិសេសសម្រាប់ជនពិការ ស្ត្រីមានផ្ទៃពោះ កុមារ និងមនុស្សចាស់ នៅច្រកចេញចូលអាគារ និងផ្នែកឡើងទៅអាគារខាងលើ គួរមានជម្រាលសមស្របហើយផ្លូវដើរនៃផ្នែកខាងក្នុងអាគារ ត្រូវមានទំហំទូលាយ ផងដែរ។

មណ្ឌលសុខភាពត្រូវមានប្រព័ន្ធផ្គត់ផ្គង់ទឹកសមស្រប ដែលរាប់បញ្ចូលប្រព័ន្ធទឹកទុយោ(បំពង់) ឬអណ្តូងទឹក និងប្រព័ន្ធត្រងទឹកភ្លៀងបន្ថែម មាន បន្ទប់ទឹក បង្គន់អនាម័យ និងកន្លែងលាងដៃសមស្រប ព្រមទាំងប្រព័ន្ធបង្ហូរទឹកកាកសំណល់ ស្របតាមគោលការណ៍ស្តីពី ការការពារការចម្លងរោគរាប់ទាំងអនាម័យ និងការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ។

មណ្ឌលសុខភាព គួរតែមានប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍ ដូចជា វិទ្យុទាក់ទង និង បណ្តាញទូរស័ព្ទ ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយនឹងមន្ទីរពេទ្យ ឬសហគមន៍ និងការិយាល័យស្រុកប្រតិបត្តិ ហើយប្រព័ន្ធនេះគួរតែរួមបញ្ចូលទៅក្នុងការគូសវាសប្លង់អគារ និងមូលដ្ឋានព័ត៌មានលេខទំនាក់ទំនងរបស់ការិយាល័យស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាលខេត្ត។

បរិវេណជុំវិញមណ្ឌលសុខភាព ត្រូវរៀបចំអោយមានលក្ខណៈសមរម្យ រាប់បញ្ចូលទាំងការធ្វើរបង និងក្លោងទ្វារ រៀបចំសួនច្បារ និងអនាម័យ។

លើសនេះថែមទៀត មណ្ឌលសុខភាពគួរតែមានមធ្យោបាយធ្វើដំណើរសមស្រប ដូចជា ទោចក្រយានយន្ត ទូក ទោចក្រយាន ។ល។ សម្រាប់ធ្វើដំណើរចុះផ្តល់សេវាតាមមូលដ្ឋានដល់សហគមន៍ អាស្រ័យទៅតាមស្ថានការណ៍ជាក់ស្តែង របស់មណ្ឌលសុខភាព។

មណ្ឌលសុខភាពត្រូវយកចិត្តទុកដាក់ និងមានវិធានការក្នុងការគ្រប់គ្រង ថែទាំ អគារ សម្ភារបរិក្ខារពេទ្យ មធ្យោបាយធ្វើដំណើរ និងគ្រឿងសង្ហារឹមឲ្យបានគង់វង្សល្អផងដែរ។

ចំពោះគំរោងប្លង់លម្អិតរបស់អគារ ឬបន្ទប់នីមួយៗ សូមអានសេចក្តីលម្អិតនៃគំរោងប្លង់អគារមណ្ឌលសុខភាព ស្តង់ដារ (សៀវភៅណែនាំស្តីពីការបរិយាយសង្ខេប អំពីអគារមណ្ឌលសុខភាព Building Brief of HC) ចុងក្រោយរបស់ក្រសួងសុខាភិបាល។

មកដល់ចុងឆ្នាំ២០១៧ មណ្ឌលសុខភាពសំណុំសកម្មភាពអប្បបរមា (MPA) មានចំនួនសរុប ១ ១៩០ ត្រូវបានបង្កើតឡើងក្រោមការអនុញ្ញាត របស់ក្រសួងសុខាភិបាល។ ក្នុងចំណោមមណ្ឌលសុខភាពទាំងនេះ អគារមួយចំនួននៅពុំទាន់មានលក្ខណៈត្រឹមត្រូវ តាមស្តង់ដារនោះឡើយ ដោយហេតុថាការសាងសង់ត្រូវបានធ្វើឡើង ដោយប្រភពផ្សេងៗ រាប់ទាំងអង្គការមិនមែនរដ្ឋាភិបាលនានា និងអង្គភាពស្ថាប័នផ្សេងៗ ក្នុងអំឡុងពេលមុនធ្វើកំណែទំរង់ប្រព័ន្ធសុខាភិបាល។ អគារមណ្ឌលសុខភាព ដែលមិនត្រូវស្តង់ដារមួយចំនួន គួរត្រូវកែលម្អទៅតាមតំរូវការ ចំនួនបន្ទប់តាមស្តង់ដារថ្មីតាមរយៈការជួសជុល ឬពង្រីកថ្មីផ្ទុយទៅវិញ ក៏មានអគារមួយចំនួនទៀតចាំបាច់ត្រូវតែវាយចោល ឬទុកប្រើប្រាស់សម្រាប់កិច្ចការអ្វីផ្សេងផងដែរ។ បានន័យថា មណ្ឌលសុខភាពនីមួយៗ ត្រូវតែទទួលការវាយតម្លៃពីស្ថានភាព អគារនីមួយៗឲ្យបានច្បាស់ ហើយបន្ទាប់មកដាក់ផែនការ ឲ្យជាក់លាក់ទៅតាមស្ថានភាពជាក់ស្តែង ។

ការចុះអង្កេតមើលថាតើអគារ ដែលមានស្រាប់អាចប្រើប្រាស់ឡើងវិញបានឬទេនោះ គឺជាកិច្ចការចាំបាច់ ហើយត្រូវចុះធ្វើឲ្យបាន។ ដោយសារសេវាសម្រាប់អ្នកជំងឺត្រូវតែផ្តល់ជូន ក្នុងខណៈដែលមណ្ឌលសុខភាពកំពុងសាងសង់ ឬកំពុងពង្រីកបន្ថែម ឬកំពុងជួសជុលស្តារឡើងវិញនោះ វាជាការចាំបាច់ ត្រូវរៀបផែនការដោយប្រយ័ត្នប្រយែង ធ្វើយ៉ាងណាឲ្យការងារសាងសង់ប្រព្រឹត្តទៅផង ហើយការផ្តល់សេវាសុខភាពបន្តទៅមិនដាច់ផង។

# ៧-សេវាត្រួតពិនិត្យអ្នកជំងឺ និងកម្មវិធី

## ៧.១ ការកត់ត្រាព័ត៌មាននិងតាមដានការផ្តល់សេវា:

### ៧.១.១ ប្រមូលព័ត៌មានអំពីប្រជារាស្ត្រក្នុងតំបន់ទទួលខុសត្រូវ

ដើម្បីឲ្យមណ្ឌលសុខភាពផ្តល់ការគ្របដណ្តប់ប្រកបដោយប្រសិទ្ធភាព និងសមធម៌ បុគ្គលិកមណ្ឌលសុខភាព ត្រូវស្រង់ព័ត៌មានអំពីតំបន់ទទួលខុសត្រូវរបស់ខ្លួន។ ព័ត៌មានទាំងនោះរួមមាន:

ភូមិសាស្ត្រលម្អិតនៃតំបន់ទទួលខុសត្រូវ ដើម្បីធ្វើផែនការផ្តល់សេវានិងសកម្មភាពចុះមូលដ្ឋានរបស់មណ្ឌលសុខភាព។

ប្រជាពលរដ្ឋ: ចំនួនប្រជាពលរដ្ឋបែងចែកតាមភេទ អាយុ និងចំនួនមនុស្សក្នុងគ្រួសារ។

ក្រុមប្រជាពលរដ្ឋប្រឈមមុខនឹងគ្រោះថ្នាក់:បុគ្គលិកមណ្ឌលសុខភាពត្រូវស្គាល់ក្រុមប្រជាពលរដ្ឋប្រឈមមុខនឹងគ្រោះថ្នាក់ និងក្រុមមនុស្សដទៃទៀតដែលមានតម្រូវការពិសេស។

ការស្រង់ព័ត៌មាននេះជាឱកាសមួយ ដើម្បីផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ អំពីសកម្មភាពមណ្ឌលសុខភាព។ បន្ទាប់មកបុគ្គលិកមណ្ឌលសុខភាព ត្រូវគូរផែនទីដែលបង្ហាញអំពី ផ្លូវ ស្ទឹងឬអូរ ភូមិនានា ចំណុចសំគាល់សំខាន់ៗ និងកន្លែងដែលសហគមន៍ប្រឈមមុខនឹងគ្រោះថ្នាក់រស់នៅ។

### ៧.១.២ ប្រព័ន្ធព័ត៌មានសុខាភិបាល

ក្រសួងសុខាភិបាលប្រមូលព័ត៌មានសុខាភិបាល និងរបាយការណ៍ពីថ្នាក់មូលដ្ឋានសុខាភិបាលដល់ថ្នាក់ជាតិ។ រូបភាពទី១ បង្ហាញអំពីកន្លែងដែលបុគ្គលិកសុខាភិបាលកត់ត្រា ប្រមូលព័ត៌មានស្តីពីអ្នកជំងឺ និងបែបបទដែលព័ត៌មានត្រូវឆ្លងកាត់ប្រព័ន្ធ ហើយយកទៅវិភាគនិងប្រើប្រាស់សម្រាប់ការធ្វើផែនការ និងកំណត់អាទិភាព។




## ៧.១.២.១ ប្រភេទរបាយការណ៍និងគោលបំណង

ប្រព័ន្ធព័ត៌មានសុខាភិបាលមានគោលបំណងផ្តល់ព័ត៌មានជាទៀងទាត់ជូនមន្ត្រីគ្រប់គ្រងសុខាភិបាល អំពីស្ថានភាពសុខភាពនៃប្រជាពលរដ្ឋដែលនៅក្នុងតំបន់គ្របដណ្តប់ សកម្មភាពផ្តល់សេវារបស់បុគ្គលិកសុខាភិបាល និងធនធានដែលមាន។ ព័ត៌មានទាំងនេះសម្រាប់ប្រើប្រាស់ក្នុងការកសាងផែនការ និងការគ្រប់គ្រងសេវាសុខាភិបាល។ មានរបាយការណ៍បួនប្រភេទនៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល៖

- របាយការណ៍ព័ត៌មានប្រចាំខែ (របាយការណ៍មណ្ឌលសុខភាព HC1): បុគ្គលិកមណ្ឌលសុខភាពត្រូវប្រើប្រាស់ **បញ្ជីស្តង់ដារ** ដើម្បីកត់ត្រានិងប្រមូលទិន្នន័យព័ត៌មានប្រចាំថ្ងៃ។ ដូចនេះព័ត៌មានដែលប្រមូលបានពីបញ្ជីស្តង់ដារនេះ
នឹងបង្កលក្ខណៈងាយស្រួលក្នុងការធ្វើរបាយការណ៍ប្រចាំខែ។
- ប្រព័ន្ធប្រកាសភាពអាសន្ន (របាយការណ៍សូន្យ): ជារបាយការណ៍ព័ត៌មានប្រចាំសប្តាហ៍ ស្រង់ព័ត៌មានអំពីចំនួនករណី កន្លែង និងភាពធ្ងន់ធ្ងរនៃជំងឺ ដើម្បីចាត់វិធានការណ៍ឆ្លើយតបជាបន្ទាន់។
- របាយការណ៍បញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំ:
របាយការណ៍នេះស្រង់ទិន្នន័យព័ត៌មានអំពីធនធានមនុស្ស សម្ភារបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ។
- របាយការណ៍ស្ថិតិសុខាភិបាលប្រចាំឆ្នាំ ។

ក្រៅពីរបាយការណ៍ខាងលើ នៅមាន **តារាងតាមដានសុខាភិបាល** (Tableau de bord) ដែលជាមធ្យោបាយសម្រាប់កត់ត្រាសកម្មភាព និងពិនិត្យតាមដាននូវព័ត៌មានសេវាប្រចាំខែ។ មណ្ឌលសុខភាព

នីមួយៗ ត្រូវរៀបចំឲ្យមានតារាងតាមដានសុខាភិបាលបិទលើជញ្ជាំងមណ្ឌលសុខភាព និងត្រូវធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែជាទៀងទាត់។

## ៧.១.២.២ បញ្ជីកត់ត្រាប្រចាំថ្ងៃសម្រាប់មណ្ឌលសុខភាព

បញ្ជីកត់ត្រាត្រូវប្រើនៅកន្លែងផ្តល់សេវានីមួយៗសម្រាប់កត់ត្រាអ្នកជំងឺដែលចូលមកពិនិត្យ ព្យាបាល និងថែទាំសុខភាព ។ កន្លែងផ្តល់សេវាមួយត្រូវមានបញ្ជីកត់ត្រាមួយ (ឧទាហរណ៍: បញ្ជីកត់ត្រាផ្នែកពិគ្រោះជំងឺក្រៅបញ្ជីកត់ត្រាផ្នែក ពិនិត្យផ្ទៃពោះមុនសម្រាល............)

ប្រើបន្ទាត់ថ្មីរាល់ការមកពិនិត្យម្តងៗ មិនត្រូវទុកបន្ទាត់ឲ្យនៅទំនេរ លើកលែងតែការចាប់ផ្តើមទំព័រថ្មីនៃខែ ។

បិទបញ្ជីនៅថ្ងៃចុងក្រោយនៃខែនីមួយៗ។

សម្រាប់ខែថ្មី កាលបរិច្ឆេទត្រូវសរសេរនៅចំកណ្តាលទំព័រថ្មីនៃសៀវភៅកត់ត្រា។

បំពេញសៀវភៅនេះ ព្រមទាំងធ្វើការសរុបប្រចាំខែនូវរាល់ទិន្នន័យនីមួយៗដោយប្រើប្រាស់ទម្រង់របាយការណ៍សកម្មភាពប្រចាំខែ HC1។

ភាគច្រើននៃបញ្ជីកត់ត្រាផ្តល់សេវាទាំងនោះ មានកូឡោនមួយសម្រាប់ ការបញ្ជូនអ្នកជំងឺទៅកាន់មូលដ្ឋានសុខាភិបាលកម្រិតខ្ពស់ ឬណែនាំឲ្យអ្នកផ្តល់សេវាបញ្ចូលព័ត៌មានបញ្ជូនទៅក្នុងកូឡោនមតិយោបល់។ លើសពីនេះទៀត មណ្ឌលសុខភាព ចាំបាច់ត្រូវមានបញ្ជីកត់ត្រាមួយទៀត សម្រាប់ការបញ្ជូនដោយពួកគេត្រូវបំពេញព័ត៌មាន និងរក្សាកំណត់ត្រារបស់អ្នកជំងឺទាំងអស់ ដែលត្រូវការបញ្ជូនទៅកាន់មូលដ្ឋានសុខាភិបាលកម្រិតខ្ពស់ នៅក្នុងបញ្ជីកត់ត្រានេះ។

## ៧.១.២.៣ បញ្ជីសម្រង់តួលេខប្រចាំថ្ងៃសម្រាប់មណ្ឌលសុខភាពៈ

បញ្ជីសម្រង់តួលេខប្រចាំថ្ងៃប្រើនៅកន្លែងផ្តល់សេវានីមួយៗ

កត់ត្រាតួលេខអ្នកជំងឺដោយស្រង់ចេញពីសៀវភៅកត់ត្រាប្រចាំថ្ងៃ

បញ្ជីសម្រង់តួលេខប្រចាំថ្ងៃប្រើប្រាស់សម្រាប់បូកសរុបរបាយការណ៍ប្រចាំខែ

## ៧.១.២.៤ កំណត់ត្រាអ្នកជំងឺ៖

កំណត់ត្រាអ្នកជំងឺចាំបាច់ត្រូវបំពេញ សម្រាប់រាល់អ្នកជំងឺដែលទទួលសេវានៅមណ្ឌលសុខភាព។ សេវាមណ្ឌលសុខភាពមួយចំនួន មានកំណត់ត្រាអ្នកជំងឺផ្ទាល់ខ្លួន របស់ពួកគេ ដូចជា៖ទម្រង់ ស.ព.ជ.ក (IMCI) ទម្រង់សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់(VCCT) សៀវភៅកម្មវិធីជាតិ ប៉ាតូក្រាហ្វ ប័ណ្ណលឿង សៀវភៅសុខភាពមាតានិងកុមារ ប័ណ្ណអតិថិជនសេវាផែនការគ្រួសារ។ល។ ទម្រង់ព្យាបាលពីរថ្មីទៀត(សូមមើលឧបសម្ព័ន្ធ) កំពុងត្រូវបានធ្វើតេស្ត និងរំពឹងថា នឹងត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្នែកមួយ នៃប្រព័ន្ធ អេឡិចត្រូនិកកត់ត្រានិងគ្រប់គ្រង ទិន្នន័យអ្នកជំងឺ (PMRS) សម្រាប់មណ្ឌលសុខភាព។

១) សម្រាប់ផ្នែកពិគ្រោះជំងឺក្រៅ និងសេវាពាក់ព័ន្ធ

២) សម្រាប់សេវាសុខភាពបន្តពូជ សុខភាពមាតា ទារកទើបកើត កុមារនិងអាហារូបត្ថម្ភ (RMNCHN)

លិខិតបញ្ជូនស្តង់ដារក៏ត្រូវបំពេញ និងផ្ញើទៅជាមួយអ្នកជំងឺ ដែលបញ្ជូនទៅកាន់មូលដ្ឋានសុខាភិបាលកម្រិតខ្ពស់ផងដែរ។ លិខិតបញ្ជូនស្តង់ដារនេះ ត្រូវបានបញ្ចូលនៅក្នុងឧបសម្ព័ន្ធ។

ប្រព័ន្ធអេឡិចត្រូនិកកត់ត្រា និងគ្រប់គ្រងទិន្នន័យអ្នកជំងឺ(PMRS) គឺជាឧបករណ៍ដំណើរការដោយកុំព្យូទ័រ ដែលត្រូវបានមណ្ឌលសុខភាពប្រើប្រាស់ ដើម្បីកត់ត្រាព័ត៌មានលម្អិត នៃការផ្តល់សេវាជូនអ្នកជំងឺ។ កំណត់ត្រាអ្នកជំងឺ សម្រាប់សេវាជាក់លាក់ត្រូវបានប្រើប្រាស់ជាឧបករណ៍ប្រមូលព័ត៌មានជាក់លាក់ អំពីអ្នកជំងឺម្នាក់ៗ រួចត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ PMRS។ ខណៈដែលប្រព័ន្ធ PMRS នៅបន្តកែសម្រួលបន្តទៀត ក្រសួងសុខាភិបាល អាចនឹងចេញសេចក្តីណែនាំដែលផ្តល់ការណែនាំដល់មណ្ឌលសុខភាព អំពីព័ត៌មានណាខ្លះដែលគួរកត់ត្រាទៅក្នុងប្រព័ន្ធPMRS។

## ៧.២-ការអនុវត្តន៍សមាហរណកម្ម សម្រាប់ការតាមដានអ្នកជំងឺ

ក្រសួងសុខាភិបាល និងកម្មវិធីជាតិផ្តល់នូវឧបករណ៍ ជាទម្រង់លិខិតនិងឧបករណ៍ដំណើរការតាមប្រព័ន្ធកុំព្យូទ័រមួយសំណុំ ដើម្បីសម្រួលដល់ការផ្តល់សេវា ដល់អ្នកជំងឺនៅតាមមណ្ឌលសុខភាព និងនៅក្នុងក្របខ័ណ្ឌសុខាភិបាលទាំងមូល។

បុគ្គលិកមណ្ឌលសុខភាព ត្រូវប្រើប្រាស់ឧបករណ៍ជាទម្រង់លិខិត និងឧបករណ៍ដំណើរការ តាមប្រព័ន្ធកុំព្យូទ័រទាំងនោះ តាមលក្ខណៈសមាហរណកម្ម ដើម្បីកត់ត្រា តាមដាន និង រាយការណ៍អំពីការថែទាំអ្នកជំងឺ។

ឧបករណ៍ជាទម្រង់លិខិតរួម មានបញ្ជីផ្សេងៗរបស់មណ្ឌលសុខភាព ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយនៅក្នុងឆ្នាំ ២០១៣ និងឆ្នាំ ២០១៤។

ក្រសួងសុខាភិបាល ក៏បានបង្កើតឧបករណ៍ដំណើរការ តាមប្រព័ន្ធកុំព្យូទ័រចំនួនពីរផងដែរ គឺប្រព័ន្ធអេឡិចត្រូនិកកត់ត្រា និងគ្រប់គ្រងទិន្នន័យអ្នកជំងឺ(PMRS)សម្រាប់ទិន្នន័យកម្រិតអ្នកជំងឺ និងប្រព័ន្ធព័ត៌មានសុខាភិបាល(HIS) សម្រាប់រាយការណ៍អំពីស្ថិតិប្រើប្រាស់សេវាប្រចាំខែជាសរុប។

ចំណុចសំខាន់មួយនៃការអនុវត្តសមាហរណកម្ម សម្រាប់ការតាមដានអ្នកជំងឺ គឺការប្រើប្រាស់លំហូរអ្នកជំងឺស្តង់ដារ ដូចដែលបានបង្ហាញនៅផ្នែកខាងក្រោម(ឬនៅក្នុងឧបសម្ព័ន្ធ)។

## ៧.៣- ការអភិបាលគាំទ្រ:

ជាដំណើរការដឹកនាំ និងគាំទ្របុគ្គលិកដើម្បីឲ្យគេអនុវត្តប្រកបដោយប្រសិទ្ធភាព ។ ការអភិបាលផ្តល់នូវការគាំទ្រ ការណែនាំ ការបណ្តុះបណ្តាល និងជួយកំណត់ និងដោះស្រាយបញ្ហា ។ ការអភិបាលគាំទ្រទាំងអស់ ទាមទារឲ្យមានជាទៀងទាត់ និងពេលវេលាសមស្រប។

## ៧.៣.១ គោលបំណងនៃការអភិបាលគាំទ្រ គឺធ្វើឲ្យកាន់តែប្រសើរនូវការផ្ដល់សេវា ដោយជួយបុគ្គលិកវិភាគនិងដោះស្រាយបញ្ហាៈ

តាមដានការងារ និងការសម្រេចបាន

ចែករំលែកព័ត៌មានពីការងារ

កំណត់ផ្នែកនានានៃការងារ តើផ្នែកណាត្រូវការ ការគាំទ្រ ការបណ្ដុះបណ្ដាល ឬការបង្វិកបន្ថែម

ទទួលស្គាល់និងដោះស្រាយបញ្ហាកើតឡើងជាក់ស្ដែង

ផ្ដល់ការបង្វឹកដល់បុគ្គលិកមណ្ឌលសុខភាពជាទៀងទាត់ និងការឯកភាពគ្នាលើអ្វីៗដែលត្រូវផ្លាស់ប្ដូរ

## ៧.៣.២ ការអភិបាល ការបណ្ដុះបណ្ដាល និងការបង្វឹកត្រូវដើរស្របគ្នា

មន្ត្រីអភិបាលជាអ្នកកំណត់សំគាល់នូវ តំរូវការបណ្ដុះបណ្ដាលជាផ្លូវការឬក្រៅផ្លូវការ ឬការបង្វិក ដល់មណ្ឌលសុខភាព។បន្ថែមពីនេះមន្ត្រីអភិបាលត្រូវចូលរួម ក្នុងការបណ្ដុះបណ្ដាលបុគ្គលិក។ ជាឧទាហរណ៍ ការបណ្ដុះបណ្ដាល អំពីការព្យាបាលជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ ត្រូវរួមបញ្ចូលបុគ្គលិកមណ្ឌល សុខភាព និងមន្ត្រីសុខាភិបាល ធ្វើការនៅក្នុងផ្នែកប្រយុទ្ធជំងឺ។

## ៧.៣.៣ គ្រប់មណ្ឌលសុខភាព ត្រូវទទួលការអភិបាល ការគាំទ្រ និងការបង្វឹកដល់កន្លែងការងារ។ ក្រុមប្រឹក្សាបច្ចេកទេសខេត្តទទួលខុសត្រូវ ក្នុងការធានាឲ្យមានប្រព័ន្ធអភិបាលរៀងរាល់ខែ សម្រាប់គ្រប់មូលដ្ឋានសុខាភិបាល។

## ៧.៣.៤ ការអភិបាល គាំទ្រ ពីស្រុកប្រតិបត្តិទៅមណ្ឌលសុខភាព

ការអភិបាលគាំទ្រ ពីស្រុកប្រតិបត្តិទៅមណ្ឌលសុខភាព ត្រូវរួមមាន ការគាំទ្រកម្មវិធីបច្ចេកទេស សកម្មភាពព្យាបាលនិងការពារ ការបង្ការរោគឆ្លងនិងអនាម័យ ការងារ ឱសថ រដ្ឋបាល ហិរញ្ញវត្ថុ និង ការងារគ្រប់គ្រង។ ការអភិបាលគាំទ្រត្រូវបានរៀបចំ សំដៅកសាងសមត្ថភាព របស់បុគ្គលិកមណ្ឌល សុខភាព ដើម្បីកែលម្អសមត្ថភាព ក្នុងការផ្ដល់សេវាក្នុងសំណុំសកម្មភាពអប្បរមា (MPA) និងកែលម្អ ដំណើរការ នៃការថែទាំប្រកបដោយគុណភាព(ការផ្ដល់សេវាថែទាំដោយអ្នកផ្ដល់ សេវាទៅដល់អ្នកជំងឺ ឬ "ការពង្រឹងបច្ចេកទេសគ្លីនិក" ស្របតាមផែនការយុទ្ធសាស្ត្រសុខាភិបាល ទី៣ HSP3)។ ការអភិបាលត្រូវៈ

ប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់សម្រាប់អភិបាលរួមបញ្ចូលគ្នាដែលគ្របដណ្ដប់សកម្មភាពនៃមណ្ឌល សុខភាពរួមមាន សកម្មភាពព្យាបាលនិងបង្ការ ការងារឱសថ ការបង្ការរោគឆ្លងក្នុងមណ្ឌលសុខភាព និងអនាម័យ និងហិរញ្ញវត្ថុ។

ពិភាក្សាអំពី តារាងតាមដានសុខាភិបាល របស់មណ្ឌលសុខភាព។

ពិនិត្យបុគ្គលិកនៅពេលផ្ដល់សេវានិងពេលចេញវេជ្ជបញ្ជា។

បង្វឹកបុគ្គលិកមណ្ឌលសុខភាព អំពីរបៀបកែលម្អការអនុវត្តន៍ប្រចាំថ្ងៃរបស់ពួកគេ ក្នុងការផ្តល់ការថែទាំគ្លីនិក និងការផ្តល់ប្រឹក្សាដល់អ្នកជំងឺ។

## ៧.៤- ការប្រជុំបុគ្គលិកជាទៀងទាត់

ប្រធានមណ្ឌលសុខភាព ត្រូវរៀបចំការប្រជុំបុគ្គលិកមណ្ឌលសុខភាពទាំងអស់ នៅតាម មណ្ឌលសុខភាពនីមួយៗជាទៀងទាត់។ ប្រធានមណ្ឌលសុខភាពក៏ត្រូវបង្កើត និងរៀបចំឲ្យមានឱកាសជាប្រចាំសម្រាប់៖ ការពង្រឹង និងការបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់កម្រិតផ្សេងៗ(កម្រិត MPA, កម្រិត CPA, កម្រិត ODs, និងកម្រិត PHDs) ព័ត៌មានត្រឡប់អំពីការចុះអភិបាល និងការបញ្ជូន និងការបន្តពង្រឹងបច្ចេកទេសគ្លីនិក និងតាមរយៈការចូលរួមរបស់បុគ្គលិក មណ្ឌលសុខភាព នៅក្នុងកិច្ចប្រជុំក្រុមសម្ព័ន្ធឆ្មប (MCATs) កិច្ចប្រជុំសម្ព័ន្ធពេទ្យកុមារ (PCATs) និងយន្តការប្រហាក់ប្រហែលផ្សេងទៀតជាប្រចាំ។

## ៧.៥- របាយការណ៍ជូនទៅស្រុកប្រតិបត្តិ

មណ្ឌលសុខភាពនីមួយៗ ត្រូវបញ្ជូនរបាយការណ៍ប្រចាំខែ (រៀងរាល់ខែ) ទៅកាន់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិរបស់ខ្លួនតាមកាលកំណត់ ។ បន្ទាប់មកការិយាល័យសុខាភិបាលស្រុកប្រតិបត្តិធ្វើការបូកសរុបរបាយការណ៍ទាំងអស់ ហើយបញ្ជូនមកមន្ទីរសុខាភិបាលខេត្ត ដែលបូកសរុបរបាយការណ៍ស្រុកទូទាំងខេត្ត បញ្ជូនទៅក្រសួងសុខាភិបាល។ ទិន្នន័យព័ត៌មានទាំងអស់ ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យវិទ្យាគេហទំព័រ ។

របាយការណ៍ HC1 អាចត្រូវបានកត់ត្រា និងបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈប្រព័ន្ធព័ត៌មានសុខាភិបាល(HIS) ដែលដំណើរការលើគេហទំព័រ ប្រសិនបើមណ្ឌលសុខភាពមានកុំព្យូទ័រ។ ប្រមាណ៤០% នៃមណ្ឌលសុខភាពទាំងអស់ មានកុំព្យូទ័រប្រើប្រាស់ (គិតត្រឹមពាក់កណ្តាល ឆ្នាំ២០១៦) និងមានសមត្ថភាពបញ្ជូនរបាយការណ៍ HC1 របស់ពួកគេតាមរយៈគេហទំព័រ។

សូចនាករដែលត្រូវបញ្ចូលក្នុងរបាយការណ៍ប្រចាំខែ (HC1) និងទម្រង់នៃរបាយការណ៍ប្រចាំខែទាំងនោះ ត្រូវបានកំណត់ដោយនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់។ របាយការណ៍ទាំងនេះអាចរកបាន នៅលើគេហទំព័រប្រព័ន្ធព័ត៌មានសុខាភិបាល របស់ក្រសួងសុខាភិបាល ដែលមានអាសយដ្ឋាន៖www.hismohcambodia.org

**ចរន្តបញ្ជូនព័ត៌មានសុខាភិបាល**




## ៧-៦ ស្ថិតិ និងស្ថានភាពប្រជាជន ក្នុងតំបន់ទទួលខុសត្រូវ

បុគ្គលិកមណ្ឌលសុខភាពត្រូវស្គាល់ទីតាំងភូមិសាស្ត្ររបស់ខ្លួនឱ្យបានច្បាស់លាស់។

មណ្ឌលសុខភាពដែលមានទីតាំងនៅកន្លែងណា គប្បីត្រូវកត់ត្រាស្ថិតិឱ្យបានច្បាស់លាស់នូវចំនួនប្រជាជន ដែលមានក្នុងតំបន់នោះ ដោយធ្វើការបែងចែកឱ្យបានត្រឹមត្រូវនូវចំនួនបុរស-ស្ត្រី ក្មេង-ចាស់ ។ល។ ព្រមទាំង ចូលរួមតាមដាននូវកំណើនរបស់ប្រជាជនជាប្រចាំទៀតផង។ ព្រោះថាកំណើននេះមានឥទ្ធិពលលើសេវារបស់មណ្ឌលសុខភាព ម្យ៉ាងទៀតដើម្បីជានាការផ្តល់សេវាដ៏មានប្រសិទ្ធភាពនោះ មណ្ឌលសុខភាពត្រូវចេះបែងចែក ក្រុមមនុស្ស និងផ្តល់អាទិភាពដល់ពួកគេងាយស្រួលក្នុងការធ្វើអន្តរាគមន៍ផ្សេងៗ ។ ឧទាហរណ៍:

- តើមានចំនួនស្ត្រីមានផ្ទៃពោះប៉ុន្មានបានចាក់ថ្នាំ ?
- ក្រុមមនុស្សដែលរស់នៅប៉ះពាល់នឹងជំងឺឆ្លង ?
- ក្រុមមនុស្សដែលមានវប្បធម៌ និង ភាសាដទៃ ?
- ក្រុមមនុស្សដែលនៅឆ្ងាយពីមណ្ឌលសុខភាព ?
- ក្រុមមនុស្សដែលរស់នៅក្នុងតំបន់លិចទឹក ?

- ក្រុមមនុស្សដែលរស់នៅក្បែរកន្លែងមិនមានបរិយាកាសសមស្រប (គំនរសំរាម លូទឹកស្អុយ) ឬក្បែររោងចក្រដែលបញ្ចេញកាកសំណល់ ដែលមានជាតិពុល ក្លិនអាក្រក់ និង លាន់ឮសំឡេងកងរំពង ។
- ក្រុមមនុស្សដែលមានបញ្ហាផ្សេងៗ ទៀត ដែលយើងគប្បីយកចិត្តទុកដាក់ ។

# ៨-ធនធានមនុស្សសុខាភិបាល

## ៨.១. ការអភិវឌ្ឍន៍ធនធានមនុស្ស

ធនធានមនុស្សសុខាភិបាល គឺជាធនធានដ៏សំខាន់ដែលមិនអាចខ្វះបានសម្រាប់បម្រើសេវាសុខាភិបាលនៅគ្រប់លំដាប់ថ្នាក់សេវាសុខាភិបាលទូទាំងប្រទេស។ ការអភិវឌ្ឍន៍ធនធានមនុស្ស គឺជាការបណ្តុះបណ្តាលធនធានមនុស្ស ឲ្យមានសមត្ថភាព និងប្រកបដោយវិជ្ជាជីវៈ ដោយរាប់បញ្ចូលទាំងចំណេះដឹង ជំនាញ និងអាកប្បកិរិយា ដើម្បីផ្តល់សេវាសុខភាពសមស្របជូនប្រជាពលរដ្ឋ។ ការបណ្តុះបណ្តាលវិស័យសុខាភិបាលនាពេលបច្ចុប្បន្ន គឺមានការបណ្តុះបណ្តាល មុនពេលបម្រើការងារ និងការបណ្តុះបណ្តាលពេលកំពុងបម្រើការងារ។

### ៨.១.១. ការបណ្តុះបណ្តាលមុនពេលបម្រើការងារ

មណ្ឌលសុខភាព មានតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាល និងនិស្សិតដែលមកធ្វើកម្មសិក្សាពិសេស ផ្នែកជំនាញគ្លីនីក។ អ្នកគ្រប់គ្រងមណ្ឌលសុខភាព ត្រូវរៀបចំផែនការបណ្តុះបណ្តាលឲ្យបានច្បាស់លាស់ គិតទាំងតម្រូវការបុគ្គលិកមណ្ឌលសុខភាព និងលទ្ធភាពស្រូបយកនិស្សិតមកធ្វើកម្មសិក្សាជំនាញគ្លីនីក នៅមណ្ឌលសុខភាព ដើម្បីគ្រប់គ្រង និងអនុវត្តការបណ្តុះបណ្តាលទាំងមុនពេលបម្រើការងារ និងពេលកំពុងបម្រើការងារឲ្យមានប្រសិទ្ធភាព។ មណ្ឌលសុខភាពដែលមានបុគ្គលិក និងគ្រូដឹកនាំកម្មសិក្សាជំនាញគ្លីនិកឲ្យបានគ្រប់គ្រាន់ សម្រាប់បង្ហាត់បង្រៀន និងដឹកនាំនិស្សិតធ្វើកម្មសិក្សាជំនាញគ្លីនិក ទើបអាចប្រើប្រាស់ជាកន្លែងធ្វើកម្មសិក្សាគ្លីនីករបស់និស្សិតបាន។ គ្រូដឹកនាំកម្មសិក្សាជំនាញគ្លីនិក ត្រូវឆ្លងកាត់ការបណ្តុះបណ្តាលវគ្គគ្រូកម្មសិក្សាជំនាញគ្លីនិក ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយត្រូវមានភារកិច្ចបន្ថែមក្នុងការបង្ហាត់បង្រៀន ដឹកនាំនិស្សិតធ្វើកម្មសិក្សាជំនាញគ្លីនិក និងវាយតម្លៃកម្មសិក្សាជំនាញគ្លីនិករបស់និស្សិតឲ្យបានត្រឹមត្រូវ និងម៉ត់ចត់ ដោយប្រើប្រាស់សៀវភៅកម្មសិក្សាជំនាញគ្លីនិក របស់ក្រសួងសុខាភិបាល។ មណ្ឌលសុខភាពដែលនឹងប្រើប្រាស់ជាកន្លែងកម្មសិក្សាគ្លីនិករបស់និស្សិត ត្រូវមានការទទួលស្គាល់ពីក្រសួងសុខាភិបាល ។

### ៨.១.២. ការបណ្តុះបណ្តាលពេលកំពុងបម្រើការងារ

ដើម្បីផ្តល់សេវាថែទាំសុខភាពនៅមណ្ឌលសុខភាព ប្រកបដោយគុណភាព និងប្រសិទ្ធភាព បុគ្គលិកដែលកំពុងបម្រើការងារនៅមណ្ឌលសុខភាព ត្រូវមានសមត្ថភាពគ្រប់គ្រាន់ គិតទាំងចំណេះដឹង

ជំនាញ និងបទពិសោធន៍នានាក្នុងវិជ្ជាជីវៈ។ ដូចនេះ ការបណ្តុះបណ្តាលពេលកំពុងបម្រើការងារ ទាមទារអោយមានការរៀបចំជាប្រចាំ និងបន្តបន្ទាប់ដល់បុគ្គលិក ដើម្បីធានាថាពួកគេទាំងអស់បានអភិវឌ្ឍន សមត្ថភាពរបស់ខ្លួនស្របតាមជំនាញ ដែលកំពុងបំពេញភារកិច្ចប្រចាំថ្ងៃ។

អ្នកគ្រប់គ្រងមណ្ឌលសុខភាព ត្រូវធ្វើផែនការបណ្តុះបណ្តាលដល់បុគ្គលិករបស់ខ្លួន ឲ្យបានគ្រប់ជ្រុងជ្រោយ ដោយសហការជាមួយការិយាល័យស្រុកប្រត្តិបត្តិ មន្ទីរសុខាភិបាលខេត្ត និងនាយកដ្ឋាន ឬអង្គភាពពាក់ព័ន្ធនៅថ្នាក់កណ្តាល នៃក្រសួងសុខាភិបាល។ ការបណ្តុះបណ្តាលទាំងនេះ និងអាចប្រើប្រាស់ថវិកាជាតិ ឬកញ្ចប់ថវិកាហិរញ្ញប្បទាន ឬការឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍សុខាភិបាល តាមរយៈគំរោងផ្សេងៗ ឬកម្មវិធីជាតិនានា ដើម្បីធានាឲ្យមានការបណ្តុះបណ្តាលបន្តជាប្រចាំ សម្រាប់បំប៉នសមត្ថភាព ពិសេសអំពីចំណេះដឹងជូនដល់ បុគ្គលិករបស់មណ្ឌលសុខភាព។

លើសនេះថែមទៀត ការបណ្តុះបណ្តាលបន្តដល់ក្រុមទ្រទ្រង់សុខភាពភូមិ ឬអ្នកស្ម័គ្រចិត្ត គឺជាការងារចាំបាច់របស់មណ្ឌលសុខភាពដែលត្រូវធ្វើជាប្រចាំ ព្រោះថា ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍន៍ និងដំណើរការផ្តល់សេវាថែទាំរបស់មណ្ឌលសុខភាព គឺមានសារៈសំខាន់ ព្រមទាំងធានាលក្ខណៈគ្រប់ជ្រុងជ្រោយ និងនិរន្តភាពនៃការផ្តល់សេវាថែទាំសុខភាព ឲ្យដល់គ្រប់ស្រទាប់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។ ដូចបានបញ្ជាក់ជូនខាងដើមស្រាប់ហើយ ក្រុមទ្រទ្រង់សុខភាពភូមិ ឬអ្នកស្ម័គ្រចិត្តមានតួនាទី ចូលរួមចំណែកយ៉ាងសកម្ម ក្នុងការផ្សព្វផ្សាយរាល់ព័ត៌មាន និងសារសុខភាពសំខាន់ៗដល់សហគមន៍ និងផ្តល់មកមណ្ឌលសុខភាពវិញ នូវរាល់បញ្ហាសុខភាពរបស់សហគមន៍ ដើម្បីមានវិធានការណ៍ដោះស្រាយជូនសហគមន៍ឲ្យបានទាន់ពេលវេលា។ ដូចនេះ អ្នកគ្រប់គ្រងមណ្ឌលសុខភាព ត្រូវរៀបចំការបណ្តុះបណ្តាលបន្ត ដល់ក្រុមទ្រទ្រង់សុខភាពភូមិ ដោយអាចពិចារណាលើប្រធានបទមួយចំនួនដូចខាងក្រោម៖

១. រាល់សារអប់រំសុខភាព ពាក់ព័ន្ធនឹងបណ្តាសុខភាពសំខាន់ៗ
២. វិធានការការពារសុខភាពទូទៅ
៣. សញ្ញាគ្រោះថ្នាក់ដែលត្រូវធ្វើការបញ្ជូន ឬផ្តល់ការជំនួយសង្គ្រោះបឋម
៤. ការផ្តល់ជំនួយសង្គ្រោះបឋម
៥. ទម្រង់ផ្សេងៗ នៃរបាយការណ៍ពីសហគមន៍ ទៅមណ្ឌលសុខភាព
៦. រោគសញ្ញានៃជំងឺមួយចំនួន ដែលមណ្ឌលសុខភាពត្រូវធ្វើការស្រាវជ្រាវ និងតាមដាន
៧. សេវាសុខភាពដែលផ្តល់ ក្នុងការគ្របដណ្តប់របស់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក
៨. ច្បាប់ ប្រកាស ឬ សេចក្តីណែនាំផ្សេងៗ ដែលទាក់ទងផ្នែកសុខភាព
៩. សេវាផ្សេងៗទៀតដែលនៅក្នុងសហគមន៍ ដែលពួកគាត់ត្រូវទាក់ទងដើម្បីសេវាសុខភាព
១០. សិទ្ធិ និងការទទួលខុសត្រូវរបស់អតិថិជន ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចអ្នកផ្តល់សេវាជាដើម។

## ៨.២. ការគ្រប់គ្រងធនធនមនុស្ស

ដើម្បីឱ្យមណ្ឌលសុខភាព មានដំណើការផ្តល់សេវាសុខាភិបាល ជូនដល់ប្រជាពលរដ្ឋក្នុងភូមិសាស្រ្តគ្របដណ្តប់របស់ខ្លួនបានល្អប្រសើរ ទាមទារឱ្យមានការយកចិត្តទុកដាក់ ក្នុងការអនុវត្តន៍ការងារគ្រប់គ្រងបុគ្គលិកសុខាភិបាល លើបណ្តាចំណុច ដូចខាងក្រោម៖

ចំនួនបុគ្គលិក និងជំនាញរបស់ពួកគាត់ត្រូវ ឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការ។

រៀបចំតួនាទី ភារកិច្ច និងចាត់ចែងការងារដល់បុគ្គលិកម្នាក់ៗ ទទួលខុសត្រូវការងារឱ្យបានច្បាស់លាស់ ដើម្បីធានាឱ្យបាននូវការផ្តល់សេវា២៤ម៉ោងលើ២៤ម៉ោង។

លើកកំពស់លទ្ធផលការងារ និងការទទួលខុសត្រូវរបស់បុគ្គលិកសុខាភិបាល។

ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ និងការគោរពវិន័យមន្រ្តីរាជការ/បុគ្គលិក ព្រមទាំងការផ្លាស់ប្តូរ ឥរិយាបថ ទម្លាប់ និងរបៀបរបបការងារជាអ្នកផ្តល់សេវា។

ផ្តល់ការលើកទឹកចិត្តដល់មន្រ្តីសុខាភិបាលឱ្យបានសមស្រប ដោយផ្អែកលើប្រសិទ្ធភាពនិងប្រសិទ្ធផលការងាររបស់បុគ្គលិកម្នាក់ៗ។

រៀបចំយន្តការនិងតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីវាស់វែងពីវឌ្ឍនភាពការងារ កំណត់បញ្ហាប្រឈម និងដំណោះស្រាយ ព្រមទាំងកំណត់អាទិភាពនិងទិសដៅសម្រាប់អនុវត្តបន្ត (ប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព )។

លើសនេះថែមទៀត ដូចបានរៀបរាប់នៅជំពូក៣ស្រាប់ មណ្ឌលសុខភាពត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រង និងបែងចែកតួនាទី ភារកិច្ច និងការទទួខុសត្រូវការងារអោយបានច្បាស់ សម្រាប់រាល់បុគ្គលិកដែលកំពុងបំរើការងារ នៅនឹងមូលដ្ឋានជាក់ស្តែង។

ប្រធានមណ្ឌលសុខភាព ត្រូវសហការជាមួយបុគ្គលិក ដើម្បីរៀបចំពេលវេលាធ្វើការឱ្យបាន ២៤ម៉ោង។ បន្ទាប់មកគេត្រូវរៀបចំជាតារាងមួយ សម្រាប់បំពេញមួយខែ ដោយមានដាក់ឈ្មោះបុគ្គលិក ថ្ងៃធ្វើការ ពេលយាម និង ការចុះផ្តល់សេវាមូលដ្ឋាន និង ការបំពេញភារកិច្ចផ្សេងៗទៀត ។

គួរមានការប្តូរវេនបុគ្គលិក ដែលគឺជាការផ្លាស់ប្តូរជាបន្តបន្ទាប់ និង ក្នុងរយៈពេលមួយកំណត់នូវបុគ្គលិកនិមួយៗ ឱ្យកាន់ការងារផ្សេងៗ នៅក្នុងមណ្ឌលសុខភាព ក្នុងករណីចាំបាច់ ។

លើសពីនេះទៀត ត្រូវមានផែនការជំនួសបុគ្គលិកពេលអវត្តមាន ដើម្បីជៀសវាងដំណើរការរអាក់រអួលនៅមណ្ឌលសុខភាព។ ប្រធានមណ្ឌលសុខភាពត្រូវមានផែនការ ជំនួសបុគ្គលិកអវត្តមានម្នាក់ដោយបុគ្គលិកម្នាក់ទៀត ដោយផ្អែកលើ៖

- កម្រិតសមត្ថភាព
- បន្ទុកការងារ និង
- ការមានទឹកចិត្តបំពេញការងារ

ក្នុងករណីខ្លះ ការផ្ទេរសិទ្ធិដោយលាយលក្ខអក្សរជាការចាំបាច់។

## ៨.៣. ការធានាការផ្តល់សេវា ២៤ម៉ោង

មណ្ឌលសុខភាព គឺជាកន្លែងដែលផ្តល់សេវាថែទាំសុខភាពជូនប្រជាជន ក្នុងមូលដ្ឋានជួរមុខមុន មន្ទីរពេទ្យបង្អែក ។ ការផ្តល់សេវាថែទាំ ឬ ការពិនិត្យពិគ្រោះជំងឺ គឺជាសកម្មភាពមូលដ្ឋានដែលទាក់ទាញ ប្រជាជន ឱ្យមកទទួលនូវសេវា ដែលពួកគាត់ត្រូវការចាំបាច់ ។

ការផ្តល់សេវានេះ ពិតមែនតែមានកំរិត តែវាជាសេវាមួយដែលប្រកបទៅដោយគុណភាព មាន ប្រសិទ្ធភាព និងដំណើការបាន ២៤ម៉ោង លើ ២៤ម៉ោង។ ដូច្នេះមណ្ឌលសុខភាពត្រូវជូនព័ត៌មានដល់ សហគមន៍ ដើម្បីជៀសវាងការចំណាយថវិកា និង ពេលវេលា ឥតប្រយោជន៍អំពី:

សេវាដែលមាននៅមណ្ឌលសុខភាព

ពេលវេលា និង សកម្មភាពរបស់មណ្ឌលសុខភាព

វត្តមានរបស់បុគ្គលិកមណ្ឌលសុខភាព ការផ្តល់សេវាថែទាំជូនប្រជាជននេះ ត្រូវផ្អែកទៅលើកត្តា ជាចំបងមួយចំនួន ដូចខាងក្រោម:

- មានបុគ្គលិកគ្រប់គ្រាន់ បច្ចេកទេស និងសម្ភារសមស្រប តាមបទដ្ឋានកំណត់របស់ក្រសួង សុខាភិបាល។
- អាចធានារ៉ាប់រងការងារបាន ២៤ ម៉ោងរៀងរាល់ថ្ងៃ និង ចេះចរាចរអ្នកជំងឺមិនឱ្យមាន ការរាំងស្ទះ ។
- រៀបចំផែនការ ការងារសម្រាប់ដំណើរការមណ្ឌលសុខភាព និង មានបុគ្គលិកយាមប្រចាំការ ក្រៅម៉ោងធ្វើការ ។
- ធានាបាននូវទំនាក់ទំនងល្អជាមួយអ្នកជំងឺ បង្កើននូវការជឿទុកចិត្តលើបុគ្គលិក ជាកត្តាជំរុញ ឱ្យមានការចូលរួមប្រើប្រាស់សេវានៅមណ្ឌលសុខភាពកាន់តែច្រើនឡើងជាលំដាប់ ។
- មានបន្ទប់យាមសមស្រប(សូមអានជំពូកហេដ្ឋារចនាសម្ព័ន្ធអគារ)។

## ៨.៤ ការប្រជុំការងារបុគ្គលិកជាទៀងទាត់

វាជាកិច្ចការសំខាន់ណាស់ ដែលអ្នកគ្រប់គ្រងមណ្ឌលសុខភាព ត្រូវយល់ដឹងពីកិច្ចការដែល បុគ្គលិករបស់ខ្លួនអនុវត្តរាល់ថ្ងៃ។ ដូច្នេះហើយការជួបជុំបុគ្គលិកជាទៀងទាត់ ម្តងយ៉ាងតិចក្នុងមួយខែ នឹងត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំនីមួយៗ គឺជាកិច្ចការចាំបាច់ខានពុំបានដើម្បី៖

តាមដាននូវដំណើរការនៃការអនុវត្តន៍ការងារ។

ផ្តល់នូវព័ត៌មានផ្សេងៗ ជុំវិញការអនុវត្តន៍ការងាររបស់បុគ្គលិក ឬព័ត៌មានដែលទទួលបានពីកន្លែង ផ្សេងទៀត។

បង្ហាញពីលទ្ធផលនៃការអនុវត្តន៍ការងារ ដោយប្រៀបធៀបនឹងផែនការ ជូនបុគ្គលិកពិនិត្យរួម។

ផ្តល់ឱកាសដល់បុគ្គលិកបញ្ចេញយោបល់ពីបញ្ហាដែលពួកគេជួបប្រទះ និងរកដំណោះស្រាយរួម។

ផ្តល់ឱកាសជូនបុគ្គលិក ពិនិត្យពិចារណាលើសកមក្មភាពដែលពួកគេអនុវត្តកន្លងមកថាតើ សកម្មភាពណាខ្លះដែលគួរធ្វើការកែលម្អ? និង ដោយវិធីណា? និង

ស្វែងយល់ពីបុគ្គលិក ថាតើ អតិថិជនពេញចិត្តនឹងសេវារបស់ខ្លួនដែរឬទេ?។ល។

ការជួបជុំបុគ្គលិកស្វែងយល់ពីគ្នាទៅវិញទៅមកអាចធ្វើទៅបានដោយទៀងទាត់ និងទទួលបានលទ្ធផលល្អ ជៀសវាងនូវបាតុភាពផ្សេងៗដែលនឹងកើតមានឡើងជាយថាហេតុ ឬក៏ខាតបង់ពេលវេលាឥតប្រយោជន៍នោះ អ្នកដឹកនាំគួរចេះជ្រើសរើសឱកាសសមស្របណាមួយ ឬធ្វើការកែប្រែកម្មវិធីជួបជុំបើអាចធ្វើបាន។

ដោយឡែក ចំពោះការប្រជុំគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព សូមអានជំពូកទី៥។

## ៨.៥. ការចូលរួមការប្រជុំនៅថ្នាក់ស្រុកប្រតិបត្តិ

ភារកិច្ចដែលត្រូវធ្វើរួមមានៈ

- ប្រធាន/អនុប្រធានត្រូវចូលរួមប្រជុំជាទៀងទាត់ជាមួយស្រុកប្រតិបត្តិរៀងរាល់ខែ ឬ តាមការចាំបាច់របស់ស្រុកប្រតិបត្តិ។
- ស្រង់ នឹងរាយការណ៍បញ្ហាសំណូមពរ ដែលមាននៅពេលប្រជុំជាមួយគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព ប្រជុំក្រុមទ្រទ្រង់សុខភាពភូមិ ប្រជុំបុគ្គលិក ឬបញ្ហាផ្សេងៗ ដែលមិនអាចដោះស្រាយបាន ជូនអង្គប្រជុំថ្នាក់ស្រុកប្រតិបត្តិដើម្បីពិនិត្យ និងជួយដោះស្រាយឱ្យបានទាន់ពេលវេលា។
- ផ្សព្វផ្សាយនូវដំណោះស្រាយ សំណូមពរ ពីថ្នាក់ស្រុកប្រតិបត្តិជូនគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ បុគ្គលិកមណ្ឌលសុខភាព តាមរយៈការប្រជុំនីមួយៗ ឬការណែនាំដោយឡែក។
- ផ្សព្វផ្សាយនូវព័ត៌មាន គោលនយោបាយថ្មីៗ ដែលទទួលបានពីថ្នាក់ស្រុកប្រតិបត្តិដល់បុគ្គលិក គណកម្មការគ្រប់គ្រងមណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ ដើម្បីរួមគ្នាអនុវត្ត។
- កត់ត្រានូវយោបល់ បទពិសោធន៍ល្អៗ ក្នុងពេលប្រជុំដើម្បីយកមកអនុវត្ត នៅអង្គភាពរបស់ខ្លួន ។

# ៩- ការគ្រប់គ្រងថវិកានៅមណ្ឌលសុខភាព

## ៩-១ ហិរញ្ញប្បទានសុខាភិបាល និងការគ្រប់គ្រងថវិកានៅមណ្ឌលសុខភាព

ហិរញ្ញប្បទានសុខាភិបាលជាផ្នែកមួយដ៏សំខាន់របស់ប្រព័ន្ធសុខាភិបាល។ ហិរញ្ញប្បទានសុខាភិបាលនៅមណ្ឌលសុខភាព សំដៅលើការប្រមូល ការបែងចែកឬវិភាជន៍ និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ របស់មណ្ឌលសុខភាព ដើម្បីបំពេញតម្រូវការផ្នែកសុខភាព របស់ប្រជាពលរដ្ឋ ពិសេសអ្នកនៅក្នុងតំបន់គ្របដណ្តប់របស់ខ្លួន។ ការអនុវត្តន៍ហិរញ្ញប្បទានសុខាភិបាល និងការគ្រប់គ្រងថវិកាបានល្អអាចប្រមូលបាននូវធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់ដំណើរការរបស់មណ្ឌលសុខភាព ព្រមទាំងអាចលើកទឹកចិត្តអោយមានការផ្តល់ និងប្រើប្រាស់សេវាប្រកបដោយប្រសិទ្ធផល។

ជាទូទៅ ប្រភពចំណូលសំខាន់ៗរបស់មណ្ឌលសុខភាពបានមកពី៖

ថវិកាជាតិ តាមរយៈមន្ទីរសុខាភិបាលរាជធានី ខេត្ត និង ស្រុកប្រតិបត្តិ

ការបង់ថ្លៃសេវារបស់អ្នកជំងឺដោយផ្ទាល់នៅពេលប្រើប្រាស់សេវា (សេវាបង់ថ្លៃ) និង

ការបង់ថ្លៃសេវាជំនួសដោយមូលនិធិសមធម៌សុខាភិបាល និងការធានារ៉ាប់រងសុខភាពនានា និងពីគម្រោងហិរញ្ញប្បទានសុខាភិបាលនានាដូចជា៖ ថវិកាលើកទឹកចិត្តផ្អែកលើស្នាដៃការងារ ប្រាក់លើកទឹកចិត្តឆ្មបប្រាក់ម៉ោងយាម ជាដើម ដែលមួយចំណែកធំមានប្រភពពីថវិកាជាតិ។

### ៩.១.១ ថវិកាជាតិ

បន្ថែមពីលើការចំណាយថ្លៃផ្គត់ផ្គង់ឱសថនិងបរិក្ខារពេទ្យ រាជរដ្ឋាភិបាលបានផ្តល់នូវថវិកាជាតិសម្រាប់ដំណើរការមណ្ឌលសុខភាព ក្នុងរូបភាពជាច្រើនដូចជា៖ ប្រាក់បៀវត្ស ថវិកាសម្រាប់ចំណាយប្រតិបត្តិការ និង ប្រាក់លើកទឹកចិត្តផ្សេងៗ។ ជាទូទៅ ថវិកាទាំងនេះត្រូវបានចាត់ចែង ដោយការិយាល័យស្រុកប្រតិបត្តិ មន្ទីរសុខាភិបាល និង ក្រសួងសុខាភិបាល ដែលជាអាណាព្យាបាល គ្រប់គ្រងលើមណ្ឌលសុខភាព។ ដោយឡែកកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សុខាភិបាល ចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនៃក្រសួងសុខាភិបាល ត្រូវគ្រប់គ្រងដោយមណ្ឌលសុខភាព។

ដើម្បីឱ្យការគ្រប់គ្រងថវិការាប់បញ្ចូលទាំងថវិកាជាតិ ពិសេសថវិកាសម្រាប់ចំណាយប្រតិបត្តិការមានភាពប្រសើរ មណ្ឌលសុខភាពទាំងអស់ត្រូវ:

មានផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ខ្លួន ដូចគម្រូស្តង់ដាររបស់នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល និងនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល។

ធ្វើការតាមដាន និង កត់ត្រាការអនុវត្តន៍ថវិកាជាប្រចាំទៅតាមប្រភពថវិកា និង ចុះតាមលេខកូដសកម្មភាព។

កត់ត្រារាល់ចំណូលចំណាយរបស់មណ្ឌលសុខភាព និង រាយការណ៍ទៅស្រុកប្រតិបត្តិឱ្យបាន ទាន់ពេលវេលា ។ចុះបញ្ជីសារពើភ័ណ្ឌអចលនវត្ថុ (តាមការណែនាំរបស់ក្រសួងសុខាភិបាល)។

ការចំណាយថវិកាជាតិសម្រាប់ប្រតិបត្តិការ ជាទូទៅត្រូវគោរពទៅតាមការណែនាំរបស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមផែនការប្រតិបត្តិរបស់មណ្ឌលសុខភាព។ បន្ថែមលើថវិកាជាតិសម្រាប់ចំណាយប្រតិបត្តិការ រាជរដ្ឋាភិបាលបានផ្តល់នូវថវិកាដល់មណ្ឌសុខភាព (១២លាន ឬ២៤លានរៀល/មណ្ឌលសុខភាព/ឆ្នាំ) សម្រាប់ចំណាយចាំបាច់និងបន្ទាន់នានា ក្នុងការលើកកំពស់គុណភាពសេវា ដែលការចំណាយថវិកានេះ ត្រូវធ្វើតាមការណែនាំ ដោយឡែករបស់ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ៩.១.២ សេវាបង់ថ្លៃ

ការបង់ថ្លៃសេវារបស់អ្នកជំងឺដោយផ្ទាល់ នៅពេលប្រើប្រាស់សេវា (សេវាបង់ថ្លៃ) គឺជាប្រភពហិរញ្ញប្បទានមួយដ៏សំខាន់ សម្រាប់បំពេញតម្រូវការថវិកា របស់មណ្ឌលសុខភាព បន្ថែមលើថវិកាជាតិ និងថវិកាដែលបានមកពីប្រភពផ្សេងៗទៀត។ មណ្ឌលសុខភាពទាំងអស់អាចអនុវត្តសេវាបង់ថ្លៃបាន តែត្រូវគោរពគោលការណ៍ នៃបញ្ញត្តិស្តីពីហិរញ្ញប្បទានសុខាភិបាល និងត្រូវធ្វើឡើងតាមសេចក្តីណែនាំសម្រាប់អភិវឌ្ឍស្រុកប្រតិបត្តិ។ ដើម្បីឱ្យការអនុវត្តន៍សេវាបង់ថ្លៃមានភាពប្រសើរ មណ្ឌលសុខភាពទាំងអស់ត្រូវអនុវត្តតាមគោលការណ៍រួម ដូចខាងក្រោមនេះ៖

ការកំណត់ឬការកែប្រែថ្លៃសេវា ត្រូវធ្វើឡើងក្នុងកម្រិតមួយសមស្រប ដោយផ្អែកលើស្ថានភាពចំណូល-ចំណាយរបស់មណ្ឌលសុខភាព គុណភាពសេវា កត្តាជីវភាពរបស់ប្រជារាស្ត្រ និង ភាពជាក់ស្តែងមួយចំនួនទៀត ដោយមានការចូលរួមពីសហគមន៍ (តាមរយៈគណកម្មការគ្រប់គ្រងមណ្ឌលសុខភាព) និងមានការយល់ព្រមពីស្រុកប្រតិបត្តិ ឬ ខេត្ត ឬក្រសួងសុខាភិបាល។ តារាងថ្លៃសេវាត្រូវបិទបង្ហាញនៅលើជញ្ជាំងខាងមុខ មណ្ឌលសុខភាព ។

ការប្រមូលប្រាក់ពីអ្នកជំងឺ ត្រូវធ្វើឡើងដោយបុគ្គលិករបស់មណ្ឌលសុខភាពម្នាក់ដែលទទួលបន្ទុកការងារបេឡា ដោយមានបង្កាន់ដៃទទួលប្រាក់ត្រឹមត្រូវ និងបញ្ជីកត់ត្រាចំណូល-ចំណាយច្បាស់លាស់។ មណ្ឌលសុខភាពត្រូវធានាថា ដំណើរការប្រមូលប្រាក់នេះដាច់ខាតមិនត្រូវរំខាន ឬពន្យាពេលផ្តល់សេវាថែទាំព្យាបាលដល់អ្នកជំងឺឡើយ ពោលគឺ ក្នុងករណីបន្ទាន់ មណ្ឌលសុខភាពត្រូវផ្តល់សេវាមុនការបង់ប្រាក់ និង លើកលែងការបង់ប្រាក់ចំពោះជនក្រីក្រ ដោយការប្រើប្រាស់មូលនិធិសមធម៌សម្រាប់ប្រជាពលរដ្ឋក្រីក្រ តាមរយៈ Pre-ID ឬ Post-ID ។

ប្រាក់ចំណូលដែលបានមកពីសេវាបង់ថ្លៃ ត្រូវបែងចែកទៅតាមគោលការណែនាំ របស់ក្រសួងសុខាភិបាល ពោលគឺ៖

សេវាហិរញ្ញប្បទាន៖ ៦០%ប្រើជាប្រាក់លាភការសម្រាប់លើកទឹកចិត្តបុគ្គលិក ៣៩%ប្រើសម្រាប់ចំណាយប្រតិបត្តិការ ពិសេសសម្រាប់លើកកម្ពស់គុណភាពសេវា និង ១%បង់ចូលរតនាគារជាតិ។

សេវាមូលនិធិសមធម៌សុខាភិបាល៖ ៦០%ប្រើជាប្រាក់លាភការសម្រាប់លើកទឹកចិត្តបុគ្គលិក និង ៤០%ប្រើសម្រាប់ចំណាយប្រតិបត្តិការ ពិសេសសម្រាប់លើកកម្ពស់គុណភាពសេវា។

## ៩.១.៣- គំរោងហិរញ្ញប្បទានសុខាភិបាលផ្សេងៗ

គំរោងហិរញ្ញប្បទានសុខាភិបាលផ្សេងៗ ដែលបាននឹងកំពុងដំណើរការនៅប្រទេសកម្ពុជា និងដែលអាចជាប់ពាក់ព័ន្ធ នឹងហិរញ្ញប្បទានសុខាភិបាលនៅមណ្ឌលសុខភាព មានជាអាទិ៖ ថវិកាលើកទឹកចិត្តផ្អែកលើស្នាដៃការងារ  មូលនិធិសមធម៌ (ដែលជាផ្នែកមួយនៃគម្រោងលើកកំពស់គុណភាពនិងសមធម៌សុខាភិបាល) ប្រាក់លើកទឹកចិត្តឆ្មបរបស់រាជរដ្ឋាភិបាល ប្រាក់ម៉ោងយាម និង ធានារ៉ាប់រងសុខភាពនានា។

### ៩.១.៣.១- ថវិកាលើកទឹកចិត្តផ្អែកលើស្នាដៃការងារ

ថវិកាលើកទឹកចិត្តផ្អែកលើស្នាដៃការងារ គឺជាថវិកាដែលបានមកពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ តាមរយៈ គម្រោងលើកកំពស់គុណភាពនិងសមធម៌សុខាភិបាល។ នៅពេលគំរោងនេះមានសុពលភាពអនុវត្តចាប់ពីខែកក្កដា ឆ្នាំ២០១៦ ថវិកាលើកទឹកចិត្តផ្អែកលើស្នាដៃការងារ ត្រូវផ្តល់ជូនដល់មណ្ឌលសុខភាព ចាប់ពីត្រីមាសទី១ ឆ្នាំ២០១៧ ដោយផ្អែកលើស្នាដៃការងាររបស់មណ្ឌលសុខភាព ក្នុងការលើកកំពស់គុណភាពសេវា ហើយដែលត្រូវវាយតម្លៃរៀងរាល់ត្រីមាស។ គោលបំណងសំខាន់មួយ នៃថវិកានេះ គឺប្រើជាប្រាក់លាភការ សម្រាប់លើកទឹកចិត្តបុគ្គលិក។ អាស្រ័យហេតុនេះ មណ្ឌលសុខភាពអាចបែងចែកថវិកានេះ (យោងទៅតាមខ្លឹមសារសេចក្តីណែនាំប្រតិបត្តិសម្រាប់មូលនិធិគាំទ្រការផ្តល់សេវា និងលើកកម្ពស់គុណភាពសេវាសុខាភិបាល និងសេចក្តីណែនាំសម្រាប់ការអនុវត្តយន្តការជាតិបង្កើនគុណភាពសេវាសុខាភិបាលប្រចាំឆ្នាំ)។

### ៩.១.៣.២-មូលនិធិសមធម៌

គំរោងមូលនិធិសមធម៌ ត្រូវបានដំណើរការដោយថវិកាជាតិ និងដៃគូអភិវឌ្ឍ ដែលចាត់ទុកជាកម្មវិធីដ៏សំខាន់សម្រាប់វិស័យសុខាភិបាល ។ មណ្ឌលសុខភាពទាំងអស់ដែលអនុវត្តគំរោងមូលនិធិសមធម៌នេះនឹងទទួលបានការទូទាត់ថ្លៃសេវាសម្រាប់ជនក្រីក្រ (ប្រើប្រាស់ប័ណ្ណមូលនិធិសមធម៌ក្រីក្រ «Pre-ID ឬ Post-ID») គាំទ្រដោយថវិកាជាតិ និងដៃគូអភិវឌ្ឍន៍ សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ អតីតយុទ្ធជន កម្មករនិយោជិតក្រៅប្រព័ន្ធ កីឡាករ កីឡាការិនី ក្រុមប្រឹក្សាឃុំ-សង្កាត់  មន្ត្រីភូមិ និងកម្មករធាក់ស៊ីក្លូ (ប្រើប្រាស់ប័ណ្ណមូលនិធិសមធម៌ ចេញដោយ ប.ស.ស)។ល។ គាំទ្រដោយថវិកាជាតិទាំងស្រុង ដែលបានមកប្រើប្រាស់សេវា នៅមណ្ឌលសុខភាព។ ប្រាក់ដែលបានមកពីការបង់ជូនពីគំរោងមូលនិធិសមធម៌ ជាទូទៅ ត្រូវបានចាត់ទុកដូចជា ប្រាក់ចំណូលដែលបានមកពីសេវាបង់ថ្លៃដៃរ លើកលែងតែមានការណែនាំដោយឡែកពី ក្រសួងសុខាភិបាល។ ដូច្នេះ មណ្ឌលសុខភាពអាចប្រើប្រាស់ថវិកានេះ ដូចជា ប្រាក់ចំណូលដែលបានមកពីសេវាបង់ថ្លៃដៃរ ពោលគឺ៖ ៦០%ប្រើជាប្រាក់លាភការសម្រាប់លើកទឹកចិត្តបុគ្គលិក និង៤០%ប្រើសម្រាប់ចំណាយប្រតិបត្តិការ លើកកម្ពស់គុណភាពសេវា។

### ៩.១.៣.៣-ប្រាក់លើកទឹកចិត្តឆ្មប

ដើម្បីកាត់បន្ថយអត្រាមរណភាពរបស់មាតា តាមរយៈការជំរុញការសម្រាលកូននៅមូលដ្ឋានសុខាភិបាល ពិសេសមណ្ឌលសុខភាព រាជរដ្ឋាភិបាលបានសម្រេចប្រើប្រាស់ថវិកាជាតិ ដើម្បីលើកទឹកចិត្តឆ្មប ក្នុងការសម្រាលកូននៅមូលដ្ឋានសុខាភិបាល តាមរយៈប្រកាសអន្តរក្រសួង (លេខ ២៦៨ សហវ.ហក ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០៧)។ តាមរយៈប្រកាសនេះ ឆ្មបនឹងទទួលបាននូវប្រាក់លើកទឹកចិត្តចំនួន ៦០.០០០រៀល សម្រាប់ការសម្រាលកូនរស់១នៅមណ្ឌលសុខភាព និង ៤០.០០០រៀល សម្រាប់ការសម្រាលកូនរស់១នៅមន្ទីរពេទ្យ។ បច្ចុប្បន្ន ប្រាក់នេះត្រូវបានចាត់ចែង និងបញ្ចូលទៅក្នុងគណនីធនាគាររបស់ឆ្មបដោយផ្ទាល់ដូចប្រាក់បៀវត្សរ៍ដែរ។ តែទោះជាយ៉ាងណាក៏ដោយ យោងតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល (លេខ ០១៧ អបស/ម.ពចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០៧) ឆ្មបមណ្ឌលសុខភាព អាចបែងចែកប្រាក់នេះមួយផ្នែកដល់បុគ្គលិកដទៃទៀតរបស់មណ្ឌលសុខភាព និងអ្នកពាក់ព័ន្ធដទៃទៀត ដូចជា ក្រុមទ្រទ្រង់សុខភាពភូមិ ដែលបានជួយជំរុញ និងបញ្ជូនស្ត្រីមានផ្ទៃពោះអោយមកសម្រាលកូននៅមណ្ឌលសុខភាព ។

### ៩.១.៣.៤-ការធានារ៉ាប់រងសុខភាព

បច្ចុប្បន្នមានគំរោងធានារ៉ាប់រងសុខភាពមួយចំនួន បាននឹងកំពុងអនុវត្តនៅប្រទេសកម្ពុជាដូចជា៖ គំរោងធានារ៉ាប់រងសុខភាពសហគមន៍ គំរោងធានារ៉ាប់រងសុខភាពសម្រាប់កម្មករនិយោជិករបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) និងគំរោងធានារ៉ាប់រងសុខភាពឯកជន។ ដោយឡែក គំរោងធានារ៉ាប់រងសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលទើបត្រូវបានរាជរដ្ឋាភិបាលសំរេចបង្កើតឡើង នៅពេលថ្មីៗនេះ បានចាប់ផ្តើមអនុវត្ត ពីខែ មករា ឆ្នាំ២០១៨ មក (លិខិតក្រសួងសុខាភិបាល លេខ ១២៧ ស.ខល ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៧)។ គំរោងធានារ៉ាប់រងសុខភាពទាំងនេះ អាចនឹងមានកិច្ចសន្យាជាមួយស្រុកប្រតិបត្តិនិងមណ្ឌលសុខភាព ព្រមទាំងបង់ថ្លៃសេវាជូនមណ្ឌលសុខភាព ជួសសមាជិករបស់ខ្លួនទៅតាមវិធីសាស្ត្រទូទាត់ដែលមានចែងក្នុងកិច្ចសន្យា។ ប្រាក់ដែលបានមកពីការបង់ជូនពីគំរោងធានារ៉ាប់រងសុខភាពទាំងនេះ ជាទូទៅ ត្រូវបានចាត់ទុកដូចជាប្រាក់ចំណូលដែលបានមកពីសេវាបង់ថ្លៃដែរ។ ដូច្នេះ មណ្ឌលសុខភាពក៏អាចប្រើប្រាស់ថវិកានេះ ដូចជាប្រាក់ចំណូលដែលបានមកពីសេវាបង់ថ្លៃដែរ ពោលគឺ៖ ៦០%ប្រើជាប្រាក់លាភការសម្រាប់លើកទឹកចិត្តបុគ្គលិក ៣៩% ប្រើសម្រាប់ចំណាយប្រតិបត្តិការ ពិសេសសម្រាប់លើកកម្ពស់គុណភាពសេវា និង ១% បង់ចូលរតនាគារជាតិ។

## ៩.២ ភារកិច្ចសំខាន់ៗក្នុងការគ្រប់គ្រងថវិកាមណ្ឌលសុខភាព

ដើម្បីធានាអោយបាននូវប្រសិទ្ធភាព និងតម្លាភាពក្នុងការគ្រប់គ្រងថវិកាមណ្ឌលសុខភាព រាប់បញ្ចូលទាំងថវិកាជាតិផង មណ្ឌលសុខភាពត្រូវអនុវត្តនូវភារកិច្ចសំខាន់ៗដូចតទៅ៖ ត្រូវជ្រើសរើសបុគ្គលិក ១រូប ដែលមានសមត្ថភាព អាចគ្រប់គ្រងថវិកាបានប្រកបដោយតម្លាភាព (លើកលែងប្រធាន ឬ សាច់ញាតិប្រធាន) អោយធ្វើជាបេឡាធិការ ។

ការទទួលចំណូលពីអ្នកជំងឺមកពិនិត្យព្យាបាលប្រចាំថ្ងៃត្រូវមានប្រព័ន្ធទទួលប្រាក់ឱ្យបានត្រឹមត្រូវដើម្បីឱ្យមានតម្លាភាព។មណ្ឌលសុខភាពត្រូវមានកន្លែងទទួលប្រាក់រួមមួយហៅថា "បញ្ជរ" សម្រាប់ទទួលខុសត្រូវក្នុងការទទួលចំណូលពីការបង់ថ្លៃសេវាពីអ្នកប្រើប្រាស់គំរោងមូលនិធិសមធម៌និងគំរោងផ្សេងៗ។ ជៀសវាងការកាត់ប្រាក់ចំណូល នៅតាមផ្នែកទុកបែងចែកដោយឡែកការងារគ្រប់គ្រងហិរញ្ញប្បទានសុខាភិបាល។

ការគ្រប់គ្រងថវិកា និង ឯកសារត្រូវអនុវត្តទៅតាមការណែនាំរបស់រាជរដ្ឋាភិបាល តាមរយៈនាយកដ្ឋានថវិកា និង ហិរញ្ញវត្ថុរបស់ក្រសួងសុខាភិបាល មន្ទីរសុខាភិបាល និងស្រុកប្រតិបត្តិ។

ការគ្រប់គ្រងថវិកាហិរញ្ញប្បទាន និងឯកសារត្រូវគោរពទៅតាមគោលការណ៍ហិរញ្ញប្បទានរបស់ (ស្រុកប្រតិបត្តិ មន្ទីរសុខាភិបាលខេត្ត) ក្រសួងសុខាភិបាល។

ត្រូវរាយការណ៍ចំណូលចំណាយថវិកាជូនបុគ្គលិកមណ្ឌលសុខភាព និង គណកម្មការគ្រប់គ្រងមណ្ឌលសុខភាពតាមរយៈការប្រជុំប្រចាំខែ ឬតាមការស្នើសុំ និងឯកភាពពីប្រធានមណ្ឌលសុខភាព (ដើម្បីតម្លាភាព) ។

ធ្វើរបាយការណ៍ចំណូលចំណាយថវិកា (ប្រចាំត្រីមាស) ផ្ញើទៅស្រុកប្រតិបត្តិតាមពេលវេលាដែលបានកំណត់ ដោយប្រើប្រាស់ទំរង់ដែលបានផ្តល់ជូន (ដោយនាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាល)។

រាល់ឯកសារគ្រប់គ្រងថវិកាត្រូវថែរក្សាឱ្យបានល្អ តាមគោលការណ៍កំណត់ ។

# ១០. ការបង្ការការចម្លងរោគ អនាម័យ និងទឹកស្អាត

## ១០.១ ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ

ក្នុងកន្លែងថែទាំព្យាបាល ភាគច្រើនជាប្រភពនៃការចម្លងរោគដែលអាចជាបុគ្គលិក អ្នកជំងឺ ឬបរិយាកាសជុំវិញ។ អតិសុខុមប្រាណនានា (មេរោគ) អាចឆ្លងមកពីប្រភពទាំងនោះ ទៅកាន់អ្នកដទៃទៀតដោយផ្ទាល់ (តាមរយៈដៃ) ឬ ដោយប្រយោលតាមរយៈ វត្ថុ ឧបករណ៍ប្រើប្រាស់ កម្រាល) តាមរយៈខ្យល់អាកាស (ដោយការក្អក កណ្តាស់) ឬ តាមរយៈភ្នាក់ងារចម្លងផ្សេងៗ (សត្វរុយ ប៉ារ៉ាស៊ីត)។ ការចម្លងមេរោគដោយប្រយោល កើតមានឡើង ញឹកញាប់ជាងគេ ។

ប្រព័ន្ធការងារមួយត្រូវតែរៀបចំឡើងសម្រាប់កាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងរោគទៅអ្នកជំងឺនិងបុគ្គលិក។ ប្រព័ន្ធការងារនេះនឹងក្លាយជាផ្នែកមួយនៃកម្មវិធីបង្ការការឆ្លងរោគ នៅក្នុងមណ្ឌលសុខភាព។ តាមរយៈកម្មវិធីនេះ ការអនុវត្តន៍វិធានការប្រុងប្រយ័ត្នជាស្តង់ដារ ជាមួយគ្រប់អ្នកជំងឺទាំងអស់ នៅក្នុងមូលដ្ឋានសុខាភិបាល គឺតម្រូវឲ្យបុគ្គលិកសុខាភិបាល សន្មត់គ្រប់ពេលថា ឈាម និងសារធាតុផ្សេងៗពីរាងកាយរបស់អ្នកជំងឺ ទាំងអស់ជាប្រភពដែលអាចបង្ករោគដោយមិនគិតពីរោគវិនិច្ឆ័យ ឬ ស្ថានភាពនៃការ

ឆ្លងរបស់ជំងឺឡើយ ។ ការប្រុងប្រយ័ត្នជាស្តង់ដារជាវិធានការណ៍ទាក់ទងនឹងការអនុវត្តន៍ការងារប្រកប ដោយសុវត្ថិភាពដែលជារួមមាន ៧ សមាសធាតុសំខាន់ៗការប្រុងប្រយ័ត្នជាស្តង់ដាររួមមាន៖

១. អនាម័យដៃ
២. ការប្រើប្រាស់ឧបករណ៍ការពារខ្លួន (PPE)
៣. ការចាត់ចែងប្រើប្រាស់សម្ភារបរិក្ខារថែទាំអ្នកជំងឺនិងកម្រាល ដោយសមស្រប
៤. ការគ្រប់គ្រងសម្អាតបរិស្ថាន
៥. ការបង្ការរបួសដោយម្ជុលឬវត្ថុមុតស្រួច
៦. ការគ្រប់គ្រងសមស្របនៃសំណល់ពីការថែទាំសុខភាព និង
៧. អនាម័យផ្លូវដង្ហើម ។

### ១០.១.១ អនាម័យដៃ

- អនាម័យដៃគឺជាជាមធ្យោបាយសំខាន់បំផុតក្នុងការបង្ការ និងកាត់បន្ថយការឆ្លងរាលដាលនៃមេរោគនៅក្នុងបរិស្ថាន នៃមូលដ្ឋានសុខាភិបាល។ ជំងឺឆ្លងដែលជាញឹកញាប់តែងឆ្លងតាមរយៈការប៉ះពាល់ដៃ និងដៃ រួមមានជំងឺផ្តាសាយធម្មតា និងជំងឺធ្ងន់ធ្ងរជាងនេះដូចជា ជំងឺរលាកស្រោមខួរ ជំងឺរលាកថ្លើមប្រភេទអា និងប្រភេទភាគច្រើននៃជំងឺរាក ។
- ទម្លាប់លាងដៃគួរត្រូវបានលើកកម្ពស់ មិនត្រឹមតែចំពោះបុគ្គលិកសុខាភិបាលទេ ប៉ុន្តែថែមទាំងចំពោះអ្នកជំងឺ និងអ្នកថែទាំអ្នកជំងឺ ព្រមទាំងសហគមន៍ទូទៅផងដែរ ។ មណ្ឌលសុខភាពត្រូវតែមានទីកន្លែងលាងដៃសមស្រប (ទឹក និង សាប៊ូ) យ៉ាងតិចប្រាំកន្លែង សម្រាប់អ្នកផ្តល់សេវា និងអ្នកមកទទួលសេវា លាងដៃបានជាប្រចាំ ។
- នៅពេលផ្តល់សេវា ប្រសិនបើមិនប្រើទឹក និងសាប៊ូសម្រាប់ធ្វើអនាម័យដៃ គេអាចប្រើទឹកលាងដៃដែលមានជាតិអាល់កុលពី៦០-៨០% ។

ចូរចងចាំថា ទឹកលាងដៃដែលមានជាតិអាល់កុលជាស្តង់ដារ អាចប្រើបានតែក្នុងករណីដែលដៃមិនប្រឡាក់ឈាម ឬ ក្អែលកខ្វក់ប៉ុណ្ណោះ ។

- មណ្ឌលសុខភាពអាចធ្វើទឹកលាងដៃដែលមានអាល់កុលដោយខ្លួនឯងបាន (សូមមើលឧបសម្ព័ន្ធទី២ សម្រាប់ការណែនាំអំពីការផលិតទឹកលាងដៃដែលមានជាតិអាល់កុលនៃសៀវភៅណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានព្យាបាល និងថែទាំសុខភាព ឆ្នាំ២០១៧)។
- ដើម្បីលើកកម្ពស់ការអនុវត្តន៍អនាម័យដៃរបស់បុគ្គលិកមណ្ឌលសុខភាពជាប្រចាំ ទម្រង់ការអនុវត្តបច្ចេកទេស ៦ ជំហាននៃការលាងដៃក្នុងពេលសំខាន់ៗទាំងប្រាំគួរត្រូវផ្សព្វផ្សាយទូលំទូលាយតាមរយៈការបិទរូបភាពទម្រង់ការអនុវត្តន៍នៅតាមទីកន្លែងលាងដៃ ។

លើសពីនេះ បុគ្គលិក និងអ្នកថែទាំ ត្រូវអនុវត្ត "ពេលវេលាទាំងប្រាំសម្រាប់អនាម័យដៃ"។ ពេលវេលាទាំងប្រាំសម្រាប់អនាម័យដៃមាន៖

១. មុនពេលពិនិត្យឬប៉ះពាល់អ្នកជំងឺ
២. មុនពេលអនុវត្តទម្រង់ការគ្មានមេរោគ
៣. ក្រោយពេលប៉ះពាល់សារធាតុរាវ នៃសរីរាង្គ
៤. ក្រោយពិនិត្យឬប៉ះពាល់អ្នកជំងឺ
៥. ក្រោយប៉ះពាល់ឧបករណ៍ និងសម្ភារប្រើប្រាស់ជុំវិញអ្នកជំងឺនិងក្រោយពីដោះឧបករណ៍ការពារខ្លួនចេញភ្លាម។

## ១០.១.២ ការប្រើប្រាស់សំភារការពារខ្លួន

- និយមន័យ៖ ជាឧបករណ៍សំភារៈ (ក្រណាត់ ឬ សំភារៈផ្សេង) ដែលបុគ្គលិកសុខាភិបាលស្លៀកពាក់ ឬ បិទបាំង ដើម្បីការពារការប៉ះពាល់ឈាមឬសារធាតុរាវរាងកាយ ឬ គ្រោះថ្នាក់ផ្សេងទៀត នៅពេលអនុវត្តការងារ។
- ឧបករណ៍ការពារខ្លួនត្រូវតែប្រើដោយ ៖
    - ➢ បុគ្គលិកសុខាភិបាល ដែលផ្តល់ការថែទាំផ្ទាល់ដល់អ្នកជំងឺ ក្នុងស្ថានភាពដែលពួកគេអាចប៉ះពាល់ឈាម វត្ថុរាងកាយ លាមក ឬទឹករំអិល ។
    - ➢ បុគ្គលិកជំនួយ រួមមានអ្នកសម្អាត ឬ បុគ្គលិកកម្មករគ្រប់គ្រងសំណល់ ក្នុងស្ថានភាពដែលពួកគេអាចប៉ះពាល់ឈាម វត្ថុរាងកាយ លាមក ឬទឹករំអិល សំណល់ឆ្លងរោគ ។
    - ➢ បុគ្គលិកមន្ទីរពិសោធន៍ ដែលធ្វើការជាមួយវត្ថុវិភាគផ្សេងៗ ។
    - ➢ អតិថិជនមកទទួលសេវា ក្នុងស្ថានភាពដែលពួកគេត្រូវប្រឈមការចម្លងរោគ
- បុគ្គលិកសុខាភិបាលត្រូវមានជំនាញគ្រប់គ្រាន់ ស្តីពីការប្រើប្រាស់ឧបករណ៍ការពារខ្លួននិងត្រូវចេះជ្រើសរើសឧបករណ៍ការពារខ្លួន មកប្រើដោយផ្អែកលើការប្រឈមនឹងគ្រោះថ្នាក់ ។ ជាអនុសាសន៍ទូទៅ អ្នកផ្តល់សេវាសុខភាព គប្បីត្រូវធ្វើការវាយតម្លៃការប្រឈម និង របៀបឆ្លងជាមុនសិនទើបអាចជ្រើសរើសឧបករណ៍ការពារខ្លួន មកពាក់បានត្រឹមត្រូវដោយផ្អែកទៅតាម៖
    - ➢ ប្រភេទលក្ខណៈនៃទម្រង់ការ ។
    - ➢ ការប្រឈមនឹងការប៉ះពាល់ឈាម ឬ វត្ថុរាវរាងកាយ ។
    - ➢ ការប្រឈមនឹងការប៉ះជាមួយមេរោគ ។
    - ➢ ការប្រឈមនឹងប្រឡាក់ជាមួយមេរោគ។

## ១០.១.៣ ការសម្លាប់មេរោគលើឧបករណ៍ថែទាំអ្នកជំងឺ

គ្រប់ឧបករណ៍បរិក្ខារពេទ្យទាំងអស់ អាចជាប្រភេទប្រើតែម្តងហើយបោះចោលឬ អាចប្រើប្រាស់ឡើងវិញបាន ។ ឧបករណ៍ដែលសម្រាប់ប្រើតែម្តង មិនគួរប្រើវិញឡើយ ហើយគួរបោះចោលឲ្យបានត្រឹមត្រូវបន្ទាប់ពីប្រើរួច។ រាល់ឧបករណ៍ដែលអាចប្រើឡើងវិញទាំងអស់ ត្រូវឆ្លងកាត់ការស្តេរីល ឬ សម្លាប់មេរោគយ៉ាងត្រឹមត្រូវនៅចន្លោះការប្រើនីមួយៗ និងមុនពេលប្រើជាមួយអ្នកជំងឺថ្មីទៀត ។

### <u>គោលការណ៍ក្នុងការសម្លាប់មេរោគ</u>

ការសម្លាប់មេរោគ គឺជាផ្នែកមួយយ៉ាងសំខាន់ នៃការអនុវត្តន៍ការងារអនាម័យ។ ក្នុងមណ្ឌលសុខភាព មានសារធាតុសម្លាប់មេរោគជាច្រើនដែលមានលក្ខណៈខុសគ្នា។ សារធាតុសម្លាប់មេរោគដែលកាន់តែមានប្រសិទ្ធិភាពខ្លាំង ក៏ពុលខ្លាំងដែរ។ ការប្រើប្រាស់សូលុយស្យុងសម្រាប់សម្លាប់មេរោគអាចជាការសមស្របប្រសិនបើមានតុល្យភាពល្អរវាងសកម្មភាពប្រើសម្រាប់ប្រឆាំងអតិសុខុមប្រាណ និងលក្ខណៈពុលនៃផលិតផលទាំងនេះ ។

### <u>គោលការណ៍ក្នុងការស្តេរីល</u>

ការរម្ងាប់មេរោគ ពេលរួមផ្សំជាមួយនឹងការលាងសម្អាត គឺកាន់តែមានប្រសិទ្ធិភាពខ្ពស់ក្នុងការកំចាត់ចោលនូវអតិសុខុមប្រាណនានា។ ការរម្ងាប់មេរោគអាចសម្លាប់ អតិសុខុមប្រាណលើសពី ៩៩% ។

ដើម្បីកាត់បន្ថយកម្រិតឆ្លងរោគរបស់សម្ភារដែលត្រូវរម្ងាប់មេរោគ ត្រូវរម្ងាប់តែសម្ភារណាដែលបានលាងសម្អាតរួចហើយប៉ុណ្ណោះ ។ ការរម្ងាប់មេរោគ អាចសម្រេចទៅបានតាមរយៈមធ្យោបាយរូបសាស្ត្រផង និងមធ្យោបាយគីមីផង: មធ្យោបាយរូបសាស្ត្រ ត្រូវផ្អែកលើសកម្មភាពដុតកម្តៅ (ការប្រើឆ្នាំងចំហុយអូតូក្លាវដែលដុតស្ងោរដោយសម្ងួត ឬសើម) ឬ ការហាលថ្ងៃ ឬតាមរយៈការច្រោះជាដើម។ រីឯមធ្យោបាយគីមីរួមមាន ការរម្ងាប់មេរោគដោយប្រើឧស្មន័អេទីឡែនអុកស៊ីត ឬ ឧស្ម័នផ្សេងៗទៀត ការដាក់សម្ភារដែលត្រូវរម្ងាប់មេរោគក្នុងសូលុយស្យុងសម្លាប់មេរោគក្នុងប្រដាប់រម្ងាប់មេរោគ (ឧទាហរណ៍ សូលុយស្យុងគ្លុយតារាលដេអ៊ីត) ។

ជាអនុសាសន៍ទូទៅ មណ្ឌលសុខភាពត្រូវអនុវត្តឲ្យបានត្រឹមត្រូវ នូវ គោលការណ៍សម្រាប់ដំណើរការឡើងវិញឱ្យមានប្រសិទ្ធភាពនៃឧបករណ៍ និងសម្ភារបរិក្ខារដូចជា:

1) ការសម្អាត (ត្រាំក្នុងទឹកប្រសិនបើចាំបាច់ សម្អាត លាងជម្រះ និងសម្ងួត)
2) ការសម្លាប់មេរោគ (កម្រិតទាប មធ្យម និងខ្ពស់) ឬ
3) ការធ្វើស្តេរីល និង
4) ការរក្សាទុកក្រោយស្តេរីលរួច ។

ព្រមទាំងគោរពឲ្យបាននូវគោលការណ៍ ៣ សំខាន់ក្នុងការស្តេរីល គឺ ១-សម្ពាធត្រឹមត្រូវ ២-សីតុណ្ហភាពត្រឹមត្រូវ និង ៣- រយៈពេលត្រឹមត្រូវ។

(សម្រាប់ព័ត៌មានបន្ថែម សូមអានសៀវភៅណែនាំស្តីពី ការបង្ការនិងការត្រួតពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានព្យាបាលនិងថែទាំសុខភាព ឆ្នាំ២០១៧ )

## ១០.១.៤ ការសម្អាតបរិស្ថាន

### <u>គោលការណ៍ក្នុងការសម្អាត</u>

- ✓ ការសម្អាតគឺជាមធ្យោបាយមូលដ្ឋានសំខាន់បំផុតក្នុងការថែរក្សាអនាម័យឱ្យបានល្អ ក្នុងបរិវេនរបស់មណ្ឌលសុខភាព។
- ✓ អនុវត្តការលាងដៃ/អនាម័យដៃ និងពាក់ឧបករណ៍ការពារខ្លួនឱ្យបានសមស្រប (យ៉ាងហោចណាស់ ស្រោមដៃកៅស៊ូ ស្បែកជើងកវែងកៅស៊ូ ឯកសណ្ឋាន ឬអៀម។ នៅពេលមានហានិភ័យនៃការខ្ទាតប្រឡាក់ឈាមដាក់មុខ ត្រូវពាក់ម៉ាសវះ កាត់ និងឧបករណ៍ការពារភ្នែក)។
- ✓ ភាគច្រើននៃមូលដ្ឋានព្យាបាល និងថែទាំសុខភាព គឺជាផ្នែកមានហានិភ័យទាប និងគួរត្រូវបានគេសម្អាតរាល់ថ្ងៃជាមួយសូលុយស្យុងសាប៊ូ (សាប៊ូ ទឹក) ដើម្បីកំចាត់វត្ថុកខ្វក់ និងសារធាតុសរីរាង្គ និងរំលាយឬបញ្ឈប់ប្រេង ខ្លាញ់ វត្ថុផ្សេងៗដែលងាយ រលាយតាមការដុសលាង។
- ✓ ផ្នែកដែលមានហានិភ័យខ្ពស់ ដែលគេគិតថាមានភាពកខ្វក់ខ្លាំង និងភាពកខ្វក់ពីបុគ្គលិក និងអ្នកជំងឺ ផ្ទៃទាំងឡាយត្រូវសម្អាតជាមួយទឹកសាប៊ូ លាងជម្រះ និងសម្ងួត មុនពេល សម្លាប់មេរោគ [ឧ. សូលុយស្យុងសូដ្យូម ហៃប៉ូក្លរីត (ក្លរីន) 0,0៥%]។
- ✓ ការលាងសម្អាតដែលធ្វេសប្រហែស ឬលាងសើរៗ មិនត្រឹមតែគ្មានប្រសិទ្ធិភាពទេ ហើយថែមទាំងផ្តល់ផលអវិជ្ជមានថែមទៀត ដោយវាធ្វើឱ្យអតិសុខុមប្រាណទាំងនោះបែកខ្ញែក រាយប៉ាយពាសពេញផ្ទៃវត្ថុ ហើយបង្កើនឱកាសចម្លងរោគ ទៅវត្ថុផ្សេងៗទៀត។ ហេតុនេះ ការលាងសម្អាតដាច់ខាតត្រូវប្រព្រឹត្តធ្វើឱ្យបានត្រឹមត្រូវតាមស្តង់ដារច្បាស់លាស់ ។
- ✓ ប្រសិទ្ធិភាពនៃការសម្លាប់ ឬការរម្ងាប់មេរោគដែលត្រូវធ្វើបន្ទាប់ កើនឡើងដោយសារតែការលាងសម្អាតដែលបានធ្វើមុន ឬ ក្នុងពេលដំណាលគ្នា ។
- ✓ បុគ្គលិកអ្នកសម្អាតរបស់មណ្ឌលសុខភាពត្រូវមានចំណេះដឹងចាំបាច់ ផ្នែកបង្ការ និងត្រួតពិនិត្យការចម្លងរោគ ពិសេសវិធានការប្រុងប្រយ័ត្នជាស្តង់ដារ និងមានសមត្ថភាពអនុវត្តវិធានការទាំងនេះ ដើម្បីសុវត្ថិភាពការងារ ដូចជាការលាយសូលុយស្យុងក្លរីន 0.0៥ % ត្រឹមត្រូវតាមរូបមន្តជាក់លាក់ សម្រាប់ធ្វើការសម្អាតបរិស្ថាន។
- ✓ ដើម្បីបរិស្ថាននិងការងារ ល្អប្រសើរ មណ្ឌលសុខភាពត្រូវតែអនុវត្តនូវគោលការណ៍ ៥ ស គឺ ១- សម្រិតសម្រាំង ២សណ្តាប់ធ្នាប់ ៣- សោភ័ណភាព ៤- ស្តង់ដារ ៥- ស្ថេរភាព។

(សម្រាប់ពត៌មានបន្ថែម សូមអានសៀវភៅណែនាំស្តីពី ការបង្ការនិងការត្រួតពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានព្យាបាលនិងថែទាំសុខភាព ឆ្នាំ២០១៧)

### ១០.១.៥ ការបង្ការរបួសដោយម្ជុល ឬ វត្ថុមុតស្រួច

ត្រូវធានាសុវត្ថិភាពចំពោះ ការកាន់ប្រើប្រាស់ ការបោះចោលក្រោយពេលប្រើរួច ឬការសម្អាត ការរម្ងាប់មេរោគ ការសម្លាប់មេរោគលើសម្ភារមានចុងស្រួចៗ/មុត (ម្ជុលសឺរ៉ាំង ឬ ឧបករណ៍វះកាត់ផ្សេងៗ) ។

មណ្ឌលសុខភាពត្រូវមានគោលនយោបាយច្បាស់លាស់ និងពត៌មានទូលំទូលាយស្តីអំពីការអនុវត្តន៍ការងារការចាក់ថ្នាំមានសុវត្ថិភាព ជាពិសេស ការចាក់ថ្នាំបង្ការ ដែលយ៉ាងហោចណាស់ត្រូវមានទម្រង់ការច្បាស់លាស់ ដូចជា ៖

- ✓ ការប្រើប្រាស់ស្រោមដៃ ម៉ាស់ និង សំលៀកបំពាក់ឱ្យបានត្រឹមត្រូវ តាមនីតិវិធីដែលពាក់ព័ន្ធនឹងអង្គធាតុរាវសម្រាប់លាងដៃ និង សម្ភារឆ្លងរោគ ។
- ✓ ការបោះចោលប្រកបដោយសុវត្ថិភាពនូវរាល់ឧបករណ៍ដែលមុតស្រួច និង សម្ភារឆ្លងរោគទាំងអស់ (ដែលរួមបញ្ចូលនូវការប្រមាណអំពីគ្រោះថ្នាក់ នៃការគ្របម្ជុលឡើងវិញ)។
- ✓ (សម្រាប់ពត៌មានបន្ថែម សូមអាន "គោលការណ៍ចាក់ថ្នាំមានសុវត្ថិភាព នៃសៀវភៅណែនាំស្តីពីការបង្ការនិងការត្រួតពិនិត្យការចម្លងរោគ សម្រាប់មូលដ្ឋានព្យាបាលនិងថែទាំសុខភាព)
- ✓ គោលការណ៍បោះចោលម្ជុល/វត្ថុមុតស្រួចដែលបានប្រើរួចៈ
    - កុំគ្របគម្របម្ជុល/វត្ថុមុតស្រួចឱ្យសោះ។
    - បោះចោលម្ជុល និងសឺរ៉ាំង នៅក្នុងប្រអប់សុវត្ថិភាពភ្លាមៗក្រោយប្រើរួច។
    - បិទប្រអប់សុវត្ថិភាពនៅពេលប្រអប់ពេញ៣/៤។ បោះចោលប្រអប់សុវត្ថិភាពឱ្យមានសុវត្ថិភាព (ឧ. តាមរយៈឡដុតសម្រាមដែលមាន កម្តៅយ៉ាងហោចណាស់៨០០អង្សាសេ)។
    - នៅពេលមិនទាន់បោះចោល ត្រូវទុកប្រអប់សុវត្ថិភាពនៅកន្លែងដែលសមស្រប នៅកន្លែងដែលឆ្លងរោគ។

### ១០.១.៦ ការគ្រប់គ្រងសំណល់

មណ្ឌលសុខភាពបង្កើតនូវសំណល់ជាច្រើនដែលអាចបង្កឱ្យមានភាពគ្រោះថ្នាក់ដល់សុខភាព ដូចជា ការឆ្លងរោគ និង របួស ។ លើសពីនេះទៀត ការគ្រប់គ្រងកាកសំណល់មិនពេញលេញ និងមិនសមស្រប បង្កឱ្យមានផលវិបាកយ៉ាងធ្ងន់ធ្ងរចំពោះសុខភាពសាធារណៈ និងផលប៉ះពាល់យ៉ាងខ្លាំងដល់បរិស្ថានដែលនៅជុំវិញ។ គោលនយោបាយសុវត្ថិភាពចែងថា ត្រូវធានាសុវត្ថិភាពចំពោះ ការកាន់ប្រើប្រាស់ ការបោះចោលក្រោយប្រើរួចនូវសារធាតុជីវសាស្ត្រ សារធាតុគីមី និងសម្ភារមិនស្អាតផ្សេងៗទៀត ។

ជាទូទៅ សំណល់ពីសេវាថែទាំសុខភាពត្រូវបានចែកចេញជា ២ ប្រភេទធំៗ គឺ សំណល់ទូទៅ និង សំណល់វេជ្ជសាស្ត្រ ។ សំណល់ទូទៅ មានបរិមាណច្រើនប្រមាណជា ៨០% នៃសំណល់ដែលមានក្នុងមណ្ឌលសុខភាព និង ប្រមាណ២០% ជា សំណល់វេជ្ជសាស្ត្រ ។

តាមនិយមន័យ សំណល់ទូទៅ ជាសំណល់ មិនមានគ្រោះថ្នាក់ នឹង ត្រូវយកទៅបោះចោលចុងក្រោយនៅទីលានចាក់សំណល់នៅតាមសហគមន៍ ក្រៅទីតាំងមណ្ឌលសុខភាព ។ ចំណែកសំណល់

វេជ្ជសាស្ត្រជាសំណល់ មានគ្រោះថ្នាក់ និងប្រឈមហានិភ័យខ្ពស់ចំពោះ សុខភាព ហើយ ចែកចេញជា ប្រាំបួនប្រភេទ គឺ ១.សំណល់ឆ្លងរោគ ២. សំណល់សរីរាង្គកាយ ៣.សំណល់មុតស្រួច ៤. សំណល់ឱសថ ៥.សំណល់គីមី ៦.សំណល់លោហៈធ្ងន់ ៧.សំណល់មានសម្ពាធ ៨.សំណល់ពុលហៀរន និង ៩. សំណល់វិទ្យុសកម្ម ។

សំណល់វេជ្ជសាស្ត្រ ដែលផលិតចេញពីការផ្តល់សេវានៅក្នុងមណ្ឌលសុខភាព មានតែ ៤ ឬ ៥ ប្រភេទ ( ប្រភេទទី ១ ដល់ ទី ៥ ) ប៉ុណ្ណោះដែល តម្រូវការគ្រប់គ្រង និង អនុវត្តន៍ ដោយការប្រុងប្រយ័ត្ន ខ្ពស់បំផុត ដើម្បីចៀសវាងបាននូវ ហានិភ័យ ពីសំណល់គ្រោះថ្នាក់ទាំងនេះ។

មណ្ឌលសុខភាព ត្រូវគ្រប់គ្រង សំណល់វេជ្ជសាស្ត្រទាំង៥ ប្រភេទនេះ ទៅតាមគោលការណ៍ ណែនាំរបស់ក្រសួងសុខាភិបាលដោយអនុវត្ត ចាប់តាំងពី ការញែកសំណល់ ការចាត់ចែង (ការប្រមូល-ដឹកជញ្ជូន-ទុកដាក់បណ្តោះអាសន្ន ) ការធ្វើប្រព្រឹត្តកម្មនិងការបោះចោលចុងក្រោយប្រកបដោយស្មារតី ទទួលខុសត្រូវរួមចំពោះសុខភាព ពិសេស សុវត្ថិភាពការងារ។

### ១០.១.៧ ការការពារការចម្លងតាមផ្លូវដង្ហើម

អនាម័យប្រព័ន្ធដកដង្ហើម និងតិយាបទល្អក្នុងការក្អកគឺជាការប្រុងប្រយ័ត្នជាស្តង់ដារ ដែលត្រូវ អនុវត្តគ្រប់អ្នកជំងឺ ភ្ញៀវ និងបុគ្គលិកមូលដ្ឋានព្យាបាល និងថែទាំសុខភាព ដើម្បីរក្សាទឹករម្អិលនៃប្រព័ន្ធ ដកដង្ហើម (ឧ. នៅពេលក្អក កណ្តាស់...) ដើម្បីចៀសវាងការចម្លងរោគតាមប្រព័ន្ធ ដកដង្ហើម។អនាម័យ ផ្លូវដង្ហើមរួមមាន៖

- ✓ គ្របច្រមុះ និងមាត់ពេលក្អក កណ្តាស់ ដោយក្រដាស ឬម៉ាស់។
- ✓ ចោលក្រដាស និងម៉ាស់ប្រើរួចក្នុងធុង សម្រាម។
- ✓ កុំ "ខាកស្តោះ" ក្នុងបរិស្ថាន ប្រើក្រដាស ជំនួស ។
- ✓ បង្ហាញរបៀបសម្អាតដៃក្រោយប៉ះពាល់ទឹករម្អិលនៃប្រព័ន្ធដកដង្ហើម។
- ✓ ចៀសវាងចាប់ដៃនៅពេលឈឺ ប្រើវិធី "ស្វាគមន៍ជាលក្ខណៈប្រពៃណី" ។

## ១០.២ គោលការណ៍គ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាព

មណ្ឌលសុខភាពផលិតសំណល់ពីសេវាថែទាំសុខភាពដែលចែកចេញជាពីរប្រភេទធំៗ គឺ សំណល់ទូទៅ និងសំណល់វេជ្ជសាស្ត្រ ៖

**សំណល់ទូទៅ:** ជាវត្ថុសំណល់ឈប់ប្រើប្រាស់ក្នុងការិយាល័យ (ក្រដាស ថង់ប្លាស្ទិក ក្រណាត់វត្ថុ ផ្សេងៗ) ស្លឹកឈើ និង ស្មៅជាដើម។ល។ សំណល់ទូទៅជាសំណល់ ដែលមិនបង្កឲ្យមានគ្រោះថ្នាក់តាមរយៈ ការឆ្លងរោគ ការពុល និងផ្តល់គ្រោះថ្នាក់ផ្សេងៗ ទៅដល់បុគ្គលិកមណ្ឌលសុខភាព អ្នកជំងឺ និងសហគមន៍ ។

**សំណល់វេជ្ជសាស្ត្រៈ** វត្ថុសំណល់ទាំងឡាយដែលមានប្រឡាក់ឈាម ខ្ទុះ ទឹករងៃ ឬ កំទេចកំទី ថ្នាំពេទ្យ សំបកដបថ្នាំ គ្រាប់ថ្នាំដែលខូចគុណភាព។ សំណល់ទាំងនេះអាចបង្កគ្រោះថ្នាក់ ដោយការពុល និងឆ្លងរោគជាខ្លាំង ។ សំណល់វេជ្ជសាស្ត្រទាំងអស់ចេញពីមណ្ឌលសុខភាព ត្រូវគ្រប់គ្រង ឲ្យបានត្រឹមត្រូវទៅតាមគោលការណ៍ណែនាំស្តីពីការបង្ការ និង ត្រួតពិនិត្យការចម្លងរោគ និងគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងសំណល់ ពីសេវាថែទាំសុខភាព ។

## ១០.២.១ វិធីសាស្ត្រនៃការគ្រប់គ្រងសំណល់ប្រកបដោយសុវត្ថិភាព ទៅតាមប្រភេទសំណល់

មណ្ឌលសុខភាពត្រូវធ្វើការបែងចែកដោយមានធុងសំណល់ដោយឡែកសម្រាប់សំណល់ផ្សេងៗគ្នា និងដាក់ផ្លាកសញ្ញាសំគាល់ឲ្យបានត្រឹមត្រូវ។ ប្រភេទធុងនីមួយៗ សំណល់ទូទៅក្តី និង សំណល់វេជ្ជសាស្ត្រក្តី ត្រូវចាំបាច់ដាក់ឲ្យមានប្រើប្រាស់ទៅតាមសេវាដែលត្រូវផ្តល់ដោយមណ្ឌលសុខភាព និង អនុវត្តទៅតាមគោលការណ៍គ្រប់គ្រងសំណល់ត្រឹមត្រូវ ចាប់តាំងពីការញែកសំណល់ ការចាត់ចែង (ការប្រមូល ដឹកជញ្ជូន ទុកដាក់បណ្តោះអាសន្ន ) ការធ្វើប្រព្រឹត្តកម្ម និង ការបោះចោលចុងក្រោយ ។

### ១០.២.១.១ សំណល់ទូទៅ

សំណល់ទូទៅត្រូវបានចាត់ទុកជាសំណល់មិនមានគ្រោះថ្នាក់ និងត្រូវបានយកទៅបោះចោលចុងក្រោយនៅទីលានចាក់សំណល់ក្រៅទីតាំងមណ្ឌលសុខភាព ឬ នៅតាមសហគមន៍។ មណ្ឌលសុខភាពគួរត្រូវកំណត់យកគោលការណ៍៣ យ៉ាង ដើម្បីមិនឲ្យសំណល់ទូទៅនេះ មានបរិមាណច្រើនបាន ដូចជាៈ

១. ការកាត់បន្ថយអប្បបរមាសំណល់
២. ការប្រើប្រាស់សំណល់ឡើងវិញ
៣. ការកែច្នៃសំណល់

ធុងពណ៌បៃតង និង ថង់ប្លាស្ទិច ពណ៌បៃតង ឬ ខ្មៅ ត្រូវកំណត់សម្រាប់ញែកសំណល់ទូទៅ ៖

- ✓ ញែកសំណល់ដាក់ក្នុងធុង និងថង់ដែលធានាថាមិនលេចហូរវត្ថុរាវចេញក្រៅ ។
- ✓ ដាក់ធុងសំណល់នៅកន្លែងសមគួរ ដើម្បីសម្រួលដល់ការប្រើប្រាស់ ។
- ✓ ណែនាំ និងជំរុញឱ្យអ្នកជំងឺចេះញែកសំណល់ទៅតាមប្រភេទធុងសំណល់ ។
- ✓ ពាក់ស្រោមដៃក្រាស់ៗ នៅពេលប៉ះពាល់ និង ដឹកជញ្ជូនសំណល់ ។
- ✓ ប្រមូលធុងសំណល់រៀងរាល់ថ្ងៃ ឬក៏ច្រើនដង ប្រសិនបើចាំបាច់ យកទៅដុតក្នុងរណ្តៅ ឬកប់ក្នុងទីតាំងមណ្ឌលសុខភាព (បើគ្មានសេវាដឹកជញ្ជូនទៅចាក់ចោលនៅទីលានចាក់សំណល់ក្រៅទីតាំងមណ្ឌលសុខភាព) ។
- ✓ បើសំណល់ត្រូវដុតចោល ចូរញែកសំណល់ដែលមិនអាចដុតបាន ដោយឡែកៗ ពីគ្នា ដូចជា ដប និង កំប៉ុងដែលអាចផ្ទុះបង្កគ្រោះថ្នាក់ និងខូចខាតដល់ឡ។

- ✓ បោសសម្អាតភ្លាមៗ នូវអ្វីដែលកំពុប ។
- ✓ ដុសលាងធុងសំណល់ទាំងអស់ ដោយសាប៊ូ និង ទឹករៀងរាល់ថ្ងៃ ។
- ✓ លាងដៃក្រោយពេលប៉ះនឹងធុងសំណល់ ។

## ១០.២.១.២ សំណល់វេជ្ជសាស្ត្រ

ជាសំណល់មានគ្រោះថ្នាក់ និង ប្រឈមហានិភ័យខ្ពស់ ចំពោះបុគ្គលិកមណ្ឌលសុខភាព និង អតិថិជនមកទទួលសេវា ។ នៅតាមមណ្ឌលសុខភាព សំណល់វេជ្ជសាស្ត្រ ៥ ប្រភេទ ប្រទះឃើញ មានច្រើន ក្នុងសេវាថែទាំសុខភាព ៖

១. **សំណល់ឆ្លងរោគ ៖** សំណល់រឹង ឬ រាវ ដូចជា បង់រុំរបួសដែលប្រើរួច ស្បៃ ឬឧបករណ៍ដែល ប្រឡាក់ឈាម ខ្ទុះ លាមក ឬ វត្ថុរាវដទៃទៀត ។ សំណល់ឆ្លងរោគនេះ មានបរិមាណតិចតួចបំផុត ប្រសិនបើចេះញែកបានត្រឹមត្រូវ ចាប់តាំងពីប្រភពសំណល់ដំបូង ។ ធុង និង ថង់ប្លាស្ទិក ដាក់សំណល់ឆ្លងរោគ មាន ពណ៌លឿង ព្រមទាំងមាន LOGO គ្រោះថ្នាក់ពណ៌ខ្មៅ ជាសញ្ញាសម្គាល់។

២. **សំណល់សរីរាង្គកាយ ៖** សំណល់សុក  កម្ទេចកម្ទីដុំឈាម ក្រោយពេលសម្រាល ឬ ដុំសាច់ ក្រោយវះកាត់តូច ។ សំណល់សរីរាង្គកាយនេះ មានបរិមាណមធ្យម នៅផ្នែកសម្ភពរបស់មណ្ឌល សុខភាព ។  ធុង និង ថង់ប្លាស្ទិក ដាក់សំណល់សរីរាង្គកាយ មាន ពណ៌លឿង ព្រមទាំងមាន LOGO គ្រោះថ្នាក់ពណ៌ក្រហម  ជាសញ្ញាសម្គាល់។

៣. **សំណល់មុតស្រួច ៖** សំណល់មុតស្រួច ដូចជា ម្ជុលនិងសឺរ៉ាំង កាំបិតវះកាត់មុខពីរ ឬ កាំបិត វះកាត់តូច  វ៉ាក់ស៊ីណូស្ទីល...។ សំណល់មុតស្រួចនេះមានបរិមាណប្រហែលជា ១% នៃសំណល់វេជ្ជសាស្ត្រ។ សេវាផ្តល់ការចាក់ថ្នាំបង្ការ នៅមណ្ឌលសុខភាព ជាប្រភពចម្បងនៃ សំណល់មុតស្រួច ។ សំណល់មុតស្រួច ត្រូវញែកដាក់ក្នុង  ប្រអប់សុវត្ថិភាព ពណ៌លឿង ព្រមទាំងមាន LOGO គ្រោះថ្នាក់ពណ៌ខ្មៅ ជាសញ្ញាសម្គាល់ ។

៤. **សំណល់ឱសថ ៖** សំណល់ឱសថ ថ្នាំគ្រាប់ ថ្នាំចាក់ ហួសអាយុកាលប្រើប្រាស់ និង ខូច គុណភាព។ សំណល់ឱសថ ថ្នាំគ្រាប់ និងសំបកកេស ក្នុងបរិមាណតិចតួច អាចដុតកម្ទេចចោល ជាមួយសំណល់ទូទៅ ក្នុងទីតាំងមណ្ឌលសុខភាព ។ ដោយឡែក ដបថ្នាំ អំពូលថ្នាំ ក្រោយ ប្រើប្រាស់រួចត្រូវដាក់ក្នុងធុង និង ថង់ប្លាស្ទិក សំណល់ឱសថ មាន ពណ៌ត្នោត ព្រមទាំងមាន LOGO គ្រោះថ្នាក់ក្បាលខ្មោច  ជាសញ្ញាសម្គាល់។ សំណល់ឱសថ ជាដបថ្នាំ ឬ អំពូលថ្នាំ គួរត្រូវ ដាក់កប់ក្នុងរណ្តៅ រួមជាមួយសំណល់ផេះដែលប្រមូលក្រោយពីធ្វើប្រព្រឹត្តកម្មជាមួយឡដុត សំណល់ឆ្លងរោគ ដែលមានក្នុងមណ្ឌលសុខភាព ។

៥. **សំណល់គីមី ៖** សំណល់គីមី ដូចជា សំណល់ប្រតិករមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ...។ សំណល់គីមី នេះមានបរិមាណតិចតួចបំផុត ហើយមានតែនៅក្នុងមណ្ឌលសុខភាព ដែលដំណើរការសកម្មភាព មន្ទីរពិសោធន៍តែប៉ុណ្ណោះ ។  គោលការណ៍គ្រប់គ្រងសំណល់គីមីនេះគឺដូចគ្នា ឬប្រហាក់ប្រហែល នឹងសំណល់ឱសថដែរ ។

ក្នុងដំណើរការប្រតិបត្តិ នូវសំណល់វេជ្ជសាស្ត្រទាំង៥ ខាងលើ នេះ តាំងពីការញែក ការចាត់ចែង (ការប្រមូល ដឹកជញ្ជូន ទុកដាក់បណ្តោះអាសន្ន) ការធ្វើប្រព្រឹត្តកម្ម និង បោះចោលចុងក្រោយ បុគ្គលិកមណ្ឌលសុខភាពទាំងអស់ ត្រូវអនុវត្ត ការប្រុងប្រយត្ន័ជាស្តង់ដារ នៃការបង្ការ ការត្រួតពិនិត្យការចម្លងរោគ ដើម្បីសុវត្ថិភាពជាចម្បង ។

ចំពោះសំណល់ឆ្លងរោគ រឹង និងរាវ ឈាម ទឹកនោម លាមក ខ្ទុះ កំហាក ទឹក វត្ថុរាវ ជាដើម បុគ្គលិកអនាម័យ គួរត្រូវបានបណ្តុះបណ្តាលនូវចំណេះដឹង សម្រាប់អនុវត្តការងារដូចជា៖

- ✓ ពាក់ស្រោមដៃក្រាស់ៗ នៅពេលប៉ះ នឹងដឹកជញ្ជូនសំណល់ ។
- ✓ ចាក់ដោយផ្ទាល់ និង ដោយប្រុងប្រយ័ត្ន នូវឈាម ទឹកនោម ឬវត្ថុរាវដទៃទៀត ចូលទៅក្នុងបង្គន់ ឬលូទឹកសាធារណៈ ជៀសវាងនូវការកំពុប ខ្ទាត់ខ្ទាយ ។
- ✓ លាងជម្រះបង្គន់ដោយទឹក ដោយប្រុងប្រយ័ត្ន និង ហ្មត់ចត់ ។
- ✓ ធ្វើការសម្លាប់មេរោគលើធុងដែលប្រលាក់ ដោយសូលុយស្យុងអូសាវែល 0,0៥%។
- ✓ ធ្វើការសម្លាប់មេរោគ និង បោសសម្អាតភ្លាមៗ នូវអ្វីដែលកំពុប ដោយប្រើ សូលុយស្យុង អូសាវែល 0,0៥% ឬក៏ សារធាតុគីមីសម្លាប់មេរោគ ផ្សេងទៀត។
- ✓ ជុសលាងភ្លាមៗនូវអ្វីដែលកំពុប ដោយប្រើសូលុយស្យុងអូសាវែល (0,0៥%)។
- ✓ ធុងសម្រាមទាំងអស់ ត្រូវសម្លាប់មេរោគ រៀងរាល់ថ្ងៃ ដោយប្រើសូលុយស្យុងអូសា វែល (0,0៥%) បន្ទាប់មកជុសលាងដោយប្រើសាប៊ូ និង ទឹក។
- ✓ កុំកាច់ ពត់ម្ជុល ឬវត្ថុមុតស្រួចដទៃទៀតមុនពេលបោះចោល ។
- ✓ ដាក់ប្រអប់សុវត្ថិភាពនៅកន្លែងដែលគេប្រើប្រាស់។ ឧទាហរណ៍: ប្រអប់សុវត្ថិភាពគួរតែដាក់ក្នុងកន្លែងផ្តល់សេវាចាក់ថ្នាំបង្ការនៅនឹងកន្លែងមណ្ឌលសុខភាព ឬ ដាក់តាមខ្លួននៅពេលដើរចាក់ថ្នាំបង្ការតាមសហគមន៍ ( នៅពេលចុះធ្វើយុទ្ធនាការ )។
- ✓ នៅពេលពេញ 3/4 បិទនូវសន្ទះអណ្តាតប្រអប់ ដើម្បីជៀសវាងការកំពុប រឺ ជ្រុះសឺរ៉ាំងចេញ ។
- ✓ ប្រអប់សុវត្ថិភាពដែលផ្ទុកដោយវត្ថុមុតស្រួចត្រូវយកទៅដុតនៅឡដែលមានសមត្ថភាព (កម្តៅ ចាប់ពី ៨00 អង្សា អាចរំលាយម្ជុលបាន) ឬ បើចាំបាច់ ( មិនមានឡ )អាចដុតក្នុងឡធម្មតានៅមណ្ឌលសុខភាពដូចដុតសំណល់ឆ្លងរោគដែរតែត្រូវប្រមូល
- ✓ សំណល់កម្ទេចផេះយកទៅកប់ចោលក្នុងរណ្តៅចុងក្រោយប្រកបដោយសុវត្ថិភាព ។
- ✓ ត្រូវប្រមូលសំណល់រៀងរាល់ថ្ងៃ ឬក៏ច្រើនដងប្រសិនបើចាំបាច់ ពិសេសសំណល់ឆ្លងរោគ និងដឹកជញ្ជូនយកទៅដុត ឲ្យបានឆាប់រហ័ស ( តិចជាង ២៤ ម៉ោង )។
- ✓ ត្រូវរៀបចំឲ្យមាន ស្តុកបណ្តោះអាសន្នមួយ ដែលធានា សុវត្ថិភាព និងសន្តិសុខ និង ប្រើប្រាស់ នៅពេលជួបឧបសគ្គ កកស្ទះសំណល់វេជ្ជសាស្ត្រ ដោយយកទៅធ្វើប្រព្រឹត្តកម្ម ឬ ដុត មិនទាន់ ។

### ១០.២.២ គុណប្រយោជន៍នៃការគ្រប់គ្រងសំណល់ប្រកបដោយសុវត្ថិភាព

- ✓ ទប់ស្កាត់នូវការរាលដាលការឆ្លងរោគ ការពុល ដល់បុគ្គលិកសុខាភិបាល និង អតិថិជនមកទទួលសេវា ដែលប៉ះពាល់នឹងសំណល់ និង ដល់សហគមន៍នៅក្នុងមូលដ្ឋាន។
- ✓ ការពារអ្នកប៉ះពាល់ជាមួយសំណល់ពីការថែទាំសុខភាព នូវការរងរបួសដោយគ្រោះថ្នាក់ដោយធានានូវ « **សុវត្ថិភាពជាចម្បង**»។
- ✓ ទប់ស្កាត់នៃសំណល់ចំហ ដែលអាចក្លាយទៅជាដី ដែលអាចចម្លងមេរោគតាមរយៈរុយ សត្វល្អិតផ្សេងៗ និងកណ្ដុរដែលអាចនាំមកជំងឺផ្ដល់គ្រោះថ្នាក់ដល់ជីវិត ។
- ✓ ផ្ដល់នូវបរិយាកាសនិងបរិស្ថានស្អាតល្អ (សំណល់ដែលមិនប្រមូលផ្ដុំ បង្កនូវក្លិនស្អុយ និង អាចបង្កនូវគ្រោះថ្នាក់ដោយអគ្គីភ័យផង)។

## ១០.៣ ទឹកស្អាត និងអនាម័យ

ទឹកស្អាត និងអនាម័យមានសារៈសំខាន់សម្រាប់ការព្យាបាល និងការបង្ការជំងឺផ្សេងៗ។ នៅមណ្ឌលសុខភាព ការផ្ដល់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់អាចធានាសុវត្ថិភាព គុណភាពសេវាថែទាំសុខភាព ជួយកាត់បន្ថយគ្រោះថ្នាក់នៃការចម្លងរោគ និងជួយដល់ក្រុមងាយរងគ្រោះ ដែលរួមមាន កុមារ ស្ត្រីមានផ្ទៃពោះ ចាស់ជរា និងជនពិការ។

### ១០.៣.១ ប្រព័ន្ធផ្គត់ផ្គង់ទឹកសមស្រប

មណ្ឌលសុខភាពត្រូវមានទឹកចេញពីប្រភពទឹកកែលម្អ (ប្រភពទឹកដែលមានការការពារការបំពុល ឬកង្វក់ពីខាងក្រៅ ជាពិសេសការបំពុលពីលាមកមនុស្ស ឬសត្វ)សម្រាប់ប្រើប្រាស់ជាប្រចាំ ។

- **ប្រភពទឹកកែលម្អៈ** ទឹកប្រព័ន្ធទុយោ ទឹកអណ្ដូងស្នប់ ទឹកអណ្ដូងលូការពារ ទឹកផុសធម្មជាតិដែលមានការការពារ ទឹកភ្លៀង ឬទឹកទិញពីប្រភពទឹកកែលម្អទាំងនេះ ។
- **បរិមាណទឹក និងការស្តុកទុកៈ** ត្រូវមានទឹកគ្រប់គ្រាន់ និងគ្រប់ពេលសម្រាប់ប្រើប្រាស់ និងផឹក ។ ទឹកត្រូវស្តុកអោយមានសុវត្ថិភាពក្នុងធុង ឬអាងដែលមានចំណុះយ៉ាងហោចណាស់ ១០០០លីត្រ អាចផ្គត់ផ្គង់គ្រប់គ្រាន់ពេញមួយថ្ងៃ និងមានគម្របការពារពីសារធាតុកខ្វក់ផ្សេងៗ។ ប្រសិនបើធុង ឬអាងស្តុកទឹកមានភ្ជាប់ជាមួយប្រព័ន្ធត្រងទឹកភ្លៀង ត្រូវមានប្រព័ន្ធបង្ហូរជំបូង សម្រាប់លាងសម្អាតសារធាតុកខ្វក់។
- **គុណភាពទឹកផឹកៈ** ត្រូវផ្ដល់ទឹកផឹកគ្រប់គ្រាន់ សម្រាប់បុគ្គលិក អ្នកជំងឺ និងអ្នកថែទាំអ្នកជំងឺ ដែលមានគុណភាពត្រឹមត្រូវស្របតាមស្តង់ដាគុណភាពទឹកផឹកជាតិ។ ធុងដាក់ទឹកសម្រាប់ផឹក ត្រូវដាក់នៅកន្លែងមានអនាម័យត្រឹមត្រូវ និងមានបិទផ្លាកសម្គាល់ ច្បាស់លាស់ ។
- **គុណភាពទឹកប្រើប្រាស់ផ្សេងៈ** ទឹកសម្រាប់ការប្រើប្រាស់ផ្សេងៗដូចជា សម្រាប់លាងសម្អាតធ្វើអនាម័យខ្លួនប្រាណ បោកគក់ និងអនាម័យផ្សេងៗ គឺជាទឹកដែលយកមកពីប្រភពទឹកកែលម្អ ដែលមានគុណភាពត្រឹមត្រូវ ស្របតាមស្តង់ដាគុណភាពទឹកផឹកជាតិ។

## ១០.៣.២ បង្គន់អនាម័យ

មណ្ឌលសុខភាពត្រូវមានបង្គន់អនាម័យកែលម្អ (ជាបង្គន់ចុចទឹក ឬ បង្គន់ចាក់ទឹក ដែលដំណើរការល្អ អាចប្រើបាន ហើយមានលក្ខណៈឯកជន និងបង្កលក្ខណៈងាយស្រួល) សម្រាប់បុគ្គលិក អ្នកជំងឺ និងអ្នកថែទាំអ្នកជំងឺ ប្រើប្រាស់  និងមានការគ្រប់គ្រងលាមកបានត្រឹមត្រូវ ដូចខាងក្រោមៈ

- មានបង្គន់មួយសម្រាប់ស្ត្រី ដែលមានឧបករណ៍ទុកដាក់សំឡី  អនាម័យ ។
- មានបង្គន់មួយសម្រាប់បុរស
- មានបង្គន់មួយដែលមានឧបករណ៍ជួយសម្រួលដល់ស្ត្រីមានផ្ទៃពោះ ជនពិការ កុមារ និងមនុស្សចាស់ (មានជម្រាលនៅច្រកចូល ផ្ទៃរាបស្មើ ទ្វារមានទំហំយ៉ាងតិច ០.៩ម៉ែត្រ បើកចូលក្នុង មានផ្ទាក់ដៃសមស្របនៅក្បែរចានបង្គន់)។
- បង្គន់អនាម័យត្រូវសង់ចំងាយ ១៥-២៥ ម៉ែត្រពីប្រភពទឹកដើម្បីការពារការបំពុលប្រភពទឹក។
- បង្គន់អនាម័យត្រូវភ្ជាប់ទៅនឹងប្រព័ន្ធលូ  ឬស្តុកក្នុងលូ និងបូមសម្អាតពេលពេញ ឬដាក់លូថ្មីបន្ថែមស្របតាមគោលការណ៍អនាម័យ និងកាកសំណល់។
- មណ្ឌលសុខភាពត្រូវដាក់កម្មវិធីថែទាំ (រួមទាំងផែនការគ្រប់គ្រងសំណល់លាមក) និងការលាងសម្អាតប្រចាំថ្ងៃក្នុងផែនការរបស់មណ្ឌល ដើម្បីធានាថាបង្គន់ស្អាត និងដំណើរការគ្រប់ពេល។

## ១០.៣.៣ កន្លែងងូតទឹក

មណ្ឌលសុខភាពត្រូវមានកន្លែងងូតទឹកក្នុងបន្ទប់បង្គន់ ឬ នៅកន្លែងដោយឡែកសម្រាប់ ទាំងបុគ្គលិក និងអ្នកជំងឺ អនុវត្តអនាម័យខ្លួនប្រាណ។ គួរមានកន្លែងអង្គុយងូតទឹក (ឬកៅអី) នៅក្នុងកន្លែងងូតទឹកដើម្បីជួយសម្រួលដល់អ្នកពិបាកក្នុងការឈរ។

## ១០.៣.៤ កន្លែងលាងសម្អាតដៃ

មណ្ឌលសុខភាពត្រូវមានកន្លែងលាងដៃ ដំណើរការល្អ (ភ្ជាប់ជាមួយប្រព័ន្ធបង្ហូរទឹក) មានរ៉ូប៊ីណេ សាប៊ូ (ឬ អាល់កុល) និងទឹកជាចាំបាច់ ក្នុងបន្ទប់សម្រាល កន្លែងពិនិត្យ-ព្យាបាលជំងឺផ្សេងៗ និងកន្លែងបង្គន់អនាម័យ។ បុគ្គលិកមណ្ឌលអាចយកអាល់កុលសម្រាប់សម្អាតដៃ តាមខ្លួនបាន នៅគ្រប់កន្លែងពិនិត្យ-ព្យាបាលជំងឺ ដែលអាចជួយសម្រួលដល់ការសម្អាតដៃបានគ្រប់ពេល។

# ១១-ការគ្រប់គ្រង ការផ្គត់ផ្គង់ឱសថ បរិក្ខារពេទ្យ

## ១១.១ ការចែកចាយឱសថនៅផ្នែកឱសថស្ថាន

គឺជាភារកិច្ចដ៏សំខាន់សម្រាប់បុគ្គលិកចែកចាយឱសថ នៅតាមឱសថស្ថាននៃមណ្ឌលសុខភាព ក្នុងការចែកចាយ វេចខ្ចប់ និងពន្យល់ណែនាំអំពីរបៀបប្រើប្រាស់ឱសថជូនអ្នកជំងឺ ព្រោះថាមន្ត្រីចែកចាយឱសថជាមន្ត្រីសុខាភិបាលចុងក្រោយគេបង្អស់ ក្នុងការចូលរួមចំណែកធ្វើឲ្យអ្នកជំងឺបានជាសះស្បើយ ឬមានសុខភាពល្អប្រសើរ ឬមួយអាចប្រឈមនឹងផលវិបាកផ្នែកសុខភាព។ កត្តាដូចបានរៀបរាប់ទាំងនេះហើយដែលតម្រូវឲ្យមន្ត្រីចែកចាយឱសថត្រូវទទួលការបណ្តុះ បណ្តាលគ្រប់គ្រាន់លើ ការគ្រប់គ្រងការចែកចាយ ការវេចខ្ចប់ និងពន្យល់ណែនាំអំពីរបៀបប្រើប្រាស់ ឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាល ជូនអ្នកជំងឺឲ្យបានត្រឹមត្រូវងាយយល់ និងចងចាំ។ ការបណ្តុះបណ្តាលត្រូវរៀបចំដោយនាយកដ្ឋានឱសថ ចំណីអាហារ និងការិយាល័យសុវត្ថិភាពចំណីអាហារ ឱសថ រាជធានី/ខេត្ត និងឱសថការីប្រធានឃ្លាំងស្រុកប្រតិបត្តិ ដោយប្រើគម្រោងមេរៀនដែលបានរៀបចំរួចស្រេចហើយ។ សូមអានសេចក្តីណែនាំស្តីអំពីវិធីគ្រប់គ្រងសេវាផ្គត់ផ្គង់ឱសថ បរិក្ខារពេទ្យ សម្រាប់មណ្ឌលសុខភាពឆ្នាំ២០០៨ (ជំពូក២) គោលការណ៍ណែនាំស្តីពីការរៀបចំទុកដាក់ ការទទួល ការចែកចាយ និងការអប់រំអ្នកជំងឺ (ទំព័រទី១៥ ដល់១៨)។

## ១១.២ ការគ្រប់គ្រងឯកសារ និងបញ្ជីសារពើភ័ណ្ឌ

គឺជាភារកិច្ចដ៏សំខាន់មួយទៀត របស់បុគ្គលិកគ្រប់គ្រងឱសថ បរិក្ខារពេទ្យ និង ផលិតផលសុខាភិបាលនៅតាមឱសថស្ថាននៃមណ្ឌលសុខភាព ក្នុងគោលបំណងទទួលបាននូវលទ្ធផលល្អប្រសើរលើការគ្រប់គ្រងឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាល នៅតាមឱសថស្ថាននៃមណ្ឌលសុខភាពរបស់ខ្លួន ដើម្បីធានាឲ្យប្រាកដថា៖

ការបំពេញឯកសារគ្រប់គ្រងឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាលនិងជាពិសេស សលាកប័ត្រឃ្លាំងរបស់លោកអ្នក ពិតជាបានធ្វើដោយត្រឹមត្រូវនិងទាន់ពេលវេលា។

ការរៀបចំទុកដាក់ឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាលតាមគោលការណ៍ណែនាំ ឧទាហរណ៍ តាមតួអក្សរធំខាងដើម តាមកំរឹត និងប្រភេទ តាមកម្មវិធីជាតិ និងតាមក្បួន FEFO និងFIFO (FEFO=First Expiry First Out និង FIFO=First In First Out) ព្រមទាំងគោលការណ៍ និងលក្ខខណ្ឌផ្សេងៗទៀត

សូមអានសេចក្តីណែនាំស្តីអំពីវិធីគ្រប់គ្រងសេវាផ្គត់ផ្គង់ឱសថបរិក្ខារពេទ្យសម្រាប់មណ្ឌលសុខភាព ឆ្នាំ២០០៨ (ជំពូក២), គោលកាណ៍ណែនាំស្តីពីការរៀបចំទុកដាក់ ការទទួល ការចែកចាយ និងការអប់រំអ្នកជំងឺ (ទំព័រទី៨ដល់១៣)។

ការគ្រប់គ្រងស្តុកពិតជាទទួលបានលទ្ធផលល្អត្រឹមត្រូវ ក្រោយពេលធ្វើសារពើភ័ណ្ឌរួច (មានន័យថាចំនួនពិតដែលបានត្រួតពិនិត្យ ស្មើនឹងចំនួនដែលបានកត់ត្រាទុកក្នុងខ្ទង់តុល្យការនៃសលាកបត្រឃ្លាំង)។

ការសិក្សាចំនួនចេញប្រើប្រាស់ជាមធ្យមប្រចាំខែនូវបរិមាណឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាល (AMC=Average Monthly Consumption)។

ស្ថានភាពស្តុកឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាលក្នុងឱសថស្ថានមានស្តុកសមស្របសម្រាប់ប្រើប្រាស់មុនថ្ងៃការផ្គត់ផ្គង់ថ្មីមកដល់ ឧទាហរណ៍ករណីស្ថានភាពស្តុក កំពុងឈានទៅរកការដាច់ស្តុក មុនដាច់ស្តុកលោកអ្នកត្រូវធ្វើការស្នើសុំ ឬបញ្ជាទិញបន្ថែម។

ការបំពេញរបាយការណ៍ចំណូលចំណាយ និងស្នើសុំឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាលតាមរូបមន្ត និងពេលវេលាដែលបានកំណត់ដោយក្រសួងសុខាភិបាល។

សូមអានសេចក្តីណែនាំស្តីអំពី វិធីគ្រប់គ្រងសេវាផ្គត់ផ្គង់ឱសថបរិក្ខារពេទ្យសម្រាប់ មណ្ឌលសុខភាព ឆ្នាំ២០០៨ (ជំពូក៤) និង គោលការណ៍ណែនាំស្តីពីការធ្វើសារពើភ័ណ្ឌ ការពិនិត្យស្ថានភាពស្តុក និងការស្នើសុំឱសថបរិក្ខារពេទ្យ (ទំព័រទី៣៨ដល់៤៩)។

## ១១.៣ ឱសថសារវន្ត និងការផ្គត់ផ្គង់

### ១១.៣.១ ឱសថសារវន្ត

ឱសថសារវន្តគឺជាឱសថទាំងឡាយណា ដែលបំពេញឲ្យតម្រូវការចាំបាច់ផ្នែកសុខភាពរបស់ប្រជាជនភាគច្រើន និងអាចរកបាននៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង (ឱសថដែលមានគុណភាពគម្រូ និងត្រូវបានទទួលស្គាល់ដោយក្រសួងសុខាភិបាល)។ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចងក្រង និងបោះពុម្ពបញ្ជីឱសថសារវន្តលើកទីមួយនៅឆ្នាំ១៩៨៦ និងលើកទី៨ នាឆ្នាំ២០១៥ ក្នុងនោះមានឱសថសម្រាប់លេបចំនួន៥១មុខ ឱសថដែលមានតម្រូវការពិសេសចំនួន ១២មុខ (ជាទូទៅឱសថដែលកម្មវិធីមានតម្រូវការពិសេសនឹងមានការបណ្តុះបណ្តាលត្រឹមត្រូវ) សម្រាប់ឱសថចាក់មានចំនួន ៤មុខ ឱសថដែលមានតម្រូវការពិសេសចំនួន១៣មុខ សេរ៉ូមចំនួន០៧មុខ និងសេរ៉ូមដែលមានតម្រូវការពិសេសចំនួន ០១មុខ ឱសថសម្រាប់លាបខាងក្រៅមានចំនួន១០មុខ ឱសថសម្រាប់កម្មវិធីភ្នែកមានចំនួន ០១មុខ ឱសថសម្រាប់កម្មវិធីកំចាត់រោគរបេងមានចំនួន០៧មុខ ឱសថមានតម្រូវការពិសេសចំនួន០១មុខ ឃ្លង់០៤មុខ ឱសថប្រយុទ្ធនឹងជំងឺគ្រុនចាញ់មានចំនួន ១០មុខ ឱសថមានតម្រូវការពិសេសចំនួន០៦មុខ និងកម្មវិធីពន្យារកំណើតមានចំនួន០៨មុខ និងកម្មវិធីតម្រូវការពិសេសជាច្រើនមុខទៀត (សូមអានបញ្ជីឱសថសារវន្តដែលបានបោះពុម្ពលើកទី៨នៅឆ្នាំ២០១៥ ជំពូកMPA ទំព័រទី១ ដល់ទី១៦)។

### ១១.៣.២ ការផ្គត់ផ្គង់

ជាទូទៅឃ្លាំងស្រុកប្រតិបត្តិត្រូវធ្វើការផ្គត់ផ្គង់ឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាលទៅឲ្យមណ្ឌលសុខភាពតាមពីរករណីៈសម្រាប់មណ្ឌលសុខភាព ត្រូវទទួលការផ្គត់ផ្គង់ប្រចាំខែ។ ជាបន្ត មណ្ឌល

សុខភាពធ្វើការចែកចាយឱសថប្រចាំថ្ងៃទៅឲ្យអ្នកជំងឺផ្នែកពិគ្រោះជំងឺក្រៅ ចែកចាយទៅឲ្យប៉ុស្តិ៍សុខភាព និងសកម្មភាពការផ្តល់សេវានៅមូលដ្ឋាន ទៅតាមផែនការបានកំណត់របស់មណ្ឌលសុខភាព ព្រមទាំងចែកចាយទៅឲ្យក្រុមការងារស្ម័គ្រចិត្តតាមភូមិ។ សូមអានសេចក្តីណែនាំ ស្តីអំពីវិធីគ្រប់គ្រងសេវាផ្គត់ផ្គង់ឱសថបរិក្ខារពេទ្យ សម្រាប់មណ្ឌលសុខភាព ឆ្នាំ២០០៨ (ជំពូក១) ប្រពន្ធ័ផ្គត់ផ្គង់ និងតួនាទីនិងភារកិច្ចលើការគ្រប់គ្រងឱសថបរិក្ខារពេទ្យ (ទំព័រទី២ដល់ទី៧)។

## ១១.៣.៣ បញ្ជីបរិក្ខារសារវន្ត

ដូចបញ្ជីឱសថសារវន្តដែរ បញ្ជីបរិក្ខារសារវន្តក៏ត្រូវបានចងក្រង និងបោះពុម្ពលើកទីមួយនៅឆ្នាំ ១៩៨៦ និងលើកទី៨ នៅឆ្នាំ២០១៥ និងមានចំនួនជាច្រើនសម្រាប់ប្រើប្រាស់នៅតាមមណ្ឌលសុខភាព សូមអានបញ្ជីឱសថសារវន្ត ដែលបានបោះពុម្ពលើកទី៨នៅឆ្នាំ២០១៥ (ជំពូកMPA) បញ្ជីបរិក្ខារសារវន្ត (ទំព័រទី១ ដល់ទី១៣)។

## ១១.៣.៤ ប្រព័ន្ធត្រជាក់

មណ្ឌលសុខភាពត្រូវមានប្រព័ន្ធត្រជាក់សមស្រប ដែលក្នុងនោះរាប់បញ្ចូលទាំងការធ្វើផែនការ ការប្រើប្រាស់ ការរក្សា និងគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌផង។

សម្ភារដែលបានផ្តល់ដោយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ សម្រាប់ថែរក្សាវ៉ាក់សាំងរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការនៅថ្នាក់មណ្ឌលសុខភាពរួមមាន៖

- ទូទឹកកកសម្រាប់ថែរក្សាវ៉ាក់សាំង៖ ទូថែរក្សាវ៉ាក់សាំងនៅថ្នាក់មណ្ឌលសុខភាពមានច្រើនប្រភេទដូចជា RCW 50EG, MK 074, VLS 064 ។ល។
- ក្លាស្សេ៖ ក្លាស្សេខ្នាតធំ ចំណុះ២៤លីត្រ សម្រាប់ថែរក្សាវ៉ាក់សាំងរយៈពេលមិនលើសពី ១សប្តាហ៍ នៅពេលដែលទូទឹកកកមានខូច ឬ ពេលលាងសម្អាតទូទឹកកក។ ក្លាស្សេខ្នាតតូច ចំណុះ១៤លីត្រ សម្រាប់ដឹកជញ្ជូនវ៉ាក់សាំង។
- ធុងវ៉ាក់សាំង៖ ធុងវ៉ាក់សាំងសម្រាប់ទុកដាក់វ៉ាក់សាំងនៅពេលបើកទិវាផ្តល់ថ្នាំបង្ការ នៅមណ្ឌលសុខភាព (Fixed site vaccination session) និង ទិវាផ្តល់ថ្នាំបង្ការនៅតាមភូមិ (Outreach vaccination session)។

## ១១.៣.៥ និរន្តភាព

ជាទូទៅគ្រប់អង្គភាពធំនិងតូចៗ ត្រូវបានទទួលការយកចិត្តទុកដាក់ ពីក្រសួងសុខាភិបាលក្នុងការពង្រឹងផែនការសកម្មភាពនិងថវិកា ក្នុងគោលបំណងឲ្យអង្គភាពនៅក្រោមឱវាទទាំងអស់មាននិរន្តភាព ក្នុងការដំណើរការនិងទទួលបាន នូវលទ្ធផលល្អប្រសើរទៅ តាមទិសដៅដែលបានកំណត់ជារៀងរាល់ឆ្នាំ។ លើសពីនេះ គឺទាមទារឲ្យមានការបណ្តុះបណ្តាលមន្ត្រីសុខាភិបាល គ្រប់លំដាប់ថ្នាក់អំពីចំណេះដឹង ក្នុងការចូលរួមធ្វើផែនការសកម្មភាព និងថវិកាដែលជាតម្រូវការផ្ទាល់ខ្លួនរបស់អង្គភាពនិមួយៗ។ ជាឧទាហរណ៍

តម្រូវការធនធានមនុស្ស សម្រាប់ឱសថស្ថានរបស់មណ្ឌលសុខភាពយ៉ាងតិចពីររូប ដែលក្នុងនោះមួយរូបជាអ្នកជំនួយការ និងដែលមានការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងចែកចាយឱសថជូនអ្នកជំងឺ។ បុគ្គលិកត្រូវមានចំណេះដឹង ក្នុងការប៉ាន់ប្រមាណតម្រូវការឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាលប្រចាំខែ ប្រចាំត្រីមាស ឬប្រចាំឆ្នាំ។ ត្រូវមានផែនការតម្រូវការថវិកាប្រចាំខែ ប្រចាំត្រីមាស ឬប្រចាំឆ្នាំ សម្រាប់បេសកកម្មឡើងមកស្នើសុំឱសថបន្ថែម ឬការងារគ្រប់គ្រងឱសថ បរិក្ខារពេទ្យ និង ផលិតផលសុខាភិបាល ការងារជួសជុលនិងសុវត្ថិភាពឱសថស្ថាន និងការងារចាំបាច់នានារបស់មន្ត្រីឱសថស្ថាន។

## ១១.៣.៦ ឱសថស្ថាន

ជាទូទៅឱសថស្ថាននៅថ្នាក់មណ្ឌលសុខភាព ត្រូវបានក្រសួងកំណត់ទំហំទៅតាមគម្រូនៃការសាងសង់មណ្ឌលសុខភាព ដែលចាប់ពីឆ្នាំ១៩៩៥ (ផែនការមេឆ្នាំ១៩៩៤ ដល់ឆ្នាំ១៩៩៦) មានចំនួនរហូតដល់ទៅបីគម្រូ។ ក្នុងនោះដែរ ឱសថស្ថាននៅថ្នាក់មណ្ឌលសុខភាពត្រូវមានយ៉ាងហោចណាស់ធ្នើសម្រាប់រៀបចំទុកដាក់ឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាលយ៉ាងតិចចំនួនពីរ តុនិងកៅអីការិយាល័យមួយយ៉ាងតិច ថាសសម្រាប់រាប់គ្រាប់ឱសថធ្វើពីដែកអីណុកមួយ ទូទុកដាក់ឯកសារមួយ ព្រមទាំងសម្ភារសំខាន់ៗមួយចំនួនទៀត។

<u>**តួនាទីរបស់មន្ត្រីឱសថស្ថាននៅមណ្ឌលសុខភាព**</u>

ការរៀបចំទុកដាក់ឱសថ បរិក្ខារពេទ្យ និងផលិតផលសុខាភិបាលតាមគោលការណ៍ណែនាំ ឧទាហរណ៍ តាមតួអក្សរធំខាងដើម តាមកំរឹត និងប្រភេទ តាមកម្មវិធីជាតិ និងតាមក្បួន FEFO និង FIFO (FEFO=First Expiry First Out និង FIFO=First In First Out ) និងមានលក្ខខណ្ឌជាច្រើនទៀត សូមអានសេចក្តីណែនាំស្តីអំពីវិធីគ្រប់គ្រងសេវាផ្គត់ផ្គង់ឱសថបរិក្ខារពេទ្យសម្រាប់មណ្ឌលសុខភាព ឆ្នាំ២០០៨ (ជំពូក២) គោលកាណ៍ណែនាំស្តីពីការរៀបចំទុកដាក់ ការទទួល ការចែកចាយ និងការអប់រំអ្នកជំងឺ (ទំព័រទី៨ដល់១៣)។

# ១២-សេវាមន្ទីរពិសោធន៍

## ១២.១ កញ្ចប់សេវាមន្ទីរពិសោធន៍ នៅមណ្ឌលសុខភាព

សេវាមន្ទីរពិសោធន៍មាននាទីសំខាន់ណាស់ ក្នុងការជួយគាំទ្រការធ្វើរោគវិនិច្ឆ័យរបស់គ្រូពេទ្យ ឬមន្ត្រីសុខាភិបាល ក្នុងការធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺ ជូនអតិថិជន។ នៅមណ្ឌលសុខភាពភាគច្រើន នៃបុគ្គលិកពុំមែនជាអ្នកបច្ចេកទេសមន្ទីរពិសោធន៍ឡើយ ដូចនេះគួរមានការវិភាគអមវេជ្ជសាស្ត្រសាមញ្ញៗ ដើម្បីជួយសម្រួលលើការកំណត់រកបញ្ហាសុខភាព ឬធ្វើរោគវិនិច្ឆ័យនៅថ្នាក់មណ្ឌលសុខភាព។ ការវិភាគសំខាន់ៗ ដែលត្រូវមាននៅថ្នាក់មណ្ឌលសុខភាពរួមមាន៖

ការរកជំងឺគ្រុនចាញ់ដោយប្រើ Rapid test និងរៀបចំកញ្ចក់ឈាមដើម្បីពិនិត្យដោយគោរពតាមស្តង់ដារប្រតិបត្តិរបស់កម្មវិធីជាតិប្រយុទ្ធជំងឺគ្រុនចាញ់។ចំពោះមណ្ឌលសុខភាពពុំមានលទ្ធភាពវិភាគកញ្ចក់ឈាមត្រូវបញ្ជូនទៅមន្ទីរពិសោធន៍នៃមន្ទីរពេទ្យបង្អែក ដើម្បីធ្វើការបញ្ជាក់អោយកាន់តែច្បាស់។

ការពិនិត្យកំហាករកមេរោគរបេងដោយមីក្រូទស្សន៍ដោយគោរពតាមស្តង់ដារប្រតិបត្តិរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺរបេង ហង់សិន។ ក្នុងករណីគ្មានមីក្រូទស្សន៍ត្រូវវេចខ្ចប់ ឬធ្វើភ្នាសកំហាករួចបញ្ជូនទៅពិនិត្យនៅមន្ទីរពិសោធន៍ នៅមណ្ឌលសុខភាពមួយចំនួន និងនៅមន្ទីរពេទ្យបង្អែកដើម្បីពិនិត្យដោយមីក្រូទស្សន៍ ឬម៉ាស៊ីនជីនអ៊ិចស្ពើត ។

ការធ្វើតេស្តរកមេរោគអេដស៍(HIV Test ) ដោយស្ម័គ្រចិត្តនិងមានការយល់ព្រមពីសាមីជន ផ្ទាល់។ រាល់ការធ្វើតេស្តត្រូវផ្តល់ប្រឹក្សាមុនពេល ធ្វើតេស្តនិងក្រោយធ្វើតេស្ត។ បែបបទនៃ ការធ្វើតេស្តឈាមរកមេរោគអេដស៍ ត្រូវអនុលោមពិធីសាររបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ការវិភាគទឹកនោមដោយប្រើDipstick សម្រាប់រក Protein, pH, Glucose ក្នុងករណីជំងឺទឹកនោមផ្អែមត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែក។

ការពិនិត្យឈាមដោយប្រើ (Rapid Test ជា Hemoglobin Color scale) ដើម្បីរកកំហាប់អេម៉ូក្លូប៊ីនដើម្បីកំណត់រកកម្រិតភាពស្លេកស្លាំងសម្រាប់ធ្វើការព្យាបាលឬបញ្ជូន។

ការធ្វើតេស្តរកវត្តមាននៃការមានផ្ទៃពោះ ដោយប្រើឌីបស្ទីក (Dipstick)

ការធ្វើតេស្តរកជាតិស្ករក្នុងឈាម(glucose) ដោយប្រើ(glucose meter) សម្រាប់ស្រាវជ្រាវរកជំងឺទឹកនោមផ្អែម ។

## ១២.២ សុវត្ថិភាពមន្ទីរពិសោធន៍

### ១២.២.១ ការចាត់ចែងសារធាតុចម្លងរោគដោយសុវត្ថិភាព

ធាតុផ្សំសំខាន់បំផុតមួយនៃការងារប្រកបដោយសុវត្ថិភាពជាមួយគ្រោះថ្នាក់ជីវសាស្រ្ត គឺការប្រកាន់ខ្ជាប់ទៅនឹងការអនុវត្ត និងបច្ចេកទេសអតិសុខុមជីវសាស្រ្តល្អ។ បុគ្គលិកដែលធ្វើការជាមួយភ្នាក់ងារចម្លងរោគ ឬសារធាតុដែលអាចចម្លងរោគ ត្រូវតែយល់ដឹងពីមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតឡើង និងត្រូវតែទទួលការបណ្តុះបណ្តាលនិងមានសមត្ថភាព នៅក្នុងការអនុវត្តការងារត្រឹមត្រូវដើម្បីចាត់ចែងគ្រោះថ្នាក់ ជីវសាស្រ្តប្រកបដោយសុវត្ថិភាព។ ការអនុវត្តទាំងនេះរួមមាន៖

#### <u>សុវត្ថិភាពផ្ទាល់ខ្លួន</u>

កុំហូប ផឹក លាបម្សៅ ស្ករកៅស៊ូ ឬពាក់កុងតាក់លែន ឬដក់បារីនៅក្នុងមន្ទីរពិសោធន៍ និងត្រូវប្រកាន់ខ្ជាប់នូវមុខងារសុវត្ថិភាពមន្ទីរពិសោធន៍។

ជៀសវាងការយកដៃទៅប៉ះមាត់ ឬយកដៃទៅប៉ះភ្នែកនៅក្នុងមន្ទីរពិសោធន៍ ក្នុងករណីប្រតិបត្តិ ។

ជានិច្ចជាកាល ត្រូវលាងដៃ មុន និងពេលចប់ការងារមុនពេលចេញពីមន្ទីរពិសោធន៍។

ពេលប្រតិបត្តិការក្នុងមន្ទីរពិសោធន៍ តម្រូវពាក់ (ម្ជូក ម៉ាស់ វ៉ែនតា អាវប្លូ ស្រោមដៃ ស្បែកជើងឃ្លុំមុខ គ្របម្រាមជើងឲ្យបានសមស្រប )។

ត្រូវដោះ សម្ភារប្រើប្រាស់ឲ្យបានត្រឹមត្រូវ តាមនិតិប្រតិបត្តិមន្ទីរពិសោធន៍ មុនពេលចាកចេញ ដូចជា (ម្ជូក ម៉ាស់ វ៉ែនតា អាវប្លូ ស្រោមដៃ ស្បែកជើងឃ្លុំមុខ)ជាដើម។

ស្រោមដៃត្រូវដោះចោលក្នុងធុងសំរាមឆ្លងរោគ

ត្រូវប្រុងប្រយ័ត្ននៅពេលធ្វើការជាមួយវត្ថុមុតស្រួច។

មិនត្រូវគ្របឡើងវិញនូវម្ជុលដែលប្រើរួចហើយ ឬលេងម្ជុលនឹងដៃឡើយ។

រៀបចំផែនការជាមុនសម្រាប់ឆ្លើយតបនឹងគ្រោះថ្នាក់ ការកំពុប និងរបួស(First Aid kit)។

## សុវត្ថិភាពបរិស្ថាន

មន្ទីរពិសោធន៍ត្រូវមានបិទស្លាកសុវត្ថិភាពឲ្យបានសមស្រប និងមិនឲ្យកូនក្មេង ឬស្ត្រីមានផ្ទៃពោះ ចូលក្នុងមន្ទីរពិសោធន៍ដោយគ្មានការអនុញ្ញាត

ត្រូវបោះចោលម្ជុល និងវត្ថុមុតស្រួចផ្សេងទៀត ក្នុងធុងឬប្រអប់ដែលមិនមុត (ធុងឬប្រអប់ដាក់ "វត្ថុមុតស្រួច") ប្រអប់សុវត្ថិភាព។

ជានិច្ចជាកាលត្រូវប្រើបំពង់ពីប៉ែតជ័រ(Pipette Pasteur)។

បិទស្លាកសញ្ញាគ្រោះថ្នាក់លើធុង កំប៉ុង ប្រអប់និងឧបករណ៍ទាំងអស់ដែលផ្ទុកសារធាតុគ្រោះថ្នាក់ ជីវសាស្ត្រ ដោយប្រើសញ្ញាគ្រោះថ្នាក់ជីវសាស្ត្រសកល (Universal Biohazard Symbol)។

រក្សាទុកសារធាតុគ្រោះថ្នាក់ជីវសាស្ត្រទាំងអស់ឲ្យបានត្រឹមត្រូវនៅក្នុងធុង កំប៉ុង ប្រអប់ដែលមានស្លាក សម្គាល់ច្បាស់លាស់ និងបិទជិត។

រំងាប់មេរោគលើផ្ទៃការងារ នៅពេលចប់ការងារ និងបន្ទាប់ពីមានកំពុប(Alcohol 70%)។

បោះចោលសំណល់វត្ថុវិភាគឲ្យបានត្រឹមត្រូវក្នុងធុងសំរាមឆ្លងរោគ។

តម្រង់ទិសដល់បុគ្គលិកថ្មី(New staff induction) មុននឹងអនុញ្ញាតឲ្យពួកគេធ្វើការដោយឯករាជ្យ ជាមួយសារធាតុគ្រោះថ្នាក់ជីវសាស្ត្រ។

ចាត់ចែងសារធាតុគ្រោះថ្នាក់ជីវសាស្ត្រទាំងអស់ ដូចជាភ្នាក់ងារចម្លងរោគដែរ។

ត្រូវមានឃីតសម្រាប់គ្រប់គ្រងការកំពុបសមស្រប ឬឧបករណ៍រំងាប់មេរោគផ្សេងទៀត។

រាយការណ៍អំពីគ្រោះថ្នាក់ទាំងអស់ដល់ប្រធានរបស់អ្នក។

(សូមអានសេចក្តីលម្អិតបន្ថែម នៅក្នុងជំពូកទី ១០)។

### ១២.២.២ ការដាក់សញ្ញាសម្គាល់សំណាក Specimen labelling and logging

ចុះឈ្មោះក្នុងបញ្ជីកត់ត្រាសម្រាប់មន្ទីរពិសោធន៍ផ្នែកជំងឺគ្រុនចាញ់ របេង ។ល។
ស្រង់វត្ថុវិភាគ និងសរសេរថ្ងៃខែឆ្នាំ ឈ្មោះឬលេខកូដអ្នកជំងឺលើសំណាក និងប័ណ្ណបញ្ជូន។
ការដាក់លេខកូដរបស់វត្ថុវិភាគត្រូវមាន ឆ្នាំ ខែ ថ្ងៃ និងលេខកូដ ឧទាហរណ៍ 2016072600

### ១២.២.៣ បែបបទសម្រាប់ការវិភាគ Instruction for lab tests

គ្រប់ការវិភាគតេស្តត្រូវអនុវត្តក្នុងបន្ទប់ពិសោធន៍ ដោយគោរពតាមនិយាមប្រតិបត្តិស្តង់ដារ ដែលកម្មវិធីជាតិនិមួយៗបានផ្តល់ជូន និងបានធ្វើការបណ្តុះបណ្តាលរួចហើយ។

### ១២.២.៤ ការស្រង់យកសំណាកនិងការដឹកជញ្ជូនសំណាក

រាល់ការស្រង់យកវត្ថុវិភាគត្រូវអនុវត្ត តាមនិតិប្រតិបត្តិគម្រូរបស់កម្មវិធីជាតិនីមួយៗ
គ្រប់វត្ថុវិភាគដែលត្រូវបញ្ជូនទៅមន្ទីរពិសោធន៍បង្អែក ត្រូវអនុវត្តន៍ទៅតាមនិយាមប្រតិបត្តិស្តង់ដារ (Standard operation procedure) និងគោលការណ៍ណែនាំរបស់ថ្នាក់ជាតិ។

## ១២.៣ ការថែរក្សានិរន្តរភាពឧបករណ៍បរិក្ខារពេទ្យ Medical Equipment maintenance

គ្រប់ឧបករណ៍មន្ទីរពិសោធន៍ ដែលមាននៅក្នុងបញ្ជីសំណុំសកម្មភាពអប្បបរមា (MPA) ត្រូវរក្សាទុកគ្រប់ឯកសារជាប់ទាក់ទង (សៀវភៅណែនាំពីការប្រើប្រាស់តំឡើងឧបករណ៍ និងជួសជុល)
គ្រប់ឧបករណ៍ទាំងអស់ត្រូវមាននិយាមប្រតិបត្តិស្តង់ដារ (Standard operation procedure) សម្រាប់ប្រើប្រាស់ និងឯកសារជំនួយ (Job aid)
មានកាលវិភាគច្បាស់លាស់ជាក់លាក់ ក្នុងការថែទាំបង្ការ(ប្រចាំថ្ងៃ ប្រចាំខែ ប្រចាំត្រីមាស)

## ១៣-ធានាគុណភាព

គ្រប់មណ្ឌលសុខភាព ត្រូវផ្តល់សេវាថែទាំសុខភាព ប្រកបដោយគុណភាពជូនប្រជាពលរដ្ឋ។ គុណភាពនេះគឺត្រូវសង្កត់លើ ***ការផ្តោតលើអតិថិជន សុវត្ថិភាព ប្រសិទ្ធភាព ប្រសិទ្ធផល សមធម៌*** ព្រមទាំងមាន ***ភាពខ្ជាប់ខ្ជួន*** ស្របតាមខ្លឹមសារ គោលនយោបាយជាតិ ស្តីពីគុណភាព និងសុវត្ថិភាពក្នុងវិស័យសុខាភិបាល (ក្រសួងសុខាភិបាល ២១ ខែសីហា ២០១៧) ។ ខ្លឹមសារគោលនយោបាយជាមគ្គុទេសក៍ទាំងនេះអាចសម្រេចទៅបានដោយផ្អែកលើកត្តាសំខាន់ៗរួមមានការរៀបចំបញ្ញាបនូវវប្បធម៌លើកកម្ពស់គុណភាព ការប្រតិបត្តិនូវយន្តការលើកកម្ពស់គុណភាព និងការប្រកាន់ខ្ជាប់នូវកម្មវិធីលើកកំពស់គុណភាពជាគោលការណ៍ចំបង ព្រមទាំងមានការវាយតម្លៃតាមគោលការណ៍ និងទៀងទាត់តាមកាលកំណត់ ។

## ១.ការរៀបចំបញ្ញាបន្ទូវវប្បធម៌លើកកម្ពស់គុណភាព

- ការបំពេញភារកិច្ចជាក្រុមដើម្បីធានានូវវត្តមានបុគ្គលិកសុខាភិបាលជាប្រចាំនៅក្នុងមូលដ្ឋានសុខាភិបាល ២៤ម៉ោង/សប្តាហ៍។
- ការប្រកាន់ខ្ជាប់ខ្ជួននូវសីលធម៌វិជ្ជាជីវៈ និងឥរិយាបទល្អជាមួយការទទួលខុសត្រូវខ្ពស់ក្នុងការផ្តល់សេវាសុខាភិបាលដែលមានគុណភាពជូនអតិថិជន។
- ការគ្រប់គ្រង និងចាត់ចែងធនធានឲ្យមានប្រសិទ្ធភាព។

## ២.ការប្រតិបត្តិនូវយន្តការលើកកម្ពស់គុណភាព

- អនុវត្តតាមនិយាមគុណភាពសេវាសុខាភិបាលដែលមានដូចនៅក្នុង៖ គោលនយោបាយជាតិស្តីពីគុណភាព និងសុវត្ថិភាពក្នុងវិស័យសុខាភិបាល ផែនការមេស្តីពីការលើកកម្ពស់គុណភាពសេវាសុខាភិបាល (ក្រសួងសុខាភិបាល ២១ ខែសីហា ២០១៧) សេចក្តីណែនាំប្រតិបត្តិ និងគ្លីនិក សម្រាប់មណ្ឌលសុខភាព។
- និយាមគុណភាពសេវាសុខាភិបាលត្រូវរក្សាទុកក្នុងបណ្ណាល័យសម្រាប់ងាយស្រួលដល់បុគ្គលិកសុខាភិបាលរៀនសូត្រ ផ្សព្វផ្សាយបន្ត ពិសេសគុណភាពនៃចំណេះដឹងរបស់បុគ្គលិក និងការធ្វើបច្ចុប្បន្នភាព។
- ការវាយតម្លៃខ្លួនឯងដើម្បីត្រៀមខ្លួនជាស្រេចសម្រាប់ការវាយតម្លៃដោយក្រុមការងារវាយតម្លៃថ្នាក់ស្រុកប្រតិបត្តិ ថ្នាក់មន្ទីរសុខាភិបាល និងការវាយតម្លៃពីស្ថាប័នខាងក្រៅសម្រាប់ការផ្ទៀងផ្ទាត់។
- ចូលរួមយ៉ាងសកម្មក្នុងការហ្វឹកហ្វឺន ហាត់រៀនសូត្របន្ថែមជាមួយក្រុមអភិបាល ក្រុមគ្រប់គ្រង របស់ថ្នាក់ស្រុកប្រតិបត្តិ មន្ទីរសុខាភិបាល និងកម្មវិធីជាតិនានា។
- បំពេញ និងរៀបចំឯកសារ អ្នកជំងឺឲ្យបានត្រឹមត្រូវទៅតាមគោលការណ៍ណែនាំការគ្រប់គ្រង និងឧបករណ៍វាយតម្លៃគុណភាពសុខាភិបាល ។
- គោរពគោលការណ៍ សិទ្ធិអតិថិជន និងការពេញចិត្ត ពេញថ្លើមរបស់អតិថិជន។
- ចូលរួមសហការជាមួយក្រុមសម្របសម្រួលជំនាញនានារួមមាន៖ ផ្នែកសម្ភព ផ្នែកជំងឺកុមារ និងផ្នែកពាក់ព័ន្ធដទៃទៀត ដើម្បីពង្រឹងជំនាញ បច្ចេកទេសគ្លីនិក ពង្រឹងប្រព័ន្ធបញ្ជូន មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ។

## ៣.ការប្រកាន់ខ្ជាប់នូវកម្មវិធីលើកកំពស់គុណភាព ជាគោលការណ៍ចំបង

គោលការណ៍ចំបងនៃការលើកកំពស់គុណភាពរួមមាន៖ សុវត្ថិភាព ប្រសិទ្ធភាព ប្រសិទ្ធផល ទាន់ពេលវេលា សមធម៌ និងនិរន្តភាព។

# ១៤-ឧបសម្ព័ន្ធ

១៤.១ បញ្ជីឈ្មោះមូលដ្ឋានសុខាភិបាលសារធារណៈ ឆ្នាំ២០១៨

១៤.២ បញ្ជីកត់ត្រាផ្នែកពិគ្រោះជំងឺក្រៅសម្រាប់មណ្ឌលសុខភាព

១៤.៣ បញ្ជីកត់ត្រាផ្នែកពិនិត្យផ្ទៃពោះ

១៤.៤ បញ្ជីកត់ត្រាការសម្រាលកូនសម្រាប់មណ្ឌលសុខភាព

១៤.៥ បញ្ជីកត់ត្រាការថែទាំក្រោយសម្រាល

១៤.៦ បញ្ជីសម្រង់អតិថិជនពន្យារកំណើត

១៤.៧ ទម្រង់ពិគ្រោះនិងព្យាបាលជំងឺ (សេវាគាំពារមាតានិងទារក)

១៤.៨ ទម្រង់ពិគ្រោះនិងព្យាបាលជំងឺ (ជំងឺទូទៅនិងកុមារ)

១៤.៩ លិខិតបញ្ជូនអ្នកជំងឺ

១៤.១០ លិខិតបញ្ជូនទារក

១៤.១១ លិខិតបញ្ជូនអ្នកជំងឺរបេង

១៤.១២ របាយការណ៍ថែទាំអ្នកជំងឺ(លើរថយន្តគិលានសង្គ្រោះ)

១៤.១៣ តួនាទី ការទទួលខុសត្រូវរួម និងកញ្ចប់សេវារបស់ប៉ុស្តិ៍សុខភាពពន្ធនាគារ

## ១៤.១ បញ្ជីឈ្មោះមូលដ្ឋានសុខាភិបាលសាធារណៈ ឆ្នាំ២០១៨

| លរ | ខេត្ត/រាជធានី/ មន្ទីរពេទ្យជាតិ | ស្រុកប្រតិបត្តិ | ឈ្មោះមូលដ្ឋានសុខាភិបាល | ប្រភេទ | កម្រិត |
|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | មង្គលបូរី | 10101. មន្ទីរពេទ្យបង្អែក សេរីសោភ័ណ_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ២ | បន្ទាយមានជ័យ | មង្គលបូរី | 10102. ម្កាក់_HC | មណ្ឌលសុខភាព | MPA |
| ៣ | បន្ទាយមានជ័យ | មង្គលបូរី | 10104. អូរអំបិល_HC | មណ្ឌលសុខភាព | MPA |
| ៤ | បន្ទាយមានជ័យ | មង្គលបូរី | 10105. ទឹកថ្លា_HC | មណ្ឌលសុខភាព | MPA |
| ៥ | បន្ទាយមានជ័យ | មង្គលបូរី | 10106. កំពង់ស្វាយ_HC | មណ្ឌលសុខភាព | MPA |
| ៦ | បន្ទាយមានជ័យ | មង្គលបូរី | 10107. ភ្នៀត_HC | មណ្ឌលសុខភាព | MPA |
| ៧ | បន្ទាយមានជ័យ | មង្គលបូរី | 10109. ឬស្សីក្រោក ១_HC | មណ្ឌលសុខភាព | MPA |
| ៨ | បន្ទាយមានជ័យ | មង្គលបូរី | 10110. ឬស្សីក្រោក ២_HC | មណ្ឌលសុខភាព | MPA |
| ៩ | បន្ទាយមានជ័យ | មង្គលបូរី | 10111. សឿ_HC | មណ្ឌលសុខភាព | MPA |
| ១០ | បន្ទាយមានជ័យ | មង្គលបូរី | 10112. ចំណោម_HC | មណ្ឌលសុខភាព | MPA |
| ១១ | បន្ទាយមានជ័យ | មង្គលបូរី | 10113. បត់ត្រង់_HC | មណ្ឌលសុខភាព | MPA |
| ១២ | បន្ទាយមានជ័យ | មង្គលបូរី | 10114. អូរប្រាសាទ_HC | មណ្ឌលសុខភាព | MPA |
| ១៣ | បន្ទាយមានជ័យ | មង្គលបូរី | 10115. បន្ទាយនាង_HC | មណ្ឌលសុខភាព | MPA |
| ១៤ | បន្ទាយមានជ័យ | មង្គលបូរី | 10116. ស្រះរាំង_HC | មណ្ឌលសុខភាព | MPA |
| ១៥ | បន្ទាយមានជ័យ | មង្គលបូរី | 10117. សំបួរ_HC | មណ្ឌលសុខភាព | MPA |
| ១៦ | បន្ទាយមានជ័យ | មង្គលបូរី | 10118. គយម៉ែង_HC | មណ្ឌលសុខភាព | MPA |
| ១៧ | បន្ទាយមានជ័យ | មង្គលបូរី | 10119. ភ្នំតូច_HC | មណ្ឌលសុខភាព | MPA |
| ១៨ | បន្ទាយមានជ័យ | មង្គលបូរី | 10120. គោកបាល្ល័ង_HC | មណ្ឌលសុខភាព | MPA |
| ១៩ | បន្ទាយមានជ័យ | មង្គលបូរី | 10123. រហាត់ទឹក_HC | មណ្ឌលសុខភាព | MPA |
| ២០ | បន្ទាយមានជ័យ | មង្គលបូរី | 10124. មន្ទីរពេទ្យខេត្តមិត្តភាព កម្ពុជាជប៉ុន_P | មន្ទីពេទ្យបង្អែកខេត្ត | CPA3 |
| ២១ | បន្ទាយមានជ័យ | មង្គលបូរី | 10125. តាឡំ_HC | មណ្ឌលសុខភាព | MPA |
| ២២ | បន្ទាយមានជ័យ | មង្គលបូរី | 10127. ព្រះពន្លា_HC | មណ្ឌលសុខភាព | MPA |
| ២៣ | បន្ទាយមានជ័យ | មង្គលបូរី | 10128. កោះពងសត្វ_HC | មណ្ឌលសុខភាព | MPA |
| ២៤ | បន្ទាយមានជ័យ | មង្គលបូរី | 10129. កំពង់ស្វាយ ២_HC | មណ្ឌលសុខភាព | MPA |
| ២៥ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10201. មន្ទីរពេទ្យបង្អែក ប៉ោយប៉ែត_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA2 |
| ២៦ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10202. ប៉ោយប៉ែត ១_HC | មណ្ឌលសុខភាព | MPA |
| ២៧ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10203. អូរឬស្សី_HC | មណ្ឌលសុខភាព | MPA |
| ២៨ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10204. សូភី_HC | មណ្ឌលសុខភាព | MPA |
| ២៩ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10205. និមិត្ត_HC | មណ្ឌលសុខភាព | MPA |
| ៣០ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10206. កូប_HCB | មណ្ឌលសុខភាពមានគ្រែ | CPA+MPA |
| ៣១ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10207. អូរបីជាន់_HC | មណ្ឌលសុខភាព | MPA |
| ៣២ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10208. សិង្ហ_HC | មណ្ឌលសុខភាព | MPA |

| | | | | | |
|---|---|---|---|---|---|
| ៣៣ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10209. ម៉ាឡៃ_HCB | មណ្ឌលសុខភាពមានគ្រែ | CPA+MPA |
| ៣៤ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10210. បល្ល័ង្គ_HC | មណ្ឌលសុខភាព | MPA |
| ៣៥ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10211. ប៉ោយប៉ែត ២_HC | មណ្ឌលសុខភាព | MPA |
| ៣៦ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10212. ទួលពង្រ_HC | មណ្ឌលសុខភាព | MPA |
| ៣៧ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10218. សិលាខ្មែរ_HC | មណ្ឌលសុខភាព | MPA |
| ៣៨ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10219. សំរោង_HC | មណ្ឌលសុខភាព | MPA |
| ៣៩ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10220. បឹងបេង_HC | មណ្ឌលសុខភាព | MPA |
| ៤០ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10221. អូរស្រឡៅ_HC | មណ្ឌលសុខភាព | MPA |
| ៤១ | បន្ទាយមានជ័យ | ប៉ោយប៉ែត | 10222. អូរសំព័រ_HC | មណ្ឌលសុខភាព | MPA |
| ៤២ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10103. បុស្សរ៉ូ_HC | មណ្ឌលសុខភាព | MPA |
| ៤៣ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10301. មន្ទីរពេទ្យបង្អែក ព្រះនេត្រព្រះ_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ៤៤ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10302. ឈ្នូរមានជ័យ_HC | មណ្ឌលសុខភាព | MPA |
| ៤៥ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10303. ព្រះនេត្រព្រះ_HC | មណ្ឌលសុខភាព | MPA |
| ៤៦ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10304. រហាល_HC | មណ្ឌលសុខភាព | MPA |
| ៤៧ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10305. ភ្នំលៀប_HC | មណ្ឌលសុខភាព | MPA |
| ៤៨ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10306. ទឹកជោរ_HC | មណ្ឌលសុខភាព | MPA |
| ៤៩ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10307. ផប់វារី_HC | មណ្ឌលសុខភាព | MPA |
| ៥០ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10308. ប្រាសាទ_HC | មណ្ឌលសុខភាព | MPA |
| ៥១ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10309. ស្រះជីក_HCB | មណ្ឌលសុខភាពមានគ្រែ | CPA+MPA |
| ៥២ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10310. ប៉ោយចារ_HC | មណ្ឌលសុខភាព | MPA |
| ៥៣ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10311. ភ្នំដី_HC | មណ្ឌលសុខភាព | MPA |
| ៥៤ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10312. ពន្លៃ_HC | មណ្ឌលសុខភាព | MPA |
| ៥៥ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10313. ណាំតៅ_HC | មណ្ឌលសុខភាព | MPA |
| ៥៦ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10319. ទានកាំ_HC | មណ្ឌលសុខភាព | MPA |
| ៥៧ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 10320. ស្ពានស្រែង_HC | មណ្ឌលសុខភាព | MPA |
| ៥៨ | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | 1031202. មន្ទីរពេទ្យបង្អែក ភ្នំស្រុក_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ៥៩ | បន្ទាយមានជ័យ | ថ្មពួក | 10401. មន្ទីរពេទ្យបង្អែក ថ្មពួក_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA2 |
| ៦០ | បន្ទាយមានជ័យ | ថ្មពួក | 10402. គម្រូ_HC | មណ្ឌលសុខភាព | MPA |
| ៦១ | បន្ទាយមានជ័យ | ថ្មពួក | 10403. គោករមៀត_HC | មណ្ឌលសុខភាព | MPA |
| ៦២ | បន្ទាយមានជ័យ | ថ្មពួក | 10404. បន្ទាយឆ្មារ_HC | មណ្ឌលសុខភាព | MPA |
| ៦៣ | បន្ទាយមានជ័យ | ថ្មពួក | 10405. បឹងត្រកួន_HC | មណ្ឌលសុខភាព | MPA |
| ៦៤ | បន្ទាយមានជ័យ | ថ្មពួក | 10406. ទ្រាស_HC | មណ្ឌលសុខភាព | MPA |
| ៦៥ | បន្ទាយមានជ័យ | ថ្មពួក | 10408. ស្លក្រាម_HC | មណ្ឌលសុខភាព | MPA |
| ៦៦ | បន្ទាយមានជ័យ | ថ្មពួក | 10409. តាផូ_HC | មណ្ឌលសុខភាព | MPA |
| ៦៧ | បន្ទាយមានជ័យ | ថ្មពួក | 10410. ផ្គាំ_HC | មណ្ឌលសុខភាព | MPA |
| ៦៨ | បន្ទាយមានជ័យ | ថ្មពួក | 10411. ភូមិថ្មី_HC | មណ្ឌលសុខភាព | MPA |

| | | | | | |
|---|---|---|---|---|---|
| ៦៩ | បន្ទាយមានជ័យ | ថ្មពួក | 10412. សារង្គ_HC | មណ្ឌលសុខភាព | MPA |
| ៧០ | បន្ទាយមានជ័យ | ថ្មពួក | 10413. គោកកឋិន_HC | មណ្ឌលសុខភាព | MPA |
| ៧១ | បន្ទាយមានជ័យ | ថ្មពួក | 1040801. ចក់ពួក_HC | មណ្ឌលសុខភាព | MPA |
| ៧២ | បន្ទាយមានជ័យ | ថ្មពួក | 1040802. មន្ទីរពេទ្យបង្អែកស្វាយចេក_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ៧៣ | បាត់ដំបង | ថ្មគោល | 20018. បឹងប្រាំ_HC | មណ្ឌលសុខភាព | MPA |
| ៧៤ | បាត់ដំបង | ថ្មគោល | 20101. មន្ទីរពេទ្យបង្អែក ថ្មគោល_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ៧៥ | បាត់ដំបង | ថ្មគោល | 20102. បន្សាយត្រែង_HC | មណ្ឌលសុខភាព | MPA |
| ៧៦ | បាត់ដំបង | ថ្មគោល | 20103. រូងជ្រៃ_HC | មណ្ឌលសុខភាព | MPA |
| ៧៧ | បាត់ដំបង | ថ្មគោល | 20104. បឹងព្រីង_HC | មណ្ឌលសុខភាព | MPA |
| ៧៨ | បាត់ដំបង | ថ្មគោល | 20105. អូរតាគី_HC | មណ្ឌលសុខភាព | MPA |
| ៧៩ | បាត់ដំបង | ថ្មគោល | 20106. អន្លង់វុន_HC | មណ្ឌលសុខភាព | MPA |
| ៨០ | បាត់ដំបង | ថ្មគោល | 20107. តាពូង_HC | មណ្ឌលសុខភាព | MPA |
| ៨១ | បាត់ដំបង | ថ្មគោល | 20108. តាម៉ឺន_HC | មណ្ឌលសុខភាព | MPA |
| ៨២ | បាត់ដំបង | ថ្មគោល | 20109. គោកឃ្មុំ_HC | មណ្ឌលសុខភាព | MPA |
| ៨៣ | បាត់ដំបង | ថ្មគោល | 20110. បវេល ១_HCB | មណ្ឌលសុខភាពមានគ្រែ | CPA+MPA |
| ៨៤ | បាត់ដំបង | ថ្មគោល | 20111. បវេល ២_HC | មណ្ឌលសុខភាព | MPA |
| ៨៥ | បាត់ដំបង | ថ្មគោល | 20112. ក្តុលតាហែន_HC | មណ្ឌលសុខភាព | MPA |
| ៨៦ | បាត់ដំបង | ថ្មគោល | 20113. អំពិលប្រាំដើម_HC | មណ្ឌលសុខភាព | MPA |
| ៨៧ | បាត់ដំបង | ថ្មគោល | 20114. ព្រៃខ្ពស់_HC | មណ្ឌលសុខភាព | MPA |
| ៨៨ | បាត់ដំបង | ថ្មគោល | 20115. ល្វា_HC | មណ្ឌលសុខភាព | MPA |
| ៨៩ | បាត់ដំបង | ថ្មគោល | 20116. ខ្នាចរមាស_HC | មណ្ឌលសុខភាព | MPA |
| ៩០ | បាត់ដំបង | ថ្មគោល | 20117. ឃ្លាំងមាស_HC | មណ្ឌលសុខភាព | MPA |
| ៩១ | បាត់ដំបង | ថ្មគោល | 20118. ជ្រោយស្ដៅ_HC | មណ្ឌលសុខភាព | MPA |
| ៩២ | បាត់ដំបង | មោងឫស្សី | 20201. មន្ទីរពេទ្យបង្អែក មោងឫស្សី_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA2 |
| ៩៣ | បាត់ដំបង | មោងឫស្សី | 20202. ព្រៃស្វាយ_HC | មណ្ឌលសុខភាព | MPA |
| ៩៤ | បាត់ដំបង | មោងឫស្សី | 20203. ឫស្សីក្រាំង_HC | មណ្ឌលសុខភាព | MPA |
| ៩៥ | បាត់ដំបង | មោងឫស្សី | 20204. ជ្រៃ_HC | មណ្ឌលសុខភាព | MPA |
| ៩៦ | បាត់ដំបង | មោងឫស្សី | 20205. តាលាស់_HC | មណ្ឌលសុខភាព | MPA |
| ៩៧ | បាត់ដំបង | មោងឫស្សី | 20206. កកោះ_HC | មណ្ឌលសុខភាព | MPA |
| ៩៨ | បាត់ដំបង | មោងឫស្សី | 20207. ធិបតី_HC | មណ្ឌលសុខភាព | MPA |
| ៩៩ | បាត់ដំបង | មោងឫស្សី | 20208. របស់មង្គល_HC | មណ្ឌលសុខភាព | MPA |
| ១០០ | បាត់ដំបង | មោងឫស្សី | 20209. មោង_HC | មណ្ឌលសុខភាព | MPA |
| ១០១ | បាត់ដំបង | មោងឫស្សី | 20210. គារ_HC | មណ្ឌលសុខភាព | MPA |
| ១០២ | បាត់ដំបង | មោងឫស្សី | 20211. ព្រៃតូច_HC | មណ្ឌលសុខភាព | MPA |
| ១០៣ | បាត់ដំបង | មោងឫស្សី | 20212. ព្រៃត្រឡាច_HC | មណ្ឌលសុខភាព | MPA |
| ១០៤ | បាត់ដំបង | មោងឫស្សី | 20213. ព្រៃកដីក_HC | មណ្ឌលសុខភាព | MPA |

| | | | | | |
|---|---|---|---|---|---|
| ១០៥ | បាត់ដំបង | មោងឫស្សី | 20214. គាស់ក្រឡ_HC | មណ្ឌលសុខភាព | MPA |
| ១០៦ | បាត់ដំបង | សំពៅលូន | 20301. មន្ទីរពេទ្យបង្អែក សំពៅលូន_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA2 |
| ១០៧ | បាត់ដំបង | សំពៅលូន | 20302. សិរីមានជ័យ_HC | មណ្ឌលសុខភាព | MPA |
| ១០៨ | បាត់ដំបង | សំពៅលូន | 20303. សំពៅលូន_HC | មណ្ឌលសុខភាព | MPA |
| ១០៩ | បាត់ដំបង | សំពៅលូន | 20304. បារាំងធ្លាក់_HC | មណ្ឌលសុខភាព | MPA |
| ១១០ | បាត់ដំបង | សំពៅលូន | 20305. ពេជ្រចិន្តា_HC | មណ្ឌលសុខភាព | MPA |
| ១១១ | បាត់ដំបង | សំពៅលូន | 20306. ត្រាង_HCB | មណ្ឌលសុខភាពមានគ្រែ | CPA+MPA |
| ១១២ | បាត់ដំបង | សំពៅលូន | 20307. កំរៀង_HC | មណ្ឌលសុខភាព | MPA |
| ១១៣ | បាត់ដំបង | សំពៅលូន | 20308. តាក្រី _HC | មណ្ឌលសុខភាព | MPA |
| ១១៤ | បាត់ដំបង | សំពៅលូន | 20309. បួរ_HC | មណ្ឌលសុខភាព | MPA |
| ១១៥ | បាត់ដំបង | សំពៅលូន | 20310. ត្រាវជូ_HC | មណ្ឌលសុខភាព | MPA |
| ១១៦ | បាត់ដំបង | សំពៅលូន | 20311. រស្មីសាមគ្គី_HC | មណ្ឌលសុខភាព | MPA |
| ១១៧ | បាត់ដំបង | បាត់ដំបង | 20401. មន្ទីរពេទ្យខេត្ត បាត់ដំបង_PH | មន្ទីរពេទ្យបង្អែកខេត្ត | CPA3 |
| ១១៨ | បាត់ដំបង | បាត់ដំបង | 20402. ស្វាយប៉ោ_HC | មណ្ឌលសុខភាព | MPA |
| ១១៩ | បាត់ដំបង | បាត់ដំបង | 20403. ស្លាកែត_HC | មណ្ឌលសុខភាព | MPA |
| ១២០ | បាត់ដំបង | បាត់ដំបង | 20404. ក្ដុល_HC | មណ្ឌលសុខភាព | MPA |
| ១២១ | បាត់ដំបង | បាត់ដំបង | 20405. ទួលតាឯក_HC | មណ្ឌលសុខភាព | MPA |
| ១២២ | បាត់ដំបង | បាត់ដំបង | 20406. វត្តគរ_HC | មណ្ឌលសុខភាព | MPA |
| ១២៣ | បាត់ដំបង | បាត់ដំបង | 20407. អូម៉ាល់_HC | មណ្ឌលសុខភាព | MPA |
| ១២៤ | បាត់ដំបង | បាត់ដំបង | 20408. ជ្រៃ_HC | មណ្ឌលសុខភាព | MPA |
| ១២៥ | បាត់ដំបង | បាត់ដំបង | 20409. រតនៈ_HC | មណ្ឌលសុខភាព | MPA |
| ១២៦ | បាត់ដំបង | បាត់ដំបង | 20410. ចំការសំរោង_HC | មណ្ឌលសុខភាព | MPA |
| ១២៧ | បាត់ដំបង | បាត់ដំបង | 20411. ឈើទាល_HC | មណ្ឌលសុខភាព | MPA |
| ១២៨ | បាត់ដំបង | បាត់ដំបង | 20412. កន្ទឺ ២_HCB | មណ្ឌលសុខភាពមានគ្រែ | CPA+MPA |
| ១២៩ | បាត់ដំបង | បាត់ដំបង | 20413. ស្ទឹង_HC | មណ្ឌលសុខភាព | MPA |
| ១៣០ | បាត់ដំបង | បាត់ដំបង | 20414. តាគ្រាម_HC | មណ្ឌលសុខភាព | MPA |
| ១៣១ | បាត់ដំបង | បាត់ដំបង | 20415. ភ្នំសំពៅ_HC | មណ្ឌលសុខភាព | MPA |
| ១៣២ | បាត់ដំបង | បាត់ដំបង | 20416. ស្ដៅ_HCB | មណ្ឌលសុខភាពមានគ្រែ | CPA+MPA |
| ១៣៣ | បាត់ដំបង | បាត់ដំបង | 20417. ត្រែង_HC | មណ្ឌលសុខភាព | MPA |
| ១៣៤ | បាត់ដំបង | បាត់ដំបង | 20418. ផ្លូវមាស_HC | មណ្ឌលសុខភាព | MPA |
| ១៣៥ | បាត់ដំបង | បាត់ដំបង | 20419. ឆករកា_HC | មណ្ឌលសុខភាព | MPA |
| ១៣៦ | បាត់ដំបង | បាត់ដំបង | 20420. ចំឡងក្លួយ_HC | មណ្ឌលសុខភាព | MPA |
| ១៣៧ | បាត់ដំបង | បាត់ដំបង | 20421. តាសាញ_HCB | មណ្ឌលសុខភាពមានគ្រែ | CPA+MPA |
| ១៣៨ | បាត់ដំបង | បាត់ដំបង | 20422. ចែងមានជ័យ_HC | មណ្ឌលសុខភាព | MPA |
| ១៣៩ | បាត់ដំបង | បាត់ដំបង | 20423. កំពង់ល្ពៅ_HC | មណ្ឌលសុខភាព | MPA |
| ១៤០ | បាត់ដំបង | បាត់ដំបង | 20424. បឹងរុន_HC | មណ្ឌលសុខភាព | MPA |
| ១៤១ | បាត់ដំបង | សង្កែ | 20502. អន្លង់វិល_HCB | មណ្ឌលសុខភាពមានគ្រែ | CPA+MPA |

| | | | | | |
|---|---|---|---|---|---|
| ១៤២ | បាត់ដំបង | សង្កែ | 20503. វត្តតាមិម_HC | មណ្ឌលសុខភាព | MPA |
| ១៤៣ | បាត់ដំបង | សង្កែ | 20504. កំពង់ព្រៀង_HC | មណ្ឌលសុខភាព | MPA |
| ១៤៤ | បាត់ដំបង | សង្កែ | 20505. កំពង់ព្រះ_HC | មណ្ឌលសុខភាព | MPA |
| ១៤៥ | បាត់ដំបង | សង្កែ | 20506. អូរដំបង ២_HC | មណ្ឌលសុខភាព | MPA |
| ១៤៦ | បាត់ដំបង | សង្កែ | 20508. អូរដំបង ១_HC | មណ្ឌលសុខភាព | MPA |
| ១៤៧ | បាត់ដំបង | សង្កែ | 20509. វាំងកេសី_HC | មណ្ឌលសុខភាព | MPA |
| ១៤៨ | បាត់ដំបង | សង្កែ | 20510. តាប៉ុន_HC | មណ្ឌលសុខភាព | MPA |
| ១៤៩ | បាត់ដំបង | សង្កែ | 20512. សំរោងក្នុង_HC | មណ្ឌលសុខភាព | MPA |
| ១៥០ | បាត់ដំបង | សង្កែ | 20513. ព្រែកហ្លួង_HC | មណ្ឌលសុខភាព | MPA |
| ១៥១ | បាត់ដំបង | សង្កែ | 20514. ពាមឯក_HC | មណ្ឌលសុខភាព | MPA |
| ១៥២ | បាត់ដំបង | សង្កែ | 20515. ព្រែចាស់_HC | មណ្ឌលសុខភាព | MPA |
| ១៥៣ | បាត់ដំបង | សង្កែ | 20516. កោះជីវាំង_HC | មណ្ឌលសុខភាព | MPA |
| ១៥៤ | បាត់ដំបង | សង្កែ | 20517. រកា_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ១៥៥ | បាត់ដំបង | សង្កែ | 20518. ព្រែកនរិន្ទ_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ១៥៦ | កំពង់ចាម | ចំការលើ | 30101. មន្ទីរពេទ្យបង្អែកចំការលើ_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ១៥៧ | កំពង់ចាម | ចំការលើ | 30102. ដូនធី_HC | មណ្ឌលសុខភាព | MPA |
| ១៥៨ | កំពង់ចាម | ចំការលើ | 30103. បុសខ្នុរ_HC | មណ្ឌលសុខភាព | MPA |
| ១៥៩ | កំពង់ចាម | ចំការលើ | 30104. តាអុង_HC | មណ្ឌលសុខភាព | MPA |
| ១៦០ | កំពង់ចាម | ចំការលើ | 30105. តាំងក្រង_HC | មណ្ឌលសុខភាព | MPA |
| ១៦១ | កំពង់ចាម | ចំការលើ | 30106. ស្វាយទាប_HC | មណ្ឌលសុខភាព | MPA |
| ១៦២ | កំពង់ចាម | ចំការលើ | 30107. ស្ពឺ_HC | មណ្ឌលសុខភាព | MPA |
| ១៦៣ | កំពង់ចាម | ចំការលើ | 30108. ជយោ_HC | មណ្ឌលសុខភាព | MPA |
| ១៦៤ | កំពង់ចាម | ចំការលើ | 30109. ចំការអណ្ដូង_HC | មណ្ឌលសុខភាព | MPA |
| ១៦៥ | កំពង់ចាម | ចំការលើ | 30110. តាប្រុក_HC | មណ្ឌលសុខភាព | MPA |
| ១៦៦ | កំពង់ចាម | ចំការលើ | 30111. ល្វាលើ_HC | មណ្ឌលសុខភាព | MPA |
| ១៦៧ | កំពង់ចាម | ចំការលើ | 30115. ចំការកៅស៊ូចំការអណ្ដូង_HC | មណ្ឌលសុខភាព | MPA |
| ១៦៨ | កំពង់ចាម | ចំការលើ | 30116. ស្វាយមាស_HC | មណ្ឌលសុខភាព | MPA |
| ១៦៩ | កំពង់ចាម | ជើងព្រៃ | 30201. មន្ទីរពេទ្យបង្អែកជើងព្រៃ_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ១៧០ | កំពង់ចាម | ជើងព្រៃ | 30202. សំពងជ័យ_HC | មណ្ឌលសុខភាព | MPA |
| ១៧១ | កំពង់ចាម | ជើងព្រៃ | 30203. ព្រីងជ្រុំ_HC | មណ្ឌលសុខភាព | MPA |
| ១៧២ | កំពង់ចាម | ជើងព្រៃ | 30204. ស្ដើងជ័យ_HC | មណ្ឌលសុខភាព | MPA |
| ១៧៣ | កំពង់ចាម | ជើងព្រៃ | 30205. ស្អាង_HC | មណ្ឌលសុខភាព | MPA |
| ១៧៤ | កំពង់ចាម | ជើងព្រៃ | 30206. ស្គន់_HC | មណ្ឌលសុខភាព | MPA |
| ១៧៥ | កំពង់ចាម | ជើងព្រៃ | 30207. ដូនដុំ_HC | មណ្ឌលសុខភាព | MPA |
| ១៧៦ | កំពង់ចាម | ជើងព្រៃ | 30208. ខ្នុរដំបង_HC | មណ្ឌលសុខភាព | MPA |
| ១៧៧ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30301. មន្ទីរពេទ្យខេត្តកំពង់ចាម_PH | មន្ទីពេទ្យបង្អែកខេត្ត | CPA3 |

| | | | | | |
|---|---|---|---|---|---|
| ១៧៨ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30302. បឹងកុក_HC | មណ្ឌលសុខភាព | MPA |
| ១៧៩ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30303. សំបួរមាស_HC | មណ្ឌលសុខភាព | MPA |
| ១៨០ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30304. វាលវង់_HC | មណ្ឌលសុខភាព | MPA |
| ១៨១ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30305. ហាន់ជ័យ_HC | មណ្ឌលសុខភាព | MPA |
| ១៨២ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30306. កៀនជ្រៃ_HC | មណ្ឌលសុខភាព | MPA |
| ១៨៣ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30307. កោះសំរោង_HC | មណ្ឌលសុខភាព | MPA |
| ១៨៤ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30308. កោះមិត្ត_HC | មណ្ឌលសុខភាព | MPA |
| ១៨៥ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30309. កោះរកា_HC | មណ្ឌលសុខភាព | MPA |
| ១៨៦ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30310. អំពិល_HC | មណ្ឌលសុខភាព | MPA |
| ១៨៧ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30311. វិហារធំ_HC | មណ្ឌលសុខភាព | MPA |
| ១៨៨ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30312. ក្រឡា_HC | មណ្ឌលសុខភាព | MPA |
| ១៨៩ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30313. ទ្រាន_HC | មណ្ឌលសុខភាព | MPA |
| ១៩០ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30324. គគរ_HC | មណ្ឌលសុខភាព | MPA |
| ១៩១ | កំពង់ចាម | កំពង់ចាម - កំពង់សៀម | 30326. ស្រក_HC | មណ្ឌលសុខភាព | MPA |
| ១៩២ | កំពង់ចាម | ព្រៃឈរ | 30801. មន្ទីរពេទ្យបង្អែកព្រៃឈរ_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ១៩៣ | កំពង់ចាម | ព្រៃឈរ | 30802. ត្រពាំងព្រះ_HC | មណ្ឌលសុខភាព | MPA |
| ១៩៤ | កំពង់ចាម | ព្រៃឈរ | 30803. មៀន_HC | មណ្ឌលសុខភាព | MPA |
| ១៩៥ | កំពង់ចាម | ព្រៃឈរ | 30804. ស្រងែ_HC | មណ្ឌលសុខភាព | MPA |
| ១៩៦ | កំពង់ចាម | ព្រៃឈរ | 30805. សូរសែន្យ_HC | មណ្ឌលសុខភាព | MPA |
| ១៩៧ | កំពង់ចាម | ព្រៃឈរ | 30806. ជ្រៃវៀន_HC | មណ្ឌលសុខភាព | MPA |
| ១៩៨ | កំពង់ចាម | ព្រៃឈរ | 30807. គរ_HC | មណ្ឌលសុខភាព | MPA |
| ១៩៩ | កំពង់ចាម | ព្រៃឈរ | 30808. បារាយណ៍_HC | មណ្ឌលសុខភាព | MPA |
| ២០០ | កំពង់ចាម | ព្រៃឈរ | 30809. ក្រូច_HC | មណ្ឌលសុខភាព | MPA |
| ២០១ | កំពង់ចាម | ព្រៃឈរ | 30810. ថ្មពូន_HC | មណ្ឌលសុខភាព | MPA |
| ២០២ | កំពង់ចាម | ព្រៃឈរ | 30811. ល្វា_HC | មណ្ឌលសុខភាព | MPA |
| ២០៣ | កំពង់ចាម | ព្រៃឈរ | 30812. តុងរ៉ុង_HC | មណ្ឌលសុខភាព | MPA |
| ២០៤ | កំពង់ចាម | ស្រីសន្ធរ | 30901. មន្ទីរពេទ្យបង្អែកស្រីសន្ធរ_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA2 |
| ២០៥ | កំពង់ចាម | ស្រីសន្ធរ | 30902. ព្រែករំដេង_HC | មណ្ឌលសុខភាព | MPA |
| ២០៦ | កំពង់ចាម | ស្រីសន្ធរ | 30903. ស្វាយសាច់ភ្នំ_HC | មណ្ឌលសុខភាព | MPA |

| | | | | | |
|---|---|---|---|---|---|
| ២០៧ | កំពង់ចាម | ស្រីសន្ធរ | 30904. ព្រែកដំបូក_HC | មណ្ឌលសុខភាព | MPA |
| ២០៨ | កំពង់ចាម | ស្រីសន្ធរ | 30905. ទងត្រឡាច_HC | មណ្ឌលសុខភាព | MPA |
| ២០៩ | កំពង់ចាម | ស្រីសន្ធរ | 30906. ព្រែកពោធិ_HC | មណ្ឌលសុខភាព | MPA |
| ២១០ | កំពង់ចាម | ស្រីសន្ធរ | 30907. បារាយណ៍_HC | មណ្ឌលសុខភាព | MPA |
| ២១១ | កំពង់ចាម | ស្រីសន្ធរ | 30908. មានជ័យ_HC | មណ្ឌលសុខភាព | MPA |
| ២១២ | កំពង់ចាម | ស្រីសន្ធរ | 30909. ស្វាយពោធិ_HC | មណ្ឌលសុខភាព | MPA |
| ២១៣ | កំពង់ចាម | ស្រីសន្ធរ | 30910. ប្រាំយ៉ាម_HC | មណ្ឌលសុខភាព | MPA |
| ២១៤ | កំពង់ចាម | ស្ទឹងត្រង់ | 30112. មេសរជ្រៃ_HC | មណ្ឌលសុខភាព | MPA |
| ២១៥ | កំពង់ចាម | ស្ទឹងត្រង់ | 30113. ដងក្ដារ_HC | មណ្ឌលសុខភាព | MPA |
| ២១៦ | កំពង់ចាម | ស្ទឹងត្រង់ | 30114. សូភាស_HC | មណ្ឌលសុខភាព | MPA |
| ២១៧ | កំពង់ចាម | ស្ទឹងត្រង់ | 30320. ព្រែកកក់_HC | មណ្ឌលសុខភាព | MPA |
| ២១៨ | កំពង់ចាម | ស្ទឹងត្រង់ | 30321. ព្រែកបាក់_HC | មណ្ឌលសុខភាព | MPA |
| ២១៩ | កំពង់ចាម | ស្ទឹងត្រង់ | 30325. មន្ទីរពេទ្យបង្អែក ហ៊ុនសែនស្ទឹងត្រង់_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ២២០ | កំពង់ចាម | ស្ទឹងត្រង់ | 30409. ខ្ពបតាងួន_HC | មណ្ឌលសុខភាព | MPA |
| ២២១ | កំពង់ចាម | ស្ទឹងត្រង់ | 30410. ពាមកោះស្នា_HC | មណ្ឌលសុខភាព | MPA |
| ២២២ | កំពង់ចាម | ស្ទឹងត្រង់ | 30411. អារក្សត្នោត_HC | មណ្ឌលសុខភាព | MPA |
| ២២៣ | កំពង់ចាម | ស្ទឹងត្រង់ | 30412. ទួលសំបូរ_HC | មណ្ឌលសុខភាព | MPA |
| ២២៤ | កំពង់ចាម | ស្ទឹងត្រង់ | 31101. ទួលព្រះឃ្លាំង_HC | មណ្ឌលសុខភាព | MPA |
| ២២៥ | កំពង់ចាម | ស្ទឹងត្រង់ | 31102. អូរម្លូ_HC | មណ្ឌលសុខភាព | MPA |
| ២២៦ | កំពង់ចាម | ស្ទឹងត្រង់ | 31104. មាយ៣_HC | មណ្ឌលសុខភាព | MPA |
| ២២៧ | កំពង់ចាម | បាធាយ | 30209. ទំនប់_HC | មណ្ឌលសុខភាព | MPA |
| ២២៨ | កំពង់ចាម | បាធាយ | 30210. ជើងព្រៃ_HC | មណ្ឌលសុខភាព | MPA |
| ២២៩ | កំពង់ចាម | បាធាយ | 30211. ផ្អាវ_HC | មណ្ឌលសុខភាព | MPA |
| ២៣០ | កំពង់ចាម | បាធាយ | 30212. ជើងឆ្នុក_HC | មណ្ឌលសុខភាព | MPA |
| ២៣១ | កំពង់ចាម | បាធាយ | 30213. មន្ទីរពេទ្យបង្អែក បាធាយ_RH | មន្ទីរពេទ្យបង្អែកស្រុក | CPA1 |
| ២៣២ | កំពង់ចាម | បាធាយ | 30214. សណ្ដែក_HC | មណ្ឌលសុខភាព | MPA |
| ២៣៣ | កំពង់ចាម | បាធាយ | 30215. សំបូរ_HC | មណ្ឌលសុខភាព | MPA |
| ២៣៤ | កំពង់ចាម | បាធាយ | 30216. បាធាយ_HC | មណ្ឌលសុខភាព | MPA |
| ២៣៥ | កំពង់ចាម | បាធាយ | 30217. ត្រប់_HC | មណ្ឌលសុខភាព | MPA |
| ២៣៦ | កំពង់ចាម | កោះសូទិន | 30314. ព្រែកតានង់_HC | មណ្ឌលសុខភាព | MPA |
| ២៣៧ | កំពង់ចាម | កោះសូទិន | 30315. មហាខ្ញូង_HC | មណ្ឌលសុខភាព | MPA |
| ២៣៨ | កំពង់ចាម | កោះសូទិន | 30316. កោះសូទិន_HC | មណ្ឌលសុខភាព | MPA |
| ២៣៩ | កំពង់ចាម | កោះសូទិន | 30317. ពាមប្រធ្នោះ_HCB | មណ្ឌលសុខភាពមានគ្រែ | CPA+MPA |
| ២៤០ | កំពង់ចាម | កោះសូទិន | 30318. ល្វេ_HC | មណ្ឌលសុខភាព | MPA |
| ២៤១ | កំពង់ចាម | កោះសូទិន | 30319. កំពង់រាប_HC | មណ្ឌលសុខភាព | MPA |
| ២៤២ | កំពង់ចាម | កោះសូទិន | 30609. ពង្រ-មហាលាភ_HC | មណ្ឌលសុខភាព | MPA |

| | | | | | |
|---|---|---|---|---|---|
| ២៤៣ | កំពង់ចាម | កងមាស | 30813. ពាមជីកង_HC | មណ្ឌលសុខភាព | MPA |
| ២៤៤ | កំពង់ចាម | កងមាស | 30814. ព្រែកក្របៅ_HC | មណ្ឌលសុខភាព | MPA |
| ២៤៥ | កំពង់ចាម | កងមាស | 30815. អង្គរបាន_HC | មណ្ឌលសុខភាព | MPA |
| ២៤៦ | កំពង់ចាម | កងមាស | 30816. សូរគង_HC | មណ្ឌលសុខភាព | MPA |
| ២៤៧ | កំពង់ចាម | កងមាស | 30911. ខ្ចៅ_HC | មណ្ឌលសុខភាព | MPA |
| ២៤៨ | កំពង់ចាម | កងមាស | 30912. រការអារ_HC | មណ្ឌលសុខភាព | MPA |
| ២៤៩ | កំពង់ចាម | កងមាស | 30913. ស្ដៅ_HC | មណ្ឌលសុខភាព | MPA |
| ២៥០ | កំពង់ចាម | កងមាស | 30914. វាយប៉ោយ_HC | មណ្ឌលសុខភាព | MPA |
| ២៥១ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | 40101. មន្ទីរពេទ្យខេត្ត កំពង់ឆ្នាំង_PH | មន្ទីរពេទ្យបង្អែកខេត្ត | CPA3 |
| ២៥២ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | 40102. ផ្សារឆ្នាំង_HC | មណ្ឌលសុខភាព | MPA |
| ២៥៣ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | 40103. កំពង់ឆ្នាំង_HC | មណ្ឌលសុខភាព | MPA |
| ២៥៤ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | 40104. ព្រៃខ្មែរ_HC | មណ្ឌលសុខភាព | MPA |
| ២៥៥ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | 40105. ជើងគ្រាវ_HC | មណ្ឌលសុខភាព | MPA |
| ២៥៦ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | 40106. ស្រែថ្មី_HC | មណ្ឌលសុខភាព | MPA |
| ២៥៧ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | 40107. ព្រៃគ្រី_HCB | មណ្ឌលសុខភាពមានគ្រែ | CPA+MPA |
| ២៥៨ | កំពង់ឆ្នាំង | កំពង់ឆ្នាំង | 40108. ពាមឆ្កោក_HC | មណ្ឌលសុខភាព | MPA |
